# មគ្គុទ្ទេសក៍នគរ

## ភាគ ១-២

ចម្លងដោយ

ផ្ទះលេខ១៣៦អឹង វិថីខេមរភូមិន្ទ រាជធានីភ្នំពេញ

ព.ស.២៥៤៤

មគ្គុទ្ទេសក៍នគរ ភាគ ១-២

ទទួលបានពីលោក ឡេង ឃុនសំអាង នាក់ក្រុណាខ្មែរ
ដើម្បីផ្ញើទៅដាក់ក្នុង eLibrary of Cambodia
តុលា 2015

# មគ្គុទ្ទេសក៍ឆតាច
## ភាគ ១

INSTITUT BOUDDHIQUE

| | | |
|---|---|---|
| ទំនៀមការផ្ទាល់ខ្លួន . . . . . . . . . . . . . . . . . . . . . | • សៀវភៅថ្លៃ | ០រ. ៦០ |
| ទឹកទន្លេសាប . . . . . . . . . . . . . . . . . . . . . | — | ០, ៦០ |
| ច្បាប់ក្រម . . . . . . . . . . . . . . . . . . . . . | — | ០, ១០ |
| ច្បាប់កេរ្តិ៍កាល . . . . . . . . . . . . . . . . . . . . . | — | ០, ១០ |
| ច្បាប់កូនចៅ . . . . . . . . . . . . . . . . . . . . . | — | ០, ១៥ |
| ច្បាប់ត្រីនេតិ . . . . . . . . . . . . . . . . . . . . . | — | ០, ១៥ |
| ភាសិត . . . . . . . . . . . . . . . . . . . . . | — | ០, ១៥ |

# រូបផ្តិតពុម្ពផ្សេងៗ


| | | | |
|---|---|---|---|
| ព្រះពុទ្ធរូបមានអគ្គសាវកអម (របាណាស៍) | ១ សន្លឹកថ្លៃ | . | ០ រ. ០៥ |
| " និព្វាន | | — | ០, ០៥ |
| រូបចេតិយ៍ត្រគ្រប់បែប | | — | ០, ០៥ |
| ព្រះពុទ្ធរូបបាយ័ន | | — | ០, ០២ |
| " មានព្រះឥន្ទ្រនឹងព្រះព្រហ្មឈរអម | | — | ០, ០៥ |
| ព្រះរូបសម្តេចព្រះមហាសង្ឃរាជ (ទៀត) | | — | ០, ០៣ |
| ព្រះរូបព្រះបាទសម្តេច ព្រះស៊ីសុវត្ថិមុនីវង្ស ក្រដាសរឹង | | — | ០, ១៥ |
| " " ក្រដាសទន់ | | — | ០, ១០ |
| " ព្រះស៊ីសុវត្ថិ | | — | ០, ២០ |
| " ព្រះចៅក្រុងកម្ពុជា ៤ ព្រះអង្គ | | — | ០, ១០ |
| រូបព្រះពុទ្ធបាទ | | — | ០, ០៥ |
| រូបព្រះឥន្ទ្រលាក់[illegible]រឿងពុទ្ធប្រវត្តិ | | — | ០, ០៥ |
| រូបវេស្សន្តរជាតក ១៣ សន្លឹក | | — | ០, ០៦ |
| រូបគំនូរតេមិយជាតក | ១០ | — | ០, ២៥ |
| " មហាជនកជាតក | ១០ | — | ០, ២៥ |
| " សុវណ្ណសាមជាតក | ១០ | — | ០, ២៥ |
| រូបសម្តេចព្រះវររាជជននី | ១ | — | ០, ០២ |
| រូបលោកសង្ឃបួសទឹកតាមាស់ | | — | ០, ០៧ |
| ប្រក្រតិទិនឆ្នាំ ១៩៤២ (សន្លឹកស្តើង) | | — | ០, ១៥ |
| " " (បន្ទះក្រាស់) | | — | ០, ៣០ |
| " " (បក) | | — | ០, ៩០ |

# មគ្គុទ្ទេសក៍នគរ

## ភាគទី ១

*អាចារ្យ ប៉ាំង-ខាត់ គ្រូបង្រៀនសំស្ក្រឹត*

*នៅសាលាបាលីជាន់ខ្ពស់ រៀបរៀង*

គណៈរដ្ឋមន្ត្រីនិងសម្តេចសង្ឃនាយកទាំងពីរគណៈ
បានអនុញ្ញាតហើយ

*បោះពុម្ពលើកទី ១*




ភ្នំពេញ

*ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ*

ព. ស. ២៤៨៦

# MAGGUDDESAKANAGARA

(Guide d'Angkor)

1ère Partie

## L'HISTORIQUE

par

L'Achar PANG-KHAT Professeur de Sanscrit

a l'École Supérieure de Pali

Cette publication a reçu l'approbation du Conseil des Ministres
et des deux Chefs de Sectes

1ère Édition

PHNOM-PENH
Éditions de l'Institut Bouddhique
1941



ព្រះពុទ្ធរូបបែបខ្មែរ ទ្រង់សមាធិម្ចុរិ គេដំកល់ទុកនៅមន្ទីរ
រក្សាបុរាណវត្ថុ សៀមរាប (ពារូបថត ព . ស . ប .)

ពាក្យប្រារព្ធ

បើយើងបានដើរមើលបុរាណដ្ឋាន ត្រង់ចំណែកខាងក្នុងប្រទេសកម្ពុជា គេនឹងបានយល់ពិតប្រាកដថា ប្រទេសកម្ពុជាក្នុងអតីតកាល ជាប្រទេសរុងរឿងយ៉ាងឯក ក្នុងចំណោមប្រទេសទាំងឡាយដែលស្ថិតនៅទិសខាងកើតនៃទ្វីបអាស៊ី ។ អ្នកដំណើរជាតិផ្សេងៗដែលធ្លាប់ដំណើរមកមើលនគរ, គេតែងនិយាយថា ប្រទេសកម្ពុជាក្នុងអតីតកាលជាប្រទេសរុងរឿងបំផុតមួយ, បណ្ដាជាតិខ្មែរសម័យនោះ ក៏មានអារ្យធម៌បរិបូណ៌, ដោយមានប្រាង្គប្រាសាទទាំងឡាយដេរដាសពាសពេញប្រទេសខ្មែរជាតឹកតាង ល្មមជាទីសន្និដ្ឋានបាន ចំពោះអារ្យធម៌នៃបណ្ដាជនជាតិខ្មែរក្នុងកាលនោះស្រាប់. បើយើងនឹងមិនត្រិះរិះឲ្យហ្មត់ចត់ទេ, យើងនឹងនឹកអាចចុះមតិថា ប្រាង្គប្រាសាទនៅនគរ ជាស្នាដៃនៃទេពនិម្មិតថ្វាយស្ដេចខ្មែរត្រង់ៗ ដូចពាក្យចម្លើយខ្មែរម្នាក់ឆ្លើយតបលោក ហង់រី-មូហូត កាលលោកមើលនគរនៅថ្ងៃ ២២-១-១៨៦១ ថា: "ប្រាសាទនគរនេះទេពតានិម្មិត មានពួកយក្សនិងស្រីទេពអប្សរប្រកេញ្ញាជួយដឹកជញ្ជូនថ្មតាមអាកាស តាមសេចក្ដីបង្គាប់នៃពិស្ណុករទេវបុត្រ" ។ ក្នុងសៀវភៅមគ្គុទ្ទេសក៍ជាភាសាអង់គ្លេស របស់លោក ដិក្កាសុន[1] ត្រង់ពង្សាវតារខ្មែរទំព័រលេខ ៥ មានសេចក្ដីថា: "ជនជាតិខ្មែរក្នុងអតីតកាល មានអារ្យធម៌ខ្ពង់ខ្ពស់ណាស់ ខ្មែរបច្ចុប្បន្ន

1 Wondrous Angkor by Deane H. Dickason, page 5 et 6, Sanghai 1937.

នេះជាខ្មែរក្រៅ" ។ សេចក្តីទាំងអស់នេះបញ្ជាក់ថា: "ជាតិខ្មែរយើងមានសេចក្តីចំរើនផុតថ្លាក់, ប្រាង្គប្រាសាទ ជាស្នាដៃដែលបុព្វបុរសរបស់យើងបានកសាង គេកាន់ប្រទំថាជាទេវតាសាងវិញ ។

លោកស្រី ការប៉ឺឡែស អគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ដែលមានសេចក្តីកប់អាឡជាតិខ្មែរស្មោះត្រង់ ប្រាថ្នាចង់ឲ្យជាតិខ្មែរភ្ញាក់ក-ណើតទំព្រឹងប្រែងរៀនសូត្រឲ្យបានចេះដឹង ឲ្យបានចំរើនទាន់អារ្យ-ធម៌ដូចសម័យនគរ ក៏បានសុំឲ្យខ្ញុំរៀបរៀងសៀវភៅមគ្គុទ្ទេសក៍នេះ, ទុកសំ-រាប់ជាតិខ្មែរដែលយុវជនខ្មែរទៅមើលនគរ ជាទេវស្ថានដែលបុព្វបុរសខ្មែរយើងបានកសាងទុក ជាគ្រឿងរំលឹកជាភស្តុតាងនៃសេចក្តីព្យាយាម ដើម្បីឲ្យកូនចៅខ្មែរយកជាតំរិះថា: "ដោយសេចក្តីព្យាយាម គេនឹងរួចពីកណ្តាប់ដៃនៃសេចក្តីទុក្ខ" ។

ដូច្នេះ, យុវជនទាំងឡាយ អ្នកត្រូវចំណាំពេលទៅមើលនគរកុំខាន "ពេលដើរចេញទៅមើលមិនមែនជាពេលខាតទេ នេះជាពាក្យពិត, ព្រោះទៅមើលនគរ ទុកដូចជាយើងទៅគោរពបូជាបូជនីយស្ថាន ដែលបញ្ចុះអដ្ឋិបុព្វបុរសរបស់យើង ដែលយើងត្រូវគោ-រពតាមមិនបានដោយទឹកចិត្តជ្រះថ្លាបរិសុទ្ធ, ជាពិសេសដែលយើងត្រូវបានអំពីការបូជានេះ គឺការចាំរឿងប្រាសាទទាំងដាប់ក្នុងចិត្ត ជាគំរូគាងនៃសេចក្តីព្យាយាម យើងនឹងកើតសេចក្តីព្យាយាមព្យាយាមប្រឹងប្រែងរៀនសូត្រ, ធ្វើការផ្សេងៗឲ្យបានសេចក្តីចំរើនដូចសម័យនគរ" ។

ដើម្បីនឹងឲ្យងាយដល់អ្នកដែលត្រូវការមើលនគរ យើងចែកសៀវភៅនេះជា ២ ភាគ ចុងសៀវភៅនេះល្អមើលកាន់ផ្លូវដើរកាត់ហេតុដើម្បីបានស្រួល

ព្រោះការឡើងប្រាសាទមួយៗ ប្រកបដោយសេចក្តីអន្តរាយច្រើនប្រការ ដោយប្រាសាទខ្លះមានជណ្តើរចោត, ប្រាសាទខ្លះមាននៅតែគ្រឹះក្បាលធា-ជាតិជុះរេរជាសពាសពេញ ញាតស្បាតពិបាកចូលមើលណាស់, ភាគទី ១ ពីវគ្គទី ១ ដល់វគ្គទី ៦, ភាគទី ២ ចាំពីវគ្គទី ៧ ដល់វគ្គទី ៨ ។ ទីបំផុត សូមផ្តាំពាក្យមួយម៉ាត់ថា "កុំមើលថ្មទទេ ត្រូវសួរថ្មផង" ។

ប. ខ.

វគ្គទី ១

# គោលពង្សាវតារខ្មែរបុរាណដោយសង្ខេប

ដោយការស្រាវជ្រាវរកតាមបុរាណវត្ថុ ដែលមានដេរដាសនៅលើផែនដីប្រទេសខ្មែរសព្វថ្ងៃនេះ គេឃើញច្បាស់ថា ជនជាតិខ្មែរបច្ចុប្បន្ននេះ គឺជាពូជពង្សជាប់រហូតតពីបុព្វបុរសខ្មែរតាំងពីបុរាណ-កាលមក ឥតសង្ស័យ ។ បើពោលតាមភូមិសាស្ត្រ ជនជាតិខ្មែរមិនមែនអាស្រ័យនៅតែក្នុងប្រទេសខ្មែរសព្វថ្ងៃដែលយើងមើលឃើញនោះទេ, មានអាស្រ័យនៅរហូតដល់ប្រទេសសៀមភាគក្រោមទន្លេមេណាម, ប្រ-ទេសលាវ និងប្រទេសកូសាំងស៊ីនចីន ។

បើនិយាយអំពីជនជាតិដែលអាស្រ័យនៅប្រទេសឥណ្ឌូចិនដំបូងចុះ លោក ហ. ម៉ារសាល់[1] លោកសរសេរថា: "ជនបុរាណដែលអាស្រ័យនៅប្រទេសឥណ្ឌូចិននេះ គឺជនជាតិឥណ្ឌូណេស៊ៀន (Indonésiens) ។ ពួកជនជាតិនេះរត់ទៅជ្រកនៅក្នុងបព៌ត ទុកទីស្ថានរបស់ខ្លួនឲ្យពួកអ្នកក្រោកនទឹកដីថ្មី គឺជាតិយួនមកពីប្រទេសចិនចូលមកនៅភាគខាងជើង, ជាតិឥណ្ឌាមកនៅភាគខាងត្បូង; សេចក្ដីពិត, ត្រូវយកបុរាណវត្ថុដែលមានពាសពេញក្នុងប្រទេសឥណ្ឌូចិនជាគោលដើម

1 H. Marchal, La collection khmère, p. 7.

មុនការក្លាយជាតិចិនជាយួន និងការក្លាយជាតិឥណ្ឌូណេសៀនជាខ្មែរ ជាប៉ះយ៉ង ចង់ចិនធំពីជនជាតិឥណ្ឌូណេសៀននោះ" ។

តាមសេចក្តីយកការអ្នកប្រវត្តិសាស្ត្រចិន[1] គេឲ្យឈ្មោះជនជាតិខ្មែរថា "ហ្វូ-ណាន", អ្នកប្រវត្តិសាស្ត្រចិននោះ បានអធិប្បាយពីសណ្ឋានបញ្ញា, ការបេះដូង និងព្រះរាជការជាន់នោះផង ដូចសេចក្តីថា: "ក្នុងរាជ ព. ស. ៨៦៣ មានជនជាតិហ្វូណានគោរពស្រ័យនៅកាន់ទាង ត្បូងប្រជាយកោះឥណ្ឌូស៊ុន នៅក្រោមការបញ្ជាព្រះស្តេចគ្រិស្តចិន" ។ ក្នុងក្សត្រការនៃរាជវង្ស ត្សុ ខាងត្បូង, មានសេចក្តីថា: "រវាង ព. ស. ១០៦៥-១០៤៦ មានព្រះរាជនិនាម លៀវ-យ៉េ (Lieu-yo) សោយរាជ្យនៅប្រទេសហ្វូណាន, ហើយមានជនម្នាក់ឈ្មោះ ហ៊ុង-តៀន (Houent ien) មកពីប្រទេសឆ្ងាយ បានសម្គាល់មោនសេនិងព្រះនាង; ជននេះ, លោក ប៉ូល-ប៉ែលីយ៉ូត៍ (Paul-Pelliot) យល់ថា ប្រហែលមកពីប្រទេសឥណ្ឌា ។ លុះដល់មកចុងសតវត្សរ៍ទី ៤ និងខាងដើមសត-វត្សរ៍ទី ១០ នៃគ្រិស្តសករាជ ទើបមានព្រាហ្មណ៍ម្នាក់មកអំពីប្រទេសឥណ្ឌា ឈ្មោះ កៅណ្ឌិន្យ ឬ កោណ្ឌញ្ញ មកសោយរាជ្យនៅប្រទេសហ្វូណាន, បានរៀបចំទំនៀមប្រពៃណីប្រទេសហ្វូណាន ឲ្យប្រព្រឹត្តទៅ

1. Paul-Pelliot. Le Fou-nan-B, E. F. E. O., p. 248-SQQ

តាមលទ្ធិប្រទេសឥណ្ឌាឡើង ។ ចំក្រុងហ្វូណន, (វ្យាធបុរៈ) លោក ក. សឺដែស(១) សរសេរថា ការនៅក្នុងនៃក្រុងភ្នំ ។

ម្យ៉ាងទៀត, សេចក្ដីរាយការរបស់ចិន មានដំណាលថា:(២) "ព្រះករាជ្យដើមកើតមកអំពីសម្ពន្ធរវាងរាស្ត្រនៃព្រាហ្មណ៍និងនាងនាគ ជាបុត្រនាគរាជ" ។ ពាក្យត្រង់នេះ អ្នកស្រី ករ៉ុល រេមុសាត់(៣) (Coral Rémusat) ប្រែស្រាយថា: "ព្រាហ្មណ៍ជ្រកជាសម្ដេចស្វាមី (ការ្យមិរ៉ា) នៅប្រទេសឥណ្ឌា, ឯនាងនាគ គឺជាគោលស្រុកទេសដើមកំណើត" ។

សេចក្ដីរាយការនៃអ្នកប្រវត្តិសាស្ត្រចិនខាងលើនេះ ហើយសេចក្ដីមកត្រូវគ្នានឹងពង្សាវតាររបស់យើង ។ ពង្សាវតាររបស់យើង, ស្ទើរតែមានសេចក្ដីពិតយ៉ាងនេះ ត្រូវតែលះបង់ចោលឈ្មោះនាងសោមាហើយ ឥតមានអ្នកណាមួយការពារទៀយ; សេចក្ដីក្នុងពង្សាវតារនោះថា(៤) "មានក្សត្រិយ៍មួយព្រះអង្គទ្រង់ព្រះនាមព្រះបាទអាទិត្យវង្ស ត្រូវគ្រងរាជ្យនៅឥន្ទបត្តបុរីសិរីមហានគរ ឥន្ទ្របាត, ទ្រង់មានព្រះរាជបុត្រ ៤ ព្រះអង្គ. ព្រះរាជបុត្រកណ្ដាលទ្រង់ព្រះនាមព្រះថោង ។ ចំណេរតមក, ព្រះបាទអាទិត្យ-

1 G. Cœdès, La tradition généologique des premiers rois d'Angkor, B. E. F. E. O., XXVIII, p. 124. 2 G, Cœdès, La Légende de la Nāgī, B. E. F. E. O., XI, 3-4, p. 391 3 Gilberte de Coral Rémusat, L'Art khmer, p. 10.

៤ ព្រះរាជពង្សាវតារព្រះមហាក្សត្រខ្មែរ, ការបោះពុម្ពក្រសួងអប់រំ, ទំព័រ ៤, និងច្បាប់ចម្លង ។

រឿងទ្រង់ព្រះពិរោធចំពោះព្រះថោង ហើយទ្រង់ត្រាស់បង្គាប់ឲ្យព្រះអនុជ ដោយចាប់តាំងព្រះរាជបរិពារស្រីប្រុស, ឲ្យកាត់សក់ជើងកញ្ចៀបខ្សាត់ ពេញកាយទាំងអស់ ហើយបណ្ដែតតាមសមុទ្រសាគរ មកទើបជាប់នៅឆ្នេរសមុទ្រជាផែនដីព្រះបាទអស្សរេយ្យរាជ ១ ថ្ងៃមួយ, ព្រះថោង ស្ដេចទ្រង់អស្សគ្រាជជាទេយ្យប្រាកព្រះឧទរ ព្រមទាំងព្រះរាជបរិពារតាមឆ្នេរសមុទ្រ ទ្រង់ទតព្រះនេត្រឃើញផ្សែងខ្សាច់កបស៊ើល ក្រោមដើមឆ្លូកមួយធំ ទើបស្ដេចទ្រង់ចូលផ្ទំក្រសាលកន្ទីទំនោះ, ចួនពេលនោះ, ទឹកសមុទ្រជោរដល់ឡើងហើយស្ទើរតែប្រាកដជាប់ស្ដេចត្រឡប់មិនបាន ក៏ស្ដេចទ្រង់ប្រថាប់នៅទីនោះរហូតដល់ត្រីកាល ១ កាលនោះ, ព្រះនាងនាគជាព្រះរាជបុត្រីនាគរាជ បបួលរាជបរិពារក្មេងៗខ្លះជាស្រីទេពអប្សរ-កញ្ញាឡើងមកក្រសាលលេងលើផ្សែងខ្សាច់តាមប្រក្រតី ត្រង់ដើមឆ្លូកដែលព្រះថោងទ្រង់ប្រថាប់នោះៗ ឯព្រះថោងទ្រង់ស្ដេចទតព្រះនេត្រឃើញនាងនាគនារី មានរូបឆោមលោមពណ៌ល្អ ក៏មានព្រះទ័យប្រតិព័ទ្ធស្នេហ៍ស្រស្មោះ ហើយសូមជាមេត្រីនឹងព្រះនាងនាគ ។ ព្រះនាងក៏មានសេចក្ដីស្នេហានឹងព្រះថោង ទើបព្រះនាងបដិញ្ញាតតាំងថ្វាយព្រះថោងថា សូមស្ដេចទ្រង់តាំងគំណត់ ៧ ថ្ងៃសិន, សឹមស្ដេចទ្រង់រៀបត្រៀមបណ្ណាការនាំមកប្រគល់នាគទុកជាកូនទីនេះ ដើម្បីនឹងថ្វាយព្រះរាជបិតា តទៅនឹងបានសំរេចពិតប្រាកដដូចព្រះទ័យប្រាថ្នាតាំងទាន; លុះប្រែថាហើយ, ព្រះនាង

នាគីក៏ក្របណាំលចុះទៅកាន់ពិភពនាគវិញ ចូលទៅក្រាបទូលព្រះរា-ជបិតាមាតា តាមប្រព្រឹត្តិហេតុឲ្យស្ដេចទ្រង់ជ្រាបសព្វគ្រប់ប្រការ ។ ព្រះបាទភុជង្គនាគរាជ, ទ្រង់ព្រះសណ្ដាប់ហើយ ក៏ស្ដេចទ្រង់យល់ព្រម តាមព្រះទ័យព្រះរាជបុត្រី, លុះគ្រប់ ៧ ទិវារាត្រីហើយ, ស្ដេចទ្រង់ដែក ប្រថពីទៀនមកជាមួយអគ្គីអគ្គមហេសី ព្រះរាជវង្សានុវង្ស សកលយោ-ធាកងបរិវារ មកកាន់ទីលានគោកធ្លក, ស្ដេចទ្រង់មានព្រះទ័យសោ-មនស្សរាទរចំពោះព្រះថោង ព្រមលើកព្រះរាជបុត្រីថ្វាយជាព្រះជាយេ-តី; ស្ដេចទ្រង់សំដែងឫទ្ធានុភាពស្រូបជក់យកទឹកមហាសមុទ្រ ត្រង់ទី-ស្ថាននោះដើម្បីនិម្មិតព្រះនគររាជធានីប្រាង្គប្រាសាទស្រេច ហើយស្ដេច ទ្រង់រៀបចំពិធីរាជាភិសេកព្រះថោងនិងនាងព្រះរាជបុត្រី ឲ្យគ្រងរាជ្យ នគរគោកធ្លក; ស្ដេចទ្រង់ថ្វាយព្រះនាមព្រះសុណ៌សាជា ព្រះបាទ សម្ដេចព្រះឈាវង្សអស្ចារ្យ, ព្រះរាជបុត្រីជា ព្រះនាងនាគករាជទេ-វី បរមបពិត្រ, ព្រះនាមនគរគោកធ្លកជា ក្រុងកម្ពុជា តាមហេតុ គ្រឹះនេះ ដែលកើតដោយឫទ្ធានុភាពព្រះបាទភុជង្គនាគរាជ ។ តាមដំ-ណើររឿងនេះ, ព្រះបាទសម្ដេចព្រះទេវវង្សអស្ចារ្យ.(ព្រះថោង) ជា ប្រថមក្សត្រិយ៍ខ្មែរនៃព្រះរាជវង្សដើមបំផុត ក្នុងក្រុងកម្ពុជាតាំងពីកាល ណោះមក ។ អ្នកប្រាជ្ញរាជបណ្ឌិត រៀបចំក្រសួងសិក្សាធិការឲ្យមានការ រៀនភាសាសំស្ក្រឹត, មគធ: ហើយផ្លាស់ប្ដូរមកជាអក្សរខេមរភាសា" ។

ហេតុដូច្នេះ, ភាសាជនជាតិខ្មែរ, តាមសិលាចារឹកជាគោល គឺគង់មិនស្លាប់, ពិតជាភាសាខ្មែរយើងនិយាយសព្វថ្ងៃនេះ, បើទុកជាមានប្លែកខ្លះតែដោយសម័យដែលឃ្លាតឆ្ងាយគ្នាតាមយុគ; ភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរ ដែលមានបែបផែនល្អហើយចាស់ជាងគេក្នុងចំណោមជនជាតិប្រទេសឥណ្ឌូចិន ក៏បានជាបែបយ៉ាងនៃជនជាតិនៅជិតខាងផង ដូចជាជាតិសៀមជាដើម ។

តាមសេចក្ដីដែលលើកនិយាយមកនេះ, ទោះជាតិសព្វថ្ងៃនេះ, ខ្ញុំហ៊ានពោលផងសំដែងប្រកដថា បច្ចុប្បន្នជនជាតិខ្មែរលោហិតមកពីបុព្វបុរសខ្មែរបុរាណពិតៗឥតសង្ស័យឡើយ ។

## ព្រះរាជាអង្គខ្លះសម័យនគរ[១]

ព្រះរូបទាំងឡាយដែលទុកដាក់នៅប្រទេសកម្ពុជា ខ្ញុំមិនបានសរសេរទុកគ្រប់ទីនេះទេ, ព្រោះសៀវភៅនេះ ខ្ញុំត្រូវការឲ្យតែយុវជនស្គាល់ព្រះនាមព្រះរូបដែលទុកដាក់នៅនគរ គ្រប់ពេលដែលទៅមើលនគរ កាន់សៀវភៅនៅដៃ អាចបើកមើលហើយស្គាល់ថា ព្រះរាជ

១ លំដាប់ព្រះរាជាទាំងឡាយនេះ ខ្ញុំដកស្រង់យកក្នុងសៀវភៅរបស់អ្នកស្រី Gilberte de Coral Rémusat ឈ្មោះ L'Art Khmèr, ក្រុមពាណិជ្ជការប្រទេសខ្មែរ, ទំព័រលេខ ៩ និង... និងសៀវភៅលោក Henri Marchal ឈ្មោះ La collection Khmère, ក្រុមពាណិជ្ជការនិងការបោះពុម្ព, ទំព័រលេខ ៨ ដល់... ។

នេះព្រះរាជាអង្គនោះទ្រង់កសាងក្នុងក្នុងសករាជប៉ុណ្ណោះ ១ជាដើម ហេតុនេះ ខ្ញុំត្រូវតែយកយកតែព្រះរាជាសម័យនគរ តាមតារាងដែលអ្នកប្រាជ្ញបារាំងសែសបានស្រាវជ្រាវឃើញ ហើយរៀបចំជាបទមាត់ការតាមលំដាប់ជំនាន់តៗ គ្នា ក្នុងកាលរៀបចំបុណ្យឋាននៅប្រទេសខ្មែរ ។

ព្រះបាទភវវរ្ម័នទី ១ ទ្រង់គ្រងរាជ្យក្នុងសតវត្សរ៍ទី ១១ នៃពុទ្ធសករាជ (ព. ស. ១០៨៣), ព្រះបាទមហេន្ទ្រវរ្ម័ន ចិត្រសេន ទ្រង់គ្រងរាជ្យក្នុងសតវត្សរ៍ទី ១២ នៃពុទ្ធសករាជ (ព. ស. ១០៩៣-១១៥៣), ព្រះបាទ ឦសានវរ្ម័ន ទ្រង់គ្រងរាជ្យក្នុងសតវត្សរ៍ទី ១២ នៃពុទ្ធសករាជ (ព. ស. ១១៥៩-១១៧០), តាំងពីព្រះអង្គនេះ ស្ដេចទ្រង់គង់នៅក្រុងហ្វូណន ហើយបានពង្រីកអាណាខេត្តហ្វូណន ឱ្យធំទូលាយឡើង ។ លុះចំណេរតមក, ព្រះបាទឦសានវរ្ម័ន បានវាយសុកដណ្ដើមហ្វូណនមកតាំងក្រុងថ្មីនៅសម្បូរណ៍ ឲ្យក្រុងឈ្មោះ ឦសានបុរៈ (តាមវេញ្ញាក្នុងសិលា-ចារឹក) ស្ថិតនៅទិសឦសាននៃខេត្តកំពង់ធំ (ប្រហែល ៣០ គ. ម. ។ ក្នុងសម័យនោះគេគោរពទេវតាឈ្មោះ ហរិហារៈ ជាទេវតាក្នុងសាសនាព្រាហ្មណ៍, នៅរូបនេះ មានទ្រង់ព្រាយព្រះឥស្សរៈនិងព្រះវិស្ណុលាយចូលគ្នា, ហើយជាពិស្ដារនៃការរចនាខ្មែរជាន់ចាស់យ៉ាងសំខាន់ ។

ព្រះបាទជ័យវរ្ម័នទី ១ ទ្រង់គ្រងរាជ្យក្នុងសតវត្សរ៍ទី ១៣ នៃពុទ្ធសករាជ

(គ.ស. ១៦០៧-១៦១០) ក្នុងកាលនេះ, ប្រទេសខ្មែរកើតកន្ត្រៃប្រែ ចែកចេញជា ២ ផ្នែក គឺប្រទេសកម្ពុជាភាគលើ នៅខាងជើង, ភាគក្រោម នៅខាងត្បូង ។ កម្ពុជាភាគលើ តាំងនៅពីត្រើយភាគកណ្ដាលនៃប្រទេសលាវ[១] ចុះមក, កម្ពុជាភាគក្រោម តាំងនៅភាគទំនាបទន្លេមេគុងនិងដែនកូសាំងស៊ីនតាំងពីមូល; ប្រទេសទាំងពីរនេះ ធ្វើសឹកសង្គ្រាមទៅវិញទៅមកក្នុងកាលនោះ ។

ក្នុងសតវត្សរ៍ទី ១៦ នៃពុទ្ធសករាជ, ពង្សាវតារខ្មែរស្ថិតនៅក្នុងភាពកំបាំង; ក្នុងកាលដែលប្រទេសទាំងពីរធ្វើសង្គ្រាមគ្នាដូច្នេះ ប្រហែលជាមានការលុកលុយមកពីនគរស្រីវិជ័យផង និងមកពីប្រទេសសូមាត្រានិងប្រទេសជ្វា ។

លុះដល់មកខាងចុងសតវត្សរ៍ទី ១៦ និងខាងដើមសតវត្សរ៍ទី ១៨ នៃពុទ្ធសករាជ, ចាប់ព្រះបាទជ័យជេដ្ឋាទី ២ ស្ដេចទ្រង់រាជ្យឡើងក្នុង គ.ស ១៦១៨, បានរួបរួមប្រទេសកម្ពុជាភាគលើភាគក្រោមទាំងពីរឲ្យជាផែនដីរួមអាណាចក្រតែមួយ ។ តាមសិលាចារឹក, មានសេចក្ដីថាព្រះរាជាអង្គនេះស្ដេចទ្រង់មកពីប្រទេសជ្វា នគរស្រីវិជ័យ, ទ្រង់បានរៀបចំប្រទេសឲ្យមានរដ្ឋបាលសាសនាបាយល្អឡើង, ស្ដេចស្ថិតនៅក្នុង-

1 G. Coedès, A propos du Tchen-la d'eau B. E. F. E. O. XXXVI,1,p 1.

ជាន់ប្រើនគន្លង(១) ក្រុងនេះគេបានស្គាល់ប្រាកដថាគឺ ក្រុងហរិ-ហរាលយៈ តាំងនៅជាប់ខាងនឹងក្រុមប្រាសាទរលួស ជាទីដើមទន្លេសាប, ស្តេចទ្រង់បានបង្កើតឲ្យមានការគោរពទេវរាជ "ស្តេចទេព-តា" ហើយ គឺស្តេចទ្រង់លើកខ្លួនព្រះអង្គជាបំណាច់ទេពតា; ការគោរពនេះ គេយកសិវលិង្គជាគោលហើយគេសន្មតជាស្ថានព្រះឥសូរ ។

អំណើរដកពីព្រះបាទជយវរ្ម័នទី ២ ទៅ ព្រះរាជាទាំងឡាយក៏ទ្រង់កសាងព្រះរាជវាំងមកនៅក្រុងហរិហរាលយៈនោះដែរ គឺ :

ព្រះបាទជយវរ្ម័នទី ៣ ទ្រង់រាជ្យ គ. ស. ៨៥០-៨៧៧ ។
ព្រះបាទឥន្ទ្រវរ្ម័នទី ១, ទ្រង់រាជ្យ គ. ស. ៨៧៧-៨៨៩, ស្តេចទ្រង់បានកសាងប្រាសាទព្រះគោ ។
ព្រះបាទយសោវរ្ម័នទី ១, ទ្រង់រាជ្យ គ. ស. ៨៨៩-៩០០, ស្តេចទ្រង់បានកសាងប្រាសាទលលៃ ។

ប្រាសាទបាគង គេចុះសម្គាល់ថាដល់ទេវរាជ "ស្តេចទេពតា" ទុកជួបជា "ភ្នំ" គោលដៅនៃព្រះនគរ ។ ព្រះបាទយសោវរ្ម័នទី ១ ស្តេចទ្រង់លះ-បង់ក្រុងហរិហរាលយៈ ហើយមកតាំងក្រុងថ្មីនៅនគរឈ្មោះ យសោ-ធរបុរៈ នៅកន្លែងដែលសៀមរាប, កណ្តាលទីនេះ មានភ្នំបាខែងជាគោលកណ្តាលនៃព្រះនគរ ។

1 G. Coedès, Les capitales de Jayavarman II, B. E. F. E. O. XXVIII, p. 113.

ក្នុងសតវត្សរ៍ទី១០ នៃគ្រិស្តសករាជ (តាំងពី ព. ស. ១៤៦៤ ឬ ១៤៧១ ទៅដល់ ១៤៨៤), ព្រះបាទជ័យវរ្ម័នទី ៤ ស្ដេចទ្រង់លះបង់ក្រុងនគរទៅបង្កើតក្រុងថ្មីទៀតឈ្មោះ ឈ្មោះករក្សារ? ដែលកោះកេរ ដោយមិនដឹងជាមានហេតុអ្វី; ក្រុងនេះស្ថិតនៅប្រហែល ១០០ គ.ម. ទិសឦសាននគរ, តែការបង្កើតក្រុងឈូកគរក្សារ មិនយូរប៉ុន្មាន ក៏មិនយូរជាង២៣ឆ្នាំ ។

ក្នុងសតវត្សរ៍ទី១០ នៃគ្រិស្តសករាជ (ព. ស. ១៤៨៧-១៥១១), ព្រះបាទរាជេន្ទ្រវរ្ម័ន ស្ដេចឡើងគ្រងរាជ្យ ហើយក្រឡប់មកគង់នៅនគរវិញ, ស្ដេចបានកសាងប្រាសាទប្រែរូប, ប្រាសាទមេបុណ្យនៅខាងកើតនគរ, ស្ដេចបានធ្វើសឹកសង្គ្រាមនឹងចាមមានជ័យជំនះ ។

ក្នុងសតវត្សរ៍ទី១០ នៃគ្រិស្តសករាជ (ព. ស. ១៥១១-១៥៤៤), ព្រះបាទជ័យវរ្ម័នទី ៥ ឡើងគ្រងរាជ្យ, ស្ដេចបានកសាងប្រាសាទតាកែវ[១], ប្រាសាទភិមានអាកាស, ប្រាសាទបន្ទាយស្រី និងព្រះរាជវាំង ។

ក្នុងដើមដំបូងសតវត្សរ៍ទី១១ នៃគ្រិស្តសករាជ · (ព. ស. ១៥៤៣ ១៥៩៤), មានច្បាំងដណ្ដើមរាជ្យឡើង ព្រះបាទសូរ្យវរ្ម័នទី ១ ស្ដេចឡើងគ្រងរាជ្យ; ទ្រង់ជាព្រះរាជបុត្រព្រះបាទឥន្ទ្រ...[២] ស្រុកជាំងកោះ

១ ប្រាសាទតាកែវ ។ ២ Gilberte de Coral Rémusat, L'Art khmèr, p. 12.

ម៉ាលេ) ។ ស្ដេចទ្រង់បានពង្រីកអាណាចក្រខ្មែរទៅដល់ក្រុងចាក់តែ ប្រទេសសៀមភាគខាងត្បូង ។ ស្ដេចជាអ្នកកាន់ព្រះពុទ្ធសាសនាមហាយាន តែស្ដេចកសាងប្រាសាទសាសនាព្រាហ្មណ៍ដែរ សម្រាប់ទុកថ្វាយព្រះឥស្សូរ និងព្រះវិស្ណុ ដូចប្រាសាទវត្តឯក នៅក្រុងបាត់ដំបង, ប្រាសាទភ្នំជីសូរ (ភ្នំឥស្សូរ) និងប្រាសាទវត្តបាសិទ្ធ ។

ចន្លោះសតវត្សរ៍ទី ១៦ និងទី ១៧ នៃពុទ្ធសករាជ (ព.ស. ១៥៩៦-១៦០៨), ព្រះបាទឧទយាទិត្យវរ្ម័នទី ២, ស្ដេចឡើងគ្រងរាជ្យ, ស្ដេចបានកសាងប្រាសាទបាពួន ។

ក្នុងសតវត្សរ៍ទី ១៧ នៃពុទ្ធសករាជ (ព.ស. ១៦០៨-១៦៣៣). ព្រះអនុជព្រះបាទឧទយាទិត្យវរ្ម័នទី ២ ព្រះនាមព្រះបាទហស៌វរ្ម័នទី ៣ ឡើងគ្រងរាជ្យ ។ ក្នុងរាជ្យព្រះអង្គ ចាប់ផ្ដើមសឹកសង្គ្រាមនឹងចាមឡើង ។ ក្នុងសម័យដែលព្រះរាជាទាំងឡាយគ្រងរាជ្យ តព្រះរាជវង្សមកពីព្រះបាទឧទយាទិត្យវរ្ម័នទី ២ ក, ប្រទេសកម្ពុជាកើតសឹកសង្គ្រាមនឹងប្រទេសចាមចលាចលខ្លាំងណាស់ ។

ក្នុងសតវត្សរ៍ទី ១៧ នៃពុទ្ធសករាជ, ព្រះបាទសូរ្យវរ្ម័នទី ២ ស្ដេចឡើងគ្រងរាជ្យ ។ ស្ដេចធ្វើបាយកលចូលដៃចាម លើកទ័ពទៅវាយយួនខានជ័យ, ហើយត្រឡប់មកវាយចាមវិញទៀត, ទ័ពខ្មែរចូលលុកក្រុង

វាយបានក្រុងចាម ចាប់ស្ដេចចាមជាឈ្លើយបានក្នុង ព.ស. ១៦៨៨ ។ ការឈ្លោះសង្គ្រាមតាមគ្រានេះមិនយូរប៉ុន្មាន, ក្នុង ព.ស. ១៦៩៦, ចាមលើកទ័ពមកលុកក្រុងខ្មែរវិញ ។ ក្នុងរជ្ជព្រះអង្គ ស្ដេចបានកសាងប្រាសាទនគរវត្ត. ក្នុងវេលា ព.ស. ១៦៩៨ ក្រោយស្ដេចទិវង្គតទៅ, ប្រទេសកម្ពុជាកើតកាន់តែប្រែ ។ ក្នុង ព.ស. ១៧១០, ចាមចូលមកលុកក្រុងនគរ ដុតផ្ទះលំនៅរឹបទ្រព្យអស់ជាច្រើន ។

ក្នុងសតវត្សរ៍ទី ១៨ នៃពុទ្ធសករាជ (ព.ស. ១៧៦៦), ព្រះបាទជ័យវរ្ម័នទី ៧ ស្ដេចឡើងកាន់ដំបល្ល័ង្ក ។ ស្រោចស្រង់សេចក្ដីសុខក្សេមក្សាន្តពោលមកដល់ក្នុងកាលៈនោះ ។ ស្ដេចចាប់ធ្វើសឹកសង្គ្រាមសងសឹកចាមវិញ ស្ដេចបានព្រះរាជបុត្រព្រះអង្គ គឺព្រះបាទឥន្ទ្រវរ្ម័នទី ២ ជាវីរៈបុរសជាតិមួយ ស្ដេចលើកទ័ពចូលទៅលុកក្រុងចាម ឡើងត្បូងចាប់ស្ដេចចាមជាឈ្លើយបាន ហើយស្ដេចតាំងព្រះរៀមថ្លៃជាស្ដេចគ្រប់គ្រងទៅនគរចាម ។ តាំងពី ព.ស. ១៧៤៦ ទៅដល់ ១៧៦៣ ប្រទេសចាមធ្លាក់មកជាប្រទេសចំណុះខ្មែរ ។ ក្នុងរជ្ជព្រះអង្គនេះ, ព្រះរាជអាណាចក្រខ្មែរធំទូលាយណាស់ លាតពេញលើទឹកដីតាមទន្លេមេគុង, ដល់ក្រុងវៀងចន្ទន៍ (ប្រទេសលាវ) និងក្រុងសុខោទ័យ (ប្រទេសសៀម) ។

ព្រះបាទជ័យវរ្ម័នទី ៧ នេះ, ព្រះអង្គជាស្ដេចសឹកដ៏ល្បីល្បាញ ជាស្ដេចអ្នកកសាងប្រាសាទដ៏លើស ជាស្ដេចធម្មិកសមានឈ្មោះល្បី, ស្ដេចបាន

គសាងប្រាសាទព្រះខាន់, ប្រាសាទតាព្រហ្ម, ប្រាសាទបន្ទាយក្តី, ប្រាសាទបាយ័ន, ជីកស្រះ (ស៊ិន្ទ) ព័ទ្ធជុំវិញក្រុង គសាងកំពែងធំសំ-បើមប្រកបដោយបុរៈ (ទ្វារធំៗ) ចាំង ៥ សម្រាប់ការពារបច្ចាមិត្រមិនឱ្យលុកក្រុងបាន ។ ដោយព្រោះតែការគសាងប្រាសាទ ស្តេចទ្រង់បានគសាងមន្ទីរពេទ្យជាច្រើនរយកន្លែង, លោក ល្វី-ហ្វីណូត៍[1] សរសេរថា: “សិលាចារឹកព្រះបាទជ័យវរ្ម័នទី ៧ ឆ្លើយប្រាប់ទាំងពីប្រទេសលាវ, ហួសទៅដល់ឆ្នេរសមុទ្រប្រទេសអណ្ណាម, និងប្រទេសសៀមរហូតដល់ខាងក្រោម ពីប្រទេសកូសាំងស៊ីនសព្វថ្ងៃនេះ, ទ្រង់និយាយបញ្ជាក់ពីជ័យជំនះរបស់ព្រះអង្គ, ទ្រង់ទៀត និយាយពីអំពើជាកុសល (គឺការកសាងមន្ទីរពេទ្យ) ដែលទ្រង់គសាង, សិលាចារឹកទាំងអស់នេះ បានព្រាលបំភ្លឺតម្រាការប្រទេសកម្ពុជាក្នុងអតីតកាលឲ្យឃើញច្បាស់ថា ព្រះបាទជ័យវរ្ម័នទី ៧ ជាមហាក្សត្រមួយព្រះអង្គទ្រង់ប្រកបដោយធម៌” ។

ដូចបានពោលមកហើយ, កាលសម័យព្រះបាទជ័យវរ្ម័នទី ២ ស្តេចទ្រង់បានប្រតិស្ឋានសំលៀកជា “ទេវរាជ ស្តេចទេវតា” ទុកជាទីគោរពបូជ-មស្សការ, លុះដល់មកជំព្រះបាទជ័យវរ្ម័នទី ៧ ស្តេចទ្រង់លើកយកព្រះពុទ្ធរូបជា “ទេវរាជ ស្តេចទេវតា” វិញ គឺព្រះពុទ្ធរូបដែលគេរើបជីកយកពីកណ្តាលប្រាសាទបាយ័ន កាល ព.ស. ២៤៧៨..., ព្រះពុទ្ធរូបនេះ

1 Louis-Finot, L'inscription sanscrite de Say-fong, B. E. F. E. O., III, p. 22.

ជាទេវរាជ ជំនាន់ព្រះបាទជ័យវរ្ម័ននោះឯង ។ ស្តេចជាសាសនូបត្ថម្ភក មហាគជ់ ប្រាគ្គប្រាសាទដែលទ្រង់កសាងតាំងពុំទាន សុទ្ធតែឧទ្ទិសបូជា ដល់ព្រះពុទ្ធសាសនាមហាយាន ដូចព្រះពោធិសត្វអវលោកិតេស្វរៈ, ព្រះប្រាជ្ញាបារមីតាជាដើម ។

ម្យ៉ាងទៀត, ទ្រង់បានកសាងផ្នូសាលា ឧទ្ទិសថ្វាយព្រះពោធិសត្វ អវលោកិតេស្វរៈ និងទេវតា ជាអ្នកថែរក្សាព្រះកជតានី តាមផ្លូវធំឆ្ងាយពីគ្នា ១៥ ក. ម. ឬ ២០ ក. ម. សម្រាប់ជាទីស្នាក់ផ្ទាកកោនឬជាទីស្នាក់នមស្ការនៃអ្នកដំណើរទាំងឡាយ ឲ្យធ្វើដំណើរពីស្ថានមួយទៅស្ថានមួយ ។ ព្រះរាជាអង្គនេះ, ទ្រង់ជាក្សត្រិយ៍សឹក (អ្នកចំបាំង) ដែលមានជ័យជំនះជាដរាប, ជាអ្នកកសាងប្រាសាទមិនឈប់ឈរ, ជាវរបុរស មានវប្បសាស-នោបាយនាំតែសេចក្តីចំរើន, ទ្រង់បានកសាងប្រទេសខ្មែរឲ្យឡើងកាន់សេចក្តីចំរើនដុំរុងរោចន៍ ដែលឥតមានព្រះរាជាអង្គណា សម័យខាងក្រោយស្មើនឹងព្រះអង្គបាន; លុះសោយទីវង្គតព្រះអង្គទៅ ទើបប្រទេសខ្មែររៀវរៀបក្រោយ ដុនដាបចុះមកជាលំដាប់ ។ តាមសេចក្តីពិនិត្យពិចារណាលោក សឺដែស អ្នកប្រាជ្ញបារាំងដ៏វិសេស ដែលលោកត្រិះរិះគិតអំពីការងាររបស់ស្តេចអង្គនេះ, លោកសរសេរទុកថា[1] "ត្រូវគិតដល់បុណ្យកេរ្តិ៍ជាតិករណ៍ជាតិខ្មែរ ក្នុងកាលដែលកន្លងទៅហើយ ដែលជាតិខ្មែរបានកសាងប្រាសាទធំៗ

1 H. Marchal, La collection Khmère, p. 25-26-27-28.

បន្ទាយសំរែ, បេងមាលា និងព្រះវិហារខ្ទុំ ដោយទឹកញើសចេញពីថ្ងាស ដូចមានការគេសាងសង់នេះទុកជាតិកតាងស្រាប់ ដែលស្តេចបានកេណ្ឌប្រជាជនទៅយកថ្មនៅភ្នំគូលេន ដឹកនាំជុំផ្តុំវាយកមកបន្តបង្កើតប្រាសាទ, ឆ្លាក់ជាក្បាច់រលេចក្បាច់គ្រឿងអលង្ការ, ត្រូវតែគិតដល់ប្រជាជនដែលទ្រង់កេណ្ឌយកមកប្រើប្រាស់ ឲ្យធ្វើការហាក់ដូចជាអ្នកមានមហន្តទោស កងការកសាងប្រាសាទទុកជាយសសក្តិព្រះរាជជនក, ព្រះរាជជននី ឬមកុដកុមារ ដែលជាការកសាងឥតមានការហាត់ទុកមុន នឹងការតែរត្រាំតែយកកេរ្តិ៍ឈ្មោះ, មិនមែនតែជាងអ្នកកសាងប៉ុណ្ណោះឡើយ, ត្រូវគិតដល់ព្រះរាជបរិវារនៃព្រះរាជអង្គនោះផង ដែលបានកេណ្ឌស្បៀងអាហារពលមនុស្ស ៨០៨០,០០០ នាក់ (៨លាន ៨ម៉ឺន) ត្រូវគិតដល់ស្បៀងអាហារដែលស្តេចអង្គនេះ បានប្រមូលយកមកអំពីប្រជាជនចម្ការ គិតជាមាស ៥ ពាន់គីឡូក្រាម, និងប្រាក់ជាច្រើនពាន់, គជ ៤ ម៉ឺន មិនគិតដល់គ្រឿងទៀតៗដែលសំកប់ជាទេវរូបនោះឡើយ ។ ដោយហេតុនេះ, ប្រទេសកម្ពុជា, ក្នុងចប់ផុតសតវត្សរ៍ទី ១៨ នៃពុទ្ធសករាជ ជាប្រទេសរុងរឿងឬ? ត្រង់នេះ, យើងត្រូវឆ្លើយថា សេចក្តីរុងរឿងនេះ បានមកដោយឈាមជ័រនៃព្រះរាជាស្តេចនៅលើបល្ល័ង្ក ហើយចង់បានកេរ្តិ៍កិត្តិយសកិត្តិនាម; យើងពិនិត្យមើលមិនឃើញពិតប្រាកដថា ប្រទេស

ខ្មែរជាប្រទេសមានទ្រព្យសម្បត្តិស្តុកស្តម្ភទៀយ. តាមដែលយើងមើលឃើញនឹងភ្នែកយើង. យើងឃើញតែផ្លូវដែលគេសាងតាមព្រះរាជបច្ច-ច័យ, ទាំងកសាងយ៉ាងស្រួល រហូតដល់ពួកជាងមិនអាចនឹងគិតថ្ម ដែលបន្តឲ្យបានសំរេច, មិនមានផ្លូវតែប្រាកដនឹងប្រើប្រាស់ហើយយកថ្មបាយក្រមមកដាក់ជំនួសខ្វះ. រៀនបាក្យក្រឡាក់មិនទាន់ហើយស្រេច, គ្រឿងអលង្ការមិនសមរម្យ ៦ព្រះបាទជ័យវរ្ម័នទី ៧ នេះទ្រង់មិនមែនជាស្តេចនៅក្នុងវ័យក្មេងឡើយ ហើយសព្វព្រះវ័យទ្រង់ទតប្រាសាទដែលទ្រង់កសាងឲ្យបានហើយស្រេចក្នុងកាលដែលទ្រង់គង់ព្រះជន្មនៅឡើយ តាមគ្រាន់ការកសាងប្រាសាទដែលទ្រង់រៀបចុក ។ អំពីនេះ លុះទ្រង់ទិ-វង្គតទៅ តើដូចម្តេច? តាមសិលាចារឹក យើងបានដឹងថាព្រះរាជាដែលទ្រង់គង់រាជ្យតមក ទ្រង់បដិសេធព្រះពុទ្ធសាសនាទាំងអស់ ហើយប្រែបត្តិតាមសាសនាព្រះព្រាហ្មណ៍ ជាសាសនាបុរាណ, គេបានឃើញប្រា-សាទជាច្រើន ដែលមានការបដិវត្តិប្រែប្រួលទៅតាមសាសនាព្រាហ្មណ៍ៈ និយាយដោយពិត, ពីព្រះរាជាអង្គនេះ ទ្រង់កសាងសេចក្តីវិនាសទុកឲ្យប្រទេស ដោយការចាយប្រាក់កាសកតបើតិត. តមក, ឥតមានកម្លាំងទប់ទល់នឹងបច្ចាមិត្តទាំងសងខាងលិចដែលទន់ខ្សោយ ដែលមាននិស្ស័យចង់គ្រងគ្រប់ស្រុក ។ លុះដល់មក គ.ស. ១៨៥៩ អ្នកដំណើរជនម្នាក់

ឈ្មោះ ចៀវតាក្វាន់ មកកាន់ប្រទេសខ្មែរ ក៏បានឃើញប្រទេសខ្មែរ ត្រូវគេកំទេចខ្ទេចខ្ទីហើយដោយចម្បាំងនឹងជាតិសៀម ។

មានអ្នកប្រាជ្ញខ្លះយល់ថា ការធ្លាក់ចុះនៃប្រទេសខ្មែរ ជាប្រស្នាដែលកាយសេចក្តីមិនបែក ហើយអ្នកប្រាជ្ញនោះបដិសេធថា ប្រាសាទអស់នេះមិនមែនជាស្នាដៃខ្មែរទេឡើយ, រឿងនេះ មិនមែនជាប្រស្នាកាយមិនបែកដូច្នោះទេ, ខ្មែរសព្វថ្ងៃនេះ ប្រាកដជាពូជពង្សដែលស្រឡាយសាច់ឈាមខ្មែរពិតប្រាកដដែលកសាងនគរ ដូចការសន្និដ្ឋានដែលមាននៅក្នុងសិលាចារឹក តាំងពីសតវត្សរ៍ទី ១២ ក៏មិនខុសពីខ្មែរសម័យយើងនេះឡើយ ប្លែកតែបន្តិចបន្តួចប៉ុណ្ណោះ ដោយក្លាយយាវគាត់មក ។

ចុះជាតិណា ដែលត្រូវគេល្អយកទៅកសាងប្រាសាទធំសំបើមៗ ដោយសេចក្តីព្យាយាមយ៉ាងមាំមួន ហើយតាមទ្រព្យសម្បត្តិកសាងប្រាសាទច្រើនដល់ប៉ុណ្ណេះ? ដ្បិតថា គឺជាតិខ្មែរដែលបានដល់ថ្នាក់ជាមហាសេដ្ឋីហើយ គឺធ្លាក់ចុះដោយការញោញីអំពីភិក្ខុយសរបស់ព្រះពជព្រះអគ្គឯង ។

ហេតុដូច្នេះ, ដល់មកខាងដើមសតវត្សរ៍ទី ១៥ នៃគ្រិស្តសករាជ, សម័យរុងរឿងនៃការកសាងថយចុះហើយ, បក្សកត្តិខ្មែរ, ដោយការលុកលុយជាតិសៀម ដែលមកធ្វើឲ្យកំរើកមហាអំណាចស្តេចខ្មែរ, ក៏ដើរទៅកាន់

សេចក្ដីលំបាកហូតដល់លះបង់ចោល ។ ក្សត្រិយ៍ខ្មែរដែលលះបង់ចោលហើយ, មកប្រតិស្ឋានចំក្រុងនៅស្រីសន្ធរ មកនៅភ្នំពេញ, នៅលង្វែក, នៅឧដុង្គ, ទីបំផុតមកនៅភ្នំពេញវិញ ដែលជាកន្លែងទិសត្បូងនេះ ។

ប្រាសាទខ្មែរ ដោយហេតុញាំញីនៃបច្ចាមិត្រដែលមានជ័យ ក៏ត្រូវលះបង់ចោល, តាំងពីកាលនោះមក, ក្នុងប្រទេសក្ដៅ អាចបង្កើតឲ្យមានរុក្ខជាតិដុះលូតលាស់យ៉ាងរហ័ស ព្រៃព្រឹក្សាក៏អាចដុះដេរដាស់ ចាក់ឫសព័ទ្ធព័ន្ធ រំលើងដុំថ្មផ្ដួលរលំប្រាសាទខ្លះអស់ជាច្រើន ។

លុះដល់ ព.ស.២៤៥០ កាលដែលសៀមប្រគល់ខេត្តបាត់ដំបងនិងសៀមរាបមកប្រទេសបារាំងសែសវិញ ទើបលោក ជ. កុម្មៃ (Jean Commaille) អ្នកថែរក្សាទីនគរជាបឋម ជាក្រុមសាលាបារាំងសែសចុងបូព៌ាប្រទេស មករៀបចាត់ចែងកាប់ឆ្ការព្រៃព្រឹក្សា ហើយជួសជុលប្រាសាទដែលរលំខ្លះឲ្យបានគង់ទ្រង់ទ្រាយវិញ, ការរៀបចំនេះគឺចាប់ផ្ដើមឡើងឥតឈប់ឈរ អាចការពារមិនឲ្យវិនាសតទៅទៀតបានជាច្រើន ។

ទីបំផុត បានរៀបចំឲ្យមានផ្លូវគមនាគមន៍នៅក្នុងទីនគរតាមរបៀបថ្មី ឲ្យបានចំរើនរហ័សជានិច្ច ។

ក្នុង ព.ស. ២៤៧៨ បានតាំងមន្ត្រីត្រួតត្រាបុរាណវត្ថុនៅប្រទេសខ្មែរ សម្រាប់ការពារប្រាសាទដែលស្ថិតនៅឆ្ងាយគ្នាពីនគរ អាចឲ្យអ្នកថែរក្សាទៅរៀបចំបានស្រួល ។

# បញ្ជីរាយនាមស្តេចសម័យនគរ(១)

| ព្រះនាមស្តេច | សម័យ | ប្រាសាទ |
|---|---|---|
| ភវវរ្ម័ន ទី ១ | រវាង ព.ស. ១០៧៣ | |
| មហេន្ទ្រវរ្ម័ន | —. ព.ស. ១១៥៣ | |
| ឦសានវរ្ម័នទី ១ | ក្រោយឆ្នាំ ព.ស. ១១៥៩ មុនឆ្នាំ ព.ស. ១១៧៨ | សម្បូរព្រៃគុក |
| ភវវរ្ម័ន ទី ២ | — ព.ស. ១១៨២ | |
| ជ័យវរ្ម័ន ទី ១ | — ព.ស. ១២០០ មុនឆ្នាំ ព.ស. ១២០៨ | |
| *សម័យកាន់ប្រែ, ប្រទេសកម្ពុជា បែកចេញជាពីរផ្នែក:* | | |
| *កម្ពុជាភាគលើ (នៅខាងជើង) ភាគក្រោម (នៅខាងត្បូង)* | | |
| ជ័យវរ្ម័ន ទី ២ | ព.ស. ១៣៤៥ — ១៣៩៣ | ប្រាសាទនៅភ្នំគូលេន |
| ជ័យវរ្ម័ន ទី ៣ | ព.ស. ១៣៩៣ — ១៤២០ | |
| ឥន្ទ្រវរ្ម័ន ទី ១ | ព.ស. ១៤២០ — ១៤៣២ | បាគង-ព្រះគោ |
| យសោវរ្ម័នទី ១ | រវាង ព.ស. ១៤៣២ ដល់មក ១៤៤៣ | បាខែង, លលៃ, [illegible] |
| ហស៌វរ្ម័ន ទី ១ | ក្នុងរវាង ព.ស. ១៤៤៣ មុនឆ្នាំ ១៤៦៥ | |
| ឦសានវរ្ម័នទី ២ | ព.ស. ១៤៦៥ | |
| ជ័យវរ្ម័ន ទី ៤ | ព.ស. ១៤៧១ — ១៤៨៥ | កោះកេរ |
| ហស៌វរ្ម័ន ទី ២ | ព.ស. ១៤៨៥ — ១៤៨៧ | កោះកេរ |
| រាជេន្ទ្រវរ្ម័ន ទី ២ | ព.ស. ១៤៨៧ — ១៥១១ | [illegible], ប្រែរូប, មេបុណ្យខាងកើត |

-1 H. Marchal. La collection khmère, P. 29, 30.

| ព្រះនាមស្តេច | សម័យ | ប្រាសាទ |
|---|---|---|
| ជ័យវរ្ម័ន ទី ៥ | ព.ស. ១៥១១ – ១៥៤៤ | បន្ទាយស្រី. តាកែវ |
| ឧទយាទិត្យវរ្ម័នទី១ | ព.ស. ១៥៤៤ – ១៥៤៥ | |
| ជយវីរវរ្ម័ន | ព.ស. ១៥៤៥ – ១៥៥៣ | |
| សូរ្យវរ្ម័ន ទី ១ | ព.ស. ១៥៤៥ – ១៥៩២ | តាកែវ |
| ឧទយាទិត្យវរ្ម័នទី២ | ព.ស. ១៥៩២ – ១៦០៩ | បាពួន |
| ហស៌វរ្ម័ន ទី ៣ | ព.ស. ១៦០៩ – ១៦៣៣ | |
| ជ័យវរ្ម័ន ទី ៦ | ព.ស. ១៦២៥ – ១៦៥០ | ពេងមាណា |
| ធរណីន្ទ្រវរ្ម័ន ទី ១ | ព.ស. ១៦៥០ – ១៦៥៦ | |
| សូរ្យវរ្ម័ន ទី ២ | ព.ស. ១៦៥៦ – ១៦៩៩ (?) | នគរវត្ត |
| ធរណីន្ទ្រវរ្ម័នទី ២ | រវាង ព.ស. ១៦៩៣ | |
| យសោវរ្ម័ន ទី ២, | រវាង ព.ស. ១៧០៣ | |
| ត្រីភុវនាទិត្យវរ្ម័ន | ព.ស. ១៧០៨ – ១៧២០ | |
| ជ័យវរ្ម័ន ទី ៧ | ព.ស. ១៧២៤ មុនឆ្នាំ ព.ស. ១៧៤៤ | កសាងនគរធំ, បាយ័ន |
| ឥន្ទ្រវរ្ម័ន ទី ២ | ព.ស. ១៧៤៤ – ១៧៨៥ | កាន់ប្រសាសនាព្រហ្មណ៍ឡើងវិញ |
| ជ័យវរ្ម័ន ទី ៨ | ព.ស. ១៧៨៥ – ១៨៣៩ | |
| ឥន្ទ្រវរ្ម័ន | ព.ស. ១៨៣៩ – ១៨៥០ | |
| ឥន្ទ្រជ័យវរ្ម័ន | ព.ស. ១៨៥០ – ១៨៧០ | |
| ជ័យវរ្ម័នបរមេស្វរៈ | ព.ស. ១៨៧០ | |

❀

## លទ្ធិសាសនា

ប្រាសាទទាំងឡាយដែលយើងបានមើលឃើញសព្វថ្ងៃនៅទីនេះ, សុទ្ធតែជាប្រាសាទដែលគេកសាងឡើងដើម្បីឧទ្ទិសដល់សាសនា មិនមែនជាប្រាសាទសម្រាប់ស្ដេចនៅនៃព្រះរាជាក្នុងសម័យនោះឡើយ ។ សម័យនោះ, ជាសម័យដែលគេគោរពសាសនាយ៉ាងមាំមួន មិនមែនតែប្រទេសកម្ពុជាឡើយ សូម្បីប្រទេសដទៃក្នុងសកលលោកសម័យជាមួយគ្នា ក៏កាន់សាសនាខ្លាំងណាស់ដែរ, ហេតុនេះ, ក្នុងសម័យនោះ គេអាចពិនិត្យឃើញមានសាសនាធំពីរជាប្រធាន ដោយការបញ្ជាក់ដោយរូបផ្សេងៗ ដែលមានជាប់នៅនឹងប្រាសាទ គឺ ព្រះពុទ្ធសាសនានឹងសាសនាព្រាហ្មណ៍ ។

## ព្រះពុទ្ធសាសនា

លទ្ធិព្រះពុទ្ធសាសនា ចំរើនបរិបូណ៌ពេញប្រទេសឥណ្ឌា ហើយផ្សាយចេញទៅក្នុងសកលលោកទាំងពីរនិកាយ គឺ ហីនយាន ១ មហាយាន ១ ។

ពុទ្ធសាសនាសម័យនោះ មិនមែនជាលទ្ធិហីនយានដូចយើងសព្វថ្ងៃនេះទេ លទ្ធិហីនយាននេះផ្សាយមកជាន់ក្រោយគឺក្នុងពេលដែលប្រទេសខ្មែរយើងមានសេចក្ដីចំរើន កាលប្រទេសខ្មែរយើងជួបគ្រាទុគ៌ត

កាលណា ទើបលទ្ធិហីនយាននេះហូរចូលមកច្រើនពេកប្រទេសសៀមហូត ដល់ពេញប្រទេសខ្មែរដូចសព្វថ្ងៃនេះ តាំងពីកាលមុន ព. ស. ២០៦៧ ទៀតមក ។

លទ្ធិមហាយាន — អ្នកកាន់តាមលទ្ធិមហាយាន ក៏ឈ្មោះថា អ្នកកាន់ព្រះពុទ្ធសាសនាដែរ, កាលដើមមានតែឈ្មោះមួយថា ព្រះពុទ្ធសាសនា លុះចំណេរតមក អ្នកកាន់ព្រះពុទ្ធសាសនាក៏បែកខ្ញែកគ្នាចេញទៅជាច្រើននិកាយ, និកាយធំៗគឺ ហីនយាននឹងមហាយាននេះ ។

ព្រះពុទ្ធសាសនាលទ្ធិមហាយាន ប្រកាន់លទ្ធិអាចារិយវាទ គឺប្រកាន់តាមគ្រូអាចារ្យរបស់ខ្លួនតៗគ្នា មិនប្រតិបត្តិតាមគោលព្រះត្រៃបិដកដូចហីនយានឡើយ ។ តាមសេចក្តីយល់អ្នកកាន់លទ្ធិមហាយាន គេបានបង្កើតគម្ពីរដាច់ឡែកចេញពីគោលដើមនៃព្រះត្រៃបិដកជាច្រើន ដូចគម្ពីរសទ្ធម្មបុណ្ឌរីក, គម្ពីរលង្កាវតារសូត្រ, គម្ពីរប្រាជ្ញាបារមិតាជាដើម ជាភាសាសំស្ក្រឹតទាំងអស់ ដោយគេយល់ថា ព្រះពុទ្ធជាគ្រូទ្រង់អនុញ្ញាតឱ្យអ្នកកាន់ព្រះពុទ្ធសាសនារៀនសូត្រជាអក្សរសំស្ក្រឹត ជាទំនាស់នឹងហីនយានដែលរៀនសូត្រតាមភាសាមគធៈ; គេបានបង្កើតទេវរូបជាច្រើនលើសលុបអំពីគណនាបាន សម្រាប់ជាទីគោរពបូជា ដូចព្រះពុទ្ធរូប, រូបលោកេស្វរៈ រូបប្រាជ្ញាបារមិតាជាដើម ។

ព្រះពុទ្ធសាសនាលទ្ធិមហាយាន មានឫទ្ធានុភាពច្រើនណាស់ ផ្សាយពីប្រទេសឥណ្ឌាចូលទៅកាន់ស្រុកតូចស្រុកធំក្នុងសកលលោក មានប្រទេសទីបេត៍, ចិន, ជប៉ុន, យួន, ខ្មែរ, ជ្វា ជាដើម ប្រទេសទាំងអស់នេះ មានព្រះពុទ្ធសាសនាលទ្ធិមហាយានឋិតថេររហូតមកដល់សព្វថ្ងៃនេះ ។

លទ្ធិហីនយាន — ព្រះពុទ្ធសាសនាលទ្ធិហីនយាន ប្រកាន់តាមលក្ខណៈថេរវាទ គឺកាន់តាមគោលត្រៃបិដកជាធំ ដូចប្រទេសខ្មែរយើង, សៀម, លង្កា, ភូមា សព្វថ្ងៃនេះ ។

## សាសនាព្រាហ្មណ៍

ព្រះពុទ្ធសាសនានឹងសាសនាព្រាហ្មណ៍ទាំងពីរនេះ កើតនៅប្រទេសឥណ្ឌាជាច្រើនរយសតវត្សរ៍មកហើយ ទើបផ្សាយចូលមកប្រទេសកម្ពុជាយើងនេះ; កាលប្រទេសយើងកំពុងរុងរឿង, សាសនាទាំងពីរនេះក៏មកប្រតិស្ឋាននៅប្រទេសកម្ពុជានេះសម័យជាមួយគ្នា, តាមសិលាចារឹក, លោក សឺដែស លោកសរសេរទុកថា: "ព្រះពុទ្ធសាសនានឹងសាសនាព្រាហ្មណ៍មានគេកាន់ការស្មើគ្នាទាំងពីរ នៅប្រទេសខ្មែរយើងគបផ្គបមក" ។ សព្វថ្ងៃនេះ ប្រទីបសាសនាព្រាហ្មណ៍រលត់បាត់បង់ទៅហើយ, កែងតែគំនិតជនជាតិខ្មែរខានសេចក្តីប្រកាន់លទ្ធិសាសនា

ព្រាហ្មណ៍នៅឡើយ លាយបន្តិចមួយនឹងព្រះពុទ្ធសាសនា ។ ឯទេវរូប សាសនាព្រាហ្មណ៍ទាំងសម័យនោះមាន ៣ គឺ ព្រះឥសូរ, ព្រះវិស្ណុនិងព្រះព្រហ្ម; សេចក្ដីយល់សម័យនោះថា ព្រះព្រហ្មជាអ្នកកសាងលោក, ព្រះឥសូរជាអ្នកបំផ្លាញលោក, ព្រះវិស្ណុជាអ្នកថែរក្សា, គេច្រើនគប់រកព្រះវិស្ណុនិងព្រះឥសូរជាង, ព្រះព្រហ្មគេមិនសូវគប់រកទេ ។ ព្រះវិស្ណុទេវតាថែរក្សាត្រកូល អវតារបានច្រើនដង, អវតារជាជ្រូកព្រៃឈ្មោះវរាហៈ ទៅដណ្ដើមយកផែនដីពីក្នុងសមុទ្រដែលយក្សលួចយកទៅ, អវតារជាសីហៈ ជួនកាលជាអណ្ដើក ឬជានរសីហៈ គឺក្បាលជាសត្វសីហៈខ្លួនជាមនុស្សវិញ, អវតារជាវាមនៈ គឺព្រាហ្មណ៍តឿជាម្ចាស់ផែនដី, អវតារជាព្រះរាម ច្បាំងដណ្ដើមយកសកលលោកដោយគ្រាន់តែឈាន ៣ ជំហាន ។ តាមធម្មតា, ព្រះវិស្ណុនេះជាទេវតាឈរ មានដៃបួន, កាន់ព្រះខាន់, កាន់ដំបង, កាន់ចក្រនិងស័ង្ខ, មានសត្វគ្រុឌជាពាហនៈ; ជួនកាលផ្ទេកបណ្ដោយលើពស់ឈ្មោះសេសៈ ឬ អនន្តៈ មានដើមឈូកដុះចេញពីផ្ចិត, នៅលើផ្កាឈូកមានរូបព្រះព្រហ្ម[១] ជួនកាលព្រះវិស្ណុនេះអវតារជាក្រិស្ណ លើកដៃទ្រភ្នំការពារហ្វូងសត្វនិងអ្នកគង្វាល ឬអវតារជាព្រះរាមច្បាំងដណ្ដើមនាងសីតាពីរាពណ៍ ក្នុងរឿងរាមកេរ្តិ៍[២] ។

---

១ អ្នកប្រាជ្ញយល់ថា រឿងរាមកេរ្តិ៍ (ព្រះវិស្ណុអវតារជាព្រះរាម) ថ្លែងកាលពួកអារ្យកៈលើកទ័ពទៅវាយយកកោះលង្កាទ្វីប ។ រឿងមហាភារតៈ (ព្រះវិស្ណុអវតារជាក្រិស្ណ) ថ្លែងកាលពួកអារ្យកៈលើកទ័ពចូលវាយប្រទេសឥណ្ឌា ។

អគ្គមហេសីព្រះវិស្ណុឈ្មោះស្រី ឬ លក្ស្មី ជាទេពធីតាបញ្ចក់ពីឧកល្យាណ តំណាងខាងទ្រព្យសម្បត្តិ នាងនេះកើតចេញមកពីសមុទ្រទឹកដោះ ដៃកាន់ផ្កា ។

ព្រះឥសូរជាទេពតាខាងបំផ្លាញនិងខាងបង្កើត, អង្គព្រះជាធនជៈ ស្ដេចនៃធ្យាន ជួយទំនុកបំរុងលោក, ជួយរាំតាណ្ឌវៈដែលលេងនៅ សមោសរនៃស្មានស្ពត, ជួនកាលគេសាងព្រះឥសូរនិងវិស្ណុលាយចូលគ្នា គេហៅឈ្មោះថា ហរិហរៈ រូបនេះមាននៅសម័យហ្វូណន ។ ភាគច្រើន, គេសាងព្រះឥសូរនៃម្នាក់ឯង ឬជាមួយនឹងយានជំនិះឈ្មោះនន្ទិ, នៅប្រាសាទដែលគេខ្ចុំសង្ហាយ គេច្រើនធ្វើរូបសិវលិង្គជំនួស, នៅជញ្ជាំងប្រាសាទ, គេឆ្លាក់រូបព្រះឥសូរស្ថិតនៅកណ្ដាលប្រាសាទ ប្រដាប់ដោយគ្រឿងអលង្ការផ្សេងៗ មានដៃច្រើន ក្បាលច្រើន ជួនកាលជារូបឥសី, គេគោរពស្គាល់រូបព្រះឥសូរបាន ដោយមានភ្នែកនៅត្រង់ថ្ងាសនិងត្រីសូល ។ អគ្គមហេសីឈ្មោះទុគ៌ា, បវ្វតី, ឧមា ឬ ទេវី, នៅប្រាសាទបាគង មានរូបព្រះឥសូរនៅកណ្ដាល នាងឧមានិងនាងគង្គានៅអម ។

ព្រះព្រហ្ម, ភាគច្រើន, គេសាងទុកកណ្ដាល ព្រះវិស្ណុនិងព្រះឥសូរនៅអមសងខាង, ព្រះព្រហ្មនេះមានមុខបួន, ដៃបួន, មានសត្វហង្សជាពាហនៈ អគ្គមហេសីឈ្មោះនាងសរស្វតី ។

ទេពតាក្នុងសាសនាព្រាហ្មណ៍ តាមដែលគេប្រកាន់ជឿ មានច្រើនយ៉ាងក្នុងសម័យនោះ គឺព្រះឥន្ទ្រជាទេពតាស្ថិតនៅស្ថានសួគ៌ ដែលកាន់វជ្រៈ (រន្ទះ) ជិះលើដំរីឯរាវណ្ណក្បាល៣, ព្រះអាទិត្យ, ព្រះចន្ទ្រ, គណេសជាកូនព្រះឥសូរ មានក្បាលជាដំរី ភ្លុកមួយ ពោះធំកំប៉ោង ដៃបួន; សេចក្តីដំណាលថា កាលព្រះឥសូរមានសេចក្តីក្រោធ, ក៏កាប់ក្បាលគណេសដាច់ហើយយកក្បាលដំរីមកតភ្ជាប់វិញ ។ល។

កេរ្តិ៍ឈ្មោះនគរស្ថិតនៅក្នុងចិត្តនៃបណ្ដាជនទូទៅ គេតែងស្គាល់ទាំងអស់គ្នា. ព្រោះក្នុងបច្ចុប្បន្នកាលនេះ. កេរ្តិ៍ឈ្មោះនគរផ្សាយទៅកាន់ប្រទេសទាំងអស់ក្នុងលោកសន្និវាស មានទ្វីបអឺរ៉ុប ទ្វីបអាស៊ីជាដើម, ប្រទេសទាំងអស់នេះសុទ្ធតែបានទទួលដំណឹងផ្សេងៗ អំពីរឿងនគរ ដោយសៀវភៅទាំងឡាយនៃនគរ ដោយទស្សនាវដ្ដីដែលគេផ្សាយចេញទៅស្ទើរតែគ្រប់ភាសា ឬដោយរូបថតដែលគេដកយកទុកនៅក្នុងពិពិធភណ្ឌរបស់ជាតិគេ ពុំនោះដោយក្រសួងអ្នកគ្រប់គ្រងត្រាវែលវីង គេផ្សាយដំណឹងអំពីទេសនាគមន៍ទៅកាន់នគរ រួមឲ្យទៅបានស្របគ្នាថា ពាក្យថា: "មិនស្គាល់នគរស្មើរនឹងមិនមានក្នុងលោកទៀយ" ។

---

សៀវភៅនគរ— អំពីអ្នកប្រទេសដែលបានមកទស្សនានគរមុនគេ ហើយសរសេរសៀវភៅនិយាយអំពីរឿងនគរ ឲ្យគេមើលមកដល់សព្វថ្ងៃនេះ គឺអ្នកប្រទេសជាតិចិនឈ្មោះ ចៀវតាក្វាន់ ជាកដទូតស្ដេចក្រុងចិន បញ្ជូនមកមើលស្រុកខ្មែរ ក្នុងពុទ្ធសករាជ ១៨៣៩ កាលនោះ ចៀវតាក្វាន់ហៅប្រទេសខ្មែរយើងថា ចេន-ឡា (កម្ពុជា) ។

លុះដល់មក ព.ស. ២១៤៧, ទើបមានជនជាតិអឺរ៉ុបដើរលេងមកមើលទៀត គឺលោក ប. រីបាដេណៃរ៉ា (P. Ribadeneyra) និងលោក

ប. កាប្រីយែល ដឺ សង់តោ អង់តូនីយោ (P. Gabriel de Santo Antonio) លោកនិយាយថា: "នៅក្នុងប្រទេសខ្មែរ មានប្រាសាទបុរាណល្អវិសេស ស្ថិតនៅកណ្ដាលព្រៃ ជាស្នាដៃជាតិរ៉ូម៉ាំង ឬស្ដេចអាឡិចសាន់ដ្រឺមហារាជ (Alexendre Le Grand), ពាក្យនេះគួរឲ្យយើងដឹងថា: 'ជាតិអឺរ៉ុបគេមិនជឿថា ជាតិខ្មែរចេះកសាងប្រាសាទល្អវិសេសបែបនេះទេ" ។

លុះមកដល់ ព.ស. ២២១៥, មានទូតជាតិបារាំងសែសម្នាក់ឈ្មោះ ប. សឺវ្រើយ (P. Chevreuil) និយាយថា: "ប្រាសាទនគរនេះល្អដូចប្រាសាទសាំងពីយែរ (Saint Pierre) នៅក្រុងរ៉ូមដែរ" ។

លុះដល់មកថ្ងៃ ២២ ខែយ៉ាំនវីយេឆ្នាំ ១៨៦១ (ព. ស. ២៤០៤) មានអ្នកប្រាជ្ញបារាំងសែសម្នាក់ទៀតឈ្មោះ ហ. មូហូត (H. Mouhot), ស្លាប់នៅថ្ងៃ ១០ ខែណូវែម្ព្រឺឆ្នាំ ១៨៦១ នៅជិតក្រុងហ្លួងប្រាបាង (ប្រទេសលាវ); លោកនេះ បានអញ្ជើញមកមើលនគរ ហើយលោកបាននិយាយអំពីនគរនេះ ប្រាប់ដល់លោកទាំងមូលឲ្យដឹងច្បាស់លាស់អំពីប្រាសាទនគរ ។ សេចក្ដីយកាទើងរូបគំនូររបស់លោក គេបានបោះពុម្ពផ្សាយចេញទៅក្នុងសកលលោក ហើយនាំឲ្យបណ្ដាជនក្នុងលោកសន្និភស ដឹងដំណឹងអំពីនគរទៀង ដូចពាក្យដែលលោក ហ. គោឡូបេវ (H. Goloubev) និយាយបញ្ជាក់ថា: "នៅនឹងពួកដែលបិទប្រាសាទនគរ

ត្រៃលោក ហ មូហុត បើកចេញហើយ, ការបើកចេញនៃទាំងប្អូនក នេះ លែងបិទទៅវិញហើយ" ៗ តាំងពីកាលនោះមក ក៏កាន់តែមានអ្នកបរទេស ចូលមកមើលនគរធំៗច្រើនគ្នា ជាលំដាប់តជាប់ ហើយកេរ្តិ៍ឈ្មោះក៏កាន់តែល្បីល្បាញទៅកាន់ប្រទេសនានាច្រើនឡើង ៗ

អំពីការរៀបចំនគរ. — កាលពីដើម, មុនដែលមានកងការប្រតិកត្តុកក៏មកនៅគ្រប់គ្រងប្រទេសកម្ពុជា នគរស្ថិតនៅកណ្ដាលទ្រនំព្រៃ, ការទៅមើលនគរតាមផ្លូវពីសៀមរាបទៅនគរវត្តឬនគរធំ, មានផ្លូវរទេះតូចៗចូលទៅ. បើត្រូវការចូលមើលប្រាសាទក៏ពិបាកណាស់ ព្រោះមានភ័យជាច្រើន ភ័យពីសត្វសាហាវយង់ឃ្នង ដូចសត្វខ្លា, ដំរី, សត្វអាសិរពិស, ជាដើម ៗ ឯបក្សីបក្សាយាសយំសូរសំឡេងគគ្រឹកគគ្រេងពេញតាំងព្រៃ ប្រាសាទទៅជាកំ មានព្រឹក្សលតាជាតិដុះជៀតជាលតាសពេញញាតស្បាតមិនងាយចូលទៅបានទេ ត្រង់កន្លែងខ្លះត្រូវតែលូនឡូករើបឡើងទៅបាន ដើមឈើឡើងល្វេះដុះតំនួតាក់នៃស្រះកៀហ៊ុំផ្ទប្រាសាទ ពិបាកសង្កេតមើលក្បាច់ចម្លាក់ផ្សេងៗ ដែលមាននៅក្នុងប្រាសាទ ៗ

ចំនួន ៣៥ ឆ្នាំមកហើយ, កងការបានប្រគល់ការរៀបចំនគរមកសាលាបារាំងសែសចុងបូព៌ាប្រទេស (École Française d'Extrême Orient) នៅក្រុងហាណូយ ដើម្បីរៀបចំឲ្យបានល្អឡើងវិញ, តាំងពីកាលនោះមក,

សាលាបាក់ឌីសែសពុងឬពាំប្រទេស ក៏បានធ្វើផ្លូវមួយកន្លែងនៅខាង ដើម្បីរៀបចំតាក់ផ្កាលើព្រៃព្រឹក្សលតាជាតិ ទីនេះរៀបឲ្យមានផ្លូវគមនាគមន៍ ទៅកាន់ប្រាសាទមួយៗបានស្រួល, កិច្ចការបានចាត់លោក ជ. កុម្មៃ (J. Commaille) ជាអ្នករក្សាខេត្តមុនគេបង្អស់ ក្នុង គ.ស. ១៩០៨-១៩១៦ (ព.ស. ២៤៥១-២៤៥៩) ។ លោកនេះ បានចាត់ចែងរៀបកាប់ឆ្ការព្រៃ នៅប្រាសាទអង្គរវត្តនិងបាយ័ននូវស្រឡះហើយ ទើបរៀបចំបាគួន, វិមានអាកាស, ទីលានតវៅ; ជាក្រោយលោក មានចោរកំណាចកាប់សម្លាប់ក្នុងខែឧសភា ១៩១៦ ទៅ ។ លំដាប់តមក, ក៏មានអ្នកថែរក្សាជាតិបារាំងមកនៅថែរក្សាទៀត, ដូចលោក ហ. ម៉ាស្សាល់ ឆ្នាំ១៩១៦-១៩៣៤; លោក ក. ត្រូវេ ឆ្នាំ ១៩៣៤-១៩៣៥; លោក គ្លេស ឆ្នាំ១៩៣៧ ។ កាលពីដើម, គេទៅកាន់ប្រាសាទមួយៗលំបាកបំផុត ព្រោះពុំបានមានផ្លូវគមនាគមន៍នឹងការចូលមើលប្រាសាទ, ឥឡូវនេះ, គេអាចធ្វើដំណើរមើលប្រាសាទទាំងអស់ក្នុងមួយថ្ងៃខ្លះ ។ អ្នកមើលក្នុងពេលនេះ, ក៏អាចភ្លេចឬនឹកស្រវៃមើលនូវកាលជាន់ដែលមានព្រៃព្រឹក្សាបាំងឃើញ ឬនឹកទៅថា ប្រាសាទអស់នេះ មានសណ្ឋានដូចនេះតែម្តង តាំងពីដើមរៀងមកដោយមានរបៀបរៀបរយ ។

## ការរចនាខ្មែរបែបផ្សេងៗតាមលំដាប់ប្រវត្តិការ(១)

*បែបការរចនាសម័យប្រាសាទសម្បូណ៌ រវាង ព.ស. ១១៦៣*

*លក្ខណប្រាសាទ :*

*ប្រាង្គធ្វើពីឥដ្ឋ*

— *ផ្តែរលើទ្វារធំៗ ជាផ្ទាក់ក្បាច់ មានក្បាច់ពាន់ត្រៃពីធីរូបមនុស្ស-ភាព; ចុងចំផុតសងខាង មានចម្លាក់រូបមករ កម្រងផ្កាធំក្បាច់ក្រប*

— *សសរតូច ធ្វើពីថ្មក្រឡឹងមូល*

*រូបចម្លាក់មនុស្សភាព*

— *រូបស្ត្រីភាពតូចៗ គ្រោងកាយ មកុដមូល , សំពត់ស្លៀកមាន ផ្ទត់ខ្លីជើង ។*

— *លក្ខណរូបខាងលើនេះកើតច្រើនឡើង*

— *រូបបុរសភាពធំៗ*

*បែបប្រាសាទសម័យនោះ :*

*ប្រាសាទសម្បូណ៌ព្រៃគុក*

*ប្រាសាទក្តុំធំ*

*ប្រាសាទជម្បូនផែក*

---

(១) គំនូរចនាដោយសង្ខេបនិងរូបថតខ្លះក្នុងសៀវភៅនេះ យកតាមការងារម៉ាដឹម៉ូសែល ការប៉ឺឡែស អគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ។

បែបការរចនាសម័យប្រាសាទព្រៃក្មេង រវាង ព.ស.១១៩៣-១២៤៣

លក្ខណប្រាសាទដូចសម័យប្រាសាទសម្បូរណ៍

- ផ្តែរលើខ្លោងទ្វារ លំអដោយក្បាច់វល្លិ

- សសរ មានលំអរៀសសរឡើង

- រូបមនុស្សភាគធំ , រូបស្ត្រីភាគច្រើនមិនស្លៀកសាយ , សំពត់ស្លៀកមានផ្នត់តាមគ្នា - ចុងសំពត់មានផ្នត់ចំនៅខាងមុខ ។

បែបប្រាសាទសម័យនោះ:

ប្រាសាទព្រៃក្មេង

ប្រាសាទស្វាយព្រហ្មណ៍

ប្រាសាទកុកប្រាសាទ (ទ្វារខាងកើត)

ប្រាសាទអណ្តែត

បែបការរចនាសម័យប្រាសាទកំពង់ព្រះ រវាង ព.ស. ១៣២៣

- កើតមានសណ្ឋានប្រាសាទបែបចេតិយ មានថ្នាក់

- ផ្តែរខ្លោងទ្វារ មានការលំអដោយក្បាច់វល្លិសុទ្ធ

- សសរតូចៗ មានចម្លាក់រំលេចស្លឹកឈើ

- ការចម្លាក់មនុស្សភាគមិនសូវដូចសុទ្ធ ដូចសម័យប្រាសាទសម្បូរណ៍និងព្រៃក្មេងទេ ។

- ចម្លាក់មនុស្សភាគម្នាក់ឯងលំអជញ្ជាំង, ស្ថិតលការរចនាតាម និងផ្កាចូលមកលាយ ។

បែបប្រាសាទសម័យនោះ:

ប្រាសាទកំពង់ព្រះ

ប្រាសាទអកយំ

ប្រាសាទត្រពាំងផុង

ប្រាសាទភ្នំបាសិទ្ធ (ទ្វារទីលិច)

ប្រាសាទភូមិប្រាសាទ

បែបការរចនាសម័យប្រាសាទគូលែន រវាង ព.ស. ១៣៦៨

- ផ្តែរលើទ្វារ មានរូបមករ និងរូបមនុស្សតាពនៅកណ្តាលក្បាច់ គន្ត្រកតើប្រកបដោយសន្លឹកឈើ ស្ថិតលការរចនាតាម ផ្កាចូលលាយ

- សសរក្លោង ៨ ជ្រុង ឬបួនជ្រុងទំរង់-នៅផ្ទៃសសរប្រកបក្បាច់សន្លឹកឈើ

- ហោជាង មានមនុស្សតាពនិងទេពប្រណម្យតិរ

- កើតមានសត្វសីហៈលុតជង្គង់ ក្បាលធំ និងប្រផ្ទៃក្រញូល

- ចម្លាក់មនុស្សតាពដូចមនុស្សមែនទែន

- សម្លៀកមនុស្សប្រុស ស្រីលើក្បាលស្ពាក់ ដូចមានជាយតឹ, ជាយសំពត់ទាងលើ បត់ស្មើនិងគោះ

បែបប្រាសាទសម័យនោះ :

ប្រាសាទនៅព្រៃប្រាសាទ
ប្រាសាទមេបុណ្យ

ប្រាសាទភ្នំគូលែន
- ដំរីក្រាប
- ស្ងួចាង
- ខ្ទីងស្លាប់
- រូបការក្ស
- ចដាប
- គគី
- ក្រហម
- អ្នកតា (ឧក្តា?)

បែបការចងាសម័យប្រាសាទព្រះគោ រវាង គ.ស.១៦១៨

- ព្រះប្រាង្គ ធ្វើពីឥដ្ឋ ស្រោបបាយអ
  ផ្តែលើខ្លោងទ្វារ រចនាក្បាច់ល្អិតមានលំអស្រស់
- សសរមូល រំលេចក្បាច់
- នៅផ្ទៃជញ្ជាំង មានមនុស្សការពារនៅកណ្ដាលស៊ុម
- ពាក់មកុដ នៅមើលឃើញផ្នួងសក់ ឬក្រងសក់ជាក់ៗ

— សម្លៀកបត់ ដោយលើបត់ជាផ្នត់មូល មានផ្នត់ធំៗ

— ក, ជង្គង់, ដៃ ប្រដាប់ដោយគ្រឿងអលង្ការ

— រូបសីហៈអង្គុយ កនមិនសូវក្រាញ

— គោនន្ទិមានខ្លួន, ជើង, ជើងពីរខាងមុខបត់

— បង្កាន់ដៃមានរូបនាគកើតឡើង ក្បាលនាគពាក់មកុដ ៗ

<u>បែបប្រាសាទសម័យនោះ:</u>

ប្រាសាទព្រះគោ រាជ្យ ព.ស. ១៤២២

ប្រាសាទបាគង រាជ្យ ព.ស. ១៤២៤

ប្រាសាទលលៃ រាជ្យ ព.ស. ១៤៣៦

<u>បែបការរចនាសម័យប្រាសាទបាខែង</u> រាជ្យ ព.ស. ១៤៤៣

— ព្រះប្រាង្គ ទ្វិប ជ្រៃប្រែង

— សសរ លំអដោយស្លឹកឈើ

— ហោជាង មានរូបមករនិងមនុស្សភាគច្រើនប្រកបដោយស្លឹកឈើ

— រូបមនុស្សធំៗ

— ត្របកភេមចំពោះត្រង់

— ភ្នែក, ពពីមាត់មានស្នាមអំខ្លួសគរ

— ពុកចង្កា, សក់ បត់ជា ៣ ជ្រុង នៅកំពៀនពីរ នៅចង្កាមួយ ៗ

— សត្វសីហៈ, សត្វសម, ព្រៃមិនដូចសុខ្ម បែបជាគ្រឿងអលង្ការ

បែបប្រាសាទសម័យនោះ

ប្រាសាទភ្នំបាខែង
ប្រាសាទភ្នំក្រោម
ប្រាសាទភ្នំបូក
ប្រាសាទភ្នំក្រវ៉ាន់ រវាង ព.ស. ១៤៦៤
ប្រាសាទប្រែរូប រវាង ព.ស. ១៤៧៣

បែបការរចនាសម័យប្រាសាទបន្ទាយស្រី រវាង ព.ស. ១៥២៣

- វិជ្ជាការកសាងប្រាសាទ កំពុងចំរើនខ្លាំង
- ហោជាង មានការរចនាក្បាច់ល្អិតពិចិត្រ នឹងសម្ភៅព្រៃ
- មានក្បាច់ចម្លាក់ជារឿងកើតឡើង
- រូបប្រៀបចក្ខុ ទៀងស្មៀកពាក់លេចធ្លោឡើង
- មុខមាត់សុភាព
- ពពីមាត់ក្រាស់ ហើយខ្វា
- មានរបៀបតែងសក់បែបថ្មី ឥតមានមកុដ
- សត្វសីហៈអង្គុយ ជង្គង់លើជើងក្រោយបត់ទៅ

បែបប្រាសាទសម័យនោះ :

បន្ទាយស្រី រវាង ព.ស. ១៥៦០
ប្រាសាទស្រឡៅ

បែបការរចនាសម័យប្រាសាទឃ្លាំង រវាង ព.ស. ១៥៣៣ ១៦៨៣

- វិជ្ជាកសាងប្រាសាទនៅចំរើននៅឡើយ
- ព្រះប្រាង្គធ្វើពីថ្ម
- ប្រាសាទបែបភ្នំកើតមានឡើង ហើយមានកេងថែវ (កេងទង) ព័ទ្ធជុំវិញ
- ផ្តែរលើទ្វារ មិនសូវមានលំអ តែនៅកណ្តាលមានក្បាលព្រះកាល
- សសរខ្ទិ ចូកម៉ងធំ ជើងមុខជើងបន្តិច
- រូបមនុស្សភាពមានសម្លៀកបំពាក់បាដាយផ្ទត់, ដាយសំពត់មានថ្នក់កង់ខ្សែរហើយត្រង់ៗ
- ខាងក្រោយ សំពត់ឡើងដល់ខ្នង, ខាងមុខបើក, ឥតមានថ្នក់, សម្លៀកស្រី ខាងថ្នក់មានសណ្ឋានជាគន្ទុយត្រី ។

បែបប្រាសាទសម័យនោះ:

ប្រាសាទតាកែវ
ប្រាសាទឃ្លាំងខាងជើង
ប្រាសាទភ្នំជីសូ (ជីសូរ)
ប្រាសាទព្រះវិហារ
ប្រាសាទចៅស្រីវិបុល

បែបការចនាសម័យប្រាសាទបាពួន កើត គ. ស. ១៥៨៣

— ប្រាសាទបែបភ្នំមានច្រើនជាន់

— កើតថែវមានរោងជុះ (ខ្លោងទ្វារ) និងប្រាសាទជ្រុងគ្រប់ថ្នាក់

— ក្របហោជាង ជាក្ដួចឆាន ក្បាលបើកកកាចេញទៅម្ខាងៗ

— រឿងព្រះក្រឹស្ណ៍ ឆ្លាក់នៅប្រអប់តូចជាប់ដោយខ្សែ

— សម្លៀកស្លៀងដល់ខ្នង ហើយមានមុខរបំពោះ

បែបប្រាសាទសម័យនោះ

ប្រាសាទបាពួន

ប្រាសាទមេបុណ្យខាងលិច

ប្រាសាទវត្ត

បែបការចនាសម័យប្រាសាទនគរវត្ត កើត គ. ស. ១៦៥០

— វិជ្ជាកសាងប្រាសាទ ល្អដល់កំរិត.

— ផ្តែរលើខ្លោងទ្វារ, សសរ, ហោជាង រំលេចក្បាច់យ៉ាងល្អ ថ្វី

ដៃវិសេស

— រូបស្ត្រីកាតានៅជញ្ជាំង ប្រកបដោយរូបសម្ផស្សនិងភ្ជាប់ល្អិត

— រឿងព្រះក្រឹស្ណ៍ពេញផ្ទៃជញ្ជាំងមួយៗ

— ទេវរូបធំៗ

— សម្លៀកប្រុសៗ

— សម្លៀកស្រ៉ះស្ត្រីមានក្បាច់ ផ្កាមានផ្ចិត

— ទេវរូបមានពាក់មកុដ

— សក់ជួនកាលបណ្តោក បែបសុភាព

— ខាងបក្ខាន់ដៃមានព្រែនទៀន. ទូខាងក្រោយផ្ចង់ជាក្បាល

— ខាងលើគពាង ប្រកបដោយគ្រឿងបញ្ចាក់

— សត្វសិង្ហៈឈរត្រឹក, ប្រែក្លាយជាអលង្ការ

— គោនន្ទិ ស្ទើរគ្មានប្តូរ ដើមមុខម្ខាងលើកបន្តិច ៗ

បែបប្រាសាទសម័យនោះ

ប្រាសាទ នគរវត្ត

ប្រាសាទ បេងមាលា

ប្រាសាទ ព្រះប៉ាលិលេយ្យ

ប្រាសាទ ភ៉ម (គ. ស. ១៦៥១)

បែបការរចនាសម័យប្រាសាទបាយ័ន រវាង គ. ស. ១៧០០

— វិជ្ជាកសាងមិនវិសេសនៅ មិនស្ទូរៈឆិត តែល្អិតល្អន់ណាស់

— កើតមានប្រាង្គមានមុខបួន

— ក្បាល្ហសាបសូន្យ, តែកើតមានរឿងរ៉ាក្យព្រិយ៍ខ្ទីរូបមនុស្ស

— បង្ហាក់ពាក្យក្រិយ៍ទ្វីរ

— កើតមានបង្ហាក់ព្រះពុទ្ធសាសនា, ផ្ទង់ពេលរចនាផ្ចាកតែលាយ

— ក្អែកឆ្មេចបំប្រែម

— ពព័មាត់ញញឹម-គ្រប់កន្លែងដាក់មុខក្រោម

— សម្លៀកប្រសទ្ធ

— ផ្ចឹសក់ទៅរួបកំពូលស្រួច ឬមកុដ ៣ ជ្រុង

— នាគបង្កាន់ដៃ មានគ្រុឌមួយ គេឆ្លាក់ភ្ជាប់នៅក្បាលនាគ

— សត្វសិង្ហៈឈរលើជើង ៤ ប្រែក្លាយជាអលង្ការ

<u>បែបប្រាសាទសម័យនោះ:</u>

ប្រាសាទតាព្រហ្ម

ប្រាសាទបន្ទាយក្ដី

ប្រាសាទតាព្រហ្មបាទី

ប្រាសាទវត្តនគរ

ប្រាសាទព្រះខ័ន

ទ្វារនគរធំនិងប្រាសាទជ្រុងនគរធំ

ប្រាសាទបាយ័ន

ប្រាសាទបន្ទាយឆ្មារ

ទីព្រះលាន នគរធំ

— ភ្នែកធ្មេចបំប្រែម

— បបូរមាត់ញញឹម-ក្របភ្នែកដាក់មកក្រោម

— សម្លៀកប្រុសខ្លី

— ផ្នួងសក់ទៅរួមកំពូលស្រួច ឬមកុដ ៣ ជ្រុង

— នាគបង្កាន់ដៃ មានគ្រុឌមួយ គេឆ្លាក់ភ្ជាប់នៅក្បាលនាគ

— សត្វសីហៈឈរលើជើង ៤ ប្រែក្លាយជាអលង្ការ

<u>បែបប្រាសាទសម័យនោះ:</u>

ប្រាសាទតាព្រហ្ម

ប្រាសាទបន្ទាយក្ដី

ប្រាសាទតាព្រហ្មបាទី

ប្រាសាទវត្តនគរ

ប្រាសាទព្រះខ័ន

ទ្វារនគរធំនិងប្រាសាទជ្រុងនគរធំ

ប្រាសាទបាយ័ន

ប្រាសាទបន្ទាយឆ្មារ

ទីព្រះលាននគរធំ

## វគ្គទី ២

# កម្មភាគមន៍

ការទៅទស្សនានគរ នេះទៅតាមព្រៃវង់ តាមផ្លូវថ្នល់យ៉ាងស្រួល បើចេញពីភ្នំពេញ មានរថយន្តចេញទៅកាន់ក្រចេះ ឬជិះរថយន្ត បុគ្គលមានរៀងរាល់ថ្ងៃ ១ សប្ដាហ៍ ។ ចម្ងាយផ្លូវពីភ្នំពេញទៅនគរធំមាន ៣២០ គីឡូម៉ែត្រ ។ តាមផ្លូវចេញពីភ្នំពេញទៅ ចន្លោះគីឡូម៉ែត្រលេខ ១៣៨ និង ១៣៩ មានប្រាសាទបុរាណមួយកន្លែងឈ្មោះវត្តកុក់ប្រាសាទ ។ ប្រាសាទនេះ ស្ថិតនៅខាងជើងព្រះវិហារ គេសាងពីថ្មភ្នំដីដូច, នៅសុំបមានក្បាច់ចេនាជាច្រើនជាន់ មានស្តុកក្បាច់ផ្សេងៗ តាមពិតនៅទីនេះ គេសាងមុខនគរ គេទទួលរាជ្យព្រះអង្គ, ចំណែកនេះ គេសាងវិហារថ្មីនៅខាងមុខ ប្រហែលគេរើប្រាសាទបុរាណពេលខ្លះ ឧកញ៉ានិម្មិតគូរប្រើប្រាស់ទៀត ។

នៅប្រហែល ១៥ គីឡូម៉ែត្រដល់កំពង់ធំ នៅលើកំពូលភ្នំសន្តុកមានព្រះពុទ្ធរូបនិងក្បាច់ជាច្រើន ។ ពីកំពង់ធំ, នៅគីឡូម៉ែត្រលេខ ២៨២, នៅផ្សារកំពង់ក្តី មានស្ពានថ្មបុរាណមួយ មានបង្កាន់ដៃនាគឈ្មោះស្ពានក្រឡុំ[១], នៅ ២០ គីឡូម៉ែត្រទៀត, គេនឹងដល់ទៅផ្សារសៀមរាប ។

---

១ បុទ្ធិស?

គោលក្រឡប់, បើចង់ដើរជុំវិញទន្លេសាបក៏បាន, ត្រូវចេញទៅសិរីសោភ័ណ, មានផ្លូវទៅដល់អរញ្ញប្រទេស ឬទៅបាត់ដំបង, ពោធិ៍សាត់, កំពង់ឆ្នាំង, ភ្នំពេញ, ឬក៏ទោះ ថយមកក្រោយវិញតាមកំពង់ធំ, ដល់មក កំពង់ថ្មមានផ្លូវបែកទៅកំពង់ចាម រហូតទៅព្រែកគរ ។

## ការទស្សនានគរ

ការទស្សនានគរនេះបែកចេញជាពីរផ្លូវ គឺ វង់តូច ១ វង់ធំ ១ ។

ការមើលវង់តូច ត្រូវចេញពីសៀមរាបទៅដល់ខាងត្បូងនគរវត្ត បត់ទៅខាងកើត, ទៅមើលប្រាសាទក្រវ៉ាន់, ស្រះស្រង់, បន្ទាយក្ដី, តាព្រហ្ម តាកែវ, ស្ពានថ្ម, ចៅសាយ, ធម្មនន្ទ, នគរធំ, បាយ័ន, បក្សីចាំក្រុង, បាពួន និងនគរវត្ត ។

ការមើលវង់ធំ ត្រូវចាប់មើលពីបាពួន, នគរធំ, បាយ័ន, ចៅសាយ, ធម្មនន្ទ, ស្ពានថ្ម, តាកែវ, តាព្រហ្ម, បន្ទាយក្ដី, ស្រះស្រង់, ក្រវ៉ាន់, ប្រែរូប, មេបុណ្យ, តាសោម, ក្រោលគោ, នាគព័ន្ធ, ព្រះខ័ន, ក្រោលដំរី និងនគរវត្ត ។

ការមើលបញ្ចប់មកចាត់ជា ២ ផ្នែក គឺ:

១. បន្ទាយស្រី, បន្ទាយសំរែ ។ ២. ប្រាសាទលលៃ, ព្រះគោ, រងឹ, ភ្នំក្រោម, តាទ្វារ, ព្រះឥន្ទកោសី, បាកយណ៍នាងលេច ។

## ចំងាយប្រាសាទមួយ ៗ រាប់ពីមុខនាគចេញទៅ

ប្រាសាទបាខែង ............. ១ គ.ម. ៥០០

បក្សីចាំក្រុង (៨០ម៉ែត្រពីផ្លូវថ្នល់) ... - ១ គ.ម. ៦០០

## ក្រុងនគរធំ

ខ្លោងទ្វារខាងត្បូង ............ ១ គ.ម. ៩០០

បាយ័ន .................. ៣ គ.ម. ៣០០

បាពួន (២៥០ម៉ែត្រពីផ្លូវថ្នល់) .. ៣ គ.ម. ៩០០

វិមានអាកាស (៣០០ ម៉ែត្រពីផ្លូវថ្នល់) . ៤ គ.ម. ១៥០

ទីលានស្ដេចគម្លង់............. ៤ គ.ម. ៣១០

ទេពប្រណម្យ (១៦០ ម៉ែត្រពីផ្លូវថ្នល់) .. ៤ គ.ម. ៤៤០

ព្រះបាលិលេយ្យ (៣៦០ ម៉ែត្រពីផ្លូវថ្នល់). ៤ គ.ម. ៤៤០

ឃ្លាំងខាងជើង (៨០ ម៉ែត្រពីផ្លូវថ្នល់)... ៤ គ.ម. ៣០០

ព្រះពិទូរ ................ ៤ គ.ម. ៤០០

| | |
|---|---|
| ឃ្លាំងខាងត្បូង (៨០ ម៉ែត្រពីផ្លូវថ្នល់) .... | ៦ គ.ម. ០០ |
| មង្គលថៈ (២៦០ ម៉ែត្រពីផ្លូវថ្នល់) ....... | ៨ គ.ម. ០០ |
| ទ្វារជ័យ .................... | ៨ គ.ម. ៨០០ |
| ខ្លោងទ្វារខាងជើង .............. | ៨ គ.ម. ២០០ |

## វង់តូច

អក្សរ "ក" សំគាល់ថាចេញពីខាងត្បូងប្រាសាទនគរវត្ត

អក្សរ "ខ" សំគាល់ថាចេញទៅខាងជើងតាមនគរធំ

| | |
|---|---|
| ចៅសាយ (៨០ ម៉ែត្រពីផ្លូវថ្នល់).. | ក. ១០ គ.ម. ៩០០ |
| | ខ. - ២ គ.ម. |
| ធម្មនន្ទ (១០០ ម៉ែត្រពីផ្លូវថ្នល់).. | ក. ១០ គ.ម. ៩០០ |
| | ខ. ២ គ.ម. |
| តាកែវ (៩០ ម៉ែត្រ)......... | ក. ១០ គ.ម. ០៨០ |
| | ខ. ៧ គ.ម. ៦០០ |
| តាព្រហ្ម ខ្លោងទ្វារខាងលិច .... | ក. ៨ គ.ម. ៩០០ |
| | ខ. ៨ គ.ម. |
| បន្ទាយក្តី ខ្លោងទ្វារខាងលិច .... | ក. ៧ គ.ម. ៧០០ |
| | ខ. ៩ គ.ម. ២៨០ |

បន្ទាយក្ដី ខ្លោងទ្វារខាងកើត ទំនឹស្រះស្រង់ ក. ៦ ក.ម. ៨០០

ខ. ១០ក.ម. ៤០០

ប្រាសាទក្រវាញ (៩០ ម៉ែត្រពីផ្លូវថ្នល់) . ក. ៨ ក.ម. ៣០០

ខ. ១១ក.ម. ៦០០

## វង់ធំ

គិតពីមុខខាងចេញទៅតាមអង្គរធំតាមខ្លោងទ្វារខាងជើង

ព្រះខ័ន ខ្លោងទ្វារខាងជើង (២០០ ម៉ែត្រពីផ្លូវថ្នល់) ៦ ក.ម. ៦០០

ព្រះខ័ន ខ្លោងទ្វារខាងកើត (២០០ ម៉ែត្រពីផ្លូវថ្នល់) ៧ ក.ម. ៦០០

នាគព័ន្ធ ..................... ១០ ក.ម. ២០០

ក្រោលគោ ...... (១២០ ម៉ែត្រពីផ្លូវថ្នល់) ១០ ក.ម. ៣០

តាសោម ....... (៤០ ម៉ែត្រពីផ្លូវថ្នល់) ១៦ ក.ម. ២០០

មេបុណ្យ ....... (៤០ ម៉ែត្រពីផ្លូវថ្នល់) ១៤ ក.ម. ៦០០

ប្រែរូប ........ (៣០ ម៉ែត្រពីផ្លូវថ្នល់) ១៨ ក.ម. ៩០០

ស្រះស្រង់ទំនឹខ្លោងទ្វារខាងកើតបន្ទាយក្ដី ១៨ ក.ម. ២០០

## ពេលមើលប្រាសាទ

សម្រាប់អ្នកមើលដែលមានការប្រញាប់នោះ, មានពេលមើលតែ១ ថ្ងៃ ត្រូវមើលប្រាសាទទាំងពីរកន្លែង គឺពេលព្រឹកមើលនគរវត្តនិងបាយ័ន ។

ដល់ពេលល្ងាចសឹមជិះរថយន្តមើលតាមវិថីធំ ចេញតាមទ្វារទិសខាង ជើងវិលមកដល់វិថីតូចមើលស្រះស្រង់ បន្ទាយក្ដី តាព្រហ្ម (ឬមើល តាព្រហ្មហើយ) តមកតាកែវ ចូលមកតាមទ្វារជ័យ មើលតែប៉ុណ្ណេះ ក៏ហាក់ដូចជាបានមើលដោយសព្វគ្រប់ ព្រោះប្រាសាទនៅនគរមាន សណ្ឋានទ្រង់ទ្រាយតែ ៣ បែបនេះជាគោលធំ ៗ

បើមានពេលមើលពីរថ្ងៃ ត្រូវចែកពេលមើលដូច្នេះ គឺ ថ្ងៃទី ១, ពេល ព្រឹកមើលបាយ័ន, ពេលល្ងាចមើលវិថីតូច ៗ ថ្ងៃទី ២, ពេលព្រឹក, មើលវិថីធំ, ព្រះខាន់, នាគពន្ធ, តាសោម, មេបុណ្យ, ប្រែរូប, ពេល ល្ងាច, មើលនគរវត្ត ម៉ោង ៤ មើលបាខែង ៗ

សម្រាប់អ្នកមើល មិនមានការប្រញាប់ប្រញាល់ទេ ខ្ញុំសូមពុតកុំ ឲ្យមើលប្រាសាទច្រើនពេកក្នុងមួយថ្ងៃ, ដើម្បីលំហែកំឡាំងមើលតទៅ ទៀត, ហើយគួរជ្រើសមើលតាមចំណុះ តែមើលបានព្រឹក ៗ ពីព្រលឹម ចាប់ពីម៉ោង ៦ ទៅដល់ម៉ោង ៩ ព្រឹក ប្រាសាទណាដែលខ្ពស់ ត្រូវមើល ក្នុងពេលត្រជាក់ស្រទន់ដូចបាខែង, តាកែវ, បាពួនជាដើម, ឯប្រាសាទ ដែលទាប ៗ គួរមើលថ្ងៃក៏បាន ដូចតាព្រហ្ម, បន្ទាយក្ដីជាដើម ព្រោះ ប្រាសាទនេះមានដើមព្រឹក្សធំខ្ពស់ ធាងមែកត្រសុំត្រសាយជួយឲ្យម្លប់ ត្រជាក់ត្រជុំ, ហើយពេលល្ងាចម៉ោង ៤ ឬ ៦ គួរជិះរថយន្តតាមវិថីតូច

ឬតាមវត្តធំ ជាទីកំសាន្ត ក្នុងផ្ទៃវីរដល្អុខ ជាផ្លូវដើរផ្លូវលក្តា ដោយក្លិនក្រអូបឈ្ងុយឈ្ងប់លើសលើយពេញព្រៃព្រឹក្សា គួរឲ្យជាទីស្នេហាណាស់. ណាមួយសូរសំឡេងសត្វព្រៃកណ្តឹងនិងឯបក្សីបក្សាយាស យំរំពងអឺងកង ឬខ្លួនគួរឲ្យស្រណោះគាវខ្សោះកាល័យ ។

ដែលបង្ហាញដូចនេះ សម្រាប់បណ្តុះជនតាមធម្មតាខ្លួនទៅ. សម្រាប់អ្នកប្រាជ្ញ, អ្នកគតិ, អ្នកវិស្វករ, ត្រូវមើលតាមចិត្ត ទៅមើលត្រង់កន្លែងណាក៏បាន ដើម្បីពិនិត្យមើលក្បាច់ចេញ, សណ្ឋានទ្រង់ទ្រាយ ឬរឿងគង្គាតែរវេរ្យងដែលខ្លួនត្រូវការ ។

—✽—

# បញ្ជីព្រះនាមស្ដេច, ទេវតា, ឈ្មោះប្រាសាទនិងទីស្ថាន និងពាក្យផ្សេងៗ[១]

## ព្រះនាមស្ដេច


អាទិត្យវង្ស ព្រះវររាជបិតាព្រះបាទទេវវង្សអស្ចារ្យ, ៣
ឥន្ទ្រវរ្ម័ន ទី ១, . . . . . . . . . . . . ៩
ឦសានវរ្ម័ន, . . . . . . . . . . . . ៥
ឧទយាទិត្យវរ្ម័ន ទី ២, . . . . . . . . ១០
កៅណ្ឌិន្យ . . . . . . . . . . . . . . ២
ជយវរ្ម័ន ទី ១, . . . . . . . . . . . ៥
ជយវរ្ម័ន ទី ២, . . . . . . . . . . . ៨
ជយវរ្ម័ន ទី ៣, . . . . . . . . . . . ៩
ជយវរ្ម័ន ទី ៤, . . . . . . . . . . . ១០
ជយវរ្ម័ន ទី ៥, . . . . . . . . . . . ១០
ជយវរ្ម័ន ទី ៧ . . . . . . . . . . . . ១២
ទេវវង្សអស្ចារ្យ ព្រះជោគ, បឋមក្សត្រិយ៍ខ្មែរ, ៨
មាលាវត្តី, ចាងចាត់ អគ្គមហេសីព្រះបាទ ទេវវង្សអស្ចារ្យ. . . . . . . . . ៨
ភវវរ្ម័ន ទី ១, . . . . . . . . . . . ៥
មហេន្ទ្រវរ្ម័ន ចិត្រសេន, . . . . . . . ៥
យសោវរ្ម័ន ទី ១, . . . . . . . . . . ៩
រាជេន្ទ្រវរ្ម័ន, . . . . . . . . . . . ១០
លីតោរ តាមក្សត្រិយ៍ប្រទេសមាលេស៊ី, ព្រះវររាជបិតាព្រះបាទសូរ្យវរ្ម័នទី ២, ១០
លៀវ-យី ក្សត្រីប្រទេសហ្វូណន, . . . ២
សូរ្យវរ្ម័ន ទី ១, . . . . . . . . . . ១០
សូរ្យវរ្ម័ន ទី ២, . . . . . . . . . . ១១
ហរ្សវរ្ម័ន ទី ៣, . . . . . . . . . . ១១
ហុន - ទៀន, . . . . . . . . . . . . ២


## ព្រះនាមអ្នកតាសាសនាព្រាហ្មណ៍និងព្រះពុទ្ធសាសនា


អវលោកិតេស្វរៈ ពោធិសត្វលទ្ធិមហាយាន, . . . . . ១៤
អាទិត្យៈ ព្រះអាទិត្យ ទេវតាសាសនាព្រាហ្មណ៍, . . . ២៦
ឥន្ទ្រៈ ព្រះឥន្ទ្រ ទេវតាសាសនាព្រាហ្មណ៍, . . . . . . . . ២៦
ឥស្វរៈ ព្រះឥស្វរ ទេវតាធំក្នុងសាសនាព្រាហ្មណ៍, . . . . . . . ៥, ២៤, ២៩,
ឧមា ទេពីព្រះឥស្វរ, . . . . . . . . . ២៩
ក្រឹស្ណៈ ទេវតាក្នុងសាសនាព្រាហ្មណ៍ អវតារនៃព្រះវិស្ណុ, . . . . . . ២៤


---

[១] លេខក្នុងទីនេះ សម្រាប់ចង្អុលទំព័រក្នុងសៀវភៅនេះ ។

ឥន្ទ្រា ទេពីព្រះឥសូរ, ....... ២៨
គណេសៈ ឱរសព្រះឥសូរ. .... ២៦
ចន្ទ្រៈ ព្រះចន្ទ្រ ទេពតាក្នុងសាសនា-ព្រាហ្មណ៍, ........ ២៦
ទុគ្គា ទេពីព្រះឥសូរ, ....... ២៨
ទេវរាជៈ នាមទេពតាដែលព្រះរាជា សម័យនគរវត្តយកតំណាងព្រះអង្គ, ............. ៨, ១៣
ធរណីៈ នាមព្រះឥសូរ ព្រោះព្រះឥសូរជាស្តេចលោកតាល្ការក្នុងស្ថានសួគ៌, ២៨
បព៌តី ទេពីព្រះឥសូរ, .... ២៨
ប្រាជ្ញាបារមិតា ឈ្មោះទេពតានិងចម្លាក់ លទ្ធិមហាយាន, .... ១៤
ព្រហ្មៈ ឬព្រហ្ម, ទេពតាធំក្នុងសាសនាព្រាហ្មណ៍, .... ២៤, ២៨
លក្ស្មី ទេពីព្រះវិស្ណុ, ....... ២៨
លោកេស្វរៈ ពោធិសត្វលទ្ធិមហាយាន, ១៤
វិស្ណុ ទេពតាធំក្នុងសាសនា-ព្រាហ្មណ៍, .... ៨, ២៤, ២៨
ស្រី ទេពីព្រះវិស្ណុ, ...... ២៨
សក្តិ ទេពីព្រះឥសូរ, ...... ២៨
ហរិហរៈ ទេពតាសម័យប្រទេសហ្វូណន, ព្រះឥសូរនិងព្រះវិស្ណុលាយគ្នា. ៨

## ប្រាសាទនិងទីស្ថាន

ឥន្ទ្របត្តបុរី បុរីព្រះបាទអាទិច្ចវង្ស, .... ៣
ឦសានបុរៈ បុរីព្រះបាទឦសានវម៌្មន (សម្បូណ៌ព្រៃគុក) .... ៨
ចិន-ឡា ពាក្យខ្មែរក្លាយទៅតាមភាសាចិន ពីកម្ពុជា, ....... ២៨
ទ្វារវតី ក្រុងសៀមបុរាណ, ..... ១១, ១២
យសោធរបុរៈ បុរីទ្រង់ទុកនូវយស (នគរធំ), ៤
វិជ័យ ក្រុងប្រទេសចាម, ..... ១២
វៀងចន្ទន៍ ក្រុងលាវ, ........ ១២
ស្រីវិជ័យ ស្រុកជ្វាបុរាណ, ..... ៤
វ្យាធបុរៈ ក្រុងខ្មែរបុរាណសម័យហ្វូណន ៣
ហរិហរាល័យៈ ស្ថានព្រះហរិហរៈ (បាគង), ៤
ហ្វូណន ក្រុងខ្មែរបុរាណ ... ២, ៣, ៥

## ពាក្យសំស្ក្រឹត

អវតារៈ កិរិយាច្បុតចុះមកចាប់កំណើត, ២៤
អាស្រមធម៌ អាស្រមធម៌, ....... ៣
កៅណ្ឌិន្យ ព្រាហ្មណ៍ម្នាក់នៅប្រទេសឥណ្ឌា មកប្រទេសហ្វូណនមុនដំបូង, ២

តោបុះ ទ្វោងទ្វារ. . . . . ១៣

ពាណ្ឌុរៈ ល្មោចក្នុងស្លាបសូត្រ, ២៨

ត្រៃវិក្រមៈ កិរិយាឈានទៅ៣ ជំហាននៃព្រះ វិស្ណុ កាលច្បាំងក្នុងត្រៃភព, ២២

ធម្មសាលា សាលាធម៌ ដែលព្រះបាទ- ជ័យវរ្ម័នទី ៧ ទ្រង់សាងតាមមាគ៌ា ជាឧបនីយស្ថាននៃអ្នកទេសចរ, ១៦

បូជនីយស្ថាន ស្ថានជាទីគោរពបូជា, ៩

ប្រតិការ សេចក្តីតបការ, . . . . . ៣១

ប្រវត្តិសាស្ត្រ វិជ្ជាពង្សាវតារ, . . . . ៣

ពង្សាវតារ រឿងរ៉ាវតាមលំដាប់ត្រកូល, ៣

ភូមិសាស្ត្រ វិជ្ជាផែនដី, . . . . . ១

មហាយាន ពុទ្ធសាសនាបែកខាងជើង,១៤,២៩

រាពណ៍ យក្សជាគូសត្រូវនឹងព្រះរាម ក្នុងរឿងរាមកេរ្តិ៍, . . . . ២៦

រាមៈ ក្សត្រិយ៍មេចម្បាំង គូសត្រូវ នឹងរាពណ៍, . . . . . . . . ២៦

គ្រឹះ ផ្ទះ, . . . . . . . . . ២៥

សតវត្សរ៍ (សតវស្ស) មួយរយឆ្នាំ

សីតា ទេវីព្រះរាម ក្នុងរឿងរាមកេរ្តិ៍, ២៦

សង្គ្រហនោរស ការចិញ្ចឹម, វិវាហមង្គល, ៣

ហីនយាន ពុទ្ធសាសនាបែកខាងត្បូង, ២០


ពាក្យបាលី


កិត្តិនាម កេរ្តិ៍ឈ្មោះ, . . . . . . . ១៨

កិត្តិយស កេរ្តិ៍យស, . . . . . . . ១៨

កោណ្ឌញ្ញ ព្រាហ្មណ៍ម្នាក់ជាតិឥណ្ឌា មកកាន់ប្រទេសខ្មែរមុនដំបូង, . . . ២

បុព្វបុរស> បុព្វបុរិស បុរសដើម, . . ៩

បច្ឆិមជាតិជន ជនកើតមកក្នុងការ ខាងក្រោយ, . . . . . . ៦

យុវជន ជនកំលោះនៅក្នុងបឋមវ័យ, . . . ៩

វង្សសាសនាចារ្យ ដោយថែរក្សាដែន, ៨

វង្សបុរស>វង្សបុរិស បុរសដែលរក្សាដែន,អង្គ្រៃ,១២

សជាតិ ក្រុង, . . . . . . . . . ៧, ៨

វិរបុរស> វិរបុរិស បុរសក្លាហាន, បុរស មានព្យាយាម, បុរសប្រសើរ, ១២


ពាក្យបរទេស


គ. កូរ៉ាល់ រេមូសាត់ G. Coral Rémusat. . . . . . . ៣

គ. សឺដែស G. Cœdès, . . . . ២៣

ជ. កូម៉ៃយ៍ J. Commaille, ១៨, ៣០

ប. សឺវ្រឺយ P. Chevreuil, . . ២៨

ហ. ឌិក្កាសុង H. Dickason, . . ក

អឺរុប Europe, . . . ២៣

ប. គាប្រីយែល ដឺ សង់តូ អង់តូ និយោ P. Gabriel de Santo Antonio, . . ២៤

ហ. គោឡូបែវ H. Goloubew, ៤៨

ឥណ្ឌូណេស្យេង Indonésiens, ១

ស. ការប៉ឺឡេស S. Karpelès, . . ៩

ហ. ម៉ារសាល់ H. Marchal, . . ០

ហ. មូហុត H. Moubut, ក, ២៨

ប. ប៉ែល្លិយោត៍ P. Pelliot, . . . ២

ប. រីបាដេនៃរា P. Ribadeneyra, ២៣

ចៀវ-តា-ក្វាន់ Tchiêu-ta-Kouan, ១៨

ល. ហ្វីណូត៍ L. Finot, . . . . ១៣

# បញ្ជីរឿង


| | ទំព័រ |
|---|---|
| ពាក្យប្រារព្ធ | ក |
| វគ្គទី ១ | ៤ |
| ពោលពង្សាវតារខ្មែរបុរាណដោយសង្ខេប | ៥ |
| ព្រះរាជាអង្គ្វាសម័យនគរ | ៦ |
| បញ្ជីរាយព្រះនាមស្ដេចសម័យនគរ | ១៩ |
| លទ្ធិសាសនា | ២០ |
| ព្រះពុទ្ធសាសនា | ២០ |
| លទ្ធិមហាយាន | ២២ |
| លទ្ធិហីនយាន | ២៣ |
| សាសនាព្រាហ្មណ៍ | ២៣ |
| កេរ្តិ៍ឈ្មោះនគរ | ២៧ |
| សៀវភៅនគរ | ២៧ |
| គំនិតការរៀបចំនគរ | ២៩ |
| ការឧតនាខ្មែរបែបផ្សេងៗ តាមលំដាប់ប្រវត្តិការ | ៣១ |
| វគ្គទី ២ | ៤១ |
| គយនាគមន៍ | ៤១ |
| ការទស្សនានគរ | ៤២ |
| ការមើលបន្ទាប់មកបាត់ជា ២ ផ្នែក | ៤៣ |
| ចំងាយប្រាសាទមួយៗរាប់ពីមុខមាត់ចេញទៅ | ៤៣ |
| ពេលមើលប្រាសាទ | ៤៥ |

# បញ្ជីសៀវភៅដែលព្រះរាជបណ្ណាល័យបោះពុម្ពផ្សាយ

| | | |
|---|---|---|
| ព្រះត្រៃបិដក (បាលីនិងប្រែ) ១ ចប់ ....... | ចំនួន ១០០ សៀវភៅថ្លៃ | ២៥០៛, ០០ |
| ព្រះធម្មបទ ........................ | ១ សៀវភៅថ្លៃ | ០៛, ១០ |
| អក្ខទោសកថា .................... | — | ០, ០៥ |
| អនត្តលក្ខណសុត្ត .................... | — | ០, ២០ |
| អភិធម្មត្ថសង្គហ បាលី .................... | — | ០, ៥១ |
| អភិធម្មត្ថសង្គហ សម្រាយ .................... | — | ០, ៧០ |
| អរិយសច្ចកថា .................... | — | ០, ៥០ |
| អំពីព្រះពុទ្ធសាសនា .................... | — | ០, ៥១ |
| អំពីប្រាសាទខ្ទះនៅគោ .................... | — | ០, ២៥ |
| កាលាមសុត្តនិងពាករសុត្ត .................... | — | ០, ១៥ |
| គិរិមានន្ទសុត្ត .................... | — | ០, ១៥ |
| ច្បាប់ថ្មី .................... | — | ០, ១៥ |
| ញាណកថា .................... | — | ០, ១០ |
| ដំណាលពុទ្ធចេតិយ .................... | — | ០, ៥១ |
| ធម្មប្រទីប .................... | — | ០, ៦០ |
| ភាណវារ .................... | — | ០, ៥០ |
| ធាតោបមាទិកថា .................... | — | ០, ០៧ |
| ចារណាវិសេសោ .................... | — | ១, ០០ |
| បាយាសិរាជញ្ញសុត្ត .................... | — | ០, ០៧ |
| ពាក្យកាព្យក្រមង៉ើរ .................... | — | ០, ០៩ |
| ឧបោសថកថា .................... | — | ០, ១៥ |
| មរណានុស្សតិ .................... | — | ០, ២១ |
| មាតាបិតុឧបដ្ឋានកថា .................... | — | ០, ៣៥ |

| | | |
|---|---|---|
| ១០០ គាថា | ១ សៀវភៅថ្លៃ | ០ រ. ១០ |
| វិជ្ជាបរណកថា | — | ០, ៣០ |
| ព្រឹក្ខាទយ | — | ០, ២៨ |
| សប្បុរិសធម៌ | — | ០, ០៨ |
| សត្តបរិត្តនិងទ្វាទសបរិត្ត | — | ០, ៨០ |
| សីមាវិនិច្ឆ័យ | — | ០, ១០ |
| សុរិយាគ្រទៀងស័ក | — | ០, ៣០ |
| សុភាសិតច្បាប់កាសិ | — | ០, ៦០ |
| សេចក្តីដាស់តឿន | — | ០, ០៦ |
| បច្ចគណគាថា និងបុប្ផសម្រេច | — | ០, ៣០ |
| សត្តធូមាណ | — | ០, ២៨ |
| សិលនិទ្ទេស | — | ០, ៨០ |
| សារទេសនា | — | ០, ០៤ |
| គម្ពីរខ្មែរផាប់និងរូបសព្ទ | — | ០, ២០ |
| ប្រស្នាវិនយបិដកសង្ខេប | — | ១, ០០ |
| រតនប្បភា | — | ០, ៦០ |
| វិធីបង្ការរោគ | — | ០, ០៣ |
| នវកបាតិមោក្ខ | — | ០, ៤០ |
| គោលសមថកម្មដ្ឋាន | — | ០, ១៥ |
| ពុទ្ធមាមកវិធី (បែបធម្មយុត្តិ) | — | ០, ៦០ |
| សាមណេរវិន័យ | — | ០, ៦០ |
| បញ្ចកភិក្ខុប្បច្ចវេក្ខណៈ | — | ០, ១០ |
| សិង្គាលោវាទសូត្រ | — | ០, ៣០ |
| អនុមោទនាវិធី | — | ០, ៨០ |
| ព្រះត្រៃលក្ខណ៍ និងសង្វេគវត្ថុ | — | ០, ១០ |

| | | | |
|---|---|---|---|
| ពាក្យកាព្យថ្លៃងរឿងពុទ្ធប្រវត្តិ | | ៩ សៀវភៅថ្លៃ | ០រ. ១៥ |
| វេស្សន្តរ | | — | ០, ១៥ |
| ធាតុជាតក | | — | ០, ៦០ |
| សតិបដ្ឋានសូត្រ | | — | ០, ៥០ |
| អវសានកិច្ច | | — | ០, ៤៥ |
| វិជ្ជាប្រាំបីប្រការ | | — | ០, ៦៥ |
| រឿងកាកី | | — | ០, ២៥ |
| ទសបារមីកថា | | — | ០, ៧៥ |
| បាតិមោក្ខសង្ខេប | | — | ០, ៤០ |
| សៀវភៅយានជំនិះខ្មែរ | | — | ០, ៤៥ |
| ធិរសារ | | — | ០, ៦០ |
| ទានកថា | | — | ០, ៦០ |
| វេយ្យាករណ៍សំស្ក្រឹត | | — | ០, ៦៥ |
| សិលាចារឹកនគរវត្ត | | — | ១, ០១ |
| [illegible] ទី ៣ (អក្សរខ្មែរ) | | — | ០, ១០ |
| " ° " (អក្សរបារាំង) | | — | ០, ៣១ |
| បទានុក្រមភាសាខ្មែរ | | — | ០, ០៩ |
| ភាមកេរ្តិ៍ លក់រាយ | | — | ០, ១០ |
| " លក់រួម | ១៣ | — | ១, ៥០ |
| ទស្សនាវដ្ដី (១ឆ្នាំ) | ២៤ | — | ៦, ៥០ |
| សាសនកិច្ចានុក្រម (១ឆ្នាំ) | ១២ | — | ១, ៥០ |
| វចនានុក្រមខ្មែរ ក្របរឹង | ១ | — | ៤, ៥០ |
| " ក្របទន់ | | — | ៣, ០១ |
| គិហិបដិបត្តិសង្ខេប | | — | ០, ១៥ |
| គិហិបដិបត្តិពិស្ដារ | | — | ០, ៥០ |

| | | | |
|---|---|---|---|
| បញ្ញាទ្វេទូកសង្ខេប | | ១ សៀវភៅថ្លៃ | ០រ, ៥៨ |
| សុភាទោសកថា | | — | ០, ១០ |
| ចិត្តទ្វេសក៏នគរ | ភាគទី ១ | — | ០, ៤៥ |
| " | ភាគទី ២ | — | ០, ០០ |
| ក្រុងសុភមិត្រ | ភាគទី ១ | — | ០, ០០ |
| " | ភាគទី ២ | — | ០, ០០ |
| " | ភាគទី ៣ | — | ០, ០០ |
| ចំលិន្ទប្រាជ្ញា | ភាគទី ១ | — | ០, ៥០ |
| " | ភាគទី ២ | — | ០, ៨០ |
| មង្គលត្ថទីបនី | ភាគទី ១ | — | ២, ០០ |
| " | ភាគទី ២ | — | ២, ៥០ |
| " | ភាគទី ៣ | — | ៣, ០០ |
| " | ភាគទី ៤ | — | ០, ០០ |
| កញ្ញាយទូបគ្គូក | ភាគទី ១ | — | ០, ៨០ |
| " " | ភាគទី ២ | — | ១, ៤០ |
| ធម្មបទដ្ឋកថា | ភាគទី ១ | — | ០, ៩០ |
| " | តាំងពីភាគទី ២ ដល់ភាគទី ៨ | — | ០, ៦៥ |
| គតិលោក | ភាគទី ១ | — | ០, ១៥ |
| " | ភាគទី ២-៣ | — | ០, ១២ |
| " | ភាគទី ៤-៥-៦-៧-៨-៩ | — | ០, ២៥ |
| រឿង ១ ពាន់ ១ យប់ | ភាគទី ១ | — | ០, ១២ |
| " | ភាគទី ២-៣-៤-៥-៦-៧ | — | ០, ២៥ |

# រូបផ្តិតពុម្ពផ្សេងៗ


ព្រះពុទ្ធរូបមានអគ្គសាវកគូ (របចាណាស់) . . . . . . . . . . . ១ សន្លឹកថ្លៃ ០រ, ០៥

〃 ចំហ្មាន . . . . . . . . . . . . . . . . . . . . — ០, ០៨

〃 ៣ ព្រះអង្គ . . . . . . . . . . . . . . . . . . — ០, ០៥

〃 មានព្រះឥន្ទ្រនិងព្រះព្រហ្មឈរគេ . . . . . . . . . . . — ០, ០៨

ព្រះរូបព្រះបាទសម្ដេច ព្រះស៊ីសុវត្ថិមុនីវង្ស ក្រដាសរឹង . . . . — ០, ១៥

〃 〃 ក្រដាសទន់ . . . . . . — ០, ១០

〃 ព្រះស៊ីសុវត្ថិ . . . . . . . . . . . — ០, ២០

〃 ព្រះបាទក្រុងកម្ពុជា ៤ ព្រះអង្គ . . . . . — ០, ៤០

រូបព្រះពុទ្ធបាទ . . . . . . . . . . . . . . . . . . . . . — ០, ៩៥

រូបព្រះឥន្ទ្រលាសំពត់ចៀងពុទ្ធប្រវត្តិ . . . . . . . . . . . . . . — ០, ០៥

រូបវេស្សន្តរជាតក ១៣ សន្លឹក . . . . . . . . . . . . . . . — ០, ០៦

រូបគំនូរនេមិយជាតក . . . . . . . . . . . . . . . . . . . ១០ — ០, ៤៥

〃 មហាជនកជាតក . . . . . . . . . . . . . . . . ១១ — ០, ២៥

〃 សុវណ្ណសាមជាតក . . . . . . . . . . . . . . ១០ — ០, ២៥

ប្រក្រតិទិនឆ្នាំថ្មី (ធំ) . . . . . . . . . . . . . . . . . ១ — ០, ២០

〃 (តូច) . . . . . . . . . . . . . . . . . . . — ០, ៦៥

# មគ្គុទ្ទេសក៍នគរ
## ភាគ ២

INSTITUT BOUDDHIQUE

# មគ្គុទ្ទេសក៍អង្គរ

## ភាគទី ២

អាចារ្យ ប៉ាំង-ខាត់ គ្រូបង្រៀនសំស្ក្រឹត
នៅសាលាបាលីជាន់ខ្ពស់ រៀបរៀង

គណៈរដ្ឋមន្ត្រីនិងសម្តេចសង្ឃនាយកទាំងពីរគណៈ
បានអនុញ្ញាតហើយ

បោះពុម្ពលើកទី ១

ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព. ស. ២៤៨៤

# MAGGUDDESAKANAGARA

(Guide d'Angkor)

2me Partie

Les monuments

par

L'Achar PANG-KHAT Professeur de Sanscrit.
a l'École Supérieure de Pali

Cette publication a reçu l'approbation du Conseil des Ministres
et des deux Chefs de Sectes

1ère Édition

PHNOM-PENH
Éditions de l'Institut Bouddhique
1941



ព្រះសិរព្រះពុទ្ធរូប មានព្រះភក្ត្រញញឹម
ការរចនាបែបនគរវត្ត រវាង គ. ស. ១.១៨០

(តាមរូបថត ស.ប.ប.)

## វគ្គទី ៣

## ប្រាសាទនគរវត្ត

នគរវត្ត ជាប្រាសាទមួយល្អជាងគេ បណ្ដាប្រាសាទទាំងឡាយនៅនគរ គេកសាងក្នុងសម័យនៃវិទ្យាសាស្ត្រកំពុងចំរើនបរិបូណ៌ ព្រោះមានទ្រង់ទ្រាយល្អនិងទ្រង់ស័ក្ដិសមនៃភាពពាក់ង លេចស្រស់ទៀងក្នុងការដើរចូលទៅជិត ហើយគេអាចយកទៅទុកជានិទស្សនកម្មនៃប្រទេសអស្ដង្គតជាន, ប្រាសាទនេះ មានភ្នាក់ទាំងទ្រង់ទ្រាយនិងលំអដ៏លើស ដូចនៅក្នុងរាជ្យលូអ៊ីទី ១៤ នៃប្រទេសបារាំងសែស, ក្នុងរាជ្យនោះ មានការលើកសួនជាច្រើនលេចឡើង ព្រោះ សណ្ឋានល្អមើលពីចម្ងាយ និងមានភាពទូលាយ ។

ប្រាសាទនគរវត្តនេះ ព្រះបាទសូរ្យវរ្ម័នទី២ ស្ដេចកសាងក្នុង សតវត្សរ៍ទី ១២ នៃគ្រិស្តសករាជ (ព.ស. ១៦៩៣?) ដើម្បីឧទ្ទិសថ្វាយព្រះវិស្ណុ, លុះដល់ស្ដេចទ្រង់ទិវង្គតទៅ គេថ្វាយព្រះនាមព្រះអង្គថា ព្រះបរមវិស្ណុលោក ។ មានមនុស្សជាច្រើនយល់ថា ប្រាសាទនេះសម្រាប់ស្ដេចគង់, ប៉ុន្តែបើតាមពិនិត្យមើលទ្រង់ទ្រាយចង្អៀតហួសមកនាំឲ្យយល់ថា ស្ដេចមិនទ្រង់គង់នៅទីនេះទេ, បើតាមន័យនៃសាសនាឃើញសមជាង; ប្រាសាទនេះអាចស្រម៉ៃបានថា ជាចេតិយ សម្រាប់បញ្ចុះព្រះអដ្ឋិនៃ

ព្រះកជាធិកដ, តាមសេចក្ដីយកការនៃអ្នកប្រវត្តិសាស្ត្រចិនម្នាក់ឈ្មោះ ចៀវ តាក្វាន់ (Tchéou Takouan) គេហៅការចេតិយ លូ-ប៉ាន់ (Lou-Pan); ប៉ុន្តែលោក ស៊ីដេស លោកសរសេរថា: "ប្រាសាទនគរវត្តនេះ គេធ្វើសង្វាយដល់ព្រះវិស្ណុ" ។

ប្រាសាទនគរវត្ត ស្ថិតនៅខាងត្បូងប្រាសាទនគរធំ ចំនួន១៨០០ ម៉ែត្រ, បែរមុខទៅកាន់ទិសបស្ចិម មានផ្លូវចូលពីខាងលិចខុសពីច្បាប់ការប្រាសាទទាំងពួង; តាមលោក ហ. ម៉ារស្គាល លោកសរសេរ ក្នុងសៀវភៅលោកថា: "ព្រោះមកពីមានសួននៅខាងកើត ហើយប្រាសាទនេះស្ថិតនៅចំផ្លូវទៅកាន់នគរធំផង" ។

បើតាមទំនៀមខ្មែរថា: ការកប់ខ្មោចឬដុតខ្មោចលើជើងថ្កល់សម្រាប់ធ្វើឈាបនកិច្ច គេច្រើនដាក់ក្បាលបែរទៅកាន់ទិសខាងលិច បែរមុខមកខាងកើតទាំងអស់, ឯប្រាសាទដែលគេធ្វើសង្វាយព្រះបរមវិស្ណុលោក ក៏ត្រូវបែរមុខទៅកាន់ទិសបស្ចិមដូចគ្នា(១) ។ ប្រាសាទនេះ មានស្រះបោក្ខរណីដក់ទឹកជួបប្រាង្គខ្ពស់ស្សា ចំពោះក្រាលថ្មដាក់ក្បាច់ រៀបជាថ្នាក់ៗ ជុំវិញទាំង ៤ ទិស បណ្ដោយ ១៥០០ ម៉ែត្រ ពីខាងកើតទៅខាងលិច, ទទឹង ១៣០០ ម៉ែត្រ ពីខាងជើងទៅខាងត្បូង; គតិស្រះបន្ទាយមានទទឹង

១ ព្រោះនគរធ្វើសង្វាយព្រះបាទសូរ្យវរ្ម័ន (បរមវិស្ណុលោក) ដែលទ្រង់ទិវង្គតទៅហើយ តាមទំនៀម មនុស្សកើតឡើងហើយ ត្រូវស្លាប់លិចបាត់ទៅវិញ ដូចព្រះអាទិត្យរះឡើងហើយ លិចបាត់ទៅទិសបស្ចិមវិញដូច្នោះ ។



ភាគប្រាសាទអង្គរវត្តទាំងមូល

ការរចនាផែនអង្គរវត្ត រវាងគ. ស. ១.៦៥០

(តាមរូបថត ត. ស. ប.)

កប់ស្មើ បានដល់ទៅកំពែងខាងក្រៅ ធ្វើពីថ្មបាយក្រៀមព័ទ្ធជុំវិញ, បណ្តោយប្រហែល ១០០០ ម៉ែត្រ, ទទឹង៨១៥ម៉ែត្រ ។ មានកំពែងទី២ ក្រាលថ្ម បណ្តោយ ៦០០ ម៉ែត្រ ចូលពីខាងទិសបស្ចិម កាត់ក្នុងស្រះ ទៅកាន់គោបុរៈ ( ខ្លោងទ្វារធំ ) នៃកំពែងខាងក្រៅ ខាងជើងនិងខាងត្បូង មិនមានថ្នល់ចូលទៅទេ, ខាងកើតមានទំនប់ដីកាត់ចូលទៅកំពែងខាងក្រៅ ។ នៅទិសខាងជើង, ខាងកើត, ខាងត្បូង មានគោបុរៈ (ខ្លោងទ្វារ) ជាតួប្រាសាទ មានកំពូលខ្ពស់ឡើង តែរបាក់បែកខ្ទេច គេធ្វើមិនទាន់ហើយស្រេច ឯគោបុរៈ (ខ្លោងទ្វារ)ទាំង ៣ ទិសនេះ មានថ្មចូលទៅដល់ប្រាសាទកណ្តាលបាន ។ ស្ពានថ្មធំចូលពីទិសបស្ចិម កាត់ក្នុងស្រះបាក្នុងណោះ ហួសទៅដល់ទ្វារធំខាងលិច មានបង្កាន់ដៃជានាគប្រែកប សិលាៈធំសំបើម ធ្វើយ៉ាងស្រស់, តែឥឡូវនេះ បាក់បែកស្ទើរតែអស់ហើយ ។ កាលណាគេចូលទៅដល់ខ្លោងទ្វារធំខាងលិច ឃើញតាមរន្ធ-រៀងរោងឆ្ងាយ. ឃើញតាមមាត់, ទ្វារធំនៃប្រាសាទនេះ គាប់ភ្នែកអ្នកដំណើរស្ញប់ស្ញែងក្នុងចិត្ត ។ ទិសខាងលិចនេះ មានរោងទងមួយវែង មានជំហូលជាប់ជាប់គ្នា ប្រដាប់ដោយគោបុរៈ៣ មានជណ្តើរ ៣ ឡើងទៅ ជណ្តើរកណ្តាលលយមកខាងមុខបន្តិច, មានរូបវិស្ណុតាំងនៅខាងក្នុង អមសងខាងទ្វារកណ្តាលនោះ, នៅគោបុរៈមួយៗ សុទ្ធតែមានកំពូលខ្ពស់ឡើង, ខ្លោងទ្វារធំកណ្តាលកំពូលខ្ពស់ជាងគេ; នៅចុងរោងខាងទាំងសង-

ខាង មានទ្វារដើរតែម្ខាងទៀតសម្រាប់ពាហនៈផ្សេងៗនៃព្រះរាជដំណើរ ។ សព្វថ្ងៃនេះ, គេចៀងចុះតាមគោបុរៈកណ្ដាល ព្រោះគោបុរៈនេះចំទៅលើប្រាសាទធំ, នៅជញ្ជាំងកាំងខាងមានចម្លាក់ផ្កាធំមូលៗស្ដើងៗជាក្បាចចិន និងរូបយក្ស, ទេពតាពេញតំ ឬ ចំរេក, សេះ, ដំរី ។ នៅផ្ទើងមានរូបស្រីអប្សរមានផ្នួងសក់ចេនាល្អៗគួរចាប់ចិត្ត ។ ឈរមើលមួយស្របក់ហើយ, ឈានដើរចុះតាមជណ្ដើរទៅកាន់លានខាងកើតបន្តិចហើយឈរបែរមុខទៅមើលខាងក្រោយវិញ គេនឹងឃើញរូបស្រីអប្សរថែមទៀតទ្វេ, ចម្លាក់សសរគោល, អ្នកជិះលើសត្វផ្សេងៗនៅជញ្ជាំង និងទ្រង់ព្រោយចាំងមូលត្បូងឲ្យគេឃើញច្បាស់ពាក់កណ្ដាលៗ តទៅ, ត្រូវដើរទៅតាមផ្លូវក្រាលថ្មរនាបប្រវែងប្រហែល ៣៥០ ម៉ែត្រ គេឃើញមានជម្ពូមន្ទីរតើ, វត្តជំ និងស្រះតំរៀត; ដល់ទៅប្រាសាទអង្គរវត្ត មានជណ្ដើរខ្ពស់ ប្រ-កបដោយជណ្ដើរថ្មក្រានដៃនាគ, មុខនាគនិងសីហៈសំរាប់យាមក្រើត, មានជណ្ដើរទៅទិសខាងជើងខាងត្បូងនិងខាងលិច, ទីលានពេញមកខាងក្រោមនេះ សម្រាប់ជាទីទទួលនៃនាម៉ឺនសព្វមុខមន្ត្រី ឬទ្រង់ទតក្បួនហែដែលមានពិធីបុណ្យផ្សេងៗ ។ ដើរបន្តិចទៅនឹងដល់ទៅក្នុងទីនៃប្រាសាទ, ត្រង់នេះ គេធ្វើជាគូប្រាសាទមានដំបូលខ្ពស់បន្តិចទៀត ហើយមានជំហូលជាយ៉ាងពេញមកខាងលិច, នៅហោជាងមានក្បាច់ចេនាសាសនាព្រាហ្មណ៍ ។



ភាគប្រាសាទនគរវត្ត មើលពីទិសខាងកើត

ការរៀបចំថែទាំនគរវត្ត រវាង គ.ស. ១.៩៨០

(តាមរូបថត ត.ស.ប.)

អ្នកមើល, កាលណាមកដល់កន្លែងនេះ ក៏នឹកស្ញប់ស្ញែងយ៉ាងសែនសុខ ចិត្ត, ណាមួយនឹកស្តាយ ព្រោះរូបនាគបក្កាន់ដៃ, សីហៈតូចធំជាច្រើន លំអ បាក់បែកបាត់អស់ខាំឲ្យបាត់លំអជាច្រើន ។ ការមើលប្រាសាទ នេះ, សូមរំឭកថា ត្រូវមើលពេលព្រឹកនឹងពេលល្ងាច ពេលថ្ងៃក្តៅ មើលទៅលើផុំថ្ម តាំងស្រាំងភ្នែក, ហើយដើរមើលពីធ្នឹងទៅស្តាំ ព្រោះ ការចងចាំងអស់ សុទ្ធតែមានចំនងពីធ្នឹងទៅស្តាំ ឲ្យសមជាចេតិយ គេ ទុំសម្ពាយព្រះបរមវិស្ណុលោក ។

ខតវត្ត មាន ៣ ជាន់ គឺ ជាន់ទី ១ ជាន់ទី ២ នឹងជាន់ទី ៣ ។ នៅជ្រុងអនុទិសគ្រប់ជាន់ទាំងប៉ុនេះ សុទ្ធតែមានកំពូលខ្ពស់ស្រួចជាកំ ព្រាង្គ មានជណ្តើរពីរប្រកបដោយសីហៈ ចុះទៅកាន់ទិសរបស់ខ្លួនគ្រប់ៗ ជ្រុង, នៅជាន់ទី ៣ មានរលោងឈ្មោះ បាកាន ឯ មានកំពូលខ្ពស់ស្រួច ទៅកាន់អាកាស មើលពីចម្ងាយឃើញខ្ពស់ធំស្កឹមស្កៃដូចភ្នំព្រះសុមេរុ ឃើញតែកំពូលប្អូនប្រាំងដូចវិមានកណ្តាល ។ នៅថ្នាក់ទី ១ គ្រប់មាត់ ទ្វារធំ មានផ្លូវបែកជា ៣ ផែក ផ្លូវកណ្តាលសម្រាប់ឡើងទៅថ្នាក់ទី ២ ផ្លូវមួយបែកទៅខាងត្បូង មួយបែកទៅខាងជើង ។ នៅជញ្ជាំងពីខាងក្នុង នៃថ្នាក់ទី ១ នេះ សុទ្ធតែមានរូបចម្លាក់រលេចរឿងក៏ទៃនឹងសិលាចារឹកផ្សេងៗ និយាយពីរឿងព្រេងនៃសាសនាព្រាហ្មណ៍ខ្លះ, រឿងពង្សាវតារខ្មែរជាន់ ខតវត្តនុះ ដូចមានសេចក្តីសង្ខេបតទៅនេះ ។

## ពាងទងខាងលិច ផ្ញាំងខាងត្បូង (តំបន់ជើងភ្នំខាងត្បូង)

និយាយរឿងមហាភារតៈ ត្រង់ចម្បាំងបាណ្ឌវៈនឹងកៅរវៈ ។ គង់ទ័ពកៅរវៈយាត្រាទ័ពចេញពីខាងជើង, គង់ទ័ពបាណ្ឌវៈពីខាងត្បូង; គង់ទ័ពទាំងពីរនៃគេនេះជ័រល្អគួរទៅប្រទះគ្នា, មានពលរទេះដំរីកាន់អាវុធយុទ្ធគ្រប់ ទំពួល, ក្រសួល, ធ្នូ, សរ, មេទ័ពជិះរទេះ, ជិះសេះ, ជិះដំរី, មេទ័ពចំណែកកៅរវណ្ឌូសរប៉ែបយ៉ាងស្អាតជាខ្លាំង, ទាំមាត់ក្រអឺត, សេនាពលហានត្រូវសរ បួសស្លាប់ដេកជួលគេ, មេទ័ពធំខាងកៅរវៈឈ្មោះ ភីស្មៈ ត្រូវសរស្ទើរពេញខ្លួន ទាំមាត់ក្រអឺត មិនគក់ស្លុត ពេញជាជាតិអ្នកចម្បាំង មានញាតិសន្ដានពោមកេមជាបរិវារ; ពាក់កណ្ដាលកេះទង គង់ទ័ពទាំងពីរចល់ប្រយុទ្ធគ្នាយ៉ាងសាហាវ សេនាពលហានទាំងពីរផ្នែក មើលទៅឃើញមានការស្អាតជាញជាញជ័យក្នុងយុទ្ធវៃ ពេញទំជាជាតិអ្នកចម្បាំង ។ ឯគង់ទ័ពបាណ្ឌវៈឃើញមេទ័ពឈ្មោះ អជ៌ុនៈ ជិះលើរទេះ មានក្រិស្ណៈដែលបួសជាមគ្គនាយក រឿងនេះមាននៅក្នុងគម្ពីរភគវត្គិតៈ ជារឿងព្រេងក្នុងប្រទេសឥណ្ឌា មុនសម័យពុទ្ធកាល ។

## នៅជ្រុងទិសនិរតី កាត់ជាក្រឡាបត្រង្គ

ពាន់ប្រចម្លាក់យ៉ាងសំខាន់ និយាយរឿងផ្សេងៗ មានជាខន្ធទ័ពក្បៀនលេចមកលើសៅរ៍ខ្លួនអស់ ។ ត្រង់នេះ គេចែកជាបួនជាន គឺ:



កាលព្រះរាមសម្លាប់យក្សមារីច ដែលក្លែងខ្លួនជាប្រើស ក្នុងរឿងរាមកេរ្តិ៍ នៅជ្រុងនិរតីប្រាសាទបាពួន.
ការចេតាបែបបាពួន រវាង គ.ស. ១.០៦០

( តាមរូបថត ស. ប. ប. )

១. ជាន់ខាងជើង, ជញ្ជាំងខាងកើត និយាយពីកាលព្រះវិស្ណុអវតារជាក្រឹស្ណៈ ជាទេវតាគង្វាលគោជាមួយនឹងនាងគោបិនីហ្វូងសត្វ. ដែលកាលកំពុងទ្រភ្នំគោវទ្ធនៈ ដើម្បីបាំងទឹកភ្លៀងកុំឲ្យទទឹកហ្វូងសត្វ ។ ជញ្ជាំងខាងលិច ត្រង់ឈើបង្អួច, និយាយរឿងកូរសមុទ្រទឹកដោះ ដែលត្រង់ទេវតានិងអសុរកំពុងទាញនាគកូរសមុទ្រ ។

២. ជាន់ខាងត្បូង, ជញ្ជាំងខាងកើតតាគខាងលើ និយាយរឿងសុគ្រីពនឹងពាលីទល់គ្នា, ដែលត្រង់ព្រះរាមបាញ់សរត្រូវពាលីស្លាប់ ។ ជញ្ជាំងខាងលិចតាគខាងលើ និយាយពីព្រះឥសូរក្លែងជាព្រះឥសីគង់លើភ្នំ ប្រដាប់ដោយផ្កា កំពុងអង្គុយសមាធិ, នាងឧមាតែងខ្លួនជាក្សត្រិយ៍អង្គុយនៅជិតខាង; ខាងក្រោម, ដែលកាលទេវតាឈ្មោះកាមៈ មានសេចក្ដីប្រាថ្នា លើកកាំទណ្ឌធ្នូសរផ្កាបាញ់ព្រះឥសូរ, ឃើញទេវតាឈ្មោះកាមៈដេកស្លាប់ដោយភ្លើងព្រះឥសូរ ។

៣. ជាន់ខាងលិច ជញ្ជាំងខាងត្បូង, និយាយត្រង់ព្រះឥសូរគង់លើកំពូលភ្នំកៃលាស ដែលត្រង់ក្រុងរាពណ៍ទសមុខ ដៃ ២០ កំពុងចាប់ភ្នំកៃលាសអង្រួន ។

៤. ជាន់ខាងកើត ជញ្ជាំងខាងជើង, ឃើញមានរូបគំនូរតាមយ៉ាងល្អ មានទេវតាហោះលើអាកាស, មានរឿងស្វាយ័ម្ពរ ប្រៀបនឹងគួន,

ភ្លើងប្រដល់មាន់ជាភ្លើងកាលជាន់នគរវត្ត; ទ្វារខាងជើង ភ្លើងកម្រគ្រឹ, គ្រង់ព្រះកមសម្លាប់ប្រែត ដែលកតណាំដំណែងមកលួចយកខាងស័ក; ទ្វារខាងលិច, ភ្លើងក្រឹស្ណ ម្តាយចងជាប់នឹងគល់ឈើ ក្រឹស្ណទាញរំលំឈើតាំងដើម; ទ្វារខាងត្បូង វិស្ណុស័ក្តិទៅគ្រងនៅព្រៃ; ទ្វារខាងកើត ភ្លើងមនុស្សជាច្រើនគ្នា យកផ្កាយទៅថ្វាយព្រះវិស្ណុ ។

## ប្រាង្គខាងត្បូង បែកខាងលិច (ពីខាងលិចទៅខាងកើត)

ចំហាយតាំងពីក្រៅតាមខ្មែរ ថ្ងៃពីអ្នកខាយកម្មបណ្ឌិត យកផ្កាយទៅថ្វាយស្តេច, ព្រះបាទសូរ្យវរ្ម័នទី ២ ដែលទ្រង់កសាងប្រាសាទនគរវត្ត ប្រថាប់នៅក្រោមស្វេតឆត្រ ដែលមានលំអដោយរូបនាគរាជ នៅលើភ្នំតំបង ទ្រង់ត្រាស់បង្គាប់ឲ្យគេណូសេនាបាទ; ខាងត្បូង, នៅខាងក្រោមមានគ្រូនៃព្រះរាជពិធីកុម្ភ័ន្ធ ទីឯកជបរិពារគាត់ជូននៅព្រៃក្រោម, នៅខាងលើ មានសេនាបាទអង្គឃប្រជុំគ្នា, នៅជិតស្តេច មានពួកពលបណ្ឌិត ពលបុរោហិត មានអ្នកកាន់ក្លស់ជាអនេកពោធមកោមជាបរិវារ; នៅខាងស្តាំ, ជិតស្វេតឆត្រ នាម៉ឺនធំម្នាក់ឈ្មោះ ធីរជិនៈ (តាមសិលាចារឹក) ដៃម្ខាងដាក់នៅលើទ្រូង បែរមុខឈមទៅរកស្តេច ដោយសេចក្តីគោរពកោតក្រែង, នៅខាងក្រោម គ្រូនៃព្រះអគ្គមហាសេនាធំលើព្រះរៃ ឬ ព្រះអគ្គីដំរីស្វាន មានពលបរិពារកាន់សើរហោងហមៈពោធមកោម;

តទៅទៀត, សេនាធាហានពាក់មួកក្បាលសត្វ យាត្រាទ័ពចុះតាំណើត ទៅកាន់ទីវាល, ពួកមេទ័ពតាំងខ្លួនជិះលើដំរី ប៉ាំងក្លស់ក្រោងក្រាត ឯពលថ្មើរជើងមានគងទំពាសេះហាហាម; តទៅទៀត, ព្រាហ្មណ៍ឬពួកសក់ កំបោយ៉ោះ នាយទៅហ្វាយជិះលើអធ្រើន មានសេនាធាហានសែនជើង-ក្រានតើ្ទងស័ក្តិសិទ្ធិ ដើម្បីបូជាទេពតាក្បួនទាហានកន្លងឃ្យាំង មានទា-ហានជុំគ្រែ កាយស្គរនៅជួរខាងមុខ ជួបក្បួនទ័ពដែលយើងឃើញសព្វ ថ្ងៃនេះផង; ជិតដល់ចាក់ថ្ងាររាងក្បួន, មានខ្សាយពីកងទ័ពសៀម ស្យាមគុក (តាមសិលាចារឹក) ទាហានសៀមនោះស្លៀកពាក់ប្លែកពី ទាហានខ្មែរ ។

## រោងទងខាងត្បូង ប៉ែកខាងកើត (ពីខាងលិចទៅខាងកើត)

ផ្ទាំងនេះ, និយាយពីស្ថានសួគ៌និងស្ថាននរក, មានសិលាចារឹក ទុំ ប្រាប់ឈ្មោះនរកដែលប្រតិត្តឡើងមាក្រោក ត្រូវបានទទួលសេចក្តី រងទុក្ខវេទនាដូចនេះដូច្នោះ ស្ថានសួគ៌នៅខាងលើ ស្ថាននរកនៅខាង ក្រោម, នៅចន្លោះស្ថានទាំងពីរនេះ មានចម្លាក់រូបព្រះមានដៃប្រាំបី ជាយក្តា, អ្នកមើល កាលណាដើរមកដល់កន្លែងនេះ នឹងឃើញព្រះ យមរាជមានដៃ១៨ជិះលើគោ; តទៅទៀត, តាមសិលាចារឹក ប្រាប់ថា ត្រង់កន្លែងនេះ "ព្រះធម៌ជាធំ" សម្រាប់កាត់ទោសនៃអ្នកដែលមាន ទោស; នៅជិតនុ៎ះ ឃើញស្មៀនព្រះយមរាជឈ្មោះ ចិត្រគុប្ត កាន់

ដំបងធំកើតជនូវទៅក្នុងសត្វនរក; គេទៅទៀត, មាននាក់រូបភាពនៃសត្វនរក ដែលនឹងទុកនៅទីនោះ ហើយសរសេរឈ្មោះទុកខាងក្រោម ប្រាប់ឈ្មោះនរកទីធំរបស់សត្វនោះប្រព្រឹត្ត ពេញទាំងជញ្ជាំងនេះ[1] ។

## រោងទងខាងកើត ប៉ែកខាងត្បូង (តាំងពីត្បូងទៅជើង)

ត្រង់នេះ, និយាយពីរឿងកូរសមុទ្រទឹកដោះ, ចម្លាក់នេះប្លែកពីកន្លែងឯទៀត ព្រោះផ្ទៃជញ្ជាំងទាំងអស់បណ្ដោយ ៥០ ម៉ែត្រ គេឆ្លាក់តែរឿងមួយ គួរឲ្យទឹកស្ញប់ស្ញែងដល់វិស្វករដែលជាអ្នកប្រតិស្ឋឲ្យកើតឡើង ព្រោះរឿងនេះ មានស្ទើរតែគ្រប់កន្លែង តែមិនល្អដូចកន្លែងនេះឡើយ ។

តាមរឿងនេះ, មានសេចក្ដីថាកាលពី ទេវតានឹងអសុរចង់បាន ទឹកអម្រឹត គឺទឹកដែលសម្រាប់ផឹកការពារមិនឲ្យស្លាប់ នេះជាហេតុនាំឲ្យកូរទឹកសមុទ្រ, គេយកភ្នំមន្ទរជាស្នូល យកនាគឈ្មោះវាសុកិជាព្រ័ត្រ សម្រាប់ទាញ ពួកអសុរទាញខាងក្បាល ទេវតាខាងកន្ទុយ, ភ្នំមន្ទរស្ថិតនៅលើខ្នងអណ្ដើក ដែលជាអវតារនៃព្រះវិស្ណុ, ពួកទាំង២ផ្នែកនេះទាញបង្វិលភ្នំយ៉ាងខ្លាំងក្លា; ការកូរទឹកសមុទ្រនេះ ជាភ័យធំសម្រាប់សត្វសមុទ្រទាំងឡាយ; ផ្ទៃកណ្ដាលឃើញសត្វសមុទ្រជាច្រើន ដូចត្រី, យក្ស, គន្ធ ជាដើមខ្ទេចខ្ទីស្លាប់អស់ជាច្រើន; កូរជាង ១០០០ ឆ្នាំ ទើបកើតមានសត្វ

---

[1] បើចង់ដឹងឈ្មោះនរកនេះ ត្រូវមើលសៀវភៅ "អំពីប្រាសាទអង្គរវត្ត" ឆ្នាំ ១៩២៨ របស់ព្រះតេជព្រះគុណព្រះគ្រូសំឃ្ហី គឺព្រះសាក្យវង្ស សព្វថ្ងៃនេះ ។

ជាប្រជុំនៃស្រីអប្សរ កើតចេញមកអំពីការកូរសមុទ្រនេះ ហេតុនោះហើយ ព្រានព្រាតទៅទាំងឡាយ; ខាងលក្បែរជាខាងបញ្ចប់ផ្ទាំងកល្យាណ គឺ កើតពីការកូរសមុទ្រនេះដែរ, ទឹកអម្រឹតត្រូវបានទៅពួកទេវតាដែលឈ្នះ ពួកអសុរ, នៅត្រង់ផ្ទៃកណ្ដាល ឃើញព្រះវិស្ណុអវតារជាមនុស្សជួយពួក ទេវតា ពួកអសុរក៏ត្រូវមូលក្រឡេក ទាក់ក្បាំងកំពូល ពួកទេវតាទាក់ មកុដស្រេច, សត្វស្វាដែលកាន់កន្ទុយនាគនេះ តាមលោកសីដែលលោក ថា ហនុមាន, នៅខាងក្រោម នាគដ៏ឈ្មោះវាសុកី ដែលពួកទេវតា និងអសុរ មិនទាន់យកមកប្រើជាខ្សែទាញកូរទឹកសមុទ្រ, នៅចុងម្ខាង ឃើញពួកបរិវារអសុរនិងទេវតា ត្រៀមចាំម្ចាស់ដែលរៀងខ្លួន ដែលទៅ កូរទឹកសមុទ្រ ។

## ជញ្ជាំងខាងកើត ប៉ែកខាងជើង ([illegible])

ដើរបន្តទៅ ដល់កន្លែងមួយ ប្រហែលពាក់កណ្ដាលខាងកើត, មាន សិលាចារឹកទៅហាយកំព្រែងម្នាក់ ទាក់ទុកកន្លែងសក់ត្បូងទិញ១៨ខែតុល. សករាជ និយាយពីបុណ្យទាន ដែលបានកសាងទុកក្នុងព្រះពុទ្ធសាសនា និងកសាងចេតិយមួយថ្មើរកំពុង បញ្ចុះអដ្ឋិប្រពន្ធយ៉ា; តទៅ, ឃើញរូប ចម្លាក់កងទ័ពពួកអសុរ យាត្រាទ័ពទៅច្បាំង ព្រះវិស្ណុជិះលើគ្រុឌ, (ព្រះ ស្កន្ធកាន់ត្រីសូល ក្បាល ១០០០ កូនពេញរះតេណសនិងក្រែស្នៈដៃ (ប្រណាម្យ) រូបចម្លាក់ត្រង់នេះ ខ្ញុំដែលមិនចំណាំនេះ នាំឲ្យសង្ស័យជាជា

ស្នាដៃជាងជាតិចិន ព្រោះរូបដំរី, រូបសេះ ឬរូបផ្សេងៗដែលជារបស់ខាងចិន សុទ្ធ ៗ មិនមែនជាស្នាដៃខ្មែរឡើយ. អ្នកមើលគួរពិនិត្យ ។

## រោងទងខាងជើង ប៉ែកខាងកើត (ពីខាងកើតទៅខាងលិច)

ត្រង់នេះ, ការរចនាក៏មិនចំណានដូចគ្នា ដែលជាថ្វីដៃជាងចិនវិញ; តាមលោកសឺដែសជាអ្នកប្រាជ្ញបារាំងវិសេស លោកសរសេរប្រាប់រឿងថា: ត្រង់នេះ, ជាចម្បាំងទេវតា គេស្គាល់បានដោយមានមកុដកំពូលស្រួច យាត្រាចំពោះមានគន់ទៅតាមក្បួនដើរមុខ ព្រះវិស្ណុក្បាល ១០០០ ជិះលើគ្រុឌ មានដៃ ៨, ថ្ងៃកណ្ដាលជាសមរភូមិ មានភ្លើងមួយនំ យាំងកងទ័ពទាំង សងខាង ភ្លើងនេះគ្រុឌសំដែងឫទ្ធិ យកទឹកទន្លេគង្គាជាភ្លើងរលត់អស់ ហើយធ្វើតំនរភ្លើងនោះទៅ; តទៅទៀត, គេឃើញយក្សក្បាល ៦ ដើង ៤ ជិះលើមាស ប្រដិប្រដិដ្ឋានច្បាំង ៗ គន់ទៅភាន ក្រិស្ណៈអវតារព្រះវិស្ណុ លុកចូលទៅក្រយទំពអសុរឈ្មោះ ពាណៈនៅក្នុងក្រុង ៗ ត្រង់នេះ ក្រិស្ណៈ ជិះលើគ្រុឌមានដៃ៤, ទៅបន្តិចទៀត ព្រះវិស្ណុមានក្បាល ១០០០ ដៃ ៨ ជិះ លើថេរមរំដោយសីហៈ មានសំពីរទាក់លុកចូលទៅ ទល់មុខគ្នានឹងអសុរ ឈ្មោះពាណៈ, (រឿងនេះមាននៅក្នុងគម្ពីរ ហរិវង្ស:); តបន្តិចទៅ, ឃើញ ព្រះឥស្វរគង់នៅឥតបង្អាក់ គួរប្រុសឈ្មោះគណេសក្បាលជាដំរី, ឬសី, កន្ទរ នៅលើភ្នំ. ព្រះក្រិស្ណៈក្បាល ១០០០ មានជ័យលើអសុរឈ្មោះពាណៈ

ក្រាបទូលសួរការព្រះឥសូរ ។ ព្រះឥសូរជួយអសុរឈ្មោះតាណៈ មានបន្ទូលទៅនាងព្រឹស្ណៈថា: "នែព្រឹស្ណៈ ឯងមានឫទ្ធិអំណាចណាស់នៅក្នុងលោកសន្និកស ឥតមានអ្នកណាមួយឈ្នះអ្នកឯងទេ, តែឯងនឹកមើល, ឥឡូវនេះ, អញបាននិយាយថាជួយអសុរតាណៈហើយ, សំដីអញមិនឥតប្រយោជន៍ទេ", ព្រឹស្ណៈឆ្លើយតបវិញដោយសេចក្ដីទាតថា: "សូមទ្រង់អសុរតាណៈមានជ័យចុះ ព្រោះខ្ញុំបានគំណត់ថាស្រោចស្រង់គេហើយ..., ឯទ្រង់ព្រះអង្គមិនខានបានត្រាស់ប៉ះជាទាស់ទេ, ខ្ញុំសព្វព្រះទ័យជួបមេត្ត ទំនួលបន្ទុកតាមចាំងអស់ ។"

## រឿងទន្សាយឆ្លង ប៉ែកខាងលិច (តំណាលកើតនៅខាងលិច)

រឿងទន្សាយនេះគឺរបាយមិនចាស់ប៉ុន្មានដែរ តែត្រាន់ប៉ះជានីទាន់កើត, និយាយពីរឿងបម្រាំងក្នុងសាសនាព្រាហ្មណ៍, តាមលោកសីថៃស លោកថា មានទេវតា ៦១ អង្គ ទេវតាម្នាក់ៗបម្រាំងនឹងអសុរម្នាក់ ដែលគេស់គាល់បានថៃ្ងគ្នាដោយមកុដនឹងក្បាល ហើយបម្រាំងតាំងគ្នា, ទេវតាដែលស្គាល់បាននោះ គឺទេវតាឈ្មោះ គុវេរៈ ជាទេវតាខាងទ្រព្យសម្បត្តិជិះលើយក្ខ, ទេវតាចម្បាំងឈ្មោះ ស្កន្ទៈ មុខ ៦ ដៃ ១០ ជិះលើក្ងោក, អគ្និៈ ជិះលើពពែកណ្ដុរ ៤ កាន់ព្រួញក្នុងដៃប្រាំមួយក្នុងប្រយោយ, គេឃើញមានយក្ខឥន្ទ្រស្ងាប់ក្នុងសមរភូមិ, ឃើញមានខាតក្បាល ៥, ឃើញវិស្ណុជិះលើគ្រុឌ; តទៅទៀត, យមៈ ជិះលើថេ

ទីមតោ, ព្រះឥសូរយឺតកៅទណ្ឌបសរ ព្រហ្មៈ ជិះលើហង្ស ទេវតាឈ្មោះ សូរ្យៈ មានសេះពីរទាញខ្លួនជិះលើរថ សារថីមានខ្លួនពាក់កណ្ដាលជាមនុស្សពាក់កណ្ដាលជាសត្វ ។ ខាងចុងក្រោយគេ ទេវតាឈ្មោះ វរុណៈ ទេវតានេះកាន់ក្បៀងជិះលើនាគ, សត្រីមនេកងទឹកទាំងពីរមានអាការវិតវែងខ្វះនិងរៀង ។

## ទៅជ្រុងរោងទងទិសពាយ័ព្យ កាត់ជាក្រឡាបព្វគ្គ (ចែកជា៤ ជា៖)

១. ជាងខាងកើត ផ្នែកខាងត្បូង, វិស្ណុជិះលើគ្រុឌ តាមលោកសឺដែសលោកថា ក្នុងពេលដែលវិស្ណុអវតារជាក្រិស្ណៈ មានជ័យជំនះត្រឡប់មកពីច្បាំងវិញ មានសេនាពាហនដឹកនាំគ្រឿងឧបករណ៍ផ្សេងៗ ដែលរឹបជាន់ពីបណ្ឌាម៉ែត្រ ថែស្កាំគ្រុឌទ្រអន្តមហេសីព្រះវិស្ណុ ។

នៅខាងលើបង្អួចខាងជើង, វិស្ណុគង់លើនាគហែលនៅលើទឹក, អគ្គមហេសីស្ថិតនៅខាងចុងព្រះបាទ, ផ្កាឈូកដុះចេញពីផ្ចិតព្រះវិស្ណុ ទេពអប្សរហោះកាន់ផ្កាពីខាងលើ, នៅខាងក្រោមមានទេវតា៩អង្គគឺ សូរ្យៈគង់លើរទេះ, កុវេរៈគង់លើយក្ស, ព្រហ្មៈគង់លើហង្ស, ស្កន្ទៈគង់លើក្ងោក, ទេវតាមួយអង្គទៀតនៅលើសេះ? ឥន្ទ្រៈគង់លើដំរីឰរាវណ្ណ, យមៈគង់លើគោ, សិវៈគង់លើគោ ។

២. ជាងខាងជើង នៅខាងលើបង្អួចខាងលិច, ថ្ងៃនីកាលព្រះរាមយកនាងសីតាទៅដុតនៅក្នុងភ្លើង ដើម្បីបញ្ជាក់សេចក្ដីបរិសុទ្ធិនៃនាង



រូបស្រីទេពអប្សរ មានសក់សំយាកពាក់មកុដ នៅជាន់ទី១ខាងលិច
ប្រាសាទនគរវត្ត

(តាមរូបថត ស.ប.ប.)

សិលា កាលដែលកពណ៌ល្អបយកទៅនៅការសក្ការៈ, ព្រះកមកនំទៅ ក្នុងប្រាសាទ, ពួកតាបានស្ងាលើកដៃបន្ទូលនៅនាទីសិលាដោយសេចក្តី អស្ចារ្យ ។

៣. ជាខាងលិច នៅលើបន្ទូចខាងជើង, ថ្ងៃនិកាលព្រះកមចប់ ឈរកពណ៌នៅក្រិនសក្តា ជាងគន់លើកដៃជណ្តាះបុស្បក: ត្រឡប់ មកក្រុងអយុធ្យាវិញ ពួកតាបានស្ងាសប្បាយរីករាយលេងរំលងថ្ងៃ ហើយស្រេច ។

នៅលើបន្ទូចខាងត្បូង, ថ្ងៃនិកាលនាងសិតានៅក្នុងប្រាសាទ កពណ៌, ព្រះកមប្រើហនុមាននៅមើលនាងសិតា, ស្រីដែលថែរក្សា នាងសិតាសុទ្ធតែយក្ខិនី មានសំលៀកបំពាក់មិនល្អ, ខុះមានចិត្តរឹងនិ ។

៤. ជាខាងត្បូង ជញ្ជាំងខាងកើត, ថ្ងៃនិកាលព្រះកមប្រទានចិញ្ចៀនឲ្យយកនាងសិតា, នាងសិតាពាក់មកុដកំពូល ៣, ហើយពួកពល- បរិវារនៅហែហម ។

បន្ទូចខាងកើត, ត្រង់កណ្តាល ព្រះកមកាន់ធ្នូ ព្រះលក្ស្មណ៍កាន់ ព្រះខាន់ ចំហាយបង់ស្ពានមេត្រីទំនិសុត្រិត; បន្ទូចខាងជើង យក្សឈ្មោះ រាពណ៍ស្រះ ជាបនឹកពណ៌ល្អបយកនាងសិតាបញ្ចូរលើភ្លៅ ចាំនិកនិឡើ ព្រះកមព្រះលក្ស្មណ៍; បន្ទូចខាងលិច ថ្ងៃនិកាលបង់ស្ពានមេត្រីព្រះកម និងយក្សឈ្មោះវិភីសណ: ជាបរិពពណ៌ (តីតិភេក្ស) ។

## ក្លោងទ្វារខាងលិច ប៉ែកខាងជើង (គឺខាងជើងទៅខាងត្បូង)

កៀនចង្ក្រាំងកបក្ដី ត្រង់ព្រះភមនឹងសេតព្រះភម កាយយកក្រុងលង្កា មានស្វាជាសេនាទាហាន ដើម្បីដណ្ដើមយកនាងសីតា; នៅក្នុងផ្ទាំងនេះ គេមើលឃើញព្រះភមជិះលើហនុមាណទេញចាំ, ខាងក្រោយព្រះលក្ស្មណ៍ និងវិភិសនៈ (ពិភេក្ស); តទៅទៀត ក្រុងរាពណ៍ទសមុខ ដៃ២០ ជិះលើរថ ។ ការបោតាតាំងអស់នេះ ជាចំរៀងដល់ពួកវិស្វករសម័យបច្ចុប្បន្ននេះពន់ពេកណាស់ ។

ដើរមើលក្រឡឹងជុំវិញហើយ ត្រូវឡើងទៅថ្នាក់ព្រះពាន់ តាមជណ្ដើរតែរនៅអមសងខាងទ្វារធំកណ្ដាល ឡើងផុតជណ្ដើរមួយជាន់ទៅដល់ក្រឡឹងទីប្រាកក្ដាក់ទ្វីផាក្រឡុចត្រគ្គ នៅបន្ទាត់ក្រឡឹងទីពាំង៤ទិសមានស្រះតូច៤ ។ នៅជ្រុងក្រឡឹងបណ្ដោយខាងត្បូង មានព្រះពុទ្ធ-រូបពុកណាច្រើន បណ្ដាជាលទ្ធិហីនយានខ្លះ មហាយានខ្លះ គេយកមកដំ-កល់ទុកតាំងរំលោះក្រោយការកសាងប្រាសាទ ។ កាលបើចេញផុតពីក្រឡឹងនៅខាងត្បូងក្ដី ខាងជើងក្ដី នឹងឃើញបណ្ណាល័យគេ, លុះបានមើលត្រង់នេះសព្វគ្រប់ហើយ ត្រូវឡើងតាមជណ្ដើរធំខាងលិចទៅដល់ជាន់ទី២, ឯជណ្ដើរឡើងទៅជាន់ទី២ មានគ្រប់ជ្រុងទិស តែពិបាកឡើង, ក្រឡឹងនេះមានព្រះពុទ្ធរូបជាច្រើន គេដំកល់ទុករៀបរៀងតាមជុំវិញ, នៅប្រឡាយធំខាងលិច មានរូបព្រះនារាយណ៍ជាច្រើន ខ្លះមានដៃ៤ ។



រូបស្ត្រីទេពអប្សរ មានផ្នួងសក់ជាមកុដ នៅជញ្ជាំងខឿនទិសខាងកើត
ប្រាសាទអង្គរវត្ត

ការរចនាសម័យប្រាសាទអង្គរវត្ត កើតឹង គ. ស. ១.៦៥០

( តាមរូបថត ស. ប. ប. )

## ថ្នាក់ទី ២

ចេញផុតពីកំពែងទី ២ ទីងឃើញទីកបរស្មើស្រឡះ, បើលទៅលើ ហាក់ដូចជាវិមានអណ្តែត, តាមទំនងនេះ បើចូលទៅលេងពេលយប់ ដែលមានព្រះចន្ទ្រពេញវង់ សមនឹងសប្បាយរីករាយអស្ចារ្យ, គេគាប់ដើរមើលជុំវិញបាន ហើយសឹមឡើងទៅជាន់ទី ៣ នៅចំពាក់ក្ដារចំកណ្តាលខាងលិច មានស្ពានគេទៅភ្ជាប់នឹងជណ្តើរចំខាងលិច ទីងមានជម្ពូទ្វារពីរនៅគែម ។

## ថ្នាក់ទី ៣

ការឡើងទៅកាន់ថ្នាក់ទី ៣ នេះ ត្រូវឡើងតាមជណ្តើរទិសខាងត្បូង ព្រោះមានបង្កាន់ដៃដែកគេធ្វើបង្អែកៗ មិនត្រូវស្ទើរប៉ុន្មាន, ប៉ុន្តែសម្រាប់អ្នកដែលមានស្មារតីល្អ ឡើងតាមជណ្តើរចំខាងលិចក៏បាន ព្រោះជណ្តើរនេះមិនសូវចោតដូចជណ្តើរឯទៀត, ថ្នាក់ទី ៣ លើបំផុតឈ្មោះ បា កាន នេះល្អអស្ចារ្យ, ត្រង់កណ្តាលមានប្រាសាទធំខ្ពស់ មានកំពែងទីពីរជុំវិញតភ្ជាប់ទៅទាំង ៤ ទិស កាត់មកជួបនឹងកំពែងខាងក្រៅ នៅត្រង់ចន្លោះផ្ទៃកំពែងមានស្រះ ៤ ។

នៅចំពាក់ក្ដារទាំង ៤ ទិសនៃប្រាសាទកណ្តាល មានព្រះពុទ្ធរូបថ្មធំឈរ មានអគ្គសាវកពីរអង្គនមស្ការ គេឆ្លាក់ភ្ជាប់នឹងថ្មដែលស្ទះបិទទ្វារនោះៗ នៅខាងមុខមានព្រះពុទ្ធរូបជាច្រើន ខ្លះគង់នៅល្អ ខ្លះបាក់

បែកខូចអស់, នៅមានតែក្បឿង គេបោះយកព្រះពុទ្ធរូបដែលឆ្លាក់នៅថ្មចេញ ខូចខាតអស់ គួរឲ្យនឹកស្តាយ ។ អ្នកមើលទាំងឡាយគួរគប្បីជាចាំ ប្រាសាទនគរវត្តនេះ ព្រះបាទសូរ្យវរ្ម័នទី ២ កសាងក្នុងសត-វត្សរ៍ទី ១៧ នៃពុទ្ធសករាជ ដើម្បីទុកសំរាប់ព្រះនារាយណ៍ក្នុងសាសនាព្រាហ្មណ៍ ដូចបានពោលមកហើយ ។

វេលាព្រះអាទិត្យទៀបអស្ដង្គត, ពន្លឺក្រហមព្រាលរស្មីចោលមកលើប្រាសាទ ដើរមើលលើ, ពពករសាត់ល្បឿនលយលើកំពូលប្រាង្គប្រាំនៃប្រាសាទ មើលមកក្រោមឃើញដំបូលរកូតប្រកបដោយហោជាងមានក្បាច់រស់រវើក អ្នកមើលសប្បាយរីករាយក្នុងប្រាណ អណ្ដែតអណ្ដូងចិត្ត, ហេតុនេះសូមជំរាបអ្នកមើលទាំងអស់ ឲ្យមើលប្រាសាទនេះ ក្នុងពេលល្ងាចទើបល្អមើល ។

## ប្រាសាទតាព្រហ្មគិល

ចម្ងាយពីមុខទ្វារ៥០០ម៉ែត្រ នៅជាប់ខាងឆ្វេងដៃ ប្រែបផ្លូវថ្នល់ប្រហែល៥០ម៉ែត្រ, មើលទៅឃើញប្រាសាទមួយបាក់បែកស្ទើរតែអស់រលីង ប្រាសាទនេះឈ្មោះ តាព្រហ្មគិល ។

ប្រាសាទនេះ, គេកសាងឡើងសម្រាប់ព្រះពុទ្ធសាសនាលទ្ធិមហាយាន ព្រោះមានរូបចម្លាក់នៅលោជាងទាំង ៤ ទិស សុទ្ធសឹងជារឿងក្នុងព្រះពុទ្ធសាសនា តែរូបចម្លាក់នោះឃើញមានខូចគេចោះចោលទៅវិញ ប្រហែលជាអ្នកកាន់សាសនាព្រាហ្មណ៍ ។ តាមដែលពួកអ្នកប្រាជ្ញគេពិនិត្យមើលរូបក្នុងប្រាសាទ និងក្បាច់ចនាផ្សេងៗ ដែលមាននៅនារូបប្រាសាទ គេស្គាល់បានថា គេកសាងសម័យប្រាសាទបាយ័ននិងនគរធំ ព្រោះមានព្រះពុទ្ធរូបនៅលោជាងខាងជើងជាច្បាក់ហាន ៗ ខាងក្នុង, មានព្រះពុទ្ធរូបផ្ចិតអង្គុយបៀតគ្នា ៗ កាលពីដើម, ប្រហែលជាមានយកចេញមកខាងមុខ ហើយប្រកាក់គ្នាជាក្រឡាចត្រង្គ ព្រោះមាននៅសល់ត្រឹមខាងក្រោម ។ កាលដែលគេជីកដីមើលជុំវិញ គេឃើញរូបជាច្រើនបែកខាងព្រះពុទ្ធសាសនា ។

## ភ្នំចារ៍១៨

ចេញពីមុខខាត, តាមផ្លូវធំជះទៅឧត្តរធំ ដែលអមដោយព្រៃព្រឹក្សា
ធំមានម្លប់ត្រជាក់ត្រឈៃ ទៅប្រហែល ៤០០ ម៉ែត្រ ទើបដល់កោមុះខាង
ត្បូងនៃឧត្តរធំ, នៅខាងឆ្វេងដៃមានសត្វសិង្ហៈឈរក្រអឺត, គេនឹងឃើញភ្នំ
មួយហៅថា ភ្នំចារ៍១៨ ត្រូវឈប់ថយត្បូងហើយឡើងតាមផ្លូវខាងមុខ ។
សូមរំឭកថា: បើទៅមើលត្រូវទៅពេលល្ងាចត្រជាក់ឬពេលព្រឹក ព្រោះ
ត្រូវឡើងភ្នំខ្ពស់បន្តិច នាំឲ្យហត់អស់កម្លាំង ស្រេកទឹកផង; សម្រាប់អ្នក
ដែលមានទ្រព្យសម្បត្តិនឹងជួលជ័រជិះឡើងទៅមើលក៏បាន ។ លុះឡើង
ទៅដល់ខាងលើភ្នំហើយ ឃើញមានទឹកបាស៊ើ មានគុម្ពបាទទេធ្វើកន
ប្រក់ពីលើ; តទៅ, ដល់ទៅប្រាសាទបារ៉ាង គេកសាងជា ៥ ថ្នាក់ ក-
ពស់ ៦៥ ម៉ែត្រ មានជណ្ដើរភាំទ្វាត្រប់ទាំង៥ថ្នាក់, នៅក្បាលជណ្ដើរមាន
សត្វសិង្ហៈជាទ្វារបាល នឹងមានប្រាសាទតូចជាប្រចាំជាផ្លូវវៀនតាព័ទ្ធ
ជុំវិញ តាំងពីថ្នាក់ក្រោមរហូតទៅដល់ថ្នាក់លើ ។ ថ្នាក់លើជាទី៤ផ្ទៃ
កបាស៊ើ ក្រាលស្មុទ្រតែធ្ម ប្រាសាទធំស្ថិតនៅកណ្ដាល ប្រាសាទតូចស្ថិត
នៅគ្រប់ជ្រុងអនុទិស; ប្រាសាទកណ្ដាលឥឡូវនេះ, បាក់បែកកំពូលអស់
ហើយ មានក្បាច់ចនាដ៏វិសេស ទ្វារបាលពីរល្អឆើតនៅអមមាត់ទ្វារ ។
ពេលល្ងាចព្រះអាទិត្យលិច, ពោលគឺព្រលប់ ខ្យល់បក់មកហើយ
ត្រជាក់ត្រជុំរសប្បាយពន្លឺក, គេអាចឈរប្រមូលយកមើលទៅទិដ្ឋជុំវិញបាន

ទាំងអស់, មើលទៅនគរវត្តមានកំពូលប្រាំប្រាង្គខ្ពស់ផុតស្លឹកឈើ, មើលទៅផ្សារសៀមរាប, ទៅបារាយទឹកថ្លានៅទិសខាងលិច ឬមើលទៅប្រា-សាទបាយ័ន នៅទិសខាងកើត, មើលទៅឆ្ងាយបែកផ្សែង, ដល់ទៅភ្នំគូ-លែន, ភ្នំបូក និងជួរភ្នំដងរែក ។

ភ្នំបាខែងនេះ, ជាគោលចារឹកនៃក្រុងនគរធំ ក្រោយដែលបានផ្លាស់ក្រុងចាស់ពីបាគងមក ។ តាមប្រពៃណីបុរាណខ្មែរ, គេច្រើនកសាងប្រាសាទធំខ្ពស់ ឬប្រាសាទនៅលើកំពូលភ្នំ ដើម្បីឧទ្ទិសថ្វាយទេវតាដែលគេគោរព; ភ្នំបាខែងនេះ គេកសាងដំណាងភ្នំព្រះសុមេរុ (ភ្នំហិមាល-យ័) ស្ថិតសៀមរាប ដំណាងទេវគ្គា តាមប្រទេសឥណ្ឌា ចូរអ្នកមើលសង្កេតផងចុះ ប្រាសាទកណ្ដាលជាភ្នំព្រះសុមេរុ ប្រាសាទតូចៗគ្រប់ថ្នាក់ ជាភ្នំសត្តបព៌ត, ចន្លោះថ្នាក់មួយៗ គឺសមុទ្រសត្តសិទន្តរ, ពួកទេវតាធំៗ ដូចព្រះឥសូរ ព្រះព្រហ្ម ព្រះនារាយណ៍ជាដើម តែងស្ថិតនៅលើភ្នំអស់នេះៗ តាមសិលាចារឹក, និយាយថា ប្រាសាទបាខែងនេះឈ្មោះឥទ្រាទ្រិ ប្រែថា: "ភ្នំដ៏សម្រាប់បូជាទេវតាធំៗ" ព្រះបាទយសោវរ្ម័នទី ១ កសាងក្នុងសតវត្សរ៍ទី ១៥ នៃពុទ្ធសករាជ (ព.ស.១៤៣៣) ទុកជាគោលឫទ្ធិជ័យនៃនគរធំក្នុងសម័យនោះ ដើម្បីឧទ្ទិសថ្វាយដល់ព្រះឥសូរ អាស្រ័យហេតុដែលព្រះបាទយសោវរ្ម័នទី ១ ឧទ្ទិសប្រាសាទនេះដល់ព្រះឥសូរ ទើបគេហៅភ្នំបាខែងនេះថា: "យសោធរេស្វរៈ" ។

## ប្រាសាទបក្សីចាំក្រុង

អ្នកផងទាំងពួងច្រើនទៅមកហួសមិនចូលមើល ដោយគិតស្មានថា ប្រាសាទនេះមិនសំខាន់អ្វីឡើយ តែតាមពិតមិនដូច្នោះទេ, ប្រាសាទបក្សីចាំក្រុង ស្ថិតនៅជាប់ខ្លោងទ្វារក្រុងខាងត្បូងនគរធំ, មានទ្រង់ទ្រាយស័ក្តិ-សម គេសាងជា ៤ ថ្នាក់ពីថ្មបាយក្រៀម បន្ទុំប្រាសាទឥដ្ឋខាងលើ មានជណ្ដើរឡើងគ្រប់ទាំង ៤ ទិស ទ្វារបញ្ឆោត ៣ ទិស, ក្បាច់ចនាស្រោប បិទពីក្រៅវិនាសបាត់អស់ហើយ នៅសល់តែក្បាច់ផ្ដើលើខ្លោងទ្វារល្អចំ-ណាប់ មានព្រះឥន្ទ្រគង់លើដំរីឯរាវ័ណ្ណ ចុងទាំងសងខាងមានគណេស; នៅតាមទ្វារខាងកើតមានសិលាចារឹកនិយាយថា ព្រះបាទរាជេន្ទ្រវរ្ម័នទី២ កសាងក្នុងសតវត្សរ៍ទី ១៥ នៃពុទ្ធសករាជ (ព.ស. ១៤៩០); ស្ដេចបានសាងរូបព្រះឥស្សរធ្វើពីមាសសុទ្ធ ដម្កល់ក្នុងកំពូលប្រាសាទនេះ ដើម្បីឧទ្ទិសថ្វាយព្រះឥស្សរ, តែសព្វថ្ងៃនេះមិនឃើញរូបព្រះឥស្សរនោះទេ គេមើលឃើញព្រះពុទ្ធរូបចូលនិព្វានវិញ, តាមចំនងនេះ ប្រហែលកាលជាន់សៀមមកវាយយកស្រុកខ្មែរ កាល ព.ស.២១៦៣ ឬ? កាលពីដើមមានកំពែងព័ទ្ធជុំវិញ ព្រោះឃើញមានសំណល់ខ្លះ ៗ នៅជិតប្រាសាទនេះទៀតខាងជើង មានប្រាសាទតូចមួយធ្វើពីឥដ្ឋថ្មបាក់ គេឲ្យឈ្មោះថា "ប្រា-សាទកាកូង" ។



ទ្វារជ័យ ភាគខាងកើត
ការរចនាបែបប្រាសាទបាយ័ន រវាង គ.ស. ១.២០០
(តាមរូបថត ស. ច. ប.)

## វគ្គទី ៤

## រាជធានីនគរធំ

ចេញពីមុខខាងចំនួន ១៧០០ ម៉ែត្រ កាត់មុខភ្នំបាខែង តាមផ្លូវធំ ប្រកបដោយម្លប់ឈើត្រជាក់ ទំរាំដល់ទៅគោបុរៈ (ខ្លោងទ្វារ) ទិសខាងត្បូងនៃនគរធំ ។ នគរធំនេះ, មានស្រះ (សិន្ធុ) ព័ទ្ធជុំវិញទាំង ៤ ទិស, មានគោបុរៈ៥ ខ្លោងទ្វារនៅទិសខាងកើត ២ គឺ ខ្លោងទ្វារនៅចំមុខព្រះលានឈ្មោះ ទ្វារជ័យ នៅចំមុខបាយ័នឈ្មោះ ទ្វារខ្មោច ។ ខ្លោងទ្វារទាំងអស់ ប្រកបដោយបន្ទាត់ដៃអសុរនិងទេពតាទាញនាគយ៉ាងល្អមើល ប្លែកពីប្រាសាទឯទៀត; ទេពតានិងអសុរនេះ មានមុខមាត់សំបើមៗ ភ្នែកលៀនចេញក្រឡោតៗ; គោបុរៈទាំង៥នេះ ជាប្រាសាទមួយ កំពស់ ២០ ម៉ែត្រ ក្បាច់ចនាទាំងក្នុងទាំងក្រៅ កំពូលជាក្បាលលោកេស្វរៈមានមុខ ៤; នៅសងខាងផ្ទៃទ្វារ មានក្បាលដំរីធំៗ ប្លែកពីប្រាសាទតាព្រហ្ម, ប្រាសាទបន្ទាយក្តី ដែលមានជារូបត្រងជុំវិញ ។ សូមប្រាប់ថា ប្រាសាទដែលមានកំពូលជាក្បាលលោកេស្វរៈមានមុខ៤ សុទ្ធតែគេទំសង់ថ្វាយដល់ព្រះពុទ្ធសាសនា ។ កំពែងព័ទ្ធពីក្រៅនេះ ធ្វើពីថ្មបាយក្រៀម កំពស់ ៨ ម៉ែត្រ, ទទឹងបណ្តោយជុំវិញ ១៤ គីឡូម៉ែត្រ, គេគាបដើរលេងកំសាន្តជុំវិញបាន ឬជិះសេះលើកំពែងនោះក៏បាន, មិនសូវក្តៅទេ ព្រោះមានមែកឈើត្របមួយចំហៀងនាំឲ្យត្រជាក់ ។

ក្រុងនគរធំ ដែលយើងមើលឃើញសព្វថ្ងៃនេះ មិនមែនជាក្រុងចាស់ពីបុរាណកាលមកទេ, កាលដើម ព្រះបាទយសោវរ្ម័នទី ១ ជាព្រះរាជបុត្រព្រះបាទឥន្ទ្រវរ្ម័នទី ១, កាលដែលទ័ពចាមចូលមកលុកលុយក្រុងធានី ស្ដេចទ្រង់មកកសាងក្រុងនគរធំនេះវិញ មុនគេបង្អស់ ក្នុងរវាងសតវត្សរ៍ទី ១៥ នៃពុទ្ធសករាជ (ព.ស ១៤៣៦-១៤៥៣) ទ្រង់ប្រទានឈ្មោះក្រុងនេះថា យសោធរបុរៈ ប្រែថា "បុរីនៃព្រះអង្គទ្រទ្រង់នូវយស"; ព្រះរាជាដែលកសាងក្រុងនគរធំនេះច្រើនព្រះអង្គ គឺពីព្រះបាទយសោវរ្ម័នទី ១ មក ។ ក្រុងនគរធំនេះ ស្កឹមស្កៃ មានកេរ្តិ៍ឈ្មោះល្បីល្បាញណាស់, អ្នកដំណើរចិនម្នាក់ឈ្មោះ ចៅតាក្វាន់ និយាយថា: "ក្រុងនគរធំជាក្រុងធំណាស់ បរិបូណ៌ដោយទ្រព្យសម្បត្តិ ប្រាសាទល្អៗជាច្រើន គឺជាកុះករដោយមហាជនជាអនេក" ។ ចូលតាមផ្លូវត្រង់ទៅទៀត ចំនួន ១.៨០០ ម៉ែត្រ គេនឹងទៅដល់ប្រាសាទបាយ័ន ។



ភាពជាក្រៅក្រៅនៃប្រាសាទបាយ័ន មើលពីទិសខាងកើត
ការរចនាបែបប្រាសាទបាយ័ន ជិត គ.ស. ១.២០០

(តាមរូបថត ក. ស. ប.)

## ប្រាសាទបាយ័ន

ស្ដាយអើយស្ដែនស្ដាយ! ល្អអ៊ីម៉្លេះ! កាលណាគេក្រឡេកមើលប្រាសាទបាយ័ននេះ គេឃើញទ្រង់ទ្រាយមានឫទ្ធិអស្ចារ្យ ទ្រង់ទ្រាយល្អឆើត ធំខ្ពស់ស្កឹមស្កៃសំបើម មុខណាគេស្ទះធំៗ នៅលើកំពូលប្រាង្គប្រាំខ្ពស់ត្រដូង ញញឹមស្រស់ប្រិមប្រិយ បែរមុខមកគេឃើញ ដូចជាស្រឡាញ់យើងណាស់, បែរទាំងនេះឃើញញញឹមស្រស់ បែរទាំងនោះឃើញញញឹមពព្រាយ ងាកមើលទៅទាំងណាក៏ឃើញដូចគ្នា នាំឲ្យយើងសប្បាយរីករាយ ចួនកាលភ័យស្ញប់ស្ញែងជាមួយផង ។

ត្រូវឈប់រថយន្តខាងត្បូង, ហើយបណ្ដាប់ឲ្យរថយន្តទៅចាំខាងជើងប្រាសាទ ចូលទៅប្រាសាទពីខាងត្បូង, ការដើរមើលប្រាសាទនេះ ត្រូវចាប់មើលពីទិសខាងកើត ខាងជើង, ខាងលិច, វិលមកខាងត្បូង ហើយសឹមឡើងទៅថ្នាក់ទីពីរ, ថ្នាក់ទីពីរត្រូវមើលដូចគ្នា ព្រោះមានរូបចម្លាក់ពង្សាវតារខ្មែរ រឿងចម្បាំងចាមនឹងខ្មែរ ដឹងទំនៀមទម្លាប់ខ្មែរបុរាណជាន់ដើម, ថ្នាក់ទីពីរក៏មានចម្លាក់ពង្សាវតារខ្មែរដែរ មានក្បាច់ចនាដេរដាសពាសពេញ, លុះមើលរួចហើយ សឹមឡើងទៅថ្នាក់ទី ៣ តាមជណ្ដើរខាងត្បូងឬជណ្ដើរខាងជើង, ប្រាសាទកណ្ដាល ធំខ្ពស់ស្កឹតនៅជាកណ្ដាល មានទ្វារចូលទាំង ៤ ទិស, តែគេហាមមិនឲ្យចូលព្រោះថ្មបាក់រលំជាច្រើន, មានយ៉ាងកាន់ចេញមកខាងកើត, មានទីលានដើរលេង

នៅជុំវិញយ៉ាងសប្បាយ, រួចហើយសឹមចុះទៅតាមទ្វារខាងជើង កាត់រហូតទៅកាន់ជាយគូនៅជ្រុងខាងជើង ។

ប្រាសាទបាយ័ន តាំងនៅពាក់កណ្ដាលក្រុងនគរធំ ឈ្មោះយសោធរគិរី ដែលជា "ភ្នំទ្រទ្រង់យស". ព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់កសាងក្នុងកន្លះសតវត្សរ៍ទី ១៨ នៃពុទ្ធសករាជ (ព. ស. ១៧៦៦-១៧៦៦), សព្វថ្ងៃនេះ ប្រាសាទបាយ័នបាក់បែកស្ទើរតែអស់ហើយ នៅសល់តែសសរច្រើន ជញ្ជាំងកេងទងនៅសល់ខ្លះ, ចុំថ្មដែលបាក់ធ្លាក់មកលើដី គេរើសគរទុក មានកំពស់ស្ទើរតែប៉ុនប្រាសាទ ។ ការនិយាយអំពីប្រាសាទបាយ័នឲ្យអស់ដំណើរ ផុតវិស័យនឹងនេះនិយាយបាន, ខ្ញុំក៏មិនទទួលកិច្ចនឹងនិយាយទៀយ ខ្ញុំគ្រាន់តែដឹកដៃអស់អ្នកទាំងឡាយមើលប៉ុណ្ណោះ ។ ទ្វារធំសម្រាប់ចូលពីខាងកើត មានជណ្ដើរខ្ពស់ តាមបង្អួចដែលនាំផ្លូវឡើង ខ្ពស់ស្រួច ទៀងពីទិសខាងណាក៏ស៊ីងតែបាន, មានចម្លាក់ពីរ នៅអមសងខាងនៃទ្វារធំនោះ; កាលពីដើម ព្រៃព្រឹក្សាដុះជិត គេទើបនឹងកាប់ចោលចេញ. សព្វថ្ងៃនេះ, បើយើងចូលទៅដល់ ទីនេះយើងឃើញតែព្រះពុទ្ធរូបនាគប្រក់ជាស្ពានដ៏យ៉ាងធំណាស់ គេដាក់រៀបរៀងគ្នា ទ្វារបាលធំសម្បើម ឬសសរថ្មប្រធំៗ មានស្ត្រីទេពអប្សរកំពុងកាន់ផ្កានៅក្នុងសសរនោះ ។

អ្នកប្រាជ្ញបារាំងវិសេស ដែលជាអ្នកត្រួតត្រាប្រាសាទនគរ បានពិនិត្យមើលឃើញថា: "ប្រាសាទបាយ័ននេះ មានកិច្ចការរចិតរចងច្រើន



មុខលោកេស្វរៈ នៅលើកំពូលប្រាសាទបាយ័ន
ការរចនាបថប្រាសាទបាយ័ន រវាង គ. ស. ១.២១០
(តាមរូបថត ស.ព.ប.)

ប្រាកដណាស់, គេមិនមែនកសាងតែម្តងហើយស្រេចទេ" ។ ពិតមែន, បើយើងមើលដោយសង្កេតហើយ ឃើញថាការកសាងនេះជួរញ្ញាះមែន ដោយមានការផ្ចាញ់ផ្ចាលនឹងឈ្នះស ប្រណាំងប្រជែងលទ្ធិសាសនា, គេអាចស្គាល់បាន ដោយការកសាងបន្ថែមគ្រឿងគរផ្សេងទៀត, និងការបោះកាសលុបរូបអ្វីមួយដែលគេមិនពេញចិត្ត, ព្រោះថាដែលកសាងប្រាសាទបាយ័ននោះច្រើនព្រះអង្គ ចែកជា ៣ កាល គឺ កាលព្រះបាទជយវរ្ម័នទី ៧ មួយ, កាលព្រះបាទយសោវរ្ម័នមួយ, កាលសៀមមួយ ។ មុនដំបូងព្រះបាទជយវរ្ម័នទី ៧ ស្តេចកាន់ព្រះពុទ្ធសាសនាកសាង, ក្រោយមក ព្រះបាទយសោវរ្ម័នកសាងបន្ថែមទៀត បំបាំងឲ្យក្លាយទៅជាប្រាសាទសាសនាព្រាហ្មណ៍វិញ, ប៉ុន្តែពេលដែលយើងត្រូវយល់នោះ ពីប្រាសាទបាយ័ននេះ គេកសាងទុកថ្វាយព្រះពោធិសត្វអវលោកិ-តេស្វរៈ ឬ លោកេស្វរៈ មានមុខ ៤ ជាគោលគំនិតនៃព្រះពុទ្ធសាសនាលទ្ធិមហាយាន ។ សូមចំណាំទុកថា: ប្រាសាទឯណាដែលគេកសាងមានកំពូលជាក្បាលមានមុខ ៤, ដូចបាយ័ន, តាព្រហ្ម, បន្ទាយក្តី ជាដើម ប្រាសាទនោះ សុទ្ធតែគេទុកថ្វាយព្រះពុទ្ធសាសនាលទ្ធិមហាយានទាំងអស់, កុំភាន់ច្រឡំដូចយើងពីដើមថាមុខព្រហ្មឡើយ, ភស្តុតាងនៅទៀតដែលនាំឲ្យយល់ច្បាស់ណាស់ ដោយបានឃើញរូបអវលោកិតេស្វរៈដែលព្រះបាទយសោវរ្ម័ន សន្ធប់ព្រះភ័ក្ត្រនឹងឈើនៅផ្នាក់ទាំងទិស

ក្បៀសានប្រាសាទកណ្ដាល ហើយនឹងព្រះពុទ្ធរូបនាគប្រក់ ដែលគេគាស់យកបានពីខាងក្នុងប្រាសាទកណ្ដាលកាល គ.ស. ១៩៣៣ ហើយដែលគេយកមកដំកល់ទុកនៅមុខព្រះលាន ៗ តមក, ព្រះរាជាដែលសោយរាជ្យតព្រះវង្ស ជាអ្នកកាន់សាសនាព្រាហ្មណ៍ គេរំពកប់ការព្រះអង្គមានព្រះបាទយសោវរ្ម័នជាដើម កសាងបន្ថែមបិទប្រកាសព្រះពុទ្ធរូបចោលចេញ ៗ

បើប្រសិនជាចូលតាមទ្វារធំខាងកើត, វេលាដែលទៅដល់ថ្នាក់ទី ១ ហើយ នឹងឃើញមានរូបជាច្រើន ដែលឆ្លាក់នៅសសរនឹងជញ្ជាំង, នៅសសរមានរូបទ្វារបាល ស្ត្រីកំពុងរាំ, រូបអ្នកស្រុកធម្មតា, ដល់មកត្រង់នេះ ត្រូវបត់ទៅខាងជើង ៗ

ថ្នាក់ទី ៣

រឿងរាជក្សត្រិយ៍

## ជញ្ជាំងខាងកើត ភាគខាងជើង (ពីខាងក្នុងទៅខាងជើង)

នៅជញ្ជាំងកន្លែងនេះមានរឿងចំបាំងតាមទំនៀមខ្មែរ កំពុងប្រយុទ្ធគ្នាយ៉ាងសម្បើម ខ្លះដេកដួលស្លាប់ដេរដាសពាសពេញ ទ័ពតាមអមពីក្រោយពាញទ័ពខ្មែរ; ក្នុងសមរភូមិ ឃើញសេនាធិការទាំង ៦ ខាង បង្កើតគ្នាខ្លាច មានគ្រឿងសាស្ត្រាវុធគ្រប់, ទង់ជ័យ, ក្លស់ក្រោងក្រាក ៗ នៅ



រូបស្ត្រីទេពអប្សរ កំពុងទង់ភ្ជង់លើផ្កាឈូក នៅសសរ ៤ ជ្រុង
ទ្វារចូលខាងកើត ប្រាសាទបាយ័ន

(តាមរូបថត ស.ប.ប.)

ផ្ទឹក្បៀសាន មានយោធាផងទាហានការពារក៏មានសណ្ឋានដាច់ដៃមួយ ទឹង ព្រះពុទ្ធរូបខាតប្រែក គេចាប់យកមកដាក់តាំងទុកក្នុងកាលឥឡូវនេះ ។

## ជញ្ជាំងរោងទងខាងជើង ភាគខាងកើត (គឺខាងកើតទៅខាងលិច)

មានរឿងបញ្ចាំងតាមខ្ចីងខ្មែរទៀត, ថ្ងៃឯកាលព្រះបាទយសោវរ្ម័នអប-ក័យតាញ់តាម; តទៅទៀត មើលមិនច្បាស់ ព្រោះកាលយូរទៅថ្មទ្រុឌឲ្យពុកផុយអស់, ស្លាយរលាយមិនអាចនឹងទាញយករឿងពីផ្ទាំងនោះបាន ។ ដល់ខ្ពាន់ទិសខាងជើង, ត្រង់ងទៅមើលរូបចម្លាក់តាមខាងលិចទៀត ។

## ជញ្ជាំងរោងទងខាងជើង ភាគខាងលិច (គឺខាងកើតទៅខាងលិច)

ដំណាលរឿងស្តេចគង់ក្រសាលសប្បាយក្នុងព្រះរាជវាំង; ក្នុងពិធីបុណ្យ មានរឿងល្បែងខ្មែរបុរាណជាច្រើនគឺ ល្បែងប្រដាល់, ល្បែងចំបាប់, ល្បែងបង្វិលកង់ដោយជើងគួរល្អមើល ដែលសម័យយើងនេះមិនមានដូច, ល្បែងគល់ មានស្រីឈរនៅលើបាតដៃទាំងសងខាង ទឹងឈរនៅលើក្បាលមនុស្សម្នាក់ ហើយទាក់ក្បាច់គួរស្ញើច ដូចល្បែងសៀកដែលយើងឃើញក្នុងបច្ចុប្បន្ននេះ ទឹងមានល្បែងផ្សេងៗជាច្រើនទៀត ។

## ជញ្ជាំងរោងទងខាងលិច ភាគខាងជើង (គឺខាងជើងទៅខាងត្បូង)

មានរូបចម្លាក់មិនទាន់ស្រេច រឿងបញ្ចាំងនិយាយត្រង់មានជ័យទ្វារ-ត្រង់អបកជ័យទ្វារ; ដល់ខ្ពង់ខាងលិច ត្រូវទៅមើលចម្លាក់នៅជញ្ជាំងរោងទងខាងលិចភាគខាងត្បូង ។

## ជញ្ជាំងរោងទងខាងលិច ភាគខាងត្បូង (ពីខាងជើងទៅខាងត្បូង)

មានរឿងចម្បាំង, រឿងស្តេចកំសាន្តព្រៃ ចាប់យក្សព្រៃរាជសីហ៍, មេទ័ពខ្មែរមានជ័យជម្នះទ័ពចាម មានសេចក្តីរីករាយសប្បាយ, មានរឿងកសាងប្រាសាទ ក៏ពុនដឹកជញ្ជូនថ្មយកទៅកសាង ។ នៅព្រៃនកនិងនីស សិរីមិនមានរូបអ្វីទេ ។

## ជញ្ជាំងរោងទងខាងត្បូង ភាគខាងលិច (ពីខាងលិចទៅខាងកើត)

មានរឿងចម្បាំងក៏ពុនយាត្រាទ័ព លើករហ័តពលសកលលោកឆា ចេញទៅកាន់សមរភូមិ ។

## ជញ្ជាំងរោងទងខាងត្បូង ភាគខាងកើត (ពីខាងលិចទៅខាងកើត)

មានរឿងកសាងប្រាសាទ, ពួកកម្មករក៏ពុងតាមអារ៉ោ កាប់ឈើ, នូវក៏ពុងរៀបចំស្ដូកណ្ដាំ រៀបរៀងការធ្វើអាហារ នៅកណ្ដាលព្រៃតាមរបៀបខ្មែរបុរាណ ដូចយើងឃើញមកដែរ ។ ម៉្យាងទៀត មានរឿងចំប៉ាំង គ្រង់ទ័ពខ្មែរទីងទ័ពចាមក៏ពុងប្រយុទ្ធគ្នា, ពួកហេវ៉ាពលសកលលោកនាំទូក ពាក់មួកមានកំពូលដូចផ្កាត្រឡប់ចុះក្រោម, ទាហានចាមអោកជ័យចាញ់ទ័ពខ្មែរ ត្រូវសរខ្មែរ របួសដួលស្លាប់ខ្លះ, ពួកទាហានកាត់សក់ខ្លី ជាទាហានខ្មែរ មានជ័យជម្នះទ័ពចាម ។ ក្បែរ (ពួកកងទ័ពដើរទឹក) ឃើញសុទ្ធតែទូកពេញដោយសេនាទាហាន, ករទ័ពមួយពួកដែលពាក់



រូបស្រីទេពអប្សរ កំលែងបណ្ដាសល្ងំលើផ្កាឈូក នៅសសរ ៤ ជ្រុង
ទ្វារចូលខាងកើត ប្រាសាទបាយ័ន

(តាមរូបថត ស.ខ.ប.)

បូកមានកំពូលជាតាហានតាម លើកមកពីប្រទេសចម្ប៉ា តាមជើងទឹកមក វាយយកប្រទេសខ្មែរ, ឃើញទ័ពខ្មែរចូលលុកវាយទ័ពតាម, ហើយពលសកលយោធាតាមចាញ់ស្លាប់ធ្លាក់ក្នុង ជាចំណីត្រីក្រពើឆ្លាមមករ ។ តទៅទៀត, និយាយពីល្បែងខ្មែរបុរាណផ្សេងៗ, មានល្បែងប្រដាល់គ្នា ឬគំនិតលើហាត់ប្រាណ, រឿងការលក់ដូរត្រីសាច់និងចំនីញផ្សេងៗ, ល្បែងប្រជល់មាន់, រឿងខេសាច, ចាប់ត្រីមានសំណាញ់, មង, រឿងព្រានព្រៃបាញ់សត្វ, ត្រីទ្វារជញ្ជាំ, រឿងទំនៀមឈាបនកិច្ច ដែលជាទំនៀមខ្មែរបុរាណ ។ អ្នកមើលត្រូវស្តែងឲ្យជាក់ច្បាស់ ដើម្បីប្រៀបធៀបគ្នានឹងទំនៀមខ្មែរបុរាណនឹងបច្ចុប្បន្ននេះ ។

នៅផ្នែកខាងលិចសព្វគ្នាយ៍ មានរឿងសាសនាព្រាហ្មណ៍ តគ្នាក់ក្រោយព្រះពុទ្ធសាសនា រឿងអ្នកផឹកស្រា រឿងបារគូបុរោហិត ។

## ជញ្ជាំងរោងខាងកើត ភាគខាងត្បូង (ពីខាងត្បូងទៅខាងជើង)

សេនាធាហានមេទ័ពជិះលើដំរី, មានទង់ជ័យ, រឿងច្បាំងមានជ័យជំនះ មានសេចក្តីរីករាយសប្បាយ, មេទ័ពជិះលើដំរី ហែហមដោយហើយពលសកលយោធាទោមជុំជិត យាត្រាទ័ពកាត់ព្រៃព្រឹក្សាមានដើមត្នោត, ដើមឈើធំ, ដើមពោធិ៍, ឃើញទាហានតាមគេចាប់ជាឈ្លើយបាន មានរទេះគោ, ក្របី, សេះ, ដំរី, ការសម្លាប់ក្របីជាគ្រឿងបូជា, ផល់មកកន្លែងគ្រងនេះអស់ថ្នាក់ទី ១ ហើយ ។

កាលណាបើបានមើលថ្នាក់ទី១រួចហើយ, ត្រូវឡើងទៅកាន់ថ្នាក់ទី២ភាគជណ្ដើរខាងកើត ។ ការចាំមើលថ្នាក់ទីពីរនេះជាការពិបាកពេក, មិនមែនយាយតែត្រង់រឿងកំរទ្ទះដែលជាគោល, ព្រោះរឿងនៅជញ្ជាំងថ្នាក់ទី២នេះ មានច្រើនជាអនេក មិនងាយនឹងពន្យល់ឲ្យអស់បានឡើយ, អ្នកមើលត្រូវបត់ទៅមើលកន្លែងខាងកើត ភាគខាងជើងជាមុនសិន (ពីខាងត្បូងទៅខាងជើង) ។

ថ្នាក់ទី ២

## រោងទងខាងកើត ភាគខាងជើង (ពីខាងត្បូងទៅខាងជើង)

នៅជញ្ជាំងខាងត្បូង ព្រះបាទយសោវរ្ម័នប្រថាប់នៅក្នុងប្រាសាទ ទតព្រះនេត្រទៅគេល្ខោន, អ្នកលេងភ្លេងនឹងអ្នកដេញពិណ, មានស្រីស្នំក្រមការកាន់ផ្លិតបក់ និងគ្រឿងប្រដាប់ឯទៀតជាច្រើន នៅចោមរោមគាល់ហ្វៅ ដូចស្ដេចដែលយើងឃើញសព្វថ្ងៃនេះដែរ, នៅសងខាងថ្ងៃនោះឃើញអគ្គមហេសីប្រថាប់លើគ្រែ មានស្រីគាល់ហ្វៅជាបរិវារ ។ នៅផ្នែកកណ្ដាល, ខាងស្ដាំទេពតាគង់នៅក្នុងប្រាសាទ, ព្រះបាទយសោវរ្ម័នកំពុងច្បាំងនឹងពស់ថ្លាន់, អ្នកមើលអាចយល់រឿងភ័យដោយសេចក្ដីសប្បាយរីករាយ ទូរហាក់ដូចជាទះដៃផង មានសេនាទាហាននៅចាំថែរក្សាដោយបញ្ជីត ។ នៅខាងស្ដាំរឿងនេះ, ព្រះបាទយសោវរ្ម័នប្រថាប់ក្នុងប្រាសាទ ទ្រង់ព្រះទាន់ត្រាស់បង្គាប់ឲ្យលើកដុំថ្ម ។ តាមជញ្ជាំងកន្លែង



រូបស្រីទេពអប្សរ នៅជញ្ជាំងប្រាសាទកណ្តាលនៃប្រាសាទបាយ័ន

(តាមរូបថត ព.ស.ប.)

ដែលបត់បែនទេរ ឯងឃើញមានរូបទេវតាជាច្រើន, មានសេនាពាហន, ទ័ពជើង ទ័ពសេះ ដាំងទ័ពដឹកនាំទ្រព្យសម្បត្តិ, ឯងនៃត្រៃស្នួន; នៅចុងខាងជើង ឃើញក្សត្រិយ៍ជិះសេះជ្រីងនៃស្នែងផ្ទាត់ជាក្បាលនាគ, មានគេទទឹមដោយមនុស្ស ។

## ជញ្ជាំងខាងជើង ភាគខាងកើត (ពីខាងកើតទៅខាងលិច)

ស្តេចស្ថិតនៅក្នុងប្រាសាទ ព្រះហស្តចាប់លើព្រះខាន់, នាម៉ឺនមុខមន្ត្រីចូលដៃដោយសេចក្តីគោរព ស្តេចទ្រង់គោរពបូជាយញ្ញ, នៅខាងក្នុង, ស្តេចទតល្ខោន មានអ្នកក់យស្គរ មានគ្រុក អ្នកដេញពិណ, ស្តេចរៀបនឹងឡើងកាន់ជទឹមដោយមនុស្ស, ឃើញប្រាសាទទទេ ស្តេចទ្រង់ចរចេញយាត្រា សេនាពាហនយាត្រាទ័ព, ឃើញព្រះឥស្សរប្រថាប់ក្នុងប្រាសាទកំពូលខ្ពង់សាក, ស្តេចគេចាំងដោយក្រូសព្រានព្រាត ឃើញព្រះនារាយណ៍និងនាងលក្សី ។ តាមកេរ៍ទងដែលបត់បែន មានរូបជាច្រើនទៀត រូបខ្ទមចន្ទស្វាវណ៍ ឃើញព្រះឥសូរ ព្រះនារាយណ៍ ក្នុងកពណ៌ទសមុខ ដៃមួយពាន់ កំពូលចាប់ភ្នំកៃលាសអង្រួនដោយសេចក្តីកញ្ចាន៍ស; តទៅទៀត, ព្រះឥសូរជិះគោនន្ទិ ទបនាងបរ្វតីនៅលើភ្នំល្ខោនកំដោយស្វាគ្មាន ។

## រោងទងខាងជើង ភាគខាងលិច (នៅចន្លោះទ្វារធំនិងទ្វារតូចខាងលិច)

ខាងឆ្វេង ព្រះឥសូរជិះលើគោឧសភ, នៅផ្នែកកណ្ដាល ទេពតាកាមៈ កំពុងយកធ្នូបាញ់ព្រះឥសូរ, ព្រះឥសូរបើកភ្នែកក្រឡេកទៅឆេះទេពតាកាមៈជាផេះ ។ តាមរឿងនិទានដែលបកប្រែ, ខាងឆ្វេង ព្រះឥសូរនៅលើភ្នំកៃលាស ព្រះព្រហ្មមានមុខ៤ និងព្រះនារាយណ៍នៅអមសងខាង ។ នៅផ្នែកកណ្ដាល ព្រះឥសូរដៃ១០ មានព្រះព្រហ្មនិងព្រះនារាយណ៍នៅអមទៀត, ឃើញមានពួករបាំតាណ្ឌវៈ ដែលល្បីឈ្មោះក្នុងស្ថានសួគ៌តាមសម័យបុរាណ មានល្បែងប្រណាំងទូក មានខ្ទះកប៉ា មានក្បាលទំនឹកនៃ ទាក់ក្បាច់យ៉ាងល្អគេត ។

## រោងទងខាងលិច ភាគខាងជើង (តាំងពីជើងទៅខាងត្បូង)

មានរឿងកូរសមុទ្រទឹកដោះ ដែលញ៉ាំងកើតទិននេះ ពុករបេះត្រង់ចំកាត់កណ្ដាល ត្រង់នេះជាកន្លែងល្អវិសេសក្នុងប្រាសាទបាយ័ន គួរស្ដាយណាស់, គេឃើញពួកអសុរនឹងពួកទេពតា ឃើញនាគវាសុកិនេះត្រូវ ដែលជាស្នូលសម្រាប់ទាញបង្វិលកូរសមុទ្រទឹកដោះ ស្វាដែលទាញកន្ទុយនាគនោះប្រហែលជាហនុមាន ព្រោះស្វាជាបក្សពួកនៃអសុរ ។ ស្នូលដែលសម្រាប់ទាញនោះ មានទ្រនំព្រាយជាសសរ មានកំពូលជាផ្កាឈូក



ព្រះនារាយណ៍ដៃ ៤ មានទេវតាគាំនិងមនុស្សប្រណម្យ ប្រាសាទបាយ័ន ។

( តាមរូបថត ក. ស. ប. )

ហើយស្ពឹតនៅលើវិស្ណុ ដែលអវតារជាអណ្ដើក; នៅសងខាងកន្លែងកូរសមុទ្រ ឃើញមានសត្វច្រើនយ៉ាង ដូចសេះ ដំរីជាដើម ដែលកើតចេញមកអំពីការកូរសមុទ្រ ។ នៅលើខ្នងនាគ, គេមើលឃើញផងស្រាប់ជាក់ទំនងមែន, តែមួយនៅសងខាង ជាក្រុមព្រះអាទិត្យនិងព្រះចន្ទ្រ, ២ ពួកទេពតាឯទៀតក៏យហោះរេឃ្លាតខ្ទៃ រូបចម្លាក់មានសណ្ឋានដូចឃើញ ឃើញនៅនគរវត្ត ។ តទៅទៀត, មានរឿងវិស្ណុនិងពួកខ្មាំងបង្ហាញចេញនាំ សំដែងសេចក្ដីក្ដៅក្រហាយ ក្នុងការប្រយុទ្ធ; តទៅទៀត, ពួកសេនាទាហាន និងពួកក្មេងកំដរស្ពានជាទីសំរេចចិត្ត, ផ្ទៃកណ្ដាល មានរឿងយាត្រាទ័ពនិងចមកាលដ៏ះលើកនេះ ។

## ពាងទងខាងលិច ភាគខាងត្បូង (តាំងជើងទៅខាងត្បូង)

នៅខាងឆ្វេង, ពួកឫសីចំរើនធម៌ក្នុងគុហា មានអង្គហាលទឹក សត្វម្រឹគបោករយ៉ាងលឿន មានបក្សីពាក់គ្រឹ, ភាគខាងក្រោម ផ្ទៃព្រះកដក់ង; នៅផ្ទៃកណ្ដាល, រឿងទឹកដើងទឹក រឿងវិស្ណុ ។ ខាងស្ដាំ, មានរឿងកសាងផ្លូវថ្នល់ មានពួកកម្មករកំពុងតាក់តែងការងារកាយមុខក្រសួង; តទៅទៀត, មានរឿងស្រីម្នាលងក្នុងទឹក ខ្លះហែល ខ្លះកងខ្លួន; ផ្ទៃកណ្ដាល មានរឿងកំនៅក្នុងប្រាសាទ អ្នកដេញតំណាលបែបបុកណ ខ្សែតំណាគេមើលឃើញច្បាស់; នៅខាងក្រោម, ខាងស្ដាំគ្នា មានរឿងច្បាំងជាំរែង

ពួកពលថ្មើរជើង, នៅកណ្ដាលសមរភូមិ ឃើញវិស្ណុជិះលើគ្រុឌ ពួករបស់ពលសេនាយោធាទាំងសងខាង សុទ្ធតែពាក់មួកមានកំពូលដូចផ្កា ការខាងក្រោមពួកសេនាទាហាន ។

## រោងទងខាងត្បូង ភាគខាងលិច (គឺខាងលិចទៅខាងកើត)

រឿងនៅប្រាសាទ ស្ដេចប្រថាប់កណ្ដាលពួកសេវកាមាត្យ ទ្រង់ត្រាស់បង្គាប់កិច្ចការរាជការ, ការខាងក្រោម ពួកអ្នកចាត់ចែងត្រៀមបូជាយញ្ញ; គេមើលឃើញថាមានគន្ធព្យាស់ទ្រង់សម ជារបស់សម្រាប់ព្រះរាជដំណើរ ប្រហែលជាក្បួនព្រះរាជដំណើរទៅនមស្ការព្រះវិស្ណុ ពួកអ្នកគោរពក្រាបសំពះត្រៀបត្រា នៅខាងមុខមានស្រះ ។ នៅក្រោមដើមឈើ មានពួកឬសី, ពួកបក្សីហើរត្រៀលឆ្ងាត់នៅខាងលើ, ទីបំផុតថ្ងៃ ព្រះផ្សូរសណ្ឋិតឈរ; តទៅទៀត, ខាងឆ្វេង ឃើញព្រះផ្សូរទាបគេឡើងកាន់គ្រឿងសូរ នឹងពួកអ្នកលេងភ្លេង, នៅផ្នែកកណ្ដាល ព្រះផ្សូរប្រថាប់នៅលើផ្កាឈូកធំ មានពួកបរិវារនៅហែហមជុំវិញ; ខាងស្ដាំ, រឿងថ្ងៃព្រះរាជវាំង មាននាម៉ឺនម្នាក់ដេក គេមើលឃើញតែក្បាល ហាក់ដូចជាព្រួយចិត្តដូចអ្នកដែលអង្គុយនៅប្របខាង; ដល់មកត្រង់នេះអស់ថ្នាក់ទី ២ ហើយ ។ នៅថ្នាក់ទី ២ បើមានឱកាសល្អ គួរទៅមើលអណ្ដូងក្នុងប្រាសាទ តែត្រូវមានចង្កៀងពិល ឬភ្លើងអ៊ីឡិចមួយបំភ្លឺមើល អណ្ដូង



រូបសីហៈនៅគោបុរៈខាងជើងនៃប្រាសាទបាយ័ន

( តាមរូបថត ត. ស. ប )

នេះស្ថិតនៅជ្រុងឦសាន ត្រូវដើរចូលតាមមាត់ទ្វារខាងកើត បត់ទៅខាងជើងបន្តិច ចូលទៅក្រោមកំពែងទីពីរបន្តិច ទៅដល់អណ្ដូងនោះ មានបង្កាន់ដៃដែកកុំឲ្យមានគ្រោះថ្នាក់ ចេញទៅខាងលិចទើបមានគន្លង ។ មើលរួចហើយ ត្រូវដើរចេញតាមក្រោមកំពែងនៅខាងលិច ទៅឡើងជណ្ដើរខាងជើងទៅថ្នាក់ទី ៣ ។

លុះអ្នកមើលបានដើរមើលថាន់ទីពីរហើយ ត្រូវឡើងទៅមើលថាន់ទី ៣ ជាថាន់លើបង្អស់ទៀត តែសូមកុំភ្លេចថា កាលដែលដើរមើលព័ទ្ធជុំវិញប្រាសាទនោះ អ្នកកាល់ត្រូវតែបានឃើញជណ្ដើរនៅទិសខាងត្បូង១ ខាងជើង១ ជណ្ដើរទាំងពីរទិសនេះគេឡើងបានដោយស្រួល, សូមកុំឡើងតាមជណ្ដើរទិសខាងកើតនិងខាងលិច ព្រោះជណ្ដើរទាំងពីរទិសនេះស៊ឹករិលអស់ហើយ អាចឲ្យគ្រោះថ្នាក់ដល់អ្នកឡើងស្ទើរតែគ្រប់ពេល, ម្យ៉ាងទៀត សូមប្រយ័ត្នព្រោះប្រាសាទបាយ័ននេះ ដក់ត្រាំត្រា ជាប់ប្រាសាទទាំងមូល អាចឲ្យគ្រោះថ្នាក់ច្រើនប្រការណាស់ ។

ថ្នាក់ទី ៣

ថ្នាក់ទី ៣ នេះ មានប្រាសាទជាច្រើន ទាំងតូចទាំងធំចំនួន ៥១ ប្រាសាទ នៅព័ទ្ធជុំវិញប្រាសាទធំកណ្ដាល, ប្រាសាទមួយៗមានទ្វារ៤ ស៊ុម៤ កំពូលជាក្បាលលោកេស្វរៈមានមុខ៤ មានមកុដទ្រទ្រង់ដោយផ្កាឈូក

មានទំហូតាក់ទៅក្រៀក; នៅទិសឦសានប្រាសាទធំកណ្តាល, គេបាន រើបស្ទូបចេញ ហើយឃើញរូបលោកេស្វរៈយ៉ាងល្អដូចជាថ្មីៗ គេយល់ ជា ព្រះបាទយសោវរ្ម័ន បិទស្ទូបបំបាំងរូបព្រះពុទ្ធសាសនា, ផ្ទាំងលើ បែបនេះ ព្រះបាទយសោវរ្ម័នស្តេចសាងថែមត្រួតសង្កត់ពីលើ លោក ទៅដល់លើប្រាសាទយ៉ាងមុខ បាត់មុខទ្វារអស់, មានជម្រមន្ទីរដើរ ទៅអម យ៉ាងវែងឆ្ងាយចេញមកខាងមុខ; ត្រង់នេះ, គេឃើញមុខលោកេស្វរៈធំ សំប៉ើមៗនៅលើកំពូលខ្លួន មើលទៅមុខញញឹមពព្រាយដូចផ្កាឈូកសព្វ ទិសនានា, មុខមួយៗមានទំហំ ១ម៉ែត្រ៧៥ ឬ២ម៉ែត្រ៨០ មើលទៅ កំពូលប្រាសាទកណ្តាលខ្ពស់ត្រដូចជាប៉ះអាកាស បាក់មុខធ្លាក់អស់ ឃើញតែដុំថ្មដេរលើគ្នា ទ្រេតហាក់ដូចជាគេគល់លើមកសង្កត់លើ គួរ ឱ្យគួរស្តាយណាស់, ហើយមើលទៅខាងលើ ឃើញពពកសាត់លឿនលយ គួរស្រើះស្រើប គួរឱ្យទឹកភ្នែកសប្បាយរីករាយ, បើប្រៀបជាពេល កក្រើមានព្រះបន្ទូលពេញលើនេះត្រចង់ដើគនាយ ទីនីរតើនៅតែសប្បាយឥត ឧបមាគួរឱ្យតែទឹកត្រៀងអនិច្ចាទុកណា... បន្ថែមកំសាន្តចិត្តទៀត ។

បណ្តាក្បាច់ចម្លាក់ដែលមាននៅប្រាសាទបាយ័ននេះ សុទ្ធតែជា ក្បាច់យ៉ាងល្អៗ, ដូចក្បាច់នៅអមសងខាងទ្វារ បង្កួចនឹងក្រោមទ្វារ នៅស៊ុមទ្វារ ឬ ហោជាង អាចទាញភ្នែកអ្នកមើលឱ្យឈរចំឈរមើល មាន អាការហាក់ដូចជាទទួលអ្នកដំណើរគ្រប់គ្នា ។ ទីបាយ័នខាងលើ បើឃើញ



៣ ប្រះថែវទិសខាងជើង ប្រាសាទបាយ័ន

( ការរូបថត ត. ស. ប. )

បានមើលក្នុងវេលាដែលព្រះអាទិត្យទៀបអស្តង្គត ទុំក៏រឹតតែល្អមើលណាស់ដែរ ព្រោះប្រាសាទទាំងអស់ ហាក់ដូចជាផុសលេចចេញមកអំពីព្រៃព្រឹក្សាលតាជាតិ កាលពន្លឺព្រះអាទិត្យចាំងមកប៉ះក៏លេចចេញមុខលោកេស្វរៈហាង ញញឹមពព្រាយគ្រប់មុខមកទទួលភ្ញៀវទាំងអស់គ្នា ។

លុះមើលសព្វគ្រប់ហើយ ត្រូវចុះទៅតាមផ្លូវខាងជើង, ត្រូវទៀតចូលមើលព្រះពុទ្ធរូបធំនៅទិសខាងកើត, តាមថ្នល់ខាងត្បូងដែរ, តទៅខាងលិចបន្តិច មានចេតិយជាទីរឭកដល់លោក ជ. កុម្មៃយ៍ (J. Commaille) ស្លាប់ដោយចោរប្លន់ក្នុងកាលអាយុ ៤៨ ឆ្នាំ នៅថ្ងៃ ៣០ ខែអាព្រិល ឆ្នាំ ១៩១៦; តាមផ្លូវខាងលិចប្រាសាទបាយ័ន មានសិលាចារឹកនិយាយអំពីគ្រឹះតាស់មុននគរធំ ដោយហេតុនេះ បានជាគេជឿនៀង[1] នគរធំនេះ; តពីចេតិយលោក ជ. កុម្មៃយ៍ ប្រហែល ២០០ ម៉ែត្រមកដល់ផ្នូរលោកការប៉ូ (Carpeau) ស្លាប់ក្នុងឆ្នាំ ១៩០៤ ដោយកើតគ្រុនចាញ់, លោកនេះជាជាតិបារាំងសែសម្នាក់ ដែលខ្នះខ្នែងក្នុងការស្រាវជ្រាវរឿងក្នុងនគរធំ; តមកទៀត ២៨ ម៉ែត្រ, ទៀងខាងទិសពាយ័ព្យ មកដល់ឃ្លាំងសម្រាប់ដាក់របស់បុរាណ ដែលគេរើសយកមកពីគល់ទុក, នៅឃ្លាំងនេះមានរូបចម្លាក់ប្លែកៗ គួរទៅពិនិត្យមើល មានរូបខ្លះគេមិនទាន់ស្គាល់ថាជារូបអ្វីនៅឡើយ, នៅខាងជើងប្រាសាទបាយ័ន

មានទីវត្តចាស់មួយ មានសទ្ទឹកសីមា មានព្រះពុទ្ធរូបធំមួយអង្គ, ខាងមុខ មានព្រះពុទ្ធរូបចូលនិព្វានកង់ស័ក្តិសម, វិហារឈើនេះ គេទើបនឹងធ្វើថ្មីទេ ដើម្បីនឹងគ្របលើព្រះពុទ្ធរូបនេះ ។



រឿងចម្បាំងព្រះរាមនឹងរាពណ៍ គោបុរៈខាងជើង កំពែងទី ២
យ៉ាងកើត មុខខាងជើង ប្រាសាទបាពួន

(តាមរូបថត ស. ប. ប.)

## ប្រាសាទបាពួន

លុះបានមើលប្រាសាទបាយ័នទាំងអស់សព្វគ្រប់ ដែលនៅជុំវិញប្រាសាទប្រែស្រេចហើយ ត្រូវចេញទៅតាមផ្លូវដ៏ធំទៅលើព្រះលានតែបន្តិច ប្រមាណ ២០០ ម៉ែត្រត្រូវឈប់ ហើយចុះពីរថយន្ត, ត្រង់កន្លែងក្នុងមើលទៅខាងលិចនឹងឃើញប្រាសាទបាពួនដ៏ខ្ពស់ស្កឹមស្កៃ ចុះដើរទៅខាងលិចបន្តិចនឹងដល់គោបុរៈ (ខ្លោងទ្វារ) ទី ១ ជាខ្លោងទ្វារធំខាងកើត មានកំពែងព្រួតជាយខ្លោងទ្វារ ជាប់ត្រដើមពីព្រះលានដែលស្ថិតនៅខាងជើង ខ្លោងទ្វារធំនេះ បាក់បែកអស់ហើយ នៅសល់តែសសរប្រង, ចូលត្រង់កាត់សំដៅទៅខាងលិច ដើរលើស្ពានថ្មដែលបាក់បែកត្រង់តែមានបន្តល់ថ្មរៀងគ្នា ក្រាលថ្មមួយសន្លឹកៗជាប់គ្នា ប្រ-មាណ ៣០០ ម៉ែត្រហួតទៅដល់គោបុរៈទី ២ គឺខ្លោងទ្វារកំពែងក្រៅខ្លោងទ្វារនេះ ជាប្រាង្គខ្ពស់ទៀងហើយមានយ៉ាយបេញទៅ ៤ ទិស, ផុតខ្លោងទ្វារចូលទៅមានស្ពានទៀត, តែស្ពាននេះបាក់ហើយ នៅសល់តែបន្តល់ថ្ម បាក់សន្លឹកថ្មក្រាលអស់ ផុតពីស្ពានផុតទៅដល់គោបុរៈទី ៣ នៅខ្លោងទ្វារនេះ មានកេងចងជាកំពែងព័ទ្ធជុំវិញ, ផុតពីទៅដល់ថ្នាក់ទី ១ ដែលត្រូវឡើងទៅកាន់ថ្នាក់ទី ២ ត្រូវដើររៀបតាមគ្រប់ប្រាសាទទៅដល់ជណ្ដើរខាងត្បូង ជណ្ដើរនេះចោតបន្តិចតែស្រួលឡើង ។ ថ្នាក់ទី ២ នេះមាន

កំពែង ប្រកបខ្លោងទ្វារព័ទ្ធជុំវិញប្រាសាទធំ ដែលបាក់បែករលំអស់ហើយ, នៅសល់តែខ្លោងទ្វារគ្រប់ទិស ឃើញមានរូបចម្លាក់រឿងរាមកេរ្តិ៍និងមហាភារតៈខ្លះ ផ្សំនឹងរឿងខ្មែរសម័យនគរ ។

## គោបុរៈខាងត្បូង

មុខខាងត្បូង ប៉ែកខាងលិច: ដំណាលអំពីក្រឹស្នៈកាលនៅជាកុមារ ភាគខាងក្រោម ខាងឆ្វេង ថ្លែងពីការសម្លាប់កុមារ, ក្រឹស្នៈកាប់ខាងក្បាល ៦ ជាពីរកំណាត់ ។

មុខខាងត្បូង ប៉ែកខាងកើត: និយាយពីរឿងចម្បាំង, ឥសីនិងជ្រកព្រៃ, សេនាទាហាននិងយក្ខ, ឥសីអង្គុយក្រោមដើមឈើ ដៃកាន់ក្បាលដាច់ក ដែលត្រូវសរ ។

មុខខាងជើង ប៉ែកខាងកើត: រឿងរាមកេរ្តិ៍, ស្វាសម្ពន្ធមិត្រព្រះរាម ច្បាំងតតាំងនឹងយក្ខ, គេស្គាល់បានដោយក្តែក្រចៀកនិងសក់ក្រញាញ់; ភាគខាងលើ, នាងសីតាស្ថិតនៅក្នុងព្រៃអសោក មានយក្ខិនីពីរនាក់ថែរក្សា ព្រះនាងទទួលហនុមាណដែលព្រះរាមបញ្ជូនមក; ភាគខាងក្រោម មិនច្បាស់ជារឿងអ្វី ដូចឥសីកូរទឹកក្នុងពាង ដំណាងកូរសមុទ្រទឹកដោះ, មនុស្សឈើ និងព្រះវិស្ណុ ... ។

មុខខាងជើង ប៉ែកខាងលិច: ចម្បាំងមនុស្សនិងសត្វ, និងរឿងទៅក្នុងព្រៃ... ។

# គោបុរៈខាងកើត

មុខខាងកើត យ៉ាខាងត្បូង ; ឡើងមកក្រី ; នៅថ្នាក់ពីខាងលើ ហោត ហ៊ីណ្ហត់តទ្បល់ជា រូបមួយជាព្រះរាម , មួយទៀតនាងសីតា ប្រយ៉ប់នៅ កណ្ដាលព្រៃព្រឹក្សា ; នៅថ្នាក់ទី ៣ ការជុតនាងសីតា ព្រោះយ៉ញនាង សីតាស្ទុះនៅកណ្ដាលភ្លក់ភ្លើង ដែលប្រណាម្យស្មើនឹងព្រះសិរ ។ ខាងស្ដាំ ទេពតាឈ្មោះអគ្គិចូលទៅកេព្រះរាម ធ្វើជាសាក្សីនិយាយពីសេចក្ដីបរិសុទ្ធិ នៃនាងសីតា ; មហាស្មុរ : ( ព្រះឥស្វរ ) ជិះគោហែហមដោយបរិពារ ស្ដេច ទតព្រះនេត្រឡើងនេះ ; ភាគខាងក្រោម ព្រះរាមនាងសីតា ស្វាម៉ក់យោ នៅជួបជុំគ្នា ; ភាគខាងក្រោម មានឡើងស្ត្រីជំនិត មានគេប្រដាប់ទីនៃ កាយទ្បូ , គទៅទៀត ឡើងចម្បាំង ។

មុខខាងកើត យ៉ាខាងជើង : ឡើងសេនាធិបាលក្មួនឡើងមហាការក , គេមើលឃើញមេធាបាលត្រូវសម្លាក់ពីលើនេះ រូបនេះគឺហោកមេទ័ព ពួកកៅរវៈឈ្មោះតិស្ស : ខាងក្រោម , សេនាធិបាលស្ពានក្ដី : នៅស៊ុម ផ្ការ មានមនុស្សសំពត់ស្រីម្នាក់ ស្រីនេះប្រហែលជាមាងក្រោតចា ។

មុខខាងលិច យ៉ាខាងជើង : ខាងក្រោម , គេឃើញកង់ពិតៈទៅតាមដំរី ថែលមួយជ្រុំង ; ភាគលើ ពួកសំអិន្ទ្រយក្រោមដើមឈើ , នៅខាងត្បូង ស្រីម្នាក់ត្រូវសរ ។

# គោបុរៈខាងជើង

មុខខាងជើង យ៉ាងខាងកើត. រឿងរាមកេរ្តិ៍, លោកហ្វ៊ីណូត៍សរសេរថាៈ នៅផ្ទៃខាងលើ, ភពណ៍ឈរលើព្រះកដេវ ច្បាំងតតាំងនឹងព្រះរាម, ព្រះរាមជិះលើហនុមាន ច្បាំងក៏យកសេះទឹមរថភពណ៍ឲ្យធ្លាក់ក, ការច្បាំងនេះក្តៅក្រហាយណាស់ ព្រោះនៅផ្ទៃខាងក្រោម ឃើញហនុមានលោតទៅលើរថភពណ៍ ដែលទឹមដោយមករក្បាលជាមនុស្ស; ផ្ទៃខាងក្រោមទៀត, ព្រះរាមយកធ្នូបាញ់បក្ខាម៉ក្រ ៗ នៅផ្ទៃខាងលើមានរឿងខ្វះទៀត, ទំលាយពិស្ដារនិយមក្ខុបរាំងគ្នា, នៅផ្ទៃកណ្ដាល លោកហ្វ៊ីណូត៍គន្យល់ថា: នាងសីតាដែលភពណ៍លួចយកទៅលាក់ទុកក្នុងប្រាសាទ, នាងគង់នៅក្នុងព្រៃអសោក, ខាងឆ្វេង ពួកយក្ខិនីនៅចាំថែរក្សា, ខាងស្តាំ គាលហនុមានស្ទើរកព្រះនាង បានជួបនឹងព្រះនាង ក្រាបទូលអំពីរឿងព្រះរាមជាព្រះជស្វាមី, បញ្ជាំនៅដៃហនុមាននោះ គឺចិញ្ចៀនដែលនាងសីតាផ្ញើទៅថ្វាយព្រះរាម ជាតស្មគាល់ឲ្យដឹងថា ហនុមានបានជួបនឹងព្រះនាងសីតាហើយ; ផ្ទៃក្រោម, ព្រះរាមជិះរថទឹមដោយសេះក្បាលមនុស្ស បាញ់សរព្រោងព្រាត ៗ

មុខខាងជើង យ៉ាងខាងលិច: ភាគខាងលើ ទ័ពមាក់បរជ័រទៅប្រជល់គ្នា, រឿងកូរទឹកក្នុងកាងជាតំណាងកូរសមុទ្រទឹកដោះ; ខាងក្រោម, រឿង

ព្រះរាមនិងព្រះលក្ស្មណ៍ ចងស្ពានមេត្រីនឹងសុគ្រីពតាវលុតដក្តីធំទៅគេ ពាលីដែលត្រូវសរ, នៅទានក្រោម, បង្កាំងសុគ្រីពនឹងពាលី ឃើញ ពាលីស្លាប់ ។ នៅទានីឆ្នេរ វែរទៅទានីស៊ុំមហាត្រ មានរឿងកម្មរក្តី ទៀត, លោកហនុមានច្បាស់ថា: កាលច្បាំងនៅក្រុងលង្កា បុត្រកាណ៍ មាត់សែកបន្ត ចាញ់សរសំដៅទៅព្រះរាមនិងព្រះលក្ស្មណ៍ហើយក្លាយ ទៅជាពស់ រុំព័ទ្ធព្រះរាមនិងព្រះលក្ស្មណ៍ដួលដេកទៅលើផែនពសុធា ហើយមាននាគទាហានពាមកេមជាបរិការ; គេមើលឃើញស្មាដែលនៅ ត្រូវកេដើមឈើធ្វើជាថ្នាំ នៅក្នុងសមុទ្រទឹកដោះ ដើម្បីនឹងយកមករំដោះ ព្រះរាមនិងព្រះលក្ស្មណ៍ឲ្យរស់ឡើងវិញ, ក្នុងកាលនោះ, នៅលើអាកាស ឃើញគរុឌយកមកប្រកបខ្យល់ព្យុះ ពីត្រូវកត្តដែលបោះដៃក្នុងមួយដំ- ណាំថៃ ឯពស់ឃើញគ្រុឌមកដូច្នោះ ក៏ភ័យហើយបោះរត់ទៅវិញបាត់ អស់, គ្រុឌយកដៃស្ទាបស្ទាបរបួសព្រះរាមព្រះលក្ស្មណ៍ធ្វើឲ្យជាឡើងវិញ; គេមើលឃើញព្រះរាមនិងព្រះលក្ស្មណ៍ដែលមានជន្មាយុហើយ និយាយ គ្នាជាមួយនឹងគ្រុឌគតដៃ, នៅទានលើ ឃើញហនុមានបោះទៅព្រៃស ហនុមាននេះជំណាន់ដែលបុស្សកដែលយើងឃើញនៅខាងក្រោ (ដំណាក់ព្យុះ លុះហើយក្រុងលង្កាឈ្នះហើយ, ព្រះរាមលើកកងទ័ពយាត្រាត្រឡប់មក កាន់ក្រុងអយុធ្យា ព្រមដោយសេហាពលសកលយោធាវិញ ។

មុខខាងត្បូង យំខាងលិច: រឿងចម្រាំងនៃសេចក្ដីអាហារ ដែល មានសត្វតាហានទៅជាមួយផង, ទៅកៀន, ឃើញខាងសំពាសក្ដីយទៅ គន្ធក្រៃសោកទៀត ។

មុខខាងត្បូង យំខាងកើត: ប្រហែលជារឿងកម្មគ្រែទៀត ខាង ស្ដាំ ឃើញសេះ នៅជើងសេះឃើញខ្សែយោល ។

## គោបុះខាងលិច

មុខខាងលិច យំខាងជើង: ស្វាន់ដ៏យក្ខចម្បាំងគ្នា រឿងចម្បាំង ផ្សេងៗ ។

មុខខាងលិច យំខាងត្បូង: មានមនុស្សបាញ់យកួសក់ក្រញាញ់, តាហានម្នាក់ៈលានទៅលើបញ្ចាម៉ែត្រ ចាប់សក់ទាញហើយសម្លាប់ចោល, ខាងក្រោម អ្នកលេងក្ដីង, នៅខាងត្បូង ដូចជាមនុស្សទាំងពីរកម្នាក់ ចាប់ដៃគ្នា ។

មុខខាងកើត យំខាងត្បូង: ចម្បាំងសត្វ, ខាងលើឃើញសេះ, គម្រក ស្វាន់ងីតាហានចម្បាំងគ្នា; រឿងល្អមើល, ឃើញមនុស្សម្នាក់ស្លៀក បួសផ្លូវ មានដំរីតូចមួយចាំប្រចាំខាងក្រោម ។

មុខខាងកើត យំខាងជើង: រឿងចម្បាំងផ្សេងៗ ។

ដើម្បីនឹងរៀនទៅចាក់លើបន្ទាស់ ត្រូវរៀនតាមដំណើរនៅទិស ខាងត្បូង ព្រោះមានដំណើរកោតដ្ឋិទៀត ស្រួលរៀនមិនមានគ្រោះថ្នាក់

ឡើយ ៗ ទ្វារនឹងកំពែងទាំងជុំវិញ បាក់ធ្លាក់អស់ហើយ, ឯប្រាសាទកណ្ដាលក៏រលំអស់ហើយដែរ កាលពីដើមមានដើមជ្រៃមួយដុះនៅពីលើកំពូលស្ដាយណាស់ បើប្រសិនណាជាបានថែរក្សានៅសមនឹងល្អណាស់ ៗ តាមអ្នកដំណើរចិនឈ្មោះចៅតាក្វាន់, កាលពីសតវត្សរ៍ទី ១៨ នៃពុទ្ធ-សករាជ និយាយថា "ប្រាសាទបាពួននេះល្អណាស់ កំពូលស្រោបដោយស្ពាន់ក្តីផ្ទុក មើលទៅឃើញល្អអស្ចារ្យ" ៗ

ពិតមែន, ប្រាសាទបាពួននេះ ជាក្រុងទី ៣ មុននគរធំ, កាលពីដើមឈ្មោះ ហេមាទ្រិ "ភ្នំមាស" សមដូចពាក្យអ្នកដំណើរចិន ៗ កាលណាបើគេបានឡើងទៅដល់ថ្នាក់លើហើយ នឹងឃើញទិដ្ឋភាពល្អពិត ធំទូលាយស្រុកស្អាតសំបើម កន្ទួលដូចព្រៃស្លាបដូចគេ ដូចជាផុសកណ្ដាលព្រៃព្រឹក្សា មើលទៅទិសខាងជើងឃើញប្រាសាទវិមានអាកាស ទៅទិសកើតឃើញទីព្រះលាន ៗ តាមសិលាចារឹក, ប្រាសាទបាពួននេះ ព្រះបាទឧទយាទិត្យវរ្ម័នទី ២ ទ្រង់កសាងក្នុងសតវត្សរ៍ទី ១៧ នៃពុទ្ធសករាជ (គ.ស. ១០៦០) ដើម្បីទុកសម្រាប់ទេពតាខាងសាសនាព្រាហ្មណ៍ ឈ្មោះ ហេមស្រីង្គេស្វរៈ ប្រែថា "ទេពតាដ៏មានស្នែងមាស" ៗ កាលពីមុន, មានព្រះពុទ្ធរូបចូលនិព្វាន ប្រហែលជាកាលតមក, អ្នកសាសនាពុទ្ធហ៊ានយកមកតម្កល់ទុក ៗ

លុះមើលរួចហើយ ត្រូវចុះមកវិញតាមជណ្ដើរខាងត្បូង ដល់មកថ្នាក់ខាងក្រោម សឹមបត់មកខាងកើត តាមទ្វារធំខាងកើត ហើយដើរកាត់ទៅខាងជើង តាមផ្លូវជើងសៀវតាមកំពែងប្រាសាទបាពួននិងវិមានអាកាស ធ្លងកំពែងនេះចំទៅខាងជើង តំរង់ទៅប្រាសាទវិមានអាកាស ។ បើពុំនោះ ត្រូវត្រឡប់មកទីព្រះលានខាងកើតវិញក៏បាន ដើរបត់ទៅខាងជើងព្រះលានរហូតទៅដល់ទ្វារធំ សឹមចូលទៅមើលផ្ទៃព្រះរាជវាំង ឬវិមានអាកាសក៏បាន ។

## ទីលានជល់ដំរី វិមានអាកាស

នៅខាងជើងប្រាសាទបាពួនបន្តិច ជាស្ថានព្រះរាជវាំង មានកំពែងថ្មបាយក្រៀមពីរជាន់ ពីខាងកើតទៅខាងលិចចំនួន ៦០០ ម៉ែត្រ ពីខាងត្បូងទៅខាងជើងចំនួន ៣០០ ម៉ែត្រ ។ មានអ្នកខ្លះគាត់ច្រឡំថា ខាងក្នុងកំពែងពីរជាន់នេះ គេហៅវិមានអាកាស (អាកាសវិមាន?). សេចក្ដីនេះមិនត្រូវទេឡើយ ផ្ទៃទាំងមូលនេះហៅថា ព្រះរាជវាំង, ដែលហៅថាវិមានអាកាសនោះ ចំពោះតែប្រាសាទមួយដែលស្ថិតនៅក្នុងផ្ទៃព្រះរាជ-វាំងនោះប៉ុណ្ណោះទេ ។ កំពែងទាំងពីរជាន់នេះ កំពែងខាងក្រៅមិនសូវមាំមួន បាក់បែកខ្ទះខ្ទាយជាច្រើនកន្លែង, ខាងកើតជាប់គ្នានឹងព្រះលានដែលកាត់បណ្ដោយតាំងពីខាងមុខប្រាសាទបាពួន រហូតដល់ទីលានស្ដេចគំលង់, កំពែងខាងក្នុងមិនបាក់បែកទៅឡើយ ព្រោះការកសាងមាំដោយការពិនិត្យពិច័យ, កំពស់ ៦ ម៉ែត្រ ព្រមទាំងមានចន្លុះផង; នៅចន្លោះកំ-ពែងទាំងពីរនេះ មានស្រះមួយមានជណ្ដើរជាថ្នាក់ៗចុះទៅ ។ ទ្វារសម្រាប់ចូលទៅកាន់ផ្ទៃព្រះរាជវាំងនេះមាន ៥, ទ្វារពីរចូលពីខាងត្បូង, ពីរពីខាងជើង, មួយពីខាងកើត, ទ្វារទាំង ៥ កន្លែងនេះ សុទ្ធសឹងប្រកបដោយកំពូលជាតួប្រាសាទដ៏មានក្បាច់ចនាពិចិត្រ; មុខព្រះលានទទឹង ១៤ ម៉ែត្រ បណ្ដោយ ៣៥០ ម៉ែត្រ ជាទីខ្ពស់ មានជណ្ដើរទាបៗ

ឡើងចំពីខាងកើតត្រង់កន្លែងល័យចេញទៅមុខ ។ តាមអ្នកដំណើរចិនឈ្មោះចៅតាក្វាន់និយាយថា: "ទីព្រះលាននេះ ជាទីប្រជុំគណៈជួមគ្រី ជាធម្មតា ឬការលេងនេះពិធីបុណ្យផ្សេងៗ, មានក្របបង្អួចមាស មានកញ្ចក់ច្រើននៅជុំវិញបង្អួច ក៏ផ្ទុកៗ, នៅខាងក្រោម មានដំរីជាច្រើនឈរជាជួរវៀងកាយ", ដូចយើងមើលឃើញរូបនៅទីលានសព្វថ្ងៃនេះ ។

ទីលាននេះ មានទីល័យចេញមកខាងកើតជាកន្លែង ទីល័យ៣ កន្លែងនៅត្រង់ទីកណ្ដាល, ពីរទៀតនៅទីបំផុតសងខាង នៅត្រង់កើយនៃទីល័យបំផុតខាងសងខាង មានចម្លាក់ជារូបដំរីកាន់ផ្កាឈូក, ត្រង់កើយទីល័យកណ្ដាល មានចម្លាក់រលេចជារូបគ្រុឌទ្រទីនោះ, ត្រង់កើយទីល័យតូចៗទាំងសងខាង មានចម្លាក់រលេចជារូបដំរីដែរ ។ នៅទីល័យខាងជើង មានចម្លាក់ជារូបសេះក្បាល៥, ត្រង់ទីល័យខាងជើងនេះ, ត្រូវពិនិត្យមើលផង ព្រោះមានរូបល្បែងផ្សេងៗ ដែលគេពីសព្វថ្ងៃនេះ ។ តាមលោក ហ. មាំរសាល់ លោកសរសេរថា: "ទីលាននេះមានការរុះរើនឹងការកសាងបន្ថែមជាច្រើនដង ដោយព្រះរាជាដែលគ្រងរាជ្យតៗគ្នា" ។

មុខព្រះលាននេះ ជាទីសប្បាយមួយកន្លែង រីឯបរិកកាយធ្វើឲ្យគាប់ចិត្ត មានសត្វសីហៈជាឆ្មាំយាម, មានបង្កាន់ដៃដាក់ សមជាទីទតព្រះនេត្រព្រះរាជាមែនៗ ។ ត្រូវមើលពេលព្រឹកឬពេលល្ងាចដែលត្រជាក់, សព្វថ្ងៃ

នេះ មានដើមឈើធំៗ មានម្លប់ត្រឈៃ មើលទៅខាងកើត មានវាលន ស្រឡះ; តទៅខាងជើង គេឃើញប្រាសាទព្រះពិធូ ខាងកើតឃើញឃ្លាំង, សួព្រ័ត្រ ស្ថិតជាជួរវៀងគ្នាក្នុងកណ្ដាលវាលព្រៃ មើលទៅឃើញកូតៗ

លុះបានមើលវាលនរួចហើយ ត្រឡប់ទៅតាមគោបុរៈខាងកើត ដើម្បីទៅមើលវិមានអាកាស, នៅគោបុរៈនេះ មានសិលាចារឹក ៨ ប្រការ ជាក្រឹត្យសំបថ ដែលពួកនាម៉ឺនមុខមន្ត្រីត្រៃគោរពប្រតិបត្តិចំពោះម្ចាស់ផែនដី, សិលាចារឹកនេះ ព្រះបាទសូរ្យវរ្ម័នទី១ ទ្រង់កសាង គឺឆ្នាំ ១៥៥៤ នៃពុទ្ធសករាជ; ក្រឹត្យនេះ មានបទខ្លះគេប្រើក្នុងពេលបុណ្យតាំងទឹកសព្ទ ថ្ងៃនេះដែរ ។ នៅក្នុងព្រះរាជវាំងនេះ មិនឃើញមានអ្វីទៅសល់ទេ ព្រះរាជដំណាក់ឬគេហស្ថាននៃព្រះរាជអគ្គមហេសី ឬស្រីស្នំក្រមការកំ រិងាសអន្តរាយបាត់អស់ហើយ នៅសល់តែកន្លែងខ្លះដែលគេអាចសន្និដ្ឋានបាន លោក ហ. ម៉ាសាល់ លោកសរសេរថា: "គឺនៃក្នុងព្រះរាជវាំងនេះ គេអាចចែកចេញជា ៤ កន្លែង តាំងពីខាងកើតទៅទល់ខាងលិច សម្រាប់ជាលំនៅនៃព្រះជាម្ចាស់ផែនដី, ព្រះអគ្គមហេសី, ព្រះរាជបរិវារ រៀងរហូតដល់អ្នកស្រែការថ្មើរជាទីបំផុត ។

កន្លែងទី១ នៅទិសអាគ្នេយ៍ ចំនួន ៧០ ម៉ែត្រ, មានប្រាសាទតូចមួយ ពិតបេះនៅឡើយ ប្រហែលជាធម្មមន្ទីរ ក្រៅពីនោះប្រហែលជាកន្លែងធ្វើការរាជការ, ជាឃ្លាំង... តែឥឡូវនេះបាក់បែកអស់ហើយ ។

កន្លែងទី ២ ចំនួន ៦៨០ ម៉ែត្រ, មានកំពែងថ្មបាយក្រៀមឃាំងខាងកើត, គេអាចសន្និដ្ឋានបានថា កន្លែងនេះជាកន្លែងសំខាន់ ប្រហែលជាព្រះរាជដំណាក់? កន្លែងឥតពីនេះ ជាទីប្រតិស្ឋាននៃប្រាសាទវិហារអាកាស ។ ប្រាសាទវិហារអាកាសនេះ មាន ៣ ថ្នាក់ មានសណ្ឋានដូចប្រាសាទប្រទេសអស្ស៊ីរី (Assyrie) បុរាណ ឬដូចប្រាសាទបុរាណខ្លះនៅលង្កា-ទ្វីប, នៅថ្នាក់លើបង្អស់ គេសាងជាកន្លែងទ្វារកាត់ខ្វែង ជាក្រឡាចត្រង្គមានមុខជាយ៉ាងចេញទៅទាំង ៤ ទិស, តាមខាងលើនៃប្រាសាទនេះ បាក់បែកអស់ហើយ, គេសាងពីថ្មបាយក្រៀមនិងថ្មប្រផេះ ។ នៅត្រង់កណ្តាលនៃប្រាសាទនេះ ស្តេចទ្រង់តែងក្រសាលជាមួយនឹងនាងនាគីកាលដែលនាងនាគីឡើងមកម្តងៗ, ដែលនាងនាគីឡើងមកម្តងៗនេះ តាមពាក្យនិយាយថា ស្រុកទេសនឹងខានសិរីសួស្តីគ្រប់ពេល ។ តាមសិលាចារឹកថា: "ប្រាសាទនេះ គេសាងឧទ្ទិសថ្វាយព្រះវិស្ណុ ក្នុងរវាង គ.ស. ១៦៨៣" ។ អ្នកដំណើរចិនបាននិយាយថា: "ប្រាសាទនេះជាប្រាសាទមាស ដូចគ្នានឹងប្រាសាទបាពួនដែរ," តែសព្វថ្ងៃមិនឃើញមានអ្វីទេ, តាមជណ្តើរគ្រប់ថ្នាក់មានសិង្ហៈជាទ្វារបាល នៅជ្រុងអនុទិសមានដំរី; បើចង់ឡើងមើលត្រូវឡើងតាមជណ្តើរខាងលិច ព្រោះមានតែជណ្តើរខ្លះគេទើបធ្វើថ្មី ។ នៅខាងជើងប្រហែល ៩០ ម៉ែត្រឆ្ងាយ មានស្រះមួយទ្រង់

៤ ជ្រុងទ្រវែង, ខាងត្បូងមានក្លុងសំដាំងខាងជើង មានផ្ទាក់ជារូបផ្សេងៗ នៅជិតមាត់ទឹក មានចម្លាក់ជារូបច្រើ ឬសត្វទឹកជាច្រើន, នៅខាងលើ មានរូបខាង ខាងខាងជើងរូបពស់ជាច្រើន មានមករ ត្រី, ទួរទៀត គេ ឆ្លាក់ហាក់ដូចជាចេញមកពីក្នុងថ្ម ។ នៅទិសអាគ្នេយ៍នៃវិមានអាកាស មាន ទីវួលខ្ពស់ មានប្រាសាទកាត់វិទ្ធជាក្រឡាចត្រង្គ ប្រហែលជាកន្លែង ដែលស្ដេចទ្រង់ទទួលសព្វមុខមន្ត្រី ជញ្ជាំងប្រាសាទនេះ មានសសរ មូលទ្រទ្រង់ផ្សេងៗខាងក្រៅ. នៅចន្លោះប្រាសាទនេះនិងទ្វារខាងត្បូង មានប្រាសាទតូច ៤ កន្លងជ្រុងទ្រវែង មានទ្វារចូលតែពីខាងលិច, ប្រាសាទតូចៗនេះ គេធ្វើសុទ្ធតែពីថ្ម ជាបាយក្រៀមនិងថ្មបបែរ ។ អ្នកស្រុកនគរគេជឿថា: "កន្លែងនេះ ជាឃ្លាំងសម្រាប់ដាក់របស់មាន ដំរៃ" ។

កន្លែងទី ៣ ចំនួន ៧០០ ម៉ែត្រ, ចែកជាផែកតូចច្រើនផែក ចំណែក ខាងត្បូង ជាកន្លែងនៃស្រះ, ផ្ទះបាយ; គេហៅទៀត ជាដំណាក់, ស្ទួន ច្បារនៃព្រះអគ្គមហេសី និងស្នំស្រ្តីមការ, នៅខាងលិចត្រង់ពីស្រះធំ មានស្រះមួយទៀត ប្រកបដោយដំណើរនិងក្រាលថ្មជុំវិញ ។ តាម ពិនិត្យមើល កន្លែងទី ៣ នេះ មិនមានទ្វារចេញចំមកខាងក្រៅទៀយ, មានច្រឡាយទឹកមួយជាប់ពីស្រះ ចេញមកស្រះដែលនៅចន្លោះកំពែង

ចាំងពីរ ។ ទីកន្លែងជាព័ស្តុតាងពីរទៀត ជាការពិបាកមិនអាចនឹងពន្យល់ ឲ្យឆ្ងាយបានឡើយ ។

បើត្រូវការចេញទៅតាមទ្វារខាងលិចនៃកំពែងខាងជើង មាន ផ្លូវមួយកាត់ចំទៅប្រាសាទបាលិលេយ្យ ហើយគេអាចចេញមកលើព្រះ ទេពប្រណម្យ ដើរហូតមកដល់ទីលានស្ដេចគំលង់, បើពុំនោះ ត្រូវ ថយក្រោយមកវិញ ហើយចេញតាមទ្វារធំខាងកើត មកលើមុខព្រះ លានដើរបត់ទៅខាងជើង ទៅមើលទីលានស្ដេចគំលង់ក៏បាន ។

## ទីព្រះលានស្តេចគំលង់

លុះមើលទីលានរួចហើយ ត្រូវបត់ទៅខាងជើងបន្តិច គេនឹងឃើញរូបស្តេចគំលង់អង្គុយបញ្ឈរជង្គង់ម្ខាង ដៃទាំងពីរដាក់លើក្បាលជង្គង់ទាំងសងខាង ៗ ទីលានស្តេចគំលង់នេះ ជាកន្លែងខ្ពស់ជាងគេ ទំនងកាលពីដើមប្រហែលជាស្ពានសម្រាប់ចុះទៅកាន់ស្រះ ដូចគ្នានឹងស្ពានស្រះស្រង់។ ព្រោះទីលានចេញទៅខាងជើងបិតថេរនៅឡើយ ទីលានខាងត្បូងរាបស្មើហើយ, ទីលានខាងជើងដែលនៅសល់នោះ ឃើញមានរូបចម្លាក់សត្វទឹកធ្វើល្អមើលណាស់ដែរ, មានរៀងស្តេចប្រថាប់ក្រសាលក្នុងប្រាសាទ ដូចគ្នានឹងរូបចម្លាក់នៅប្រាសាទបាយ័ន ខ្លះលេងល្បែងពោះគង់ចក្រ លេងលេបដាវ ត្រីនាគក្បាល ៦ ជាដើម; លោក ហ. ប៉ារម៉ង់ទេ (H Parmentier) លោកថា: "ជាស្រះធំដែរ តែព្រះបាទជ័យវរ្ម័នទីលាយចោល ក្នុងកាលធ្វើទីលាន គ.ស. ១៧៦៤–១៧៦៣" ។ ទៅដល់ហើយ, អ្នកមើលត្រូវចូលតាមច្រកតូចនៅខាងត្បូង មានស្នាមជើងគេដើរទៅតៗ មានកំផែងទាំងពីរខាង ដើរបត់ចុះបត់ឡើងជាច្រើនជាន់, កាលកំពុងដើរមើល ហាក់ដូចជាស្ទើរខ្លាចរកផ្លូវចេញ, ព្រោះរូបនាគ រូបត្រី រូបយក្ស រូបស្រីទេពអប្សរកញ្ញាដោះចចើល នៅក្បែរទន្ទឹងពោះយើង, បន្តិចទៅទៀត មានជណ្តើរជាថ្នាក់ឡើងទៅខាងលើ

មកដល់ស្តេចគំលង់ ៗ រូបនេះ នៅមានប្រស្នាដែលគ្នាច្រើនប្រការ ណាស់, តាមខ្មែរយើងនិយាយគ្នាថា: "ស្តេចនេះ គឺព្រះបាទយសោវរ្ម័ន ស្តេចកើតរោគឃ្លង់ហើយទ្រង់ទំរង់គេទៅជាយ៉ាងនេះ," តាមពិត, សព្វថ្ងៃនេះ យើងទាំងអស់គ្នាក៏ អ្នកប្រាជ្ញបារាំងមានលោក ជ. គ្មៃ ជាដើម ក៏ បានពិនិត្យមើលមិនឃើញមានហេតុអ្វីនៅរូបនោះសោះ ជាភស្តុតាង ស្មមថាកើតរោគឃ្លង់មែន, អ្នកប្រាជ្ញបារាំងខ្លះ ដូចលោក ហ. ម៉ាំរសាល់ លោកថាជារូបឥសីចំរើនឈាន ៗ តាមសៀវភៅលោក ហ. បាំរម៉ង់ទេរ លោកថា: "មានសិលាចារឹកនៅជើងសសរខាងក្រោម អាចកាត់សេចក្តី សង្ស័យដែលថាប្រស្នាដែលគ្នានេះបានថា: "រូបនេះជារូបយមរាជជាអ្នក កាត់ក្តីនៅស្ថាននរក" ៗ លុះដើរមើលរូបហើយ, ត្រូវចេញទៅតាម ច្រកទិសពាយ័ព្យ មានផ្លូវដើរកាត់ទៅតេបប្រណម្យ ៗ

## ព្រះទេពប្រណម្យ

ទេពប្រណម្យ ជាស្ថានវិហារពុទ្ធសាសនាបុរាណ បណ្ដោយ ៨៤ ម៉ែត្រ ទទឹង៣៤ម៉ែត្រ, នៅខាងលិចប្រតិស្ឋានព្រះពុទ្ធរូបធំមួយអង្គ ទ្រង់ស័ក្តិសម កំពស់៤ម៉ែត្រ ។ ជុំវិញ, តាមមើលទំនង, មានបង្កាន់ដៃនាគ សព្វថ្ងៃនេះ មិនឃើញមានអ្វីសល់នៅទេ ឃើញតែថ្មដែលគេក្រាលនៅកន្លែងនោះ, តទៅខាងលិចបន្តិច មានព្រះពុទ្ធរូប១អង្គទៀត ទ្រង់សណ្ឋានឈរទ្រង់ព្រះហស្តជាអភយមុទ្រ: បំណែកព្រះភក្ត្រវិនាសរកមិនឃើញ ។ នៅខាងលិចតទៅទៀត មានស្រះមួយធំ ក្នុងស្រះក្រាលថ្មជុំវិញផ្ទៃ ។ ទេពប្រណម្យនេះ តាមសិលាចារឹកនៅសសរបួនជ្រុងនិយាយថា: "ទីនេះ គេកសាងនៅទីបំផុតនៃសតវត្សរ៍ទី ១៨ នៃពុទ្ធសករាជ ដោយព្រះបាទយសោវរ្ម័ន, តាមលោក ហ. ប៉ារម៉ង់ទៀ លោកនិយាយថា: "សិលាចារឹកនេះ គេយកមកពីបាកយបុក្ខិស ដោយស្ដេចអង្គណាមួយដែលមានជំនឿផ្ទុយគ្នា ឯសិលាចារឹកដើមនុំវិនាសបាត់បង់ហើយ" ពាក្យនេះគួរជឿបាន ព្រោះព្រះបាទយសោវរ្ម័នមិនមែនជាពុទ្ធសាសនិកជនទេ ។ .

## ប្រាសាទបាលិលេយ្យ

តពីទេពប្រណម្យទៅ មានផ្លូវមួយចេញទៅខាងលិច ចំពោះទៅលើប្រាសាទព្រះបាលិលេយ្យ, ប្រាសាទព្រះបាលិលេយ្យនេះ, មានកំពែងថ្មបាយក្រៀមមួយជាន់ ចំនួន ៥០ ម៉ែត្រ ៤ ជ្រុង ខាងកើតមានទីលានពីរជាន់ លយចេញមកប្រទាក់គ្នាជាក្រឡាចត្រង្គ លានទីមួយទាប លយផុតចេញមកខាងកើត, លានទីពីរខ្ពស់ មានបង្កាន់ដៃនាគប៉ិតថេរនៅឡើយ មានលំអគួរចាប់ចិត្តអ្នកមើល ព្រោះជាចនាខ្មែរសុទ្ធ, ទីលានមួយៗ មានទ្វារបាលមួយគូនឹងសិង្ហៈមួយគូ; ផុតពីទីលាន មានទ្វារបាលមួយគូទៀតនឹងព្រះពុទ្ធរូបធំមួយអង្គ គង់ពែនភ្នែនព្រះបាទជាក្បួនមិស្សប៉ិមុទ្រះព្រះកេក្រញាញ់ ដូចសម័យទេពប្រណម្យដែរ ។

នៅគោបុរៈចូលពីខាងកើត មានទ្វារចូល ៣, គោបុរៈនេះ គេធ្វើលើទីខ្ពស់ ចំនួន ៧ ម៉ែត្រ ផុតមានក្បាច់ចម្លាក់ជាសំខាន់ទេ នៅហោជាង, មានរូបចម្លាក់ផ្នែកពុទ្ធសាសនាសុទ្ធ, តាមលោក ហ. ម៉ាសាល់ លោកថា៖ "រូបចម្លាក់នេះ ជារូបចម្លាក់ពុទ្ធសាសនាទេ ជាសាសនាព្រាហ្មណ៍ទេ", តែតាមពិតនិត្យមើល ខ្ញុំយល់ថា រូបចម្លាក់នៅហោជាងនេះ សុទ្ធតែរឿងពុទ្ធសាសនា ដូចមានតទៅនេះ៖



គោបុរៈទិសខាងកើតនៃប្រាសាទបាលិលេយ្យ
ការរចនាបែបប្រាសាទនគរវត្ត រវាង គ. ស. ១.៦៤០

( តាមរូបថត ព. ស. ប. )

## មុខខាងកើត

១ – នៅលើថ្នាក់កណ្ដាល ភាគលើ ព្រះពុទ្ធរូបទ្រង់សណ្ឋិតលើទ្រង់ព្រះហស្តជាអភយមុទ្រៈ មានមនុស្សទេពតានមស្សការជាបរិវារ, ភាគក្រោម ព្រះពុទ្ធទ្រង់ចូលព្រះនិព្វាន,

២ – នៅលើថ្នាក់ខាងជើង ព្រះពុទ្ធរូបគង់ពាក់ព្រៃវក្ខនៃពេនព្រះបាទ មានដំរីបាលិលេយ្យ នឹងសត្វស្វាកាន់ពុងថ្វាយទឹកឃ្មុំ,

៣ – នៅលើថ្នាក់ខាងត្បូង ព្រះពុទ្ធអង្គទ្រង់ទទួលភោជនាហារពីឈ្មួញពីរនាក់ គឺ តបុស្សៈនឹងភល្លិកៈ, នៅហោជាងខាងមុខខាងជើង, ភាគលើ រឿងមារវិជ័យ, ភាគក្រោម ទ្រង់ទូន្មានដំរីនាឡាគិរី ។

## មុខខាងលិច

១ – នៅលើថ្នាក់កណ្ដាល ថ្ងៃកាលព្រះពុទ្ធអង្គស្ដេចទៅជួបនាងពិម្ពាយសោធរា នឹងរាហុលកុមារ, មានដំរីបនីក្ខ,

២-នៅលើថ្នាក់ខាងជើង ព្រះពុទ្ធអង្គទទួលមធុបាយាសនាងសុជាតា,

៣ – នៅលើថ្នាក់ខាងត្បូង ព្រះពុទ្ធអង្គទ្រង់សំដែងធម៌ទេសនា

## នៅហោជាងខាងត្បូង

ព្រះពុទ្ធអង្គទ្រង់ស្ដេចទៅកាន់ប្រាសាទនាងពិម្ពាយសោធរាទ្រង់ព្រះកន្សែង មានពួកស្រីស្នំជាបរិវារ ។

ខាងក្នុងប្រាសាទ មានព្រះពុទ្ធរូបជាច្រើន បែបមហាយាន ព្រះពុទ្ធ-រូបមួយអង្គធំ ទ្រង់ជាក្បួនសម្បុរទ្រ: គង់ស័ក្តិសម, មួយអង្គទៀតធំដែរ ទ្រង់ជាអភយមុទ្រ: វិនាសបាត់ព្រះកេសចិនព្រះបាទអស់ហើយ ព្រះពុទ្ធ-រូបឯទៀតសុទ្ធតែតូចៗ ។

ប្រាសាទបាលិលេយ្យនេះ មានសណ្ឋានប្លែកគួរពិនិត្យមើល ព្រោះប្រាសាទដែលសាងថ្វាយព្រះពុទ្ធសាសនាបែបមហាយាន សុទ្ធតែមានរូបលោកេស្វរៈជាគ្រឿងលំអ, ឯប្រាសាទនេះ មិនមានរូបលោកេស្វរៈទេ បែបទំនងជាសាងថ្វាយព្រះពុទ្ធសាសនាបែបហីនយាន, តាមលោក ហ. បាម៉ង់ទីយេរ លោកនិយាយថា: ប្រាសាទនេះ ព្រះបាទជយវរ្ម័នទី ៧ ទ្រង់កសាងបន្ថែមជាខាងក្រោយ កាលដែលមានអគ្គិភ័យនៅក្រុងនគរធំ ព្រោះពិនិត្យឃើញការរៀបបន្ថែមជាច្រើន ក្នុងរវាងសតវត្សរ៍ទី ១៨ នៃពុទ្ធសករាជ ។



សិវលិង្គ ប្រាសាទព្រះពិធ្នូ

( តាមរូបថត ព . ស . ប .)

## ព្រះពិធូ

នៅខាងកើតទីមុខព្រះលានជល់ដំរី នៅខាងមុខទេពប្រណម្យ មានប្រាសាទ៥ខ្នង ស្ថិតនៅជិតៗគ្នា ហៅថា ក្រុមប្រាសាទព្រះពិធូ ។

ប្រាសាទព្រះពិធូនេះ កសាងនៅលើទីខ្ពស់ បែរមុខមកកាន់ទិសខាងលិចទាំងអស់ មានទីលានលយចេញមកខាងលិច ប្រកបដោយបង្កាន់ដៃខាង មានក្បាលនាគស្ទើន សុទ្ធតែល្អមើលគួរចាប់ចិត្ត, អ្នកមើលទាំងឡាយ គួរទៅមើលខានមិនបាន ព្រោះក្បាច់ចនាទាំងអស់នេះ បើយើងបានចំឡងយកមកប្រើ ឬឆ្លាក់ចំណាយ គឺកើតទ្រព្យសម្បត្តិបរិបូណ៌មិនខាន ។ ប្រាសាទព្រះពិធូទាំង ៥ ខ្នងនេះ គេកសាងដើម្បីឧទ្ទិសថ្វាយព្រះឥស្សរខ្លះ ព្រះពុទ្ធសាសនាខ្លះ ព្រោះគេបានរើមើលឃើញក្នុងប្រាសាទខ្លះ មានសិវលិង្គ ខ្លះមានព្រះពុទ្ធរូប ។

ប្រាសាទទី ១ ដែលស្ថិតនៅខាងលិចបង្អស់ ស្ទើរនេះវិនាសអន្តរាយអស់ហើយ នៅសល់តែគ្រឹះ ក្បាច់ចនាដែលសព្វនៅល្អសំខាន់ណាស់, ក្បាច់ដែលគេរើសយកមកតាំងក មានសត្វគ្រុឌល្អិតរលាស់ទំនួរស្ទើរ ៗ ក្បាច់ចនាមុខពោធិ ដែលគេរក្សាឃើញនៅដី មានរឿងកូរសមុទ្រទឹកដោះ, ក្បាច់នៅផ្នែកប្រាសាទ មានរូបទេពតាផ្សេងៗ ដូចមាននៅនគរវត្តនិងបាយ័ន, ប្រាសាទនេះ បើប្រៀបនឹងជាតៅដូចដើម គុំឲ្យមាន

ស្ដែងផុំផ្ទះ សមរម្យនឹងល្អឥតឧបមា ។ នៅខាងកើត មានប្រាសាទមួយទៀតតូចតែមួយជាន់ ស្ថិតលើគ្រឹះខ្ពស់ នឹងក៏តែងមួយជាន់ ក្បាច់របាំប្រាសាទនេះក៏ល្អណាស់ដែរ ប៉ុន្តែឥឡូវនេះ ការវិនាសអន្តរាយផុលទៅមុខហើយ មិនអាចពិនិត្យមើលឲ្យសព្វគ្រប់បាន, នៅទ្វារចូលមានទ្វារបាលពីរ ដែលរលំនៅផ្ទៃអង្គុយ នៅហោជាងមានព្រាហ្មណ៍គោរពសំពះ, នៅលើទ្វារ ស្ដែងជិះលើគ្រុឌ ព្រះវិស្ណុមានដៃច្រើនកំពុងឆក់, ប្រាសាទទាំងពីរនេះ មានស្រះមួយយ៉ាងធំ, មានផ្លូវដើរមួយកាត់ទៅខាងកើត ចំទៅលើប្រាសាទទី ៣ ។

ប្រាសាទទី ៣ មានការកសាងថ្មគ្នាបន្តិច, គេកសាងនៅលើគ្រឹះខ្ពស់ហើយស័ក្តិសម-ថែបម៉ាតែមិនទាន់ហើយស្រេច ។ នៅខាងក្នុងប្រាសាទ មានបញ្ចក់ព្រះពុទ្ធរូបជាថ្ម ចាំងថ្លៃដៃមិនចំណាន មានព្រះមូលជាគេដេះដូចជាអណ្តាតភ្លើង ។ នៅខាងកើតប្រាសាទនេះ មានកន្លែងវិហារពុទ្ធសាសនាចាស់មួយនៅចុងគ្រឹះខាងកើត មានជណ្ដើរតូចផ្សុទ្ធបែបយ៉ាងល្អ មានសីហៈជាទ្វារបាល, ក្បាលនាគ តែឥឡូវនេះវិនាសស្ទើរតែអស់ហើយ ។

នៅខាងជើងប្រាសាទទាំង ៣ នេះ ជាទីប្រតិស្ឋានប្រាសាទទី ៤ ស្ថិតនៅលើគ្រឹះខ្ពស់ មានជាន់ពីរ មានក្បាច់រចនាយ៉ាងល្អវិសេស ទ្រង់ទ្រាយបែបឈ្មង, តែមានការកសាងបន្ថែមក្រោយទៀត, ការកសាង

ខាងក្រោយនេះ មិនមានស្នាដៃល្អទេ ។ នៅខាងជើងប្រាសាទទី៦ ជាទីប្រតិស្ឋានប្រាសាទទី៥ ។

ប្រាសាទទី៥នេះ ប្លែកពីប្រាសាទទាំង ៦ ដែលបានពណ៌នារួចមកហើយ មានសណ្ឋានបែបជាកន្លែងសម្រាប់អ្នកដំណើរមកពីឆ្ងាយ ដូចជាប្រាសាទតូចៗដែលគេបានឃើញនៅប្រាសាទព្រះខាន់និងប្រាសាទតាព្រហ្ម. កងកៅប្រាសាទនេះ ចូនជ្រុង, ហើយមានប្រាង្គនៅពីលើ ។

ការដើរមើលប្រាសាទក្រុមព្រះពិធូរនេះ ចប់ចុះដោយការកាន់យកផ្លូវដែលកាត់ព្រៃព្រឹក្សលតាជាតិ ប្រកបដោយសូរសំឡេងបក្សីបក្សា យាសយំគង់រំពង ពិរោះដូចភ្លេង ជាទីកំសាន្តសប្បាយ ដើរកាត់ត្រង់ទៅខាងជើងទៅលើស្រះមួយ បណ្ដោយ ៤០ម៉ែត្រ ទទឹង ៦០ម៉ែត្រ ដីមានទឹកទៅនៅព្រៃព្រឹក្សាខៀវស្រងាត់ព័ទ្ធជុំវិញ ទឹកថ្លាយង់ធ្លូរជាទីបន្ទាបន់ញ៉ាសក្អុល បើប្រសិនជាមានពាហារយកទៅបរិភោគ គួរយកទៅបរិភោគនៅក្រោមដើមឈើមាត់ស្រះនោះ ក៏រឹងរឹតតែមានរសឆ្ងាញ់ពិសាអនេក ព្រោះក្រឡេកមើលទៅទឹកស្រះថ្លាប្រកបដោយសាពយ សត្វតាក្រកាកហើរហែលនៃព្រានព្រាត ចុះហែលលលៃប្រឡែងគ្នាជាកំសាន្ត ដៃព្រឹក្សាមានសន្លឹកខៀវស្រស់ មានម្លប់ត្រឈឹងត្រឈៃ មានកំហោបក់មកល្ហើយត្រសៀក បន្ទំដោយភ្លេងគីសូរសំឡេងសត្វចាបលោតក្រាកតាក់ និងសត្វផ្សេងៗជាអនេក ។

## ប្រាសាទសួព្រ័ត្រនិងឃ្លាំង

នៅខាងមុខទីព្រះលាន ខាងកើតស្ពានកណ្ដាលនៃនគរធំ មានប្រាសាទ ១០ ធ្វើពីថ្មបាយក្រៀម មានសណ្ឋានជាចេតិយមានកំពូលតាល ស្ថិតជាជួរតៀងគ្នាពីខាងជើងទៅខាងត្បូង នៅចន្លោះផ្លូវធំទៅទ្វារជ័យ; តាមជំនឿខ្មែរយើងយល់ថា: ប្រាសាទសួព្រ័ត្រ គឺកាលជំនាន់នគរ គេលេងល្បែងសួព្រ័ត្រនៅប្រាសាទនេះ សម្រាប់ស្ដេចទ្រង់ទតក្នុងពិធីបុណ្យមួយៗ" តែពាក្យនេះ តាមដែលពិនិត្យមើលមិនមានខ្លឹមសារអ្វី នឹងយកមកធ្វើជាតឹកតាងគោលបានតែមិនបាន; តាមអ្នកដំណើរចិន ចៀវ-តាក្វាន់ និយាយថា: "កន្លែងនេះជាទីដំកល់ទេវតាសក្ដិសិទ្ធិ សម្រាប់ជាទីស្បថនៃអ្នកដើមចោទនិងអ្នកចុងចោទ ក្នុងការរកក្ដីគ្នា," សេចក្ដីនេះឃើញសម ព្រោះពិធីស្បថក៏ជាកិច្ចមួយជាប់ជាមេគតិក្នុងចិត្តខ្មែរជាតិយើងនេះ ។ ប្រាសាទនេះ បែរមុខមកខាងលិច ក្បាច់ចម្លាក់នៅធ្វើមិនទាន់ហើយស្រេច, ខាងកើតបន្តិច មានប្រាសាទដូចគ្នាពីរទៀត, នៅចន្លោះប្រាសាទនេះ មានស្រះមួយ មានជណ្ដើរថ្ម ។

នៅខាងកើតប្រាសាទសួព្រ័ត្របន្តិច, មានប្រាសាទពីរនៅអមផ្លូវទៅទ្វារជ័យ មួយខាងជើង មួយខាងត្បូង, មានក្បាច់ចម្លាក់ពិសេស គេហៅថា ប្រាសាទឃ្លាំង ។ ប្រាសាទឃ្លាំងនេះ គួរមើលណាស់ដែរ

ព្រោះថ្មដែកសាននោះដោយធាតុពិនិត្យពិបាកណាស់, តាមទំនងនេះ មិនសមឈ្មោះថា យ៉ាន ដូចសេចក្ដីយល់របស់យើងឡើយ ។ តាមពិត គួរជាទីទទួលសំណាក់នៃក្សត្រិយ៍ឬនាម៉ឺនជាន់ខ្ពស់ៗ ។ នៅប្រាសាទយ៉ានខាងជើង គេបានរកឃើញរូបស្និតសម្រិទ្ធ ១ ។

លុះបានមើលប្រាសាទសួគ៌ត្រឹមយ៉ានរួចហើយ ត្រូវឡើងរថយន្តទៅតាមផ្លូវចំទៅទ្វារជ័យខាងកើត ដើម្បីទៅមើលព្រះពុទ្ធរូប ដែលគេនាំបានពីគន្លងកណ្ដាលប្រាសាទបាយ័ន ដូចបាននិយាយខាងមកហើយ គន្លងប្រាសាទបាយ័ន នៅតែបន្តិចប្រហែល៤០០ម៉ែត្រដល់ហើយ ។ ព្រះពុទ្ធរូបនេះ គេយកមកតម្កល់ទុកជាបានក្បួនផ្ទះនេះ នៅលើកន្លែងវិហារបុកណរ ដែលតូចនេះ, គេបានរៀបចំជាថ្មី ហើយធ្វើជាកេនតូចសម្រាប់ជាទីដែកនៃព្រះពុទ្ធរូបនេះ ។ លុះមើលរួចហើយ ហួសទៅខាងកើតបន្តិចទៀត ដើម្បីទៅមើលប្រាសាទតូចមួយ ដែលបាក់បែកអស់ហើយ ឈ្មោះ មង្គលជិ ។

## ប្រាសាទមង្គលអ៌ថ

ប្រាសាទនេះ ស្ថិតនៅចន្លោះទ្វារជ័យនិងទ្វារខ្មោច, ចុះពីរថយន្តហើយដើរចូលទៅបន្តិច តាមផ្លូវតូចខាងស្ដាំដៃនឹងឃើញប្រាសាទមង្គលអ៌ថនេះ ។ គេកសាងពីថ្មសុទ្ធ បែរមុខមកខាងកើត មានទ្វារបញ្ឆោតទាំង ៤ ទិស ផ្ទៃខាងបាក់បែកស្ទើរអស់ហើយ; បណ្ដាថ្មធ្លាក់ជាក្បាច់ដែលគេរើសបាន មានថ្ម១ដុំកំពស់១ម៉ែត្រ៤៦ មានវិស្ណុដេកនៅលើពស់អនន្តនិងព្រះព្រហ្មគង់លើផ្កាឈូក, វិស្ណុដៃ៤នៅលើស្មាគ្រុឌ, ខាងលើក្រឹស្ណៈពាក់មកុដកំពូល៣ ទ្រភ្នំការពារហ្វូងគោនិងគង្វាល, ព្រះរាមកាន់ធ្នូ, នៅថ្មនេះ គេមើលឃើញអវតារនៃវិស្ណុសព្វគ្រប់, មានថ្មមួយដុំទៀត, គេឆ្លាក់រូបលោកេស្វរៈដៃ ៤ ខាងបរិកនិងមករក្លាយជាក្រពើ; នៅហោជាង ព្រះឥសូរជិះមេគោ, ព្រះឥសូរគង់ជាមួយនឹងឧមាមហេសីឈ្មោះខាងសក្ដិ ។ ប្រាសាទនេះ គេកសាងថ្វាយសាសនាព្រាហ្មណ៍, តាមសិលាចារឹកមួយ គេទើបរកឃើញមានសេចក្ដីថា: "ប្រាសាទនេះ គេកសាងក្នុងសតវត្សរ៍ទី ២០ នៃពុទ្ធសករាជ" ។

ផ្ទៃក្រៅពីប្រាសាទមង្គលអ៌ថនេះ មានគ្រឿងបុរាណជាច្រើន ដូចជាកំពែង, គ្រឹះ, ទឹកបន្ទស់ ជាដើម ដេរដាសសកក់កយពាសពេញនៅក្នុងផ្ទៃកំពែងនគរធំ, បុរាណវត្ថុដែលសល់នៅ គេមិនទាន់រកឃើញ

នោះច្រើនណាស់ សព្វថ្ងៃ ការថែរក្សានគរក៏ចេះតែរៀបចំតទៅ ។ ចំណែកខ្មែរយើង, មិនគួរលះបង់ប្រាសាទទាំងអស់ចោលសោះ ព្រោះប្រាសាទទាំងអស់នេះ ជាកេរ្តិ៍នៃបុព្វបុរសខ្មែរយើង ហើយជាទ្រព្យសម្បត្តិខ្មែរយើងផង បើយើងបានរៀនចំណេះវិជ្ជាអំពីប្រាសាទនេះអស់ហើយ យើងនឹងកើតទ្រព្យសម្បត្តិច្រើនប៉ុណ្ណា ហើយដើរតាមស្នាមជើងដូនតាជាន់នគរបាន ។

វត្ថុទី ៨

# រង្វង់តូច

## ប្រាសាទធម្មនន្ទ និងប្រាសាទចៅសាយ

នៅគីឡូម៉ែត្រលេខ ១៦ ផ្លូវវង់តូច ដែលចេញតាមទ្វារជ័យនគរធំ មាន ប្រាសាទពីរទន្ទឹមគ្នា, ប្រាសាទស្ថិតនៅខាងជើងផ្លូវឈ្មោះ ធម្មនន្ទ ខាងត្បូងផ្លូវឈ្មោះ ចៅសាយ ។

ប្រាសាទធម្មនន្ទ សណ្ឋានជាប្រាង្គមួយ មានយ៉ៈលយ៉ៈចេញទៅខាងមុខ មានបណ្ណាល័យមួយស្ថិតនៅទិសអាគ្នេយ៍, កំពែងព័ទ្ធជុំវិញ បណ្តោយ ៦០ម៉ែត្រ ទទឹង៤០ម៉ែត្រ, តួប្រាសាទបណ្តោយប្រហែល ២០ម៉ែត្រ ។ ការរចនាប្រាសាទនេះ ក៏ល្អសំខាន់ណាស់ដែរ ទ្វារចូលពីទិសខាងលិច មានចម្លាក់ដោយស្នាដៃពិសេស អ្នកផងទាំងពួងគួរមើល, ក្បាច់ដែលនៅសសរទ្វារបញ្ឆោតក៏ល្អ ឯសសរខាងកើតនៃទ្វារមុខខាងត្បូងក៏គួរមើល, នៅខាងក្នុងប្រាសាទ ត្រង់យ៉ាងប់គំនិតប្រាង្គ មានផ្ទៃលើទ្វារល្អណាស់ ប្រកបដោយព្រះឥន្ទ្រជិះលើដំរីឰរាវ័ណ្ណក្បាលបី, នៅហោជាងពាលីជាស្តេចស្វាស្លាប់, រាពណ៍ចាប់អង្គនាងសីតា, ក្រឹស្នៈទ្រភ្នំ និងរឿងកូរសមុទ្រទឹកដោះ ។

ប្រាសាទនេះ ទំនងជាគេធ្វើសង់ថ្វាយព្រះនារាយណ៍ តាមដែលមានរឿងកំដាប់ទឹងប្រាសាទ, ព្រោះមើលឃើញរឿងរាមកេរ្តិ៍ គេមើលឃើញព្រះរាមនឹងព្រះលក្ស្មណ៍, ចម្បាំងពាលីនឹងសុគ្រីព, តួស្វាញីពោម រាមជាប៉ុរោ សេនាស្វាយាសយ៉អ៊ីងគន៍ ។

លុះមើលរួចហើយត្រូវដើរទៅខាងត្បូង ដើម្បីទៅមើលប្រាសាទចៅសាយ ចម្ងាយប្រហែល ៣០ ម៉ែត្រពីផ្លូវថ្នល់ ។

ប្រាសាទចៅសាយនេះ គេធ្វើសង់ថ្វាយព្រះឥសូរ ព្រោះមានគោនន្ទិជាជំនិះព្រះឥសូរ, មានសណ្ឋានក្បាច់ចម្លាក់ស្រដៀងគ្នានឹងប្រាសាទធម្ម-នន្ទ ប៉ុន្តែមានធម្មសាលមួយដែលនៅទិសអាគ្នេយ៍ មានទ្វារចូលពីខាងលិច, ឥឡូវនេះ ធម្មសាលនោះបាក់បែកអស់ហើយ នៅសល់តែគ្រឹះ; យ៉ាដែលលយចេញពីប្រាង្គមានគ្រឹះខ្ពស់បណ្ដុះសសរមូល ក្បាច់ចម្លាក់ក៏ល្អ; តែប្រាសាទនេះដាក់ត្រាំត្រោះច្រើនជាងគេ ដុំថ្មដែលគេរើសតម្កល់នៅខាងលើង ពិនិត្យទៅឃើញមានខាតមានក្បាលច្រើន ក្បាច់ចម្លាក់ដែលធ្លាក់ពុះពីរហោចជានិមតក៏បាក់បែកជាច្រើន ។

ប្រាសាទទាំងពីរនេះ មិនទាន់ឃើញមានសិលាចារឹកពិតប្រាកដទេ តែតាមលោក ហ. ប៉ារម៉ង់ទីយេ លោកនិយាយថា: "ក្បាច់ចម្លាក់មានសណ្ឋានដូចអង្គរវត្ត, ប្រហែលជាកសាងក្នុងរវាងសតវត្សរ៍ទី ១៧ នៃពុទ្ធ-សករាជ" ។

## ស្ពានថ្ម

នៅក្នុងក្រុងនគរធំ មិនមានស្ពានថ្មទេ មានតែស្ពានមួយស្ថិតនៅខាងកើតនគរធំ ចម្ងាយពីទ្វារជ័យប្រហែល ៧០០ ម៉ែត្រ, គឺស្ពានឆ្លងស្ទឹងសៀមរាបនេះឯង, តាមលោក ហ. ម៉ាសាល់ លោកនិយាយថា: "ខ្មែរមិនចេះរៀបធ្វើស្ពានទេ ព្រោះស្ពានថ្មនេះ ទុកដូចជាទំនប់សំរាប់ទប់ទឹកតែម្តង គេរៀបថ្មធ្វើជាគួសសរជាប់ពីបាតស្ទឹងមកដល់ផ្ទៃស្ពានខាងលើ ទុកប្រហោងតូចៗ ចុះបើមានសំណាក់ដែលហូរមកតាមស្ទឹង ទុះក៏មិនប៉ះស្ពានធ្លាក់ខូចហើយ។" ។

កន្លែងស្ពានថ្មសព្វថ្ងៃនេះ មិនមែនកន្លែងស្ពានបុរាណទេ កន្លែងស្ពានបុរាណ ស្ថិតនៅខាងជើងទៀងខាងលិចបន្តិច, ដោយស្ទឹងបែរហូរទៅខាងកើតបន្តិច គេចាប់ទឹងធ្វើស្ពានថ្មីទៀត តែគេយកថ្មក្រួសមកធ្វើដែរ ស្ពាននេះល្អចំណាំរបស់គេ ។



ភាពប្រាសាទតាកែវទាំងមូល មើលពីទិសអាគ្នេយ៍
ការរចនាថែវប្រាសាទឃ្លាំង រវាង គ.ស.១៩៣៣-១៦៩៣

( តាមរូបថត ស.ប.ជ. )

## ប្រាសាទតាកែវ[១]

ប្រាសាទតាកែវ ស្ថិតនៅជិតគីឡូម៉ែត្រលេខ ៣ តាមផ្លូវជុំតូច កាលណាគេក្រឡេកមើលមុនដំបូង គេនឹងឃើញប្លុកថ្មភក់ជាងមើលប្រាសាទទាំងមូល, ប្រាសាទនេះកាន់សក្តិសម កសាងត្រឹមត្រូវតាមខ្នាត, សណ្ឋានខ្ទង់ត្រាយល្អឈ្ងន់ លេចត្រដែតឡើងកណ្តាលទ្រូងព្រៃ ប្រកបដោយកំពូលប្រាង្គទាំង៥ ខ្ពង់ខ្ពស់ស្កឹមស្កៃ ទាញភ្នែកអ្នកមើលឲ្យបាញ់ត្រង់ទៅគេ, ហើយមិនមានក្បាច់ចនាអ្វី មើលទៅឃើញស្អាតចេស ។ លោក ហ. ម៉ាសាល់ និយាយថា: "បណ្តាប្រាសាទនៅនគរធំ ប្រាសាទនេះល្អយ៉ាងឯក ពិតមែនតែមិនមានក្បាច់ចនា ឬ ចម្លាក់រឿងអ្វី" ។

ប្រាសាទតាកែវនេះ មានថ្នាក់ ៣ ជាន់, ថ្នាក់លើបង្អស់ ជាទីប្រតិស្ឋានប្រាសាទកណ្តាលដែលខ្ពស់ជាងគេ ប្រាសាទ ៤ ស្ថិតនៅគ្រប់ជ្រុងអនុទិស; កាលណាគេបានទៅដល់ហើយ ត្រូវចូលពីខាងកើតប្រាសាទ ឈប់រថយន្តហើយ ចុះដើរចូលទៅ ។

ថ្នាក់ក្រោម បណ្តោយ ១២០ ម៉ែត្រ, ទទឹង ១០០ ម៉ែត្រ, ថ្នាក់ទី២ បណ្តោយ ៨០ ម៉ែត្រ, ទទឹង ៧៥ ម៉ែត្រ, ប្រតិស្ឋាននៅលើជាន់ទី១ កំពស់ ៥ ម៉ែត្រ ៥០, មានជំណាក់ជាច្រើន មានកន្លែងដើរជុំវិញ, ថ្នាក់

១ ប្រាសាទកែវ ។

ទី ៣ ជាទីបញ្ចប់នៃប្រាសាទទាំង ៤ ។ តាមដែលខ្មែរយើងនិយាយតៗគ្នាថា: "ប្រាសាទនេះបានជាមិនមានក្បាច់រចនាចុះ, ព្រោះកាលពីដើម, គេស្រាវទទឹងដែលប្រកបក្បាច់រចនាផ្សេងៗ ស្រាប់តែរបះបែកអស់ហើយ", តែលោក ហ.មាស៊ាល់ និយាយថា: "ប្រាសាទនេះ បានជាគេមិនឆ្លាក់ក្បាច់ដូចប្រាសាទទាំងពួងនោះ ព្រោះថ្មនេះមានសាច់រឹងណាស់ មិនចេះដូចថ្មទាំងពួង", ការដែលទាំងពីរនេះ នៅជាប្រស្នាដែលគ្មានទៀត មិនទាន់ដាច់ស្រេចដូចម្ដេចឡើយ ។

ប្រាសាទតាកែវនេះ គេកសាងឧទ្ទិសថ្វាយដល់ព្រះឥស្វរ តាមសិលាចារឹកដែលគេបានរកឃើញ, ម្យ៉ាងទៀត មានគោនន្ទិជាគោលផង; ព្រះបាទសូរ្យវរ្ម័នទី១ [១] ស្ដេចកសាងក្នុងសតវត្សរ៍ទី១៦ នៃពុទ្ធសករាជ (គ.ស. ១៥៦៣) ។

អ្នកមើលត្រូវឡើងប្រាសាទនេះ ក្នុងពេលត្រជាក់ស្រួល ពេលព្រឹកឬល្ងាច, តាមជណ្ដើរខាងកើត ត្រូវប្រយ័ត្ន ព្រោះប្រាសាទខ្ពស់ជណ្ដើរចោតសឹកគគាំងជាច្រើនកន្លែង, ឡើងដល់ខាងលើហើយ, គេអាចមើលឃើញជុំវិញខ្លួនបាន, ព្រោះប្រាសាទខ្ពស់ត្រដួតផុតចុងឈើ ហាក់ដូចជានៅកណ្ដាលអាកាស, មើលទៅឆ្ងាយ ឃើញភ្នំគូលែនឆ្ងាយ ឃើញហុយផ្សែងដាច់កន្ទុយភ្នែក ។

១ អ្នកស្រី កូរាល រេមូសាត់ (Coral Rémusat) សៀវភៅ (L'Art Khmer) ទំព័រ ១៤ និយាយថា ប្រាសាទតាកែវនេះ ព្រះបាទជ័យវរ្ម័នទី ៥ ស្ដេចកសាង ។



ដើមឈើដុះចាក់ឫសសត់ខ្វត់ខ្វ លើកំពូលប្រាសាទតាព្រហ្ម

( តាមរូបថត ស. ច. ម. )



កាលព្រះពោធិសត្វទ្រង់គង់លើកណ្ឋកតាជីមានទេវបុត្រជាបរិវារ
ទ្រង់ចេញសាងអភិនិស្ក្រមណ៍; លោកដាងគ្រាសាទខាងក្នុងកំពែង
ទី ៣ ប្រាសាទតាព្រហ្ម

( តាមរូបថត ព. ស. ប. )

# ប្រាសាទតាព្រហ្ម

សព្វថ្ងៃនេះ ប្រាសាទតាព្រហ្ម គេមិនកាប់ឆ្ការព្រៃស្រឡះដូចជាប្រាសាទឯទៀតទេ គេចង់ទុកឲ្យឃើញច្បាស់ថា សភាពប្រាសាទដែលគ្រាលគាថាគំលុកលុយទ ព្រៃនន្ទុំរតំបែបដូចម្ដេច? ដូច្នេះយើងឃើញក្នុងប្រាសាទនេះ មានដើមឈើធំៗ មានឫសរុំព័ទ្ធក្ដោបកៀវជាប់នៅនឹងថ្មផ្ទុំ តាមផ្លូវដែលចូលទៅទិសក្នុង គេគ្រាន់តែកាប់ឆ្ការបន្តិចបន្តួចល្មមនឹងដើរមើលបានខ្លះណោះ ។ ប្រាសាទដែលមានភាពសណ្ឋានខ្ទង់ត្រាយប្រហែលគ្នា មាន ៣ គឺ ប្រាសាទតាព្រហ្ម, ប្រាសាទបន្ទាយក្ដីនិងប្រាសាទព្រះខាន់ ដែលត្រូវនិយាយតទៅខាងមុខ ។, ឯប្រាសាទតាព្រហ្មនេះ ក៏មានកិច្ចការថែទាំជាច្រើនត្រូវនិយាយ អ្នកប្រាជ្ញបារាំងខាងបុរាណ-វត្ថុ មានសេចក្ដីសរសើរជាយ៉ាងច្រើនអំពីប្រាសាទនេះដែរ ។

មានកំពែងថ្មជាន់, កំពែងក្រៅ, បណ្ដោយពីទិសកើតទៅទិសលិច ១០០០ ម៉ែត្រ ទទឹងពីទិសត្បូងទៅទិសជើង ៦០០ ម៉ែត្រ, មានគោបុរៈគ្រប់ទិសទាំងបួន, គោបុរៈដែលចូលមើលបានគាល់សព្វថ្ងៃនេះមានតែពីរ គឺទិសកើតនិងទិសលិច, បើឈប់ទិសកើត ឲ្យរថយន្តទៅឈប់ចាំទិសលិច, បើឈប់ទិសលិច ឲ្យរថយន្តទៅចាំទិសកើត, ហើយសឹមចូលទៅ ។ គោបុរៈទាំង៤ទិសនេះ សុទ្ធសឹងប្រកបដោយមុខលោកេស្វរៈថែរទៅតាម

ទិសទាំង ៤ នៅជ្រុងនៃគោបុរៈមួយៗ ប្រកបដោយរូបគ្រុឌចេញទាំ ។ លុះ
ចូលផុតគោបុរៈខាងកើតហើយ ត្រូវដើរចូលទៅតាមផ្លូវដើរ, បន្តទៅ
ដល់ស្ពានថ្មតូចខ្វាងកាត់ស្រះ ដែលមាននៅជុំវិញកំផែងទីពីរ, គោបុរៈនៃ
កំផែងទីពីរនេះ គេធ្វើជាប្រាសាទមានកំពូល មានទ្វារតូចពីរនៅអមសង
ខាងៗគេ, ដំបូលមានសណ្ឋានជាកង់ទង នៅសងខាងទ្វារមានរូបចម្លាក់
ទេវតាញីៗ ។ ចូលផុតពីកំផែងទីពីរទៅ ទីនេះឃើញប្រាសាទមួយ
បណ្ដោយប្រវែង ៣០ម៉ែត្រ, ទទឹង២០ម៉ែត្រ, មានទ្រង់ទ្រាយដូច
សាលា តែវិនាសអន្តរាយជាច្រើន នៅសល់តែសសរនិងជញ្ជាំង,
ជាន់ខាងលើនឹងបន្ទប់បន្ទះមួយៗ មានក្បាច់ចម្លាក់ល្អណាស់ ។ កំផែង
ទី ៣ មានសណ្ឋានជាការ៉េទទឹងជុំវិញ មានទ្វារបើកចំទិសបួនទិស ខាង
លើទ្វារគេធ្វើជាកំពូលខ្ពស់ឡើង ប្រកបដោយក្បាច់ចម្លាក់ល្អៗ ។ ផុត
ពីកំផែងទី ៣ ទៅទីនេះឃើញកំផែងទី ៣ ជួរ ដែលជាផ្លូវចូលទៅកាន់កំ-
ផែងទី ៤, នៅចន្លោះកំផែងទី ៣ និងទី ៤ សងខាងផ្លូវបែកទៅខាងកើត
មានប្រាសាទជាច្រើន នៅផ្នែកលើទ្វារប្រាសាទមុខខាងត្បូង មានរូបចម្លាក់
ព្រះមហាសត្វទ្រង់ប្រសូតចេញតាមក្លៀក នៃព្រះនាងសិរីមហាមាយានៅ
ព្រៃលុម្ពិនី មានរូបព្រះអង្គទ្រង់និងទេវតាជាច្រើន, នៅសងខាងផ្លូវបែក
ខាងលិច មានប្រាសាទពីរ មួយខាងត្បូងធ្វើដោយថ្ម, មួយខាងជើង
ធ្វើដោយថ្មបាយក្រៀម, នៅខាងជើងនិងខាងត្បូង មានកន្លែងពីរជួរ



រូបភិក្ខុប្រណម្យ ប្រាសាទតាព្រហ្ម

(តាមរូបថត គ. ស. ម.)



កាលព្រះពោធិសត្វប្រសូត ព្រះព្រហ្មនិងព្រះឥន្ទ្រទទួល
ហោជាងប្រាសាទខាងត្បូង ក្នុងកំពែងទី ៣ ប្រាសាទតាព្រហ្ម
( តាមរូបថត ស. ប. ប )

គជាប់ពីកន្លែងជាន់ទី ៣ ទៅជាប់នឹងកន្លែងជាន់ទី ៤ ។ កំពែងទី ៤ មានសណ្ឋានជាកន្លែងពីរជុំវិញ ហើយមានកន្លែងគទៅជាប់នឹងកំពែងទី ៥, កំពែងទី ៥ នេះ ក៏មានសណ្ឋានជាកន្លែងវែង, ចំកណ្ដាលជាទីប្រតិស្ឋានប្រាសាទធំខ្ពស់ជាងប្រាសាទទាំងអស់ ដែលមាននៅនឹងកន្លែងជុំវិញ ហើយមានកន្លែងជាប់ពីកន្លែងខាងកើតនឹងខាងលិច ត្រង់ទៅដល់ប្រាសាទកណ្ដាល, ឯប្រាសាទកណ្ដាលនេះ មានល្វែង ៤ ជ្រុង ហើយមានទ្វារទៅកាន់ទិសទាំង ៤, គេដើរកាត់ពីទ្វារខាងកើតទៅទ្វារខាងលិច ត្រង់ចំហៀងទៅកាន់គោបុរៈទិសខាងលិចបាន ។

នៅកន្លែងប្រាសាទតាព្រហ្មនេះ គេមើលឃើញសិលាចារឹកនៅសសរថ្មមួយ និយាយប្រាប់ថា ព្រះបាទជ័យវរ្ម័នទី៧ បានទ្រង់ត្រាស់បង្គាប់ឱ្យធ្លាក់សិលាចារឹកនេះ គឺ ព.ស. ១៧២៩ ជាទីឧបស្សការដល់ព្រះរតនត្រ័យ គឺ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ, ព្រះពោធិសត្វអវលោកិ-តេស្វរៈ, ប្រាប់អំពីទ្រង់ធ្វើសឹកសង្គ្រាមមានជ័យជំនះ ទាំងនិយាយពីប្រាសាទទាំងប៉ុន្មានដែលទ្រង់កសាង ។

សេចក្ដីម្យ៉ាងទៀតថា: "ប្រាសាទតាព្រហ្មនេះ ជាអារាមសម្រាប់ព្រះមហាថេរៈ ១៨ អង្គ សម្រាប់ភិក្ខុ ២.៧៤០ រូប, នៅក្នុងកំពែងប្រាសាទនេះ មានសាវ័ក ២.២៣២ រូប ព្រមទាំងស្រីល្អ ៦១៥ នាក់នឹង

ស្រី-ប្រុសឯទៀត ៦៦.៦២៥ នាក់ផង ជាអ្នកធ្វើខ្ញុំត្រៀមសក្ការបូជាទាំងឡាយ ។

ទីប្រាសាទតាព្រហ្មនេះ មានកន្លែងពិបាកចូលមើលជាច្រើនកន្លែង ច្រើនរប៉ិកទាំងក្បែង, បើប្រសិនជាចូលទៅមើលក្នុងវេលាយប់ ក្នុងថ្ងៃដែលមានព្រះចន្ទពេញវង់ នឹងឃើញប្រាសាទនេះល្អមើលណាស់ ប៉ុន្តែត្រូវគេមនុស្សអ្នកនាំផ្លូវទៅជាមួយផង ហើយត្រូវឲ្យមានភ្លើងពិលចង្កៀងអ៊ុំយ៉ាំងក្នុងពេលដែលចូលទៅមើល; បើចូលតាមគោបុរៈខាងលិច ហើយហួសទៅដល់គោបុរៈខាងកើត, នៅខាងជើងនឹងឃើញធម្មសាលាមួយ គេឧទ្ទិសថ្វាយព្រះពោធិសត្វលោកេស្វរៈ នឹងសម្រាប់ជាទីផ្ដេកនៃអ្នកទៅនមស្សការ, កាលចេញផុតពីកំពែងប្រាសាទតាព្រហ្មនេះហើយ បែរមើលទៅទិសអាគ្នេយ៍ នឹងឃើញកំពែងប្រាសាទបន្ទាយក្ដី ព្រោះប្រាសាទនេះស្ថិតនៅជិតគ្នា មួយទិសអាគ្នេយ៍ មួយទិសពាយ័ព្យ ។

ប្រាសាទតាព្រហ្មនេះ ព្រះបាទជ័យវរ្ម័នទី៧ ទ្រង់សាងក្នុងសក-វស្ស័ទី ១៨ នៃពុទ្ធសករាជ (ព.ស.១៧២៩) ថ្វាយព្រះវររាជមាតា ដើម្បីឧទ្ទិសថ្វាយព្រះពុទ្ធសាសនា, ស្ដេចបានសាងព្រះរូបព្រះវររាជមាតាជា "ទេវកជ" ស្មើព្រះប្រាជ្ញាបារមិតាដម្កល់ទុកក្នុងទីនេះ ។



រូបទ្វារបាល នៅរានហាលកំពែងទី ៣ ទិសខាងលិច

ប្រាសាទតាព្រហ្ម

ការរចនាបែបបាយ័ន រវាង គ. ស. ១២០០

(តាមរូបថត ស. ច. ប.)

## ប្រាសាទបន្ទាយក្តី

ប្រាសាទនេះ មានសណ្ឋានដូចប្រាសាទតាព្រហ្ម ដែលបានពោលរួចហើយ ប៉ុន្តែមានទំហំតូចជាង, មានកំពែងព័ទ្ធជុំវិញ បណ្តោយ ៩០០ម៉ែត្រ ទទឹង៧០០ម៉ែត្រ, មានគោបុរៈគ្រប់ទាំងបួនទិស គោបុរៈខាងកើតជាទ្វារធំចម្បងជាងគេ ដ៏ប្រកបដោយកំពូលមានមុខលោកេស្វរៈ បែរទៅកាន់ទិសទាំង៤, នៅត្រង់ជ្រុងទាំង៤នៃទ្វារក៏ទ្វារនោះមានរូបគ្រុឌចេញផ្កា ។

សព្វថ្ងៃនេះ គេចេញចូលតាមគោបុរៈខាងលិចនិងខាងកើត, ឈប់រថយន្តហើយដើរចូលទៅ ដើរបន្តិចដល់ទៅមុខប្រាសាទ មានហាន ប្រកបដោយបង្កាន់ដៃនាគមានក្បាលងើយស្ទើង ក្រាលស្មុគ្ជ, តទៅបន្តិច ដល់កំពែងទីពីរ ។ កំពែងទីពីរព័ទ្ធជុំវិញជាប់គន្លោះហួតដល់ប្រាសាទកណ្តាល ហើយមានទ្វារធំ សម្រាប់ចេញចូលទាំងខាងលិចនិងខាងកើត, ទ្វារកណ្តាលជាទ្វារធំ មានកំពូលខ្ពស់ ហើយមានរោងទងជាប់គ្នាវៀងហួតទៅដល់ប្រាសាទកណ្តាល ។ តាមដែលពិនិត្យមើល, ប្រាសាទនេះឃើញបាក់បែកជាច្រើន នៅសល់តែសសរនិងជញ្ជាំង, តទៅទៀត, មានផ្លូវចំនួន៥០ម៉ែត្រ តជាប់នឹងកំពែងទី៣, កំពែងនោះមានសណ្ឋានជារោងទងព័ទ្ធជុំវិញ ត្រង់កន្លែងទ្វារគេធ្វើជាគូប្រាសាទ មាន

កំពូលខ្ពស់ ហើយមានរោងនិងទ្វារតាំងនៅជាត្រឡប់ត្រឹក ជាប់គ្នានឹងប្រាសាទកណ្តាល, ឯប្រាសាទកណ្តាលនេះ ធំខ្ពស់ជាងប្រាសាទទាំង ៨ ដែលស្ថិតនៅក្នុងជុំវិញ ។

ក្នុងប្រាសាទបន្ទាយក្តីនេះ ឃើញមានស្នាមគោសល្អប់ព្រះពុទ្ធរូប ដែលគេឆ្លាក់នៅសសរ ឬនៅហោជាង ហើយឆ្លាក់ជារូបសាសនាព្រាហ្មណ៍វិញ សេចក្តីឲ្យឃើញថា ប្រាសាទនេះ គេកសាងឧទ្ទិសថ្វាយព្រះពុទ្ធសាសនា, លុះចំណេរតមក ពួកសាសនាព្រាហ្មណ៍មានអំណាច គោសល្អប់រូបដែលពុទ្ធសាសនាចោលចេញ ហើយឆ្លាក់រូបសាសនាព្រាហ្មណ៍វិញ, នៅត្រង់កន្លែងខ្លះ ឃើញមានរូបចម្លាក់ត្រង់មារវិជ័យ, ត្រង់គេបីព្រះសិទ្ធត្ថរាជកុមារពោធិសត្វ ឲ្យទៅថ្វាយបង្គំព្រះកាលតាបស, ត្រង់កន្លែងខ្លះ ឃើញគេគោសល្អប់រូបសាសនាព្រាហ្មណ៍ចោលវិញ សេចក្តីនេះនាំឲ្យយល់ថា សាសនាទាំងពីរមានឫទ្ធិអំណាចម្តងម្នាក់ ល័ចអន្លើគ្នា ហើយប្រណាំងប្រជែងគ្នា, តមកក្រោយទៀត ប្រហែលជាមានពុទ្ធសាសនាហីនយានចូលមក បានជាមានព្រះពុទ្ធរូបពុទ្ធសាសនាហីនយានជាច្រើនអង្គ ស្ថិតនៅសព្វថ្ងៃនេះ ។

បើចូលតាមទ្វារខាងកើត ត្រូវឲ្យរថយន្តទៅឈប់ចាំនៅខាងលិច បើចូលពីខាងលិច ត្រូវឲ្យរថយន្តមកចាំនៅខាងកើត, កាលបើបានមើល



រូបឥសីសាសនាព្រាហ្មណ៍ អង្គុយចំរើនធម៌ ឆ្លាក់មិនទាន់ហើយ
កន្លែងឥសីនេះ កាលមុនគេឆ្លាក់ជាព្រះពុទ្ធរូប១ នេះគេកោសលុបចោល

( តាមរូបថត ត. ស. ប. )

រួចសព្វគ្រប់ហើយ ត្រូវចេញមកទាន់កើតតាមគោបុរៈធំ ហើយហួសទៅមើលស្រះស្រង់ ព្រោះស្រះស្រង់ស្ថិតនៅជិតចំពោះមុខប្រាសាទបន្ទាយក្តីនេះ ។ ប្រាសាទនេះ ព្រះបាទជ័យវរ្ម័នទី៧ ទ្រង់កសាងដើម្បីឧទ្ទិសថ្វាយព្រះពុទ្ធសាសនា ក្នុងសតវត្សរ៍ទី ១៨ នៃពុទ្ធសករាជ (ព.ស. ១៧២៦-១៧៦៦) ។

## ស្រះស្រង់

ស្រះស្រង់នេះ, ជាស្រះមានសណ្ឋានបួនជ្រុងទ្រវែង ប្រកបដោយភ្និក្រាលថ្មជាជណ្ដើរចុះទៅកាន់ទឹក, នៅមាត់ស្រះមានរនាំងឈើចុះចត ជុំវិញ មានមួយតែជាក់ស្ដែង បណ្ដោយ៨០០ម៉ែត្រ ទទឹងប្រហែល ៦០០ម៉ែត្រ ។ កាលពីដើម ប្រហែលជាជាប់គ្នាពីប្រាសាទបន្ទាយក្ដីដឹង? តាមសេចក្ដីសន្និដ្ឋានអ្នកប្រាជ្ញបុរាណវិទ្យាជាច្រើន យល់ថាស្រះស្រង់នេះ ជាប់គ្នានឹងប្រាសាទបន្ទាយក្ដី សេចក្ដីយល់នេះសមណាស់ ។

ទិសខាងលិច ជាកំពង់, គេសាងជាទីលានខ្ពស់ប្រកបដោយបន្ទាន់ដៃនាគស្ទើរជ្រុងជ្រាលចុះទៅកាន់ទឹក, ពេលព្រះអាទិត្យលិចចុះកាន់អស្តង្គតប្រទេស, បញ្ចេញពន្លឺព្រាលឡើងលាបមកលើទីលាននេះ បើជាយើងឈរបង្អែតក្រឡេកបន្តិច ឈរមើលទៅខាងកើតនៅពេលនុះ រឹងរឹតតែល្អមើលណាស់ ។ នៅកណ្ដាលស្រះ មានប្រាសាទតូចមួយ តែឥឡូវនេះវិនាសហើយ មើលទៅឃើញថ្មជ្រុះៗ ។ នៅខាងត្បូងកំពង់ជាទីលាន មានសាលាប្រក់ក្បឿងមួយ ជាទីសំចតផ្ទុំសម្រាប់បរិភោគអាហារ ។

បើមានពេលតិច មិនអាចនឹងមើលទៅទៀតបាន ត្រូវត្រឡប់ទៅវិញតាមផ្លូវចេញទៅខាងត្បូង ប្រហែល ៦០០០ម៉ែត្រដល់នគរវត្ត, តាមផ្លូវនេះ មានប្រាសាទ ៥ ស្ថិតនៅខាងត្បូងផ្លូវ គួរឈប់ចុះមើល ប្រាសាទនេះឈ្មោះ ប្រាសាទក្រវាន់ ។



ភាគទំលានស្រះស្រង់ មើលពីទិសពាយ័ព្យ
ការរចនាប្រាសាទបាយ័ន រវាង គ. ស. ១២០០
( តាមរូបថត ស. ច. ប. )

# ប្រាសាទក្រវាន់

តាមផ្លូវថ្នល់តូច ដែលចេញពីសៀមរាប ពីខាងត្បូងនគរវត្តទៅស្រះស្រង់ នៅចន្លោះគីឡូម៉ែត្រលេខ៧ពីនឹង៨ មានប្រាសាទ៥ល្វែងនៅខាងត្បូងជិតផ្លូវថ្នល់ បៀងគ្នាជាជួរពីខាងជើងទៅខាងត្បូង មានផ្លូវថ្នល់តូចចូលទៅមើល ឡានប្រាំងឡានទៅស្រួលបាន ។

ប្រាសាទនៅខាងជើងបាក់បែកអស់ហើយ នៅសល់តែប្រាសាទ ៤, ប្រាសាទទាំងអស់ គេសាងដោយឥដ្ឋ ប្រកបស៊ីមង់ដោយឆ្លាក់ក្បាច់ បែរមុខទៅខាងកើតទាំងអស់. ប្រាសាទខាងជើង មានរូបចម្លាក់ព្រះនារាយណ៍ដៃ៤ មានទេពប្រណម្យនៅជញ្ជាំងខាងលិច, ព្រះនារាយណ៍ឈរ មានទេពតាប្រណម្យពីរអង្គទៀត, នៅកណ្តាលប្រាសាទ មាន យោនីនឹងមានភេគគត, នៅទ្វារមានសិលាចារឹក ។

ប្រាសាទបន្ទាប់ខាងជើងមិនមានអ្វីឃាយទេ ។ នៅប្រាសាទកណ្តាល មានទ្វារបាលពីរនាក់ ឆ្លាក់ជាប់នៅជញ្ជាំងឥដ្ឋ, ខាងក្នុងប្រាសាទ ជញ្ជាំងខាងជើង ព្រះនារាយណ៍ដៃ៨ជិះលើគ្រុឌ មានទេវបុត្រទេវតាឈរនមស្ការ, នៅខាងលើ ព្រះនារាយណ៍អវតារជាត្រៃតា, ជញ្ជាំងខាងត្បូង ព្រះនារាយណ៍ដៃ៤ ឈរនៅលើជើងទ្រ មានទេវបុត្រទេវតានមស្ការ, ស៊ីផ្ទាំងទៀតយកក្បាលអ្នកទ្រជើង គឺនាងលក្ស្មី,

ឃើញទៀងទឹកវាលកក្ដាញ់ក្នុងសមុទ្រ សំដែងឲ្យឃើញថា កាលព្រះនារាយណ៍ក្រាប់ទៅក្នុងនៃក្រពត; នៅកណ្ដាលមានសិវលិង្គ, នៅខាងមានសំណាតាកែ ប្រាសាទខាងលិចនេះមិនមានគ្រឿងលំអយាយទេ ។

ប្រាសាទនេះ ព្រះបាទហរ្សវរ្ម័នទី១ ទ្រង់កសាងក្នុងសតវត្សរ៍ទី១៥ នៃពុទ្ធសករាជ (ព. ស. ១៤៨៣-១៤៦៨) ដើម្បីឧទ្ទិសថ្វាយដល់ព្រះនារាយណ៍ ។

អ្នកដំណើរដែលមានឱកាសច្រើន ត្រូវទៀតដើរយកគួរសំរបទៅស្រះស្រង់ ចំងាយ ៣២០០ ម៉ែត្រផងហើយ, បើមិនមានពេលច្រើនទេ ត្រូវត្រឡប់មកសៀមរាប ហើយអញ្ជើញទៅតាមប្រាង្គធ្លុះ ។



ភាគប្រាសាទព្រែរូបទាំងមូល មើលពីទិសខាងកើត
ការរចនាបែបប្រាសាទបាខែង រវាង គ.ស. ១៤៥៣

( តាមរូបថត ស.ប.ប. )

## វគ្គទី ២

## វង់ធំ

### ប្រាសាទប្រែរូប

ប្រាសាទប្រែរូប ស្ថិតនៅជិតគីឡូម៉ែត្រលេខ១៦ នៃវង់ធំ គឺ បន្ទាយក្តី៦៨០០ម៉ែត្រ, បណ្តោយកំពែង១៦០ម៉ែត្រ ទទឹង១០៨ម៉ែត្រ ។ ប្រាសាទប្រែរូបនេះ គេកសាងពីឥដ្ឋសុទ្ធ ប្រកបស៊ុមទ្វារដោយថ្ម មើលពីចំងាយឃើញឥដ្ឋពណ៌ក្រហមប្រផេះ, កំពូលទាំង៥ខ្ពស់ត្រដែត កណ្តាលអាកាស ។

មានថ្នាក់៣ មានជណ្តើរចុះទៅកាន់ទិសទាំង៤, នៅក្បាលជណ្តើរ មួយៗ មានសត្វសិង្ហជាទ្វារបាល, តែជណ្តើរដែលឡើងបានស្រួលនោះ បានតែជណ្តើរខាងកើត, នៅថ្នាក់ទី៣ ជាទីប្រតិស្ឋានប្រាសាទទាំង៥ ប្រាសាទកណ្តាលធំខ្ពស់ ប្រាសាទទាំង៤នៅតាមគ្រប់ជ្រុងអនុទិស ហើយ បែរមុខទៅកាន់ទិសខាងកើត, បីទិសទៀត មានតែទ្វារបញ្ឆោត ។

នៅថ្នាក់ទី២ មុខជណ្តើរ កណ្តាលផ្លូវឡើងទៅកាន់ថ្នាក់ទី៣ មាន ស្តូបសណ្ឋាន៤ជ្រុងទ្រវែង នៅជុំវិញមានបង្គោលថ្មទំនងជាជើងថ្ករ, តាមទំនងនេះ, នាំឲ្យគេយល់ថា ប្រាសាទនេះគេធ្វើសម្រាប់បូជាសព ស្តេច បានជាគេឲ្យឈ្មោះថា ប្រាសាទប្រែរូប ។

ក្បាច់រចនាប្រាសាទនេះក៏ល្អចំណានណាស់ដែរ ដូចប្រាង្គមួយនៅខាងត្បូង ត្រង់ផ្តែរលើទ្វារខាងជើង មានចម្លាក់ព្រះនារាយណ៍អវតារជាសីហៈ (នរសិង្ហៈ) ចាប់ហែកយក្សស៊ី, ក្បាច់ខ្លះទៀតគេធ្វើមិនទាន់ហើយស្រេច ។

ប្រាសាទនៃប្រែរូបនេះ ព្រះបាទរាជេន្ទ្រវរ្ម័នទី ២ ទ្រង់កសាងក្នុងចុងសតវត្សរ៍ទី ១៨ នៃពុទ្ធសករាជ (ព.ស. ១៦៩៦) ដើម្បីឧទ្ទិសថ្វាយដល់សាសនាព្រាហ្មណ៍ ។

លុះមើលរួចហើយ ត្រូវវៀងរថយន្តទៅមើលប្រាសាទមេបុណ្យទៀត នៅចំងាយចំនួន ១៦០០ ម៉ែត្រ ពីប្រាសាទនេះ ។



រូបព្រះវិស្ណុផ្ទំផ្ទៀង ធំអស្ចារ្យ គេជីកឃើញនៅប្រាសាទមេបុណ្យទិសខាងកើត
ការរចនាសម័យប្រាសាទបាពួន រវាង គ.ស. ១៥៩៣

( តាមរូបថត ស. ព. ប. )

## ប្រាសាទមេបុណ្យ

ប្រាសាទមេបុណ្យ ស្ថិតនៅចន្លោះគីឡូម៉ែត្រលេខ១០ និងលេខ១១ នៃផ្លូវធំ កណ្ដាលស្រះដ៏រីងហួតទឹកអស់, ស្រះនេះបណ្ដោយ ៧ គីឡូ-ម៉ែត្រ ពីខាងកើតទៅខាងលិច ទទឹង ១៨០០ ម៉ែត្រ ពីខាងជើងទៅខាងត្បូង មានភ្លឺព័ទ្ធជុំវិញ ជាស្រះសម្រាប់ទុកទឹកប្រើប្រាស់ក្នុងក្រុង, ហើយប្រហែលជាគេបង្ហូរទឹកពីស្ទឹងសៀមរាបបញ្ចូលមកផង, ប្រាសាទនេះ គេហៅថា "មេបុណ្យខាងកើត" ។

តាមសិលាចារឹកជាច្រើនកន្លែង មាននិយាយថា: "ព្រះបាទយសោ-វរ្ម័នទី១ ទ្រង់កសាងស្រះមួយឈ្មោះ យសោធរតដាកៈ ស្រះទ្រ ទ្រង់ឱ្យយស នៅកណ្ដាលស្រះនោះ ទ្រង់បានកសាងភ្នំព្រះសុមេរុ គឺប្រហែលជាប្រាសាទមេបុណ្យនេះឯង ក្នុងខាងចុងសតវត្សរ៍ទី ៩ នៃគ្រិស្តសករាជ" ។

នោះគឺបុរៈហួសទៅនេះ មានសិលាចារឹកនិយាយពីព្រះបាទរា-ជេន្ទ្រវរ្ម័ន ទ្រង់កសាងប្រាសាទមេបុណ្យនេះ ជាស្ពចទ្រទ្រង់ឱ្យបូជា អំណាចបកជស័ក្ដិជ័ទ្ធទ័ន្ទស ផ្សាយអំណាចទូទៅដល់សមុទ្រ... ។

ប្រាសាទនេះ គេកំពុងរៀបចំធ្វើឡើងជាថ្មីវិញ មានកំពស់ទាបជាងប្រាសាទប្រែរូប, របស់ដែលត្រូវមើល គឺប្រាសាទនេះ គេច្រើនធ្វើពីឥដ្ឋ ស៊ីមង់តិ៍ ហើយមានដំរីនៅត្រង់ជ្រុងមនុស្សខាងក្រោមចំនួន ៤ ថ្នាក់ ដំរីនេះ.

មានវៀនកន្ទឹងកណ្ដឹង, នៅថ្នាក់ទី ១ មានប្រាសាទ ៦, នៅថ្នាក់ទី ២ មាន ប្រាសាទតូចជារង្វង់ព័ទ្ធជុំវិញ, ថ្នាក់ទី ៣ ប្រាសាទកណ្ដាលធំខ្ពស់ មានជណ្ដើរឡើងបានទាំង ៤ ទិស ហើយមានប្រាសាទតូចៗ ស្ថិតនៅគ្រប់ជ្រុង អនុទិស មានសីហៈជាទ្វារបាលនៅតាមគ្រប់ជណ្ដើរ; នៅលានថ្នាក់ទី ២ មានទទឹកឆ្លាក់ជាក្បាលសីហៈសម្រាប់បង្ហូរទឹកចេញ ។

ប្រាសាទមេបុណ្យនេះ ព្រះបាទរាជេន្ទ្រវរ្ម័នទី ២ ទ្រង់កសាងក្នុង ខាងចុងសតវត្សរ៍ទី ១៥ នៃពុទ្ធសករាជ (ព. ស. ១៤៩៧) ដើម្បីឧទ្ទិស ថ្វាយសាសនាព្រាហ្មណ៍ ។

លុះមើលរួចហើយ ត្រូវឡើងជិះយន្តទៅទៀត ទៅបន្តដល់ស្ទឹង សៀមរាប មានស្ពានស៊ីម៉ងត៍ មើលទៅឃើញទឹកថ្លាយង់គួរមុជជំរះកាយ, ផុតស្ពានទៅទៀត មានប្រាសាទមួយស្ថិតប្រហែលជាខាងកើត មើល ឃើញគោបុរៈក្រៅ មានដើមឈើដុះពុះពាក់កណ្ដាលដូចជាសក់ មាន មែកស្រស់ស្រាយ គេហៅឈ្មោះថា ប្រាសាទតាសោម ។

## ប្រាសាទតាសោម

ប្រាសាទតាសោម ស្ថិតនៅជិតគីឡូម៉ែត្រលេខ ៨ នៃផ្លូវធំ មានគោបុរៈបែរមុខលោកេស្វរៈទាំង៤ ដូចបានឃើញនៅប្រាសាទនគរធំ, ប្រាសាទតាព្រហ្ម, ប្រាសាទបន្ទាយក្តី ការរចនាសម័យជាមួយគ្នា ។

អ្នកមើល, ត្រូវឈប់រថយន្តហើយ ចូលតាមគោបុរៈខាងលិចនៃកំពែងខាងក្រៅ ដែលមានកំពូលដុះសក់វែងនឹងដើមជ្រៃ, កំពែងនេះ បណ្តោយ ២៤០ម៉ែត្រពីខាងលិចទៅខាងកើត, ទទឹង ២០០ ម៉ែត្រពីខាងជើងទៅខាងត្បូង, តទៅ គេត្រូវឆ្លងស្រះមួយទៀត តែឥឡូវគោកអស់ហើយ ។ ប្រាសាទនេះ គេមិនទាន់កាប់ឆ្ការព្រៃ គេទុកឲ្យនៅតាមសភាពដើម ដែលមានរុក្ខលតាជាតិញ៉ាំញី តែអាចដើរចូលមើលបានយ៉ាងស្រួលមិនពិបាកឡើយ ។ អ្នកមើល, លុះឆ្លងផុតស្រះទៅកំពែងជាន់ទី២ហើយ ត្រូវចូលទៅតាមទ្វារតូចខាងទិសនិរតី ទ្វារតូចទិសពាយ័ព្យ ដើមជ្រៃដុះពាក់ឫសជិតចូលមិនបាន, នៅហោជាងនៃកេងទិសក្នុងជុំវិញប្រាសាទកណ្តាល មានឆ្លាក់រឿងក្នុងព្រះពុទ្ធសាសនា, នៅខាងកើតទីវាល, ក្នុងកំពែងទី២មានធម្មសាលាពីរ ។ លុះមើលរួចហើយ គេអាចចេញមកវិញ តាមផ្លូវទិសឦសាន តាមទ្វារកោពទិសខាងកើត ហើយដើរត្រឡប់មកខាងលិច វៀចបែរទៅខាងជើង ។

គោបុរៈខាងកើត មានសណ្ឋានដូចគោបុរៈខាងលិចដែលបានពោលរួចហើយ ។

នៅខាងក្នុងកំពែងក្រៅ មានដើមឈើដុះដេរដាសពាសពេញ មានដើមធ្នៀ ដល់ផ្លូវជុំវិញទេព្រៃ, មានផ្ទុំ មានសេដាក់ធ្លាញញីកសា ។

ប្រាសាទតាសោមនេះ ព្រះបាទជ័យវរ្ម័នទី៧ ទ្រង់កសាងក្នុងសត-វត្សរ៍ទី ១៨ នៃពុទ្ធសករាជ (ព.ស. ១៧២៦-១៧៦៦) ដើម្បីឧទ្ទិសថ្វាយដល់ព្រះពុទ្ធសាសនា ។

លុះមើលរួចហើយ ត្រូវឡើងជិះរថយន្តសំដៅទៅតាមផ្លូវធំ ត្រង់ទៅខាងជើង ទៅបន្តិច បត់ត្រង់ទៅខាងលិចចំនួនពីរគីឡូម៉ែត្រ នឹងឃើញផ្លូវរទេះមួយ នៅខាងជើងផ្លូវថ្នល់ ចុះដើរកាត់ព្រៃបន្តិច នឹងដល់ប្រាសាទមួយអន្តរាយអស់ ឈ្មោះ ប្រាសាទក្រោលគោ ។

## ប្រាសាទក្រោលគោ

ប្រាសាទនេះ, មានការរចនាប្រហែលគ្នានឹងនាគព័ន្ធ មានរូបលោកេស្វរៈ, នៅហោជាងខ្ពស់មានរឿងព្រះនារាយណ៍, នៅហោជាងដែលធ្លាក់ធ្លាក់មកលើដីខាងទិសអាគ្នេយ៍ មានរឿងក្រិស្ណៈច្រត់ ដើម្បីការពារហ្វូងសត្វពាហនៈនឹងគង្វាល ។

កំពែងព័ទ្ធខាងក្រៅ ធ្វើពីថ្មបាយក្រៀម បណ្ដោយ៣៥ម៉ែត្រ ទទឹង២៨ ម៉ែត្រ មានចំណាននឹងគោបុរៈចូលពីខាងកើត, នៅខាងត្បូង, ខាងលិច, ខាងជើង មានស្រះព័ទ្ធជុំវិញ ។

លុះមើលរួចហើយ ត្រូវថយត្រឡប់មកវិញ ទៀតរថយន្តបត់ទៅខាងលិចបន្តិច នឹងឃើញថ្នល់ខាងឆ្វេងដៃ ជាប់ពីផ្លូវធំ ផ្លូវនេះទៅប្រាសាទនាគព័ន្ធ ។



ភាពប្រាសាទនាគព័ន្ធ ដែលគេកាប់ឆ្ការព្រៃហើយ
ការរចនាថែមប្រាសាទជាយ័ន រវាង គ.ស. ១៩៣០

(តាមរូបថត ស.គ.ប.)

## ប្រាសាទនាគព័ន្ធ

តាមផ្លូវធំ នៅចំគីឡូម៉ែត្រលេខ ៦ មានផ្លូវបែកទៅខាងត្បូងកាត់ព្រៃធំ រហូតដល់កំពែងខាងជើង ឥឡូវនេះឃើញតែទំនប់ដីខ្ពស់. កំពែងក្រៅនេះ ទំហំ ៣៥០ ម៉ែត្របួនជ្រុងស្មើ ៗ ជ្រុងកំពែងទាំង៤ទិស តាមលោក ហ. ម៉ាស្សាល់ លោកសន្និដ្ឋានថា ប្រហែលជាមានរូបដំរីនៅគ្រប់ជ្រុងទាំងអស់ ដូចប្រាសាទមេបុណ្យ ព្រោះឃើញមានរូបដំរីនៅជ្រុងពាយ័ព្យ. លោកយល់ម្យ៉ាងទៀតថា ទីប្រាសាទនាគព័ន្ធនេះ ស៊ីអស់បណ្ដោយ ៣ គីឡូម៉ែត្រ ទទឹង ៩០០ ម៉ែត្រ ហើយជាប់គ្នាពីប្រាសាទព្រះខ័នមក ដូចស្រះស្រង់ជាប់គ្នានឹងបន្ទាយក្ដី ។

នៅក្នុងកំពែងខាងក្រៅ មានស្រះធំ បួនជ្រុងស្មើ នៅគ្រប់ទិស, ត្រង់ស្រះធំនេះ មានស្រះតូចៗស្ថិតនៅគ្រប់ទិសទៀត ជិតដល់ស្រះធំកណ្ដាល ដែលជាទីប្រតិស្ឋានប្រាសាទនាគព័ន្ធ, ស្រះអស់នេះ សុទ្ធតែមានថ្មក់ជាជណ្ដើរចុះទៅកាន់ទឹក ។ ឯស្រះធំកណ្ដាល មានប្រាសាទតូចៗគ្រប់ទិសទាំងបួន ជាទីបង្ហូរទឹកទៅកាន់ស្រះតូចៗដែលស្ថិតនៅគ្រប់ទិសទាំង៤, ប្រាសាទតូចៗនេះ បែរមុខចេញក្រៅ មានសណ្ឋានជារូបបើកមុខ ហើយធ្លាក់ថ្មជាខាងសណ្ឋានដូចផ្កាឈូក កាលបើបើកទឹកទៅ ទឹកនឹងហូរចូលទៅកាន់ស្រះទាំង៤ តាមថ្មដែលគេឆ្លាក់ជាក្បាលផ្សេងៗគ្នា

ខាងកើតជាក្បាលមនុស្ស, ខាងត្បូងជាក្បាលសីហៈ, ខាងលិចជាក្បាលគោ[១] ខាងជើងជាក្បាលសេះ, កាលបើទឹកស្រះធំកណ្ដាលពេញ ក៏ហៀរហូរចេញមកកាន់ស្រះតូចៗ ដែលនៅគ្រប់ទិស ។ នៅទិសខាងកើត មានសំរិទ្ធិ កាលគេចាក់ទឹកតាមទទឹកនោះ ទឹកក៏ហូរតាមទៅលើយោនីនាង១មាគោតវតី ហើយហូរធ្លាក់ចុះមកក្រោម បើមានមនុស្សចុះនៅអង្គុយពីក្រោមទឹកហូរធ្លាក់លើក្បាលល្មមស្រួល ៗ នៅរោងជាងប្រាសាទតូចៗទាំង ៤ ទិស មានរូបលោកេស្វរៈកំពុងធ្វើសេចក្ដីសង្គ្រោះមនុស្សក្រៀកក្រមនុស្សឈឺចាប់ និងកំពុងប្រោសផង ។

នៅកណ្ដាលស្រះធំ ជាទីប្រតិស្ឋានប្រាសាទនាគព័ន្ធ មានសណ្ឋានជាកោះមូលខ្ពស់ឡើង, ប្រាសាទនេះ ស្ថិតនៅលើផ្ចិតនាគពីរមូលយ៉ាងជំ កន្ទុយនាគទាំងពីរមកឡើងព័ទ្ធព័ន្ធគ្នា ក្បាញ់ឡើងលើនៅទិសខាងលិច, ក្បាលនៅទិសខាងកើត ។ ប្រាសាទនេះតូច មានសណ្ឋានដូចជាប្រាង្គ បែរមុខទៅខាងកើត ស្ថិតនៅលើស្រទាប់ផ្កាឈូក ទ្រង់ស័ក្តិសម ។ កាលពីដើម មានត្រានមួយជើងដុះចំពីលើប្រាសាទ ចាក់ឬសព័ទ្ធជុំវិញប្រាសាទ, មានមែកសំយាកស្រសាយដូចជាសក់ ឬ ដៃគ្រញាំងពីលើ, សព្វថ្ងៃនេះ, ខ្ទង់ធ្លាញ់ធ្លាក់ខ្ទេចអស់ គួរឲ្យស្ដាយ–ព្រោះអស់គ្រឿង

(១) សៀវភៅ ហ. ម៉ាះសាល់ (H. Marchal) ថាក្បាលសេះ; សៀវភៅព្រះតេជព្រះគុណព្រះ[illegible] តាមអ្នកដំណើរចិន ជៀវ តាក្វាន់ ថា ក្បាលគោវិញ ។



រូបលោកេស្វរៈនៅទ្វារបញ្ឆោត, នៅហោជាងខាងលើ
ផ្ទៃនៃកាលពោធិសត្វទ្រង់គង់លើកណ្ដាលកាលចេញសាងនិក្ខមន៍ស្តូបណ៍
ប្រាសាទនាគព័ន្ធ

( តាមរូបថត ស.ប.ប.)

អលង្ការជាច្រើនល្អ ហើយគេកាប់រំលោះចេញនៅសល់តែប្រាសាទទទេ ។

នៅលើស៊ុមទ្វារខាងកើត, មានរូបចម្លាក់កាលព្រះពោធិសត្វកាត់កោរព្រះកេសាទ្រង់ព្រះផ្នួស ខាងក្រោម, សេះកណ្ឋកៈនិងឆន្នអាមាត្យ ស៊ុមខាងត្បូងមានរូបដំរី, នៅបន្ទប់បញ្ចកខាងជើងនិងខាងលិច មានរូបលោកេស្វរៈ, ខាងត្បូង រូបលោកេស្វរៈនិងព្រះអាទិត្យព្រះចន្ទ្រ. ក្បាច់ចម្លាក់នេះ សុទ្ធសឹងតែល្អចំឡែក; ខាងក្នុងប្រាសាទ មានព្រះពុទ្ធរូបនាគប្រក់ ដែលគេយកមកដម្កល់ទុកជាខាងក្រោយ ។

នៅខាងមុខប្រាសាទនេះ សេះមួយកំពុងហោះល្បឿនលឿន, ទ្រង់ព្រាយបញ្ចូនខ្លួន មានចាប់តោងមនុស្សគោងកន្ទុយ ហាក់ដូចជាមានមេត្តាករុណា ស្រោចស្រង់ហោះនាំទៅកាន់សិរីស្ថាន, សេះនេះឈ្មោះ ពលាហកៈ(១) ។ សេះពលាហកៈនេះ តាមលោក ល. ហ្វីណូត៍ និង វ. គោលូបេវ លោកនិយាយថា មានសិលាចារឹកនៅវិមានអាកាស សេចក្តីថា ពោធិសត្វលោកេស្វរៈ ដំណែងជាសេះពលាហកៈ ហោះទៅស្រោចស្រង់មហាជនស៊ីប្រុស ដែលធ្លាយសំពៅលិចលង់នៅកណ្តាលមហាសមុទ្រ បានទៅផែកស្រ័យនៅកោះនាងយក្ខិនីមួយ, នាងយក្ខិនីនេះ ចាប់បណ្តាជនទាំងនោះគោរពជាអាហារ បានពោធិសត្វលោកេស្វរៈ ដែលដំណែង

(១) ក្នុងគម្ពីរបាលី មានជាតកមួយ ឈ្មោះពលាហកជាតក មានសេចក្តីដូចគ្នានឹងរឿងនេះ ។

ជាសេះគលាហកៈ ហោះទៅស្រោចស្រង់នាំយកបណ្តាជននោះមកកាន់ជម្ពូទ្វីប ដែលជាស្រុកទេសរៀងខ្លួន បានសេចក្តីសុខសប្បាយ ។ រូបសេះគលាហកៈនេះ នូវអស្ចារ្យដល់គំនិតអ្នកគិតប្រតិស្ឋានឡើងណាស់ ព្រោះមានថ្វីដៃយ៉ាងសំខាន់ ពិបាកប្រាប់តួប្រៀប ។

កាលបើជញ្ជឹងគិតមើល, គេនឹងឃើញគំនិតឡើងថា ប្រាសាទនាគព័ន្ធនេះ គេកសាងតំណាងឲ្យកន្លែងមួយ មានទ្វីប៤, មហាសមុទ្រ៤ ជាបរិវេត្រ កណ្តាលប្រតិស្ឋានភ្នំព្រះសុមេរុ មានភ្នំសត្តបរិភណ្ឌ៧ជាន់ នឹងសត្តសិទន្តរ ៧ ជាន់ ជុំវិញភ្នំព្រះសុមេរុ តាមជំនឿនៃជនជាន់បុរាណ ។

ប្រាសាទនាគព័ន្ធនេះ ព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់កសាងក្នុងកណ្តាលសតវត្សរ៍ទី ១៨ នៃពុទ្ធសករាជ (ព.ស.១៧២៤-១៧៤៤) ដើម្បីទុំសក្ការដល់ពោធិសត្វលោកេស្វរ. ។

លុះមើលរួចហើយ ត្រឡប់ចេញមកតាមផ្លូវដដែល ដល់មកផ្លូវធំ ត្រង់មកខាងលិចបន្តិច នឹងឃើញផ្លូវបត់មួយទៀត ហើយចូលទៅមើលប្រាសាទព្រះខាន់ តាមទិសខាងកើត ។



មុខលោកេស្វរៈ នៅលើកំពូលប្រាសាទព្រះខាន់ ទ្វារចូលខាងលិច
ការរចនាបែបបាយ័ន រវាង គ.ស. ១៣៤០
(តាមរូបថត ព.ស.ប.)

## ប្រាសាទព្រះខាន់

ផ្លូវធំ ចេញតាមគោបុរៈខាងទិសជើង, នៅចន្លោះគីឡូម៉ែត្រលេខ ៦ និងលេខ៧ មានប្រាសាទធំយ៉ាងល្អវិសេសមួយ ឈ្មោះ ព្រះខាន់ ។

វិជ្ជាគសាងប្រាសាទនេះ ដូចប្រាសាទតាព្រហ្ម និងប្រាសាទបន្ទាយក្តី ប៉ុន្តែមានទំនំទូលាយសមជាង កំពែងទាំងក្រៅធ្វើពីថ្មបាយក្រៀម បណ្តោយ ៨០០ម៉ែត្រ ទទឹង៧០០ម៉ែត្រ, មានស្ទឹងគូជុំវិញ លើកផ្លូវចូលទាំង ៤ ទិស, ផ្លូវចូលទាំង ៤ ទិសនេះ ប្រកបដោយបង្កាន់ដៃអសុរនិងទេវតាទាញនាគធ្វើជាព្រែក; ទិសខាងកើត, គប់បង្កាន់ដៃអសុរនិងទេវតាទាញព្រែកនេះ មានបង្គោលសីមាព័ទ្ធអមផ្លូវផង ។

គោបុរៈទាំងអស់នៃកំពែងខាងក្រៅ វិចិត្រគួរយើងចាប់មើល ស្អាត មានទ្វារ៣, ទ្វារមួយៗ មានកំពូលខ្ពស់ប្រដាប់ដោយក្បាច់ផ្កាឈូក, កំពូលទ្វារកណ្តាលនៃគោបុរៈខាងលិច រលំបាក់ខូចហើយ, ទ្វារអមទាំងសងខាង មានស៊ុមទាំងក្នុងទាំងក្រៅ, គោបុរៈកណ្តាល សម្រាប់ក្បួនទ័ពក្បួនពិធីបុណ្យផ្សេងៗ; នៅសងខាងគោបុរៈ មានរូបគ្រុឌចេញធំ ទ្រាក់ភ្ជាប់នៅជញ្ជាំងកំពែង ។

លុះចូលផុតទ្វារទៅ គេត្រូវដើរតាមផ្លូវតូច អមដោយព្រៃព្រឹក្សាលតាជាតិ ប្រកបដោយសូរសំឡេងបក្សីបក្សាហាសយំអឺងកងរំពងពាសពេញព្រៃ, នៅមុខប្រាសាទប្រហែល ៦០ម៉ែត្រ មានធម្មសាលា

ក្នុងរង្វង់នៃផ្កាឈូកនេះគេឆ្លាក់ជាព្រះពុទ្ធរូបដែរ ទុំនេះក៏ត្រូវគេកោសលុបចោល អស់ទៅវិញ ឃើញនៅសល់តែស្នាមកោសលុបនោះ ត្រង់កន្លែងខ្លះ គេឆ្លាក់ថែមជារូបឥសីទៀតវិញ ។

នៅក្នុងកំពែងទី ២, ប្រាសាទខ្លះ មានហោជាងឆ្លាក់ជារូបលោកេ-ស្វរៈ ហោជាងខ្លះមានរឿងព្រះពុទ្ធសាសនា ។ នៅក្នុងកំពែងទី ៣, ផ្តែរ ឈើទ្វារ មានរូបស្ត្រីអប្សរកំពុងសល្អ, មានសសរមូល កន្លែងខ្លះ ប្រហែលជាធម្មន្តរៀង ។ នៅក្នុងកំពែងទី ៤ គេកំពុងរៀបចំទៅ មាន រូបខ្លះជារូបកិន្នរ នៅចន្លោះព្រះពុទ្ធរូបដែលគេកោសលុបចោលទៅ ។ ទាំង សង, ប្រាសាទមួយខាងជើង, នៅហោជាងមុខខាងត្បូង មានរូបព្រះឥស្សូរ មានផ្កាឈូកចេញពីខ្លួន អង្គុយលើប្រាសាទជើង ជិះលើមករ មានត្រីនៅ ក្រោម មានមនុស្សឈើនៅអម, មុខខាងកើត មានរូបព្រះឥស្សូរអង្គុយ កណ្តាលព្រះព្រហ្ម ។ នៅហោជាងដែលឆ្លាក់មកក្រោម, មានរឿងកម-ក្តី ត្រង់ព្រះកាមទិនកណ្តាប់ចាប់ដីនា, ហោជាងមួយទៀត, ឃើញព្រះ រាម ហនុមាននឹងព្រះលក្ស្មណ៍, ហោជាងខ្លះមានរូបព្រះអាទិត្យ ព្រះ ចន្ទ្រ ព្រះនារាយណ៍ នឹងរឿងកូរទឹកសមុទ្រ ។ លុះចេញផុតមក តាម ទ្វារខាងជើង មានទ្វារបាលពីរនាក់ធំសំបើម ដៃជើងមាំៗ មានដុំសាច់ ធំៗ នាំឱ្យយល់ថា សេនាខាងហាននសម័យនោះ មានរាងកាយក្រៀមណាយ៉ាង វិសេស ដូចប្រទេសទុំរូបសម័យនេះដែរ ។

ការមើលប្រាសាទនេះ គេគាប់ចូលពីគោបុរៈខាងលិចក៏បាន បើចូលពីខាងលិច ត្រូវឲ្យរថយន្តទៅឈប់ខាងកើត, បើចូលពីខាងកើត ឲ្យរថយន្តទៅឈប់ចាំខាងលិច ។

ប្រាសាទព្រះខាន់នេះ ព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់កសាងឡើង ឧទ្ទិសថ្វាយព្រះពុទ្ធសាសនា ក្នុងកណ្ដាលសតវត្សរ៍ទី ១៨ នៃពុទ្ធសករាជ (ព.ស. ១៧៦៦-១៧៦៦) ។ តាមសិលាចារឹក ដែលគេបានឃើញក្នុងប្រាសាទនេះ, លោក គ. សឺដែស បានបកស្រាយសិលាចារឹកនៅចុងបញ្ចាំប្រទេស បានពន្យល់ថា: "ប្រាសាទនេះ ព្រះបាទជ័យវរ្ម័នទី៧កសាងក្នុងព.ស. ១៧៣៦, ដើម្បីឧទ្ទិសថ្វាយពោធិសត្វលោកេស្វរៈ, ទ្រង់កសាងព្រះបរមរូបព្រះបាទធរណីន្ទ្រវរ្ម័ន ជាព្រះវររាជបិតា ជាទេវរាជតំណាងលោកេស្វរៈ, ដូចគ្នានឹងប្រាសាទតាព្រហ្ម, ស្ដេចទ្រង់កសាងព្រះបរមរូបព្រះវររាជជននី តំណាងនាងប្រាជ្ញាបារមិតា ក្នុងរវាង ៨ ឆ្នាំក្រោយប្រាសាទព្រះខាន់នេះ" ។

លុះមើលរួចហើយ ត្រូវឡើងរថយន្តមកតាមផ្លូវវិញ ចូលមកនគរធំ ជិតដល់នគរធំនៅ ៤០០ ម៉ែត្រ គួរចូលមើល ក្រោលដំរី, តាមផ្លូវតូចចូលទៅ ។

## ក្រោលដំរី

ក្រោលនេះ មានកំពែងថ្មបាយក្រៀម វង់មូល កំពស់ ៣ ម៉ែត្រ មានផ្លូវចូលពីរកន្លែង, ជាកន្លែងសម្រាប់ផ្សាំងដំរីដែលទើបនឹងចាប់បាន; នៅប្រទេសសៀម មានក្រោលដំរីដូចគ្នាដែរ គឺនៅក្រុងលុពបុរី ។ លុះមើលរួចហើយត្រូវឡើងរថយន្តចូលទៅតាមទ្វារនគរធំ ខាងជើង កាត់នគរធំ បាយ័ន នគរវត្ត មុខខាង ទៅសៀមរាបវិញ ។



ភាគប្រាសាទវត្តអង្គរ ដែលធំល្អត្រូវជាភាគហើយ
ការរចនាសម័យប្រាសាទនគរវត្ត រវាង គ. ស. ១.៦៥០

(តាមរូបថត ភ. ស. ប.)

### វគ្គ ទី ៧

# ប្រាសាទផ្សេងៗ

## ប្រាសាទវត្តអធ្វា

តាមផ្លូវខាងលិចដងស្ទឹង ចុះពីផ្សារសៀមរាបទៅភ្នំក្រោម នៅចន្លោះគីឡូម៉ែត្រលេខ ៦ និងលេខ ៧ មានផ្លូវមួយបែកចេញទៅខាងលិច. ត្រង់ផ្លូវបែកនេះ មានខ្លោងទ្វារឈើមួយដាក់ឈ្មោះថា "វត្តអធ្វា" ។ ផ្លូវនេះ គេអាចទៅដោយរថយន្តតូច-ធំបាន, កាត់វាលស្រែចំនួនជា ៨០០ ម៉ែត្រ គេនឹងដល់ទៅវត្តមួយឈ្មោះ វត្តអធ្វា, វត្តនេះគេកសាងថ្មី នៅជាប់នឹងកំពែងទិសខាងជើង ។

ប្រាសាទវត្តអធ្វា ជាប្រាសាទមួយល្អណាស់ដែរ មានសណ្ឋានទ្រង់ទ្រាយស្រដៀងប្រាសាទនគរវត្ត, គេកសាងបែរមុខទៅខាងលិចដូចគ្នា, មានកំពែងថ្មបាយក្រៀមព័ទ្ធជុំវិញ ។ ប្រាសាទធំស្ថិតនៅកណ្ដាលមានទ្វារ ៤, មានយ៉រលយចេញទៅខាងលិច, នៅយ៉រនេះ គេមើលឃើញព្រះពុទ្ធរូបខ្លះ គេលាបពណ៌ផ្សេងៗ; មានប្រាង្គស្ថិតនៅគ្រប់ជ្រុងអនុទិស ។ សព្វថ្ងៃ ប្រាសាទនេះវិនាសអន្តរាយទៅច្រើនហើយ, គេមិនទាន់អាចរកដើមកំណើតប្រាសាទបានថា គេកសាងពីកាលណា ឬស្ដេចណាកសាង, មើលតាមទំនង ក្បាច់ចម្លាក់ដូចក្នុងប្រាសាទនគរវត្ត ។ លុះមើលរួចហើយ, ទៀងរថយន្តទៅមើល ប្រាសាទភ្នំក្រោម ទៀត ។



ភាពប្រាសាទភ្នំក្រោម មើលចំពាក់កណ្ដាល
ការរចនាបែបប្រាសាទបាខែង រាវ ព.ស. ១៤៤៣

( តាមរូបថត ស.ច.ប. )

## ប្រាសាទភ្នំក្រោម

ត្រូវធ្វើដំណើរទៅតាមផ្លូវថ្នល់ស្ពឺនគរវៀនទៅ, បើគិតចំងាយពីផ្សារសៀមរាបទៅភ្នំក្រោមនេះ ប្រហែល ១៣ គីឡូម៉ែត្រ, ទៅដល់ភ្នំក្រោមមានផ្លូវឡើងទៅលើភ្នំ, ត្រូវប្រយ័ត្ន បើមានថយន្តតូចសឹមឡើង ថយន្តធំត្រូវឈប់នៅក្រោម, ព្រោះផ្លូវឡើងទៅនេះមានគ្រោះថ្នាក់ច្រើន ។

ភ្នំក្រោមជាភ្នំគ្រិល ត្រង់ទីខ្ពស់គេសាងជាប្រាសាទ ៣ ខ្នងរួមគ្នាបែរមុខទៅខាងលិច, មានទេវរូបតូច ៤ ខ្នងដែលបែរមុខទៅកើត, មានកំពែងព័ទ្ធជុំវិញ; កាលដែលកំពុងរៀបចំ, គេបានរកឃើញទេវរូបដែលបាក់បង់ទៅ គឺ ព្រះព្រហ្ម ព្រះឥសូរ និងព្រះវិស្ណុ, ឥឡូវនេះ, គេយកមកដំកល់ទុកនៅប្រាសាទនោះវិញ; នៅមុខប្រាសាទ, មានទ្វារបាលមួយធំ ៗ ប្រាសាទនេះល្អណាស់ដែរ, តែដោយប្រាសាទនេះស្ថិតនៅកណ្ដាលវាល· ត្រូវភ្លៀងត្រូវខ្យល់ខ្លាំងក៏ពុកផុយ របេះរបេកក្បាច់ចម្លាក់ស្ទើរតែអស់ នាំឲ្យខាតលំអជាច្រើន ។ នៅខាងមុខប្រាសាទនេះ តាមទីទំនាបកបស្ទើ មានវត្តមួយ, ខាងមុខវត្តនេះ មានទ្វារបាលមួយទៀត រូបស័ក្តិសម, មានអលង្ការដ៏វិចិត្រ ។

ការមើលប្រាសាទនេះ ត្រូវមើលពេលព្រឹកឬពេលល្ងាចត្រជាក់, ព្រោះពេលថ្ងៃក្ដៅណាស់ ហើយគ្មានដើមឈើជាម្លប់ជ្រកផង; កាលដែល

គេនៅលើភ្នំ គេអាចមើលទៅជុំវិញភ្នំបាន មើលទៅទិសត្បូង ឃើញខេត្ត សាចឆ្ងាយសន្ធឹមជាប់កន្ទុយភ្នែក ឃើញតែមេឃជាប់នឹងទឹកដូចមើលសមុទ្រ; មើលទៅទិសជើង ..ឃើញប្រាសាទនគរវត្ត, ឆ្ងាយទៅទៀត ឃើញភ្នំគូលែន, ភ្នំបូក, ភ្នំដងរែក ជាប់គ្នាវែង; មើលទៅទិសកើត, ទិសលិច, ឃើញវាលស្រែជាប់ជាយស៊ុមទ្រុមគួរឲ្យទស្សនាស ប្រាណរំ-ភើបចិត្ត, ពុំនោះ ងើបមើលទៅលើអាកាស, ឃើញពពកសាត់សៀង លយផុតទៅលើក្បាល ហាក់ដូចជាវិមានអណ្តែតទៅលើទេវាល័យ, មុខគួរសប្បាយអ្វីម៉្លេះទេ! ។



រូបទ្វារបាល គេទើបនឹងជីកបាននៅប្រាសាទភ្នំក្រោម
ការបោសសម្អាតប្រាសាទបាទែង ឆ្នាំ គ. ស. ១៩៦៣

( តាមរូបថត ស. ប. ប. )

## ព្រះឥន្ទកោសិយ៍

កាលយើងត្រឡប់មកដល់សៀមរាបហើយ, គួរទៅមើលប្រាសាទតូចមួយនៅវត្តព្រះឥន្ទកោសិយ៍ ដែលជាវត្តមួយស្ថិតនៅខាងលើផ្សារ, ត្រូវឡើងដើរតាមផ្លូវខាងលិចផងស្ទឹង, ហួសស្ពានថ្ម តាមមាត់ស្ទឹង ប្រកបដោយព្រឹក្សាមានសន្ទឹកទៀតវិទ្ធិ, ត្រជាក់ត្រឈឹងត្រឈៃ ជិតទៅដល់មន្ទីរថែរក្សានគរ មានស្ពានឈើមួយដើរឆ្លងទៅបាន ឆ្លងស្ពានទៅដល់វត្តព្រះឥន្ទកោសិយ៍ ។ នៅខាងកើតវត្ត មានប្រាសាទ ២ខ្នង, សុទ្ធឥដ្ឋមានក្បាច់រចនាដ៏ពិចិត្រ, មានសិលាចារឹកនៅមាត់ទ្វារ, ខាងក្នុងប្រាសាទមានព្រះពុទ្ធរូបជាច្រើនមានសណ្ឋានថ្លៃកាត់ផ្គា ខ្ទះស្ទើរតែយើងមិនដែលបានឃើញ ។ នៅខាងកើតថ្នល់ មានស្ពានវិហារពាស ឃើញតែទីទួលខ្ពស់ មានសន្ទឹកសិមា ។

## មេបុណ្យខាងលិច (បារាយ)

ពេលល្ងាច, ក្រោយដែលបានដើរមើលប្រាសាទបុរាណរួចហើយ ខ្ញុំទៅមុជទឹកជម្រះកាយ ជាទីកំសាន្ត នៅស្រះបារាយខាងលិច កុំភ្លេច ត្រូវយកសំពត់ងូតទឹកនិងប្រដាប់សំរាប់ងូតគ្រប់យ៉ាងទៅផង, មានកន្លែងសម្រាប់ផ្លាស់សំពត់ និងកន្លែងសម្រាប់សប្បាយប្រចាំស្រាប់ មានទូកសម្រាប់ជុំលេងកំសាន្តមួយ ។ ឯស្រះបារាយនេះ, ជាកន្លែងមុជទឹកជាទីរីករាយសប្បាយណាស់ ពេលថយខ្លួនចូលដល់ ឃើញទឹកថ្លាហ្វង់ ទាញភ្នែកឲ្យបាញ់ត្រង់ទៅរក នៅមាត់ស្រះ មានព្រឹក្សាទៀតស្រងាក់ ជុំជាយសំឡេងសត្វយាសយំពីរកេះរង់ ធ្វើឲ្យអ្នកមើលសប្បាយចិត្តចង់តែងកាព្យ ឬឲ្យចិត្តចង់ស្រែកច្រៀងថា អឺយ៉ៃ... ។

ស្រះបារាយនេះ មានប្រាសាទមួយស្ថិតនៅចំកណ្តាលស្រះ ឈ្មោះប្រាសាទ "មេបុណ្យ" ដូចប្រាសាទមេបុណ្យតាមផ្លូវទៅធំដែរ តែប្រាសាទមេបុណ្យតាមផ្លូវទៅធំគេឲ្យឈ្មោះ "មេបុណ្យខាងកើត", ប្រាសាទនេះ គេឲ្យឈ្មោះ "មេបុណ្យខាងលិច" ។ តាមដែលពិនិត្យមើល ឃើញមានតួប្រាសាទតូចតិច ស្ថិតនៅលើកោះតូចកណ្តាលស្រះ មានកំពែងព័ទ្ធជុំវិញ មានបង្កាន់ដៃខាងលយចេញពីទិសទៅខាងកើត, សព្វថ្ងៃនេះ ព្រៃព្រឹក្សាដុះគ្របពាសអគ្គកាយអស់ហើយ, គេឃើញ

មានតែទឹកថ្លាឈ្វេងល្អាចណាស់ពេញ. ត្រង់កន្លែងដែលជ្រៅ មានជម្រៅពី៤ម៉ែត្រទៅដល់៥ម៉ែត្រ; ស្រះនេះរាង៤ជ្រុងទ្រវែង បណ្ដោយ៨គីឡូ-ម៉ែត្រ ទទឹង៦គីឡូម៉ែត្រ ។ តាមសេចក្ដីយល់អ្នកខ្លះថា ស្រះបារាយនេះជាស្ពានកផនារី (ទំនប់ទឹក) អ្នកខ្លះថា ជាទីប្រជុំចុះនៃផ្លូវទឹកដែលគេសំរាប់ប្រើប្រាស់ទៅគ្រប់ក្រុង គ្រប់កាលនោះ ៗ អ្នកទៅមើលស្រះបារាយនេះ ត្រូវចេញទៅតាមផ្លូវពីក្រុងសៀមរាបទៅបាត់ដំបង ដល់គីឡូ-ម៉ែត្រលេខ ១៣ ត្រូវបត់ទៅតាមខាងស្ដាំដៃ ចូលទៅប្រហែល ៣០០ ម៉ែត្រ ដល់ស្រះបារាយនោះ, គេទៅដោយយានគ្រប់បែបបានយ៉ាងស្រួល ៗ តាមមាត់ស្រះខាងត្បូង ចម្ងាយពីសាលាឈប់សម្រាកប្រហែល ១០០០ ម៉ែត្រ, មានប្រាសាទតូចណាមួយបាក់បែកអស់, គេលើកក្ដីស្រះបារាយនេះត្រូវបាក់, គេទើបនឹងរកឃើញឥឡូវនេះឯង ។

## ប្រាសាទលលៃ · ប្រាសាទព្រះគោ
## និង ប្រាសាទបាគង

ប្រាសាទទាំង៣ នេះ ស្ថិតនៅជាជួរវៀនគ្នាពីទិសខាងជើងទៅទិសត្បូង ចម្ងាយពីគ្នាក្នុងមួយៗ ប្រហែល ១.៦០០ ម៉ែត្រ៖ អ្នកដំណើរដែលបាន ទៅដល់គីឡូម៉ែត្រលេខ ៣០១ តាមផ្លូវពីកំពង់ធំទៅសៀមរាប, បែរមើល ទៅខាងជើង, នៅកណ្តាលវាលស្រែ នឹងឃើញកំពូលប្រាសាទលលៃ ខ្ពស់ នៅខាងក្រោយវិហារវត្ត ដែលគេសាងថ្មីនេះ ។

### ប្រាសាទលលៃ

ប្រាសាទលលៃនេះ គេសាងជាប្រាង្គបួន[១] រៀងជាពីរជួរខាង មុខខាងក្រោយ ស្ថិតនៅលើទួលខ្ពស់ កណ្តាលបឹងព្រះឥសូរ មានកំ- ពែង៤ជាន់, ជាន់ទី២ ធ្វើពីឥដ្ឋបូកបាយអរឆ្លាក់ជាក្បាច់រស់រវើក មាន សណ្ឋានដូចប្រាសាទប្រែរូប មានសិលាចារឹកដូចប្រាសាទព្រះគោ បែរ មុខទៅខាងកើត ហើយមានទ្វារបញ្ឆោតទាំង៣ ទិស ផ្តែរលើទ្វារមាន ក្បាច់រចនាយ៉ាងល្អចំឡែកជាងប្រាសាទឯទៀត គួរឲ្យនឹកស្ងើចដល់វិស្វករ ដែលនឹកប្រតិស្ឋានធ្វើឡើង, នៅអមមាត់ទ្វារ ក្នុងប្រអប់ មានចម្លាក់ជា

(១) កាលពីដើម ប្រហែលជាមានប្រាសាទ៦ ស្ថិតនៅជាពីរជួរ តែលោកកសាងវត្តក្រោយ លោករំលាយប្រាសាទ ២ ចោលទៅនៅសល់តែ ៤ ។

រូបប្រាសាទ មានទ្វារបាលីដែកាន់សែបួត្រិស្វល់, នៅកណ្ដាលបឹងនោះ ប្រាសាទមានខ្ទង់ទឹកធ្វើពីថ្ម ថ្លុកពីប្រាសាទឯទៀត, ទងនោះទុកជាមេដើម ថែកសម្រាប់បង្ហូរទឹកទៅកាន់ស្រះព្រះស្រូវទាំង៤ទិស ដែលនៅជុំវិញប្រាសាទ, ឯទីស្រះដែលនៅជុំវិញប្រាសាទ រលាយបាត់អស់ហើយ ក្លាយទៅជាវាលស្រែម៉ែលមិនឃើញ ។

តាមសិលាចារឹកថា "ប្រាសាទនេះ ព្រះបាទជ័យវរ្ម័នទី ៧ កសាងក្នុងរវាងសតវត្សរ៍ទី ១២នៃគ្រិស្តសករាជ (ព.ស. ១៦៣៦) ដើម្បីឧទ្ទិសថ្វាយដល់ព្រះវិស្ណុ ក្នុងសាសនាព្រាហ្មណ៍" ។



សសរក្រឡឹងមូល គោបុរៈខាងកើតនៃប្រាសាទព្រះគោ
ការរចនាសម័យប្រាសាទព្រះគោ រវាង គ.ស. ១៤២៤

(តាមរូបថត ត.ស.ប.)



រូបទ្វារបាល នៅជ្រុងចំទ្វារខាងកើត ប្រាសាទព្រះគោ

( តាមរូបថត ព.ស.ប. )

## ប្រាសាទព្រះគោ

កាលបានមើលប្រាសាទលលៃរួចហើយ ត្រូវត្រឡប់ថយក្រោយ ហើយទន្ទឹមកាត់ផ្លូវចំទៅទិសត្បូង តាមផ្លូវតូច ដើម្បីទៅមើលប្រាសាទព្រះគោនឹងបាគង ។ ប្រាសាទនេះ គេហៅថា ប្រាសាទព្រះគោ ស្ថិតនៅចំកណ្ដាលផ្លូវកណ្ដាលវាលព្រៃ ជាចន្លោះប្រាសាទលលៃនឹងបាគង ។ អ្នកដំណើរត្រូវឈប់ហើយចុះទៅមើល ឬបង្ហួសទៅមើលប្រាសាទបាគងឲ្យហើយសិន សឹមត្រឡប់មកមើលវិញក៏បាន ។ ប្រាសាទព្រះគោមានកំពែង ៤ ជាន់ធ្វើពីថ្មបាយក្រៀម, កំពែងខាងក្រៅបណ្ដោយ ៨០០ ម៉ែត្រ ទទឹង ៤៥០ ម៉ែត្រ មានស្រះកើតនៅខាងក្នុង, កំពែងទី ២ ជិតគ្នានឹងកំពែងទី ១ ប្រហែល ៩៨ ម៉ែត្របួនជ្រុង, មានធម្មសាលមួយខ្នងស្ថិតនៅខាងត្បូង, គេទៅ ៦០ ម៉ែត្រ បានដល់ទៅកំពែងទី ៣ មានស្រះមួយនឹងប្រាសាទមានសសរមូលប្រកបក្បាច់, កំពែងទីបួន ៦០ ម៉ែត្រ ៤ ជ្រុងស្មើ, នៅក្នុងកំពែងនេះ, មានប្រាសាទ ៦ ខ្នង សង់រៀងគ្នាជាពីរជួរនៅលើទីទួលជាមួយគ្នា បែរមុខទៅខាងកើត ធ្វើពីឥដ្ឋបូកបាយអធ្វាក់ក្បាច់ ស៊ុមទ្វារធ្វើពីថ្ម ទ្វារបញ្ឆោត ៣ ទិស មានជណ្ដើរតូចៗឡើងទៅប្រាសាទ, អមទ្វារមានយក្ខិនីជាទ្វារបាល ដៃកាន់ត្រីសូល៍ នៅមុខប្រាសាទមានគោនន្ទិ ៣ ក្រាបគោរពបែរមុខទៅរកប្រាសាទ អាស្រ័យដោយហេតុនេះ បាន

ជាទីឲ្យឈ្មោះថា ប្រាសាទព្រះគោ ។ សត្វថ្មបាយអដែលគេបូកនៅ ជញ្ជាំងប្រាសាទ របេះធ្លាក់មកជាច្រើនកន្លែង ដែលមាននៅសល់ខ្លះ គេអាចមើលឃើញក្បាច់ផ្កាល្អិតដ៏មានឆ័យទៅខ្ទង់លំអដ៏លើស, ផ្តេរលើខ្លាំង ទ្វារ ទ្វាក់ទីនឹងក៏ល្អសំខាន់ណាស់ដែរ ។

មានទេវរូបមួយល្អចំណាប់ ជារូបមហាយាន គេកឃើញហើយគេទុកនៅទីនៃប្រាសាទទីមួយខាងលិច, តាមពិនិត្យមើលរូបនេះ គេស្គាល់ថា មិនមែនធ្វើឡើងក្នុងកាលពីជាន់ប្រាសាទនេះទេ ប្រហែលជាព្រះជ័យវរ្ម័ន យកមកដាក់តម្កល់ទុកខាងក្រោយ ដែលតាមលើកទ័ពមកច្បាំងក់យកនគរធំ កាលពីពុទ្ធសករាជ១៧២០; ក្នុងសិលាចារឹកនិយាយថា: ប្រាសាទ ៣ ខាងកើត គេឧទ្ទិសថ្វាយព្រះឥសូរ ដែលមាននាមខុំជាភាជាខេយ្យ, ប្រា-សាទ៣ខាងលិច គេឧទ្ទិសថ្វាយព្រះអគ្គទេពីព្រះឥសូរឈ្មោះនាងគៅរី ។ ប្រាសាទនេះ ព្រះបាទឥន្ទ្រវរ្ម័នទី ១ កសាងក្នុងរជ្ជសករាជទី ១៨ នៃពុទ្ធសករាជ (គ. ស. ១៤៤៤) ។



រូបព្រះឥស្វរ នាងឧមានិងនាងគង្គា មើលពីខាងក្រោយ
ទិសឦសានប្រាសាទបាគង
(តាមរូបថត ស.ប.ប.)



រូបព្រះឥស្វរ ខាងមុខនិងខាងឆ្វេង មានដោះចលើល
មើលពីមុខ ទិសឦសាន ប្រាសាទបាគង,
ការរចនាសម័យប្រាសាទព្រះគោ រវាង គ. ស. ៨.៦៨
(តាមរូបថត ស.ប.ប.)

# ប្រាសាទបាគង

ប្រាសាទដែលស្ថិតនៅខាងត្បូងបំផុត ក្នុងចំណោមប្រាសាទរលួស គឺ ប្រាសាទបាគង; អ្នកមើល, កាលបើបានទៅដល់ទិសខាងជើងនៃកំពែងខាងក្រៅហើយ ត្រូវបត់ចូលទៅតាមទ្វារទិសខាងកើត មានផ្លូវសម្រាប់ឲ្យឡានចូលទៅបានស្រួល, សព្វថ្ងៃប្រាសាទនេះ គេកំពុងរៀបចំឡើងជាថ្មី ផងហើយៗ; កាលពីដើម, ប្រាសាទកណ្តាលបាក់បែកស្ទើរតែអស់ សូម្បីថ្មប្រកបក្បាច់ក៏ខាតបាត់បង់ទៅជាច្រើន ។ កំពែងខាងក្រៅធ្វើពីថ្មបាយក្រៀម មួយចំណែកកប់បាត់នៅក្នុងដីព្រៃ មួយចំណែកទៀតបាក់បែកខ្ទេចអស់ មានបណ្តោយ ៨៥០ ម៉ែត្រ ទទឹង ៦៥០ ម៉ែត្រ; កំពែងទីពីរបណ្តោយ ៣៥០ ម៉ែត្រ ទទឹង ៣១០ ម៉ែត្រ មានប្រាសាទតូចៗជាច្រើន ដែលបាក់បែកខ្ទេចអស់ ក្នុងកំពែងនេះ មាននៅសល់ខ្លះ អាចមើលឃើញក្បាច់ចម្លាក់ផងដែរ; មានស្រះ (ស៊ិទ្ធ) ធំពីរជុំវិញ ទទឹង ៦០ ម៉ែត្រ នៅសល់តែទិសខាងកើត; មានផ្លូវធំពីរ មួយខាងកើត មួយខាងលិច, ផ្លូវនេះកាលពីដើម សុទ្ធតែមានបង្កាន់ដៃនាគទទឹងតាមសីមា, ឥឡូវនេះ វិនាសបាត់អស់ហើយ ។ កំពែងទី ៣ បណ្តោយ ១៥០ ម៉ែត្រ, ទទឹង ១៣៥ ម៉ែត្រ មានប្រាសាទជាច្រើននៅព័ទ្ធជុំវិញប្រាសាទធំ; ប្រាសាទធំកណ្តាលនេះ ស្រោបដោយថ្មប្រផេះ

គ្រឹះក្រោមទំហំ ៦០ ម៉ែត្រ, មានប្រាសាទ ៥ នៅពីខាងជុំវិញ សុទ្ធតែកសាងពីថ្មបាយក្រៀមសុទ្ធ ផ្តែរលើទ្វារឆ្លាក់ល្អៗ សសរអមទ្វារ បញ្ចាក់ប្រែកបក្កាច់សំរេក, ទ្វារបាលមីងក្បាលយក្សមុខសំបើម ធ្លាក់ចុះនៅក្រអប់ទ្វារបញ្ចោត ដូចប្រាសាទព្រះគោ និងលលៃដែរ, សំដៅនឹងឲ្យឃើញស្នាដៃទៀតផ្លាត នឹងការប៉ុនប្រសប់នៃវិស្វករក្នុងសម័យនោះ ៗ នៅទិសខាងកើត មានប្រាសាទជាច្រើនពីរកន្លែងនឹងខ្ទាត់ខ្ទៃ ទុកចំងាយក្រៀមថ្មបត្រែផ្ដែរ ប៉ុន្តែប្រាសាទអស់នេះ បាក់បែកស្ទើរតែអស់ហើយ, មានរូបព្រះវិស្ណុមួយនៅប្រាសាទទិសត្បូងខាងកើតស្អិតល្អណាស់ ដៃបួន កោះជក់ក្បាច់បន្តិច ឃើញមានដៃខ្ទប់ពីខាងក្រោយ, រូបនោះមាននីងចិត្តកំល្អណាស់ដែរ មើលហើយគួរឲ្យចាប់ចិត្ត, រូបនេះប្រហែលជាចម្លងពីរូបប្រែស្រួលណា? ៗ ខាងក្រៅនៃកំពែងខាងត្បូង មានក្តមួយដែលគេជីកនៃម៉ែនខុសជា ការគេសាងក្តនេះ ចាំឲ្យរួចខាតបុកណាតែជាច្រើន ហើយបណ្តាជនចាំទុកចិត្តមិនត្រូវយកគម្រាប់ទៀយ ៗ

ប្រាសាទកណ្តាលជាកំពូលមាន ៥ ជាន់ មានជាន់តូចៗជាចំណាត់ជាលំដាប់ទៅដល់ជាន់លើបំផុត មានជណ្តើរឡើងទៅលើត្រង់ទិសទាំង ៤, តែអ្នកឡើងមើល ត្រូវឡើងតាមជណ្តើរទិសខាងកើត ព្រោះមានជណ្តើរឡើងស្រួល ៗ តាមផ្លូវដើរចូលទៅ តាំងពីគោបុរៈខាងកើត គេនឹងប្រទះឃើញរូបគោ, ទ្វារបាលកងគៀក្រញាញ តាំងប្រាសាទនៅអមសង



រូបយក្ស នៅគ្រឹះថ្នាក់ទី ៤ នៃប្រាសាទបាគង
ការរចនាបែបប្រាសាទព្រះគោ រវាង ព.ស. ១៤២៤
( តាមរូបថត ស. ជ. ប. )

ខាង ក៏មានសណ្ឋានក្រអាញដូចគ្នាដែរ, តាមជណ្ដើរឡើងទៅលើ, ត្រង់ចាំងនៃថ្នាក់ គេមើលឃើញទ្វារបាល ដែលស្នាដៃមិនទាន់ចំណាន ទ្វាក់ក្ដាប់ទីធំដូចក្បាលជណ្ដើរឡើង, នៅជ្រុងអគ្គទិស មានរូបដំរី, នៅជ្រុងទិសធំមានសត្វសីហៈ, នៅថ្នាក់ទី ៣ មានប្រាសាទ ១៤ ព័ទ្ធជុំវិញ, នៅក្ដាប់ទីធំជញ្ជាំងថ្នាក់នីមួយៗ សុទ្ធតែមានរូបចម្លាក់រឿងសាសនាព្រាហ្មណ៍ តែរូបនេះល្អបរស្មើរទីធំអស់ហើយ, នៅថ្នាក់លើបំផុត ជាទីប្រតិស្ឋាននៃប្រាសាទកណ្ដាល, ប្រាសាទនេះ មានជណ្ដើរឡើងទៅកាន់ទិសទាំង ៤ បាន មានស្ត្រីអប្សរជាទ្វារបាល នៅតាមទ្វារដូចប្រាសាទបាគង ។ នៅហោជាងទ្វារខាងជើង មានរូបចម្លាក់កាលកពណ៌ ដែលសរសេរកើតជាខាងរុំព័ទ្ធព្រះលក្ស្មណ៍ មានស្លាបពេញកេមជុំវិញជាបរិការ ហោជាងខាងលិចវិស្ណុជិះលើយករ, ហោជាងខាងត្បូងល្អមើលមិនច្បាស់, ហោជាងខាងកើត ព្រះវិស្ណុដៃបួន ។

ប្រាសាទបាគងនេះ ជាគោលចារិកធំ ជាទីប្រតិស្ឋាននៃក្រុងបុរាណមុននគរធំ ឈ្មោះ ហរិហរាលយៈ ដូចប្រាសាទបាខែង ឈ្មោះ យៈ·សោធរបុរៈ ជាគោលចារិកធំនៃក្រុងនគរធំ, ព្រះបាទឥន្ទ្រវរ្ម័នទី ១ ទ្រង់កសាងដែលសង់នៅត្រូវទី ៩ នៃពុទ្ធសតវត្ស (ព.ស.១៤៤៤) ដើម្បីឧទ្ទិសថ្វាយដល់សាសនាព្រាហ្មណ៍, តមកខាងក្រោយ, ទើបមានលទ្ធិពុទ្ធសាសនាមហាយាន ចូលមកលាយឡំ ។



គោបុរៈកំពែងទី ៣ ប្រាសាទបន្ទាយស្រី

ការរចនាបែបប្រាសាទបន្ទាយស្រី រាវ៉ង ព. ស. ១.៥២៣

( តាមរូបថត ត. ស. ប. )

## ប្រាសាទបន្ទាយស្រី

ប្រាសាទបន្ទាយស្រីនេះ ស្ថិតនៅកណ្ដាលទ្រនំព្រៃធំ ខាងទិសឦសាននគរធំចំងាយ ២១ គីឡូម៉ែត្រ ។ ការទៅមើលប្រាសាទបន្ទាយស្រី, គេទៅមើលបានស្រួលតែរដូវប្រាំង តាមរថយន្តតូចធំ តែក្នុងរដូវវស្សា ពេលដែលមានភ្លៀងធំ ធ្លាក់ជ្រាំច្រើនពេក ទើបពិបាក បើភ្លៀងបង្គួរ ល្មមទេ បែរទៅជាស្រួលវិញ ព្រោះផ្លូវទៅកាន់ប្រាសាទនេះ មានដីខ្សាច់ចាំឲ្យរឹងហួតតាប់ស្រស់ដី ។ អ្នកដំណើរត្រូវចេញទៅតាមផ្លូវធំ ត្រង់គីឡូម៉ែត្រលេខ ១១ បត់តាមផ្លូវទៅភ្នំគូលែន, ប្រហែល ១.៨០០ ម៉ែត្រ ដល់ទៅភូមិខ្មែរមួយឈ្មោះ ភូមិប្រដាក ហើយបត់ទៅខាងឆ្វេងដៃ តាមផ្លូវគេទៅខាងជើង កាត់ត្រង់ទៅលើស្ទឹងធំ គឺស្ទឹងសៀមរាប, ផ្លូវត្រង់នេះសុទ្ធដីខ្សាច់ អ្នកកាន់ចង្កូតរថយន្តត្រូវប្រយ័ត្ន ។ ត្រូវឈប់នៅមាត់ស្ទឹងខាងត្បូង បើមានរថយន្ត, ហើយឆ្លងស្ពានឈើទៅ ត្រូវដើរតាមផ្លូវជើង មានព្រៃព្រឹក្សនៅអមសងខាង បន្តិចទៅដល់ប្រាសាទបន្ទាយស្រី ដែលស្ថិតនៅខាងស្ដាំស្ទឹង ។ ផ្លូវនេះ កាត់ចំពីខាងត្បូងគោបុរៈខាងកើតកំពែងខាងក្រៅ ។ អ្នកដើរមើល កាលបើបានចូលដល់ហើយ ត្រូវដើរទៅមើលទីលានខឿនគោបុរៈខាងកើតសិន សឹមត្រឡប់ចូលទៅមើលប្រាសាទនៅខាងលិច ។

បណ្ដាប្រាសាទទៅទៀត ប្រាសាទបន្ទាយស្រីនេះ ជាប្រាសាទល្អវិសេសមួយ មានឈ្មោះល្បីជាងគេ មានក្បាច់ល្អិតឆ្មាររស់រវើកជាងប្រាសាទទាំងអស់ ។ គេសាងបែរមុខទៅខាងបូព៌ទិស, តាមសិលាចារឹកប្រាសាទនេះ ឈ្មោះ ឥស្វរបុរៈ[(១)] ប្រែថា "បុរីនៃព្រះឥសូរ" មិនមែនឈ្មោះ បន្ទាយស្រី ដូចយើងស្គាល់ទេ, ព្រះបាទជយវរ្ម័នទី៥ ទ្រង់កសាងឧទ្ទិសថ្វាយដល់ព្រះឥសូរ ក្នុងខាងដើមសតវត្សរ៍ទី ១៦ នៃពុទ្ធសករាជ (ព.ស. ១៥១០) ។ ប្រាសាទនេះ មានកំពែងថ្មបាយក្រៀមព័ទ្ធ ៣ ជាន់ មានទីលានក្រាលថ្មវែងទៅទិសខាងកើត, មានគោបុរៈប្រកបដោយក្បាច់វិចិត្រ នៅចំពាក់កណ្ដាលទីលាន មានរោងទងខ្នាតខ្វែងជាក្រឡាចត្ត ចេញទៅខាងជើង១ ចេញទៅខាងត្បូង១ សុទ្ធសឹងប្រកបក្បាច់ចចាល្អវិចិត្រ; សព្វថ្ងៃនេះ បាក់ធ្លាក់អស់ហើយ សល់តែសសរទ្រូងប្រាងគួរឲ្យស្ដាយ; លុះមើលទីលានហើយ ត្រូវចូលទៅតាមគោបុរៈខាងកើតនៃកំពែងខាងក្រៅ មានទីលានកាត់ពីខាងកើតចូលទៅដល់ខាងលិច, មានសិង្ហអមខាងជើងខាងត្បូង ។ ត្រង់នេះ អ្នកមើលនឹងឃើញប្រាសាទជាច្រើន នឹងគោបុរៈមានហោជាងប្រកបដោយក្បាច់ចចា មានសន្លឹកភ្ញីល្វើវល្លិ៍ផ្ទៃ

(១) សៀវភៅលោក ហ. ម៉ារសាល់ (H. Marchal) ឈ្មោះ ត្រីកូខេមរៈឥស្វរៈ ប្រែថា "ស្ថាននៃព្រះឥសូរ ជាដំកូនព្រៃភត" ។



តេះបុះកំផែងទី ៣ ខាងលិច មុខខាងកើត ប្រាសាទបន្ទាយស្រី

(តាមរូបថត ព.ស.ប.)

ឲ្យស្ញើច, តទៅទៀត យើងឃើញប្រាសាទ ៣ ខ្នងមុខគ្នា ៗ ប្រាសាទនេះ កាលពីដើម, ដើមឈើដុះស្រោបបាក់បែកអស់ តែឥឡូវនេះ គេកាប់ឆ្ការ ព្រុះរើរៀបចំជាថ្មីវិញបានល្អដូចដើម, គេសង់ជាតួប្រាង្គ ៣ ខ្នង[១] ជួរស្មើ ជាប់ទន្ទឹមគ្នា ពីខាងជើងទៅខាងត្បូង មានទ្វារចូលពីខាងកើត ៣ ទិស ជាទ្វារបញ្ឆោត, ប្រាសាទកណ្ដាល មានយ៉ាលយ៉ះចេញមកខាងកើត, ខាងមុខមានធម្មន្ទីរមួយខ្នង នៅទិសឦសាន ១ ទិសអគ្នេយ៍ ១, ធម្មន្ទីរនេះបែរមុខទៅខាងលិច ៗ ប្រាសាទបន្ទាយស្រីនេះ ជាប្រាសាទមួយ ដែលមានក្បាច់ចនាយ៉ាងបញ្ចង់ចេតនាយ មានសន្លឹកក្បាច់ល្អិតវិលវល់ល្អិត ឆ្មារល្អស្រស់ស្រាវក្រៃ ដែលគួរឲ្យនឹកគិតជាយ៉ាងឥតមានសន្ទុះសង្ស័យថា ទេពកាន់និម្មិត ៗ សន្លឹកក្បាច់មួយទំនងដែលវិលវល់ជុំមូលក្រឡង់ អាចទាញភ្នែកឲ្យគយគន់មៀងមើលម្ដងហើយម្ដងទៀត ទើបឲ្យឈរព្រឹងកាំង ភ្លេចខ្លួនដញ្ញកមាត់ដោយសេចក្ដីស្ញើចស្ញែង សំដែងឲ្យឃើញថា សម័យកសាងប្រាសាទបន្ទាយស្រីនេះ ជាសម័យនៃការបេះដើរស្នាក់ជំនាញ យ៉ាងចាស់ក្លារបស់គណៈជាងក្នុងសម័យនោះ ៗ

---

(១) តាមសណ្ឋាប់សាសនាព្រាហ្មណ៍ គេមានត្រៃទេវរូបជាទីគោរព ហេតុនេះ បានជាគេកសាងប្រាសាទ ៣ ខ្នងទុកថ្វាយ ដល់ព្រះឥសូរាកណ្ដាល, ព្រះនារាយណ៍ខាងជើង, ព្រះព្រហ្មខាងត្បូង ៗ



រូបទេពតា ឆ្លាក់ជាប់នៅជញ្ជាំងប្រាសាទខាងជើង ទិសនិរតី
ប្រាសាទបន្ទាយស្រី

(តាមរូបថត ស. ច. ប.)

## រូបចម្លាក់នៅបោរាជាជ័

១. ធម្មទ្វារខាងជើង ហោជាងខាងកើត, និយាយពីរឿងក្រិស្ណៈនឹងពលរាមៈជាប្អូន ប្រកាន់ព្រៃព្រឹក្សកណ្ដាលហ្វូងសត្វ, ខាងលើព្រះឥន្ទ្រ គង់លើដំរីឯរាវ័ណក្បាល ៣ (ទ្រង់សំដែងឫទ្ធិឲ្យកើតជាភ្លៀងធំ ជាទីស្រោចស្រប់ព្រឹក្សលតាជាតិទាំងព្រៃពេក) ដែលធ្លាក់ទាំងហើយទៀលធ្លាក់ ក្នុងផ្ទៃអំណាក់ទឹកភ្លៀង ។

២ ធម្មទ្វារខាងជើង ហោជាងខាងលិច, និយាយពីរឿងក្រិស្ណៈសម្លាប់ស្ដេចកាម្សៈ នៅក្នុងប្រាសាទច្រើនជាន់ ឃើញមានស្រីស្នំក្រម-ការព្រះបរិពារជាច្រើន, ខាងក្រោម ឃើញមនុស្សស្លាប់ដោយស្នាដៃក្រិស្ណៈនិងពលរាមៈជាប្អូន, នៅអមសងខាងឃើញមេទ័ពជិះលើរថ ។

៣. ធម្មទ្វារខាងត្បូង ហោជាងខាងកើត, និយាយពីរឿងកបរក្តិត្រង់ក្រុងរាពណ៍ទសមុខ ចាប់ភ្នំកៃលាស ជាព្រះរាជដំណាក់ព្រះឥសូរអង្រួនដោយសេចក្តីឈ្លានីស ឃើញព្រះឥសូរចាប់គងនាងឧមា ដែលភិតភ័យឡើងលើភ្លៅ ឃើញពួកព្រះបរិពារភ័យស្ទុះស្ទាវត់ខ្ចាត់ខ្ចាយ ។

៤. ធម្មទ្វារខាងត្បូង ហោជាងខាងលិច, និយាយពីរឿងទេពកាមៈបាញ់ព្រះឥសូរដោយសរផ្កា ព្រះឥសូរគង់លើកំពូលភ្នំ នាងស័ក្តិគង់ជិតខាង, ស្ដេចទ្រង់សម្លឹងមើលទេពកាមៈ ដោយភ្នែកកណ្ដាលថ្ងាស, ទេពកាមៈនេះខ្លោចជាផេះធូលី ។



ផ្នែកខ្លះ ប្រាសាទបន្ទាយសំរែ

(តាមរូបថត ស ប.ម.)

## ប្រាសាទបន្ទាយសំរែ

ដើម្បីទៅមើលប្រាសាទនេះ គេត្រូវចេញទៅតាមផ្លូវធំ ដល់គីឡូម៉ែត្រលេខ១១ បត់តាមផ្លូវទៅភ្នំគូលែន កាត់ភូមិប្រទាក ត្រង់ទៅខាងកើត (កុំបត់ទៅខាងជើងតាមផ្លូវទៅភ្នំគូលែនទៀត) ទៅហួសពីទំនប់ស្រះបារាយខាងកើត ចំនួន៣៥០ម៉ែត្រ បត់ទៅខាងត្បូងខាងស្ដាំដៃ តែបន្តិចនឹងដល់គោបុរៈ ខាងជើងនៃកំពែងខាងក្រៅ ត្រូវឈប់រថយន្ត ហើយដើរសៀរតាមកំពែងទៅខាងកើត ផុតកំពែងបត់បន្តិចទៅខាងត្បូង នឹងដល់ទៅគោបុរៈធំខាងកើត ។

ប្រាសាទបន្ទាយសំរែ ទ្រង់ទ្រាយធំមាំ កសាងពីថ្មប្រៃផះ កំពែងក្រៅធ្វើពីថ្មបាយក្រៀម; ខាងមុខ មានចំណានប្រកបដោយបង្កាន់ដៃតាមក្បាលបើកគពារសៀនចេញទៅកាន់ទិសផ្សេងៗ មានសីហៈចាំជាទ្វារបាលនៅចាំគ្រប់ចាំងអស់ ។ អ្នកដំណាំងគួរ គួរទៅមើលហួតដល់គោបុរៈខាងកើតបំផុត កាលណាត្រឡប់មកវិញ មើលមកប្រាសាទនឹងឃើញទ្រង់ទ្រាយសំបើមដូចភ្នំ ។

គោបុរៈខាងកើតធំមាំសង្ហាស្អាតណាស់ តែក្បាច់ចម្លាក់ពុករិលរលួយអន្តរាយទៅច្រើន, កាលណាគេចូលហួសទៅក្នុងកំពែង គេនឹងឃើញប្រាសាទធំនៅកណ្ដាលខ្ពស់ត្រដែត មានថ្នល់យចេញមកខាងមុខ មានចម្លូតដើរបែរមុខទៅខាងលិចអបសង់ខាង, មានកំពែងចង្អៀតជុំវិញប្រាសាទៗ

រូបចម្លាក់ជាគ្រឿងអលង្ការល្អវិសេស ខាងប្រាសាទក៏សម្បូរម្យ៉ាង ណាស់ ក្បាច់ផ្តែរឈើខ្លាំងក្លា របស់ខ្មែរហាក់ដូចជាចែងនិយាយពីរឿង កែរព្រះវិស្ណុ, រឿងក្រឹស្ណៈស៊ូតាមៅកូនឲ្យបរ៍យ, រឿងក្រឹស្ណៈទ្រគំភ្នំគោវធ៌នៈ, រឿងទេវតានិងអសុរកួរសមុទ្រទឹកដោះជាដើម ។

ប្រាសាទបន្ទាយស្រីនេះ មិនទាន់មានទេសចរណ៍ឃើញប្រាកដជា គេកសាងជំនាន់ប្រាសាទណា ឬស្ដេចអង្គណាកសាង, តាមសន្និដ្ឋានមើល ទំនងជាយនិងការរចនាក្បូរទឹកប់បញ្ចូលក្បួនក្បាច់ប្រាសាទនគរវត្ត ក្នុង វត់ទសតវត្សរ៍ ១៧ នៃគ្រិស្តសករាជ ។



សីហៈ ធំនៅទីលានខាងកើត ប្រាសាទបន្ទាយសរ

(តាមរូបថត ត.ស.ប.)



ផ្តែរលើទ្វារខាងក្នុងនៃប្រាសាទកណ្តាល ប្រាសាទបន្ទាយស្រី

(តាមរូបថត ស.ប.ប.)

## សៀមរាប

បណ្ដាក្រុងទាំងឡាយ ដែលជាទីរួមខេត្ត ក្នុងកម្ពុជរដ្ឋ បើនិយាយតាមទីកន្លែងជារមណីយដ្ឋាន ក៏មិនមានក្រុងខេត្តណាយកឈ្នះក្រុងសៀមរាបបាន ពិតជាក្រុងសៀមរាបគួរជាទីគេ ។ តាមដងស្ទឹង, មានផ្លូវនៅត្រើយទាំងសងខាង ប្រកបដោយព្រៃព្រឹក្សាជាជំណាំ មានស្ទឹកទៀតរុំ ត្រជាក់ត្រឈឹងត្រឈៃគួរជាទីកំសាន្ត, ទឹកស្ទឹងថ្លាហូរ ពេញព្រៀបមាត់ច្រាំង ហូរមៗ, មានរហាត់ទឹកវិលរេគាំងឮស្នូរគ្រឹកអែប... តាំងពីខាងលើផ្សារហូតទៅខាងក្រោមផ្សារគួរឲ្យគយគន់ ។

នៅតាមដងស្ទឹងមានវត្តជាច្រើន ត្រើយខាងកើត តាំងពីលើស្ទឹងមកខាងក្រោម មានវត្តព្រះឥន្ទ្រកោសីយ៍, វត្តព្រះឥន្ទ្រកោសា, វត្តពោធិ៍លង្កា, វត្តកជបូត, វត្តដំណាក់, វត្តស្វាយ, វត្តពោធិ៍ព្រៅ, វត្តគន់មុជ ។ ត្រើយខាងលិច, ពីខាងលើទៅខាងក្រោម វត្តយុខណ្ណោះ វត្តលង្កា, វត្តថ្មី, វត្តព្រះព្រហ្មរ័ត្ន, វត្តអង្គ; បណ្ដាវត្តទាំងអស់នេះ វត្តដែលគួរចូលមើលនោះ គឺវត្តព្រះព្រហ្មរ័ត្ន និងវត្តដំណាក់ ។ វត្តព្រះព្រហ្មរ័ត្នជាវត្តបុរាណ គេប្រកបក្បាច់ចនាជាទីថ្លៃល្អប៉ុណ្ណោះ, ក្នុងវិហារ មានព្រះរូបបដិមាធំមួយអង្គ; នៅវត្តដំណាក់ មានសាលាបាលីរង, មានធម្មមន្ទីរ, មានចេតិយ

ខ្ពស់, មានយុវសាលា, ក្នុងវិហារមានពិពិធភណ្ឌ មានរបស់ប្លែកៗគួរចូលមើល គួរឲ្យសរសើរស្នាដៃលោកគ្រូមេគណ តាម ទិម ជាចៅអធិការ លោកខំប្រឹងប្រែងធ្វើឲ្យកើតឡើង ។

នៅស្ពានថ្ម មានចំការដ៏ធំសម្រាប់ចិញ្ចឹមសត្វព្រៃប្លែកៗទុកមើល ដូចខ្លាធំជាដើម; នៅក្រៅកន្លែងនេះ មានមន្ទីរលក់របស់ផ្សេងៗ ដូចរូបថត, ក្បាច់រចនាផ្សេងៗ លោក-អ្នកត្រូវការគួរអញ្ជើញចូលមើលកុំខាន ។

—៚—



# បញ្ជីព្រះនាមស្ដេច ទេវតា ឈ្មោះប្រាសាទនឹងទីស្ថាន នឹងពាក្យផ្សេងៗ

## ព្រះនាមស្ដេច


អគ្និមុខៈ មេទ័ពក្នុងបាណ្ឌុរៈ, . . . . . . ១២

កាឡុងៈ ព្រះរាជាក្នុងរឿងព្រេង, . . . . ២០៣

ការ៉ាវៈ កងទ័ពនៃដែនក្រុង, . . . . . . ១៤

ចិត្រគុប្តៈ ឈ្មោះស្មៀនព្រះយមរាជ, . . . ១៣

ជ័យរាជទេវី អគ្គមហេសីព្រះបាទជ័យវរ្ម័ន ទី ៧, . . . . . . . . . . ១៦០

បរមវិស្ណុលោក ព្រះរាជក្នុងព្រះកោដ្ឋនៃ ព្រះបាទសូរ្យវរ្ម័នទី២, ៣, ០៩

បាណ្ឌុរៈ កងទ័ពក្នុងបាណ្ឌុ, . . . . . . ១២

ពលរាជៈ ប្អូនក្រឹស្ណៈ, . . . . . . . . ២០៣

ពាណៈ ឈ្មោះអសុរជាសត្រូវនៃទេវតា, ២០

ពាលីន៍ <ពាលិនិ, ស្ដេចស្វា ក្នុងរឿង រាមកេរ្តិ៍, . . . . . . . . . . . ៤៨,៣៣

ភីស្មៈ មេទ័ពក្នុងកៅរវៈ, . . . . . . ៤២,៣៨

រាក្សសៈ ចង្រៃពពក, ដែលលួចនាង សីតា ក្នុងរឿងរាមកេរ្តិ៍, . . . . ២៨

រាពណ៍ យក្សជាគូសត្រូវនឹងព្រះរាម, . . ១៨

វិសេសៈ ឬ ពិភេក្ស ប្អូនរាពណ៍ ជាបរការ ព្រះរាម, . . . . . . . . . . ២៨

ស្រីវធិមៈ ឈ្មោះរាជ្យធំ ក្នុងរាជ្យព្រះបាទ សូរ្យវរ្ម័នទី ២, . . . . . . . ១៦

សីតា ទេពីព្រះរាមក្នុងរឿងរាមកេរ្តិ៍, ៤៦,២២

សុគ្រីព ប្អូនពាលីន៍ ស្ដេចស្វាសោធា ព្រះរាម, . . . . . . . ៤៨,៣៣


## ព្រះនាមទេពតាសាសនាព្រាហ្មណ៍នឹងពុទ្ធសាសនា


ឥន្ទ្រៈ ព្រះឥន្ទ្រ ទេពតាសាសនាព្រាហ្មណ៍, ២៩

ឥស្វរៈ ព្រះឥស្វរទេពតាសាសនាព្រាហ្មណ៍, ១៩

ឧមា សក្តិព្រះឥស្វរ, . . . . . . . . . ១៨

កាមៈ ទេពតាខាងកាមារម្មណ៍, ១៧, ៥៨, ២០៣

កុវេរៈ ទេពតាទ្រព្យសម្បត្តិ, ស្ដេចនៃពួក យក្ស, . . . . . . . . . . . . ២១,២២

ក្រឹស្ណៈ អវតារព្រះវិស្ណុ ក្នុងរឿងមហា- ភារតៈ, . . . . . . . . . . . ១៨,២០

គង្គា សក្តិព្រះឥស្វរៈ ឈ្មោះទន្លេនៅ ប្រទេសឥណ្ឌា, . . . . ៣៣, ១៩២

គណេសៈ បុត្រព្រះឥស្វរ និងនាង បារ្វតី, . . . . . . . . . . . . . ១៩

## ព្រះនាមទេវតាសាសនាព្រាហ្មណ៍ និងពុទ្ធសាសនា

នារាយណ៍ ឈ្មោះមួយនៃព្រះវិស្ណុ,.. ១៣៨
បរិតី សត្វព្រះឥសូរ,........ ២០
ព្រហ្ម ព្រះព្រហ្ម ទេវតាជាអ្នកបង្កើតលោក,............. ២២
មហេន្ទ្រៈ នាមមួយនៃព្រះឥសូរ,.... ៧៨
យមៈ ព្រះយមរាជ ស្ដេចស្ថាននរក, ២១,២២
លក្ស្មី សត្វព្រះវិស្ណុ,....... ១៨
លោកេស្វរៈ ពោធិសត្វមហាយាន,.. ៣៥
វរុណៈ ទេវតាខាងទឹកភ្លៀង,..... ២២
នន្ទិៈ គោឧព្រះឥសូរ,........ ២២
សិរិមហាមាយា អគ្គទេពីព្រះសិទ្ធត្ថកុមារ,............ ១១៦
សូរ្យៈ ព្រះអាទិត្យ ទេវតាសាសនាព្រាហ្មណ៍,........... ២៦
ស្កន្ទៈ (កុមារ) ឱរសព្រះឥសូរ ទេវតាចម្បាំង,.......... ២១,២២
ហេមស្រីវេត្ថៈ គោឧព្រះឥសូរ,ជាទេវតាធំមានស្នែងមាស,....... ៧៩

## ឈ្មោះប្រាសាទនិងទីស្ថាន

អយុធ្យា ឬ អយោធ្យា រាជធានីព្រះរាមក្នុងរឿងរាមកេរ្តិ៍,........ ២៨
អស្សកប្រទេស ឬ ប្រទេសអស្សកៈ ប្រទេសខាងទិសពាយ័ព្យ,ទ្វីបអឺរុប ...៣,១៣២
ឥន្ទ្រាទ្រី ភ្នំធំសម្រាប់បូជាទេវតាធំ, ឈ្មោះភ្នំបាខែង,........ ៣៣
ឦឝ្វរបុរៈ បុរីនៃព្រះឥសូរ, ឈ្មោះប្រាសាទបន្ទាយស្រី,.......... ១៩៨
កៃលាសៈ ស្ថានព្រះឥសូរ,...... ១៨
គោវធ៌នៈ ឈ្មោះភ្នំដែលក្រឹស្ណៈទ្រការពារហ្វូងសត្វ,........ ១៩,២១០
ជាការ ឈ្មោះប្រាសាទទេពវត្តថ្នាក់ទី ៣,......... ១១,២៩
លុម្ពិនី ឈ្មោះសួនដែលព្រះសក្យមុនីគោតមទ្រង់ប្រសូត,.... ១១៦
មន្ទរ ឈ្មោះភ្នំដែលពួកទេវតានិងអសុរយកធ្វើជាស្នូលទាញកូរសមុទ្រ, ១៨
យសោធរគិរី ភ្នំទ្រទ្រង់នូវយស,ឈ្មោះប្រាសាទបាយ័ន,......... ៦២
យសោធរេឝ្វរៈ ព្រះឥសូរទ្រទ្រង់នូវយស, ឈ្មោះភ្នំបាខែង,...... ៣៣,១៩៨
យសោធរេឝ្វរបុរៈ បុរីនៃព្រះឥសូរ ទ្រទ្រង់នូវយស, ឈ្មោះរាជធានីនគរធំ, . ៣៨

## ឈ្មោះប្រាសាទនិងទីស្ថាន

គិរិបទ: ឈ្មោះភ្នំជាទីព្រះមហេន្ទ្រ, ភ្នំគូលែន ឬ?,.............. ១៦
សុមេរុ ឈ្មោះភ្នំក្នុងរឿងព្រេង,១១,៣៣,១៤៦
ហរិហរាលយៈ ស្ថានព្រះហរិហរៈ,
ឈ្មោះប្រាសាទបាគង,...... ១៩៥
ហេមាទ្រី ភ្នំមាស,ឈ្មោះប្រាសាទបាពួន, ៥៩
ហេមាលយៈ ឈ្មោះភ្នំធំក្នុងលោក នៅ ប្រទេសឥណ្ឌា,......... ៣២

## ពាក្យសំស្ក្រឹតនិងពាក្យបាលី

អម្ឫតៈ ទឹកអម្រឹត, ........ ១៨
អស្តង្គត ដែលលិចទៅកាន់ទិស បស្ចិម,............ ៣,៣០
គោបុរៈ ខ្លោងទ្វារ,.. ៧, ៣៧, ៥៣,១៨៩
ពាណ្ឌារៈ ល្ហែងក្នុងស្ថានសួគ៌,...... ៨៨
ប្រវត្តិសាស្ត្រ វិជ្ជាពង្សាវតារ,....... ៤
ភគវទ្គីតៈ ឈ្មោះគម្ពីរដែលនិយាយពីរឿង មហាភារតៈ,.......... ១៤
មហាភារតៈ រឿងចម្បាំងធំរវាងពួកកោ- រវៈនិងពួកបាណ្ឌពៈ,........ ១២
វាសុកិ នាគដែលទេពតានិងអសុរយកធ្វើជា ព្រ័ត្រកញ្ច្រាសមុទ្រ,... ១៨,៦៩,៨៨
វិទ្យាសាស្ត្រ វិជ្ជាផ្សេងៗ,......... ៣
វិស្សុកម្ម ឈ្មោះទេវបុត្តជាមេជាង នៅ ស្ថានសួគ៌,............. ៣
វិស្សុករ មេជាង,........... ១៨
សត្តបរិត ភ្នំស្ថិតនៅព័ទ្ធភ្នំព្រះសុមេរុ ៧ ជុំ,.......... ៣៣,១៤៦
សត្តសិទ្ធូរ សមុទ្រស្ថិតនៅព័ទ្ធភ្នំព្រះសុមេរុ ៧ ជុំ,........... ៣៣,១៤៦
ឥសវស្ថាន ស្ថានព្រះឥស្វរ,.... ១៥៨
ហរិវង្ស ឈ្មោះគម្ពីរដែលនិយាយពីរឿង ក្រឹស្ណះ,............ ២០

## ពាក្យបរទេស

ប. ការប៉ូ P.Carpeau,....... ៦៩
គ. សឺដែស G. Cœdès,.. ៤,២០,១៦២
ជ. កូម៉ៃយ៍ J. Commaille,.... ៦៩
ល. ហ្វីណូត៍ L.Finot,... ៥៦,១៨៨
វ. គោលូបេវ V. Goloubew,. ១៥៨
ស. ការប៉ឺឡែស S. Karpelès,.... ១៦១
ល្វាន,.............. ៤
ហ. ម៉ារសាល់ H. Marchal,.. ៤,៨៨
ហ. ប៉ារម៉ង់ទេរ H. Parmentier, ៨៧,៨៨
វៀតណាម,...... ៤,៣៩,៥៩,១៥០

# បញ្ជីរឿង


ទំព័រ

វគ្គទី ៣ ប្រាសាទនគរវត្ត . . . . . . . . . . . . . . . . . . . . . . ៧

ថ្នាក់ទី ១ រឿងរាជក្សត្រិយ៍ . . . . . . . . . . . . . . . . . . ១១

ថ្នាក់ទី២ ព្រះពាន់ . . . . . . . . . . . . . . . . . . . . ២៩

ថ្នាក់ទី៣ បាកាន . . . . . . . . . . . . . . . . . . . . ២៩

តាព្រហ្មកិល . . . . . . . . . . . . . . . . . . . . . . ៣០

បាខែង . . . . . . . . . . . . . . . . . . . . . . . . ៣២

បក្សីចាំក្រុង . . . . . . . . . . . . . . . . . . . . . . ៣៤

វគ្គទី ៤ រាជធានីនគរធំ, គោបុរៈ . . . . . . . . . . . . . . . . . . ៣៧

ប្រាសាទបាយ័ន . . . . . . . . . . . . . . . . . . . . . ៤១

ថ្នាក់ទី ១ រឿងរាជក្សត្រិយ៍ . . . . . . . . . . . . . . . . . ៤៦

ថ្នាក់ទី ២ រឿងរាជក្សត្រិយ៍ . . . . . . . . . . . . . . . . . ៥៤

ថ្នាក់ទី ៣ ប្រាសាទពណ្ណកាល . . . . . . . . . . . . . . . ៦៨

ប្រាសាទបាពួន . . . . . . . . . . . . . . . . . . . . . . ៧៣

គោបុរៈខាងត្បូង រឿងរាជក្សត្រិយ៍ . . . . . . . . . . . . . . ៧៤

គោបុរៈខាងកើត រឿងរាជក្សត្រិយ៍ . . . . . . . . . . . . . . ៧៥

គោបុរៈខាងជើង រឿងរាជក្សត្រិយ៍ . . . . . . . . . . . . . . ៧៦

គោបុរៈខាងលិច រឿងរាជក្សត្រិយ៍ . . . . . . . . . . . . . . ៧៨

ទីលានខាងវិមានអាកាស . . . . . . . . . . . . . . . . . . . ៨០

ទីលានស្តេចគំលង់ . . . . . . . . . . . . . . . . . . . . . ៨៣

ព្រះទេពប្រណម្យ . . . . . . . . . . . . . . . . . . . . . ៨៩

ព្រះបាលិលេយ្យ . . . . . . . . . . . . . . . . . . . . . ៩០

ព្រះពិថូរ . . . . . . . . . . . . . . . . . . . . . . . ៩៣

ប្រាសាទសួរព្រ័ត្រ, ឃ្លាំងនិងព្រះពុទ្ធរូបបាយ័ន . . . . . . . . . . . . ១១០

ប្រាសាទមង្គលអ័ថ . . . . . . . . . . . . . . . . . . . . . ១១២

ទំព័រ

វគ្គទី ៥ វត្តគូប .......... ១០២
ពង្គតន្ត ទឹកពៅលាយ .......... ១០២
ស្ពានថ្ម .......... ១០៦
ប្រាសាទតាកែវ .......... ១០៩
ប្រាសាទតាព្រហ្ម .......... ១១៨
ប្រាសាទបន្ទាយក្ដី .......... ១២៧
ស្រះស្រង់ .......... ១៣២
ប្រាសាទក្រវ៉ាន់ .......... ១៣៨
វគ្គទី ៦ វត្តធំ .......... ១៣៩
ប្រែរូប .......... ១៣៩
មេបុណ្យខាងកើត .......... ១៤៣
តាសោម .......... ១៤៥
ក្រោលគោ .......... ១៤៧
នាគព័ន្ធ .......... ១៥១
ព្រះខាន់ .......... ១៥៩
ក្រោលដំរី .......... ១៦៣
វគ្គទី ៧ ប្រាសាទទៀងគាវ .......... ១៦៧
វត្តអធ្វា .......... ១៦៧
ភ្នំក្រោម .......... ១៧១
ព្រះពិទ្ធកោសីយ៍ .......... ១៧៤
មេបុណ្យខាងលិច (បារាយ) .......... ១៧៦
លលៃ .......... ១៧៨
ព្រះគោ .......... ១៨៥
បាគង .......... ១៨៦
បន្ទាយស្រី .......... ១៨៩

| | ទំព័រ |
|---|---|
| បន្ទាយស៊ីរៃ . . . . . . . . . . . . . . . . . . . . . . . . . . | ២១០ |
| សៀមរាប . . . . . . . . . . . . . . . . . . . . . . . . . . . | ២១៣ |
| បញ្ជីព្រះនាមស្ដេច, ទេវតា, ឈ្មោះប្រាសាទនិងទីស្ថាននិងពាក្យផ្សេងៗ . . | ក |
| ព្រះនាមស្ដេច . . . . . . . . . . . . . . . . . . . . . . . . | ក |
| ព្រះនាមទេវតាសាសនាព្រាហ្មណ៍និងពុទ្ធសាសនា . . . . . . . . . | ក |
| ប្រាសាទនិងទីស្ថាន . . . . . . . . . . . . . . . . . . . . | ខ |
| ពាក្យសំស្ក្រឹតនិងពាក្យបាលី . . . . . . . . . . . . . . . . | គ |
| ពាក្យបរទេស . . . . . . . . . . . . . . . . . . . . . . . . | ឃ |
| បញ្ជីរឿង . . . . . . . . . . . . . . . . . . . . . . . . . . | ង |
| បញ្ជីរូបថត . . . . . . . . . . . . . . . . . . . . . . . . . | ឈ |

ទំព័រ

១៨ – សិរីលិង្គ ប្រាសាទព្រះពិទូរ .................... ៩៨

១៩ – ភាពប្រាសាទតាកែវទាំងមូល មើលពីទិសអាគ្នេយ៍ .......... ១០៧

២០ – ដើមឈើដុះចាក់ឫសព័ទ្ធព័ន្ធលើកំពូលប្រាសាទតាព្រហ្ម ......... ១១១

២១ – កាលពោធិសត្វទ្រង់កណ្ឌកភាជី, មានទេវបុត្រជាបរិវារ, ចេញសាងមហា-
ភិនិក្ខមណ៍ ហោជាងប្រាសាទខាងត្បូង ក្នុងកំពែងទី៣ ប្រាសាទតាព្រហ្ម... ១១៣

២២ – រូបកិច្ចប្រណម្យ ប្រាសាទតាព្រហ្ម .................. ១១៧

២៣ – កាលព្រះពោធិសត្វប្រសូត ព្រះព្រហ្មនិងព្រះឥន្ទ្រទទួល ហោជាងប្រាសាទ
ខាងត្បូង ក្នុងកំពែងទី ៣ ប្រាសាទតាព្រហ្ម ............. ១១៩

២៤ – រូបទ្វារបាល នៅគោបុរៈនៃកំពែងទី៣ ទិសខាងលិច ប្រាសាទតាព្រហ្ម .. ១២៣

២៥ – គោបុរៈខាងកើត នៃកំពែងខាងក្រៅ ប្រាសាទបន្ទាយក្ដី ......... ១២៥

២៦ – រូបឥសីសាសនាព្រាហ្មណ៍ អង្គុយចំរើនធម៌ ធ្លាក់មុខខាងហើយ កន្លែងឥសី
នេះកាលមុនគេធ្លាក់ព្រះពុទ្ធរូប ៗនេះគេកោសលុបចោលទៅ ....... ១២៩

២៧ – ភាពទីលានស្រះស្រង់ មើលពីទិសពាយ័ព្យ ............. ១៣៣

២៨ – ភាពប្រាសាទប្រែរូបទាំងមូល មើលពីខាងកើត ........... ១៣៧

២៩ – រូបព្រះវិស្ណុផើកផ្ទៀងធំអស្ចារ្យ គេជីកឃើញនៅប្រាសាទមេបុណ្យខាងកើត.. ១៤១

៣០ – ភាពប្រាសាទនាគព័ន្ធ ដែលគេកាប់ឆ្ការព្រៃហើយ ........... ១៤៩

៣១ – រូបវលាហកស្សៈ នៅទ្វារបញ្ចោត, នៅហោជាងខាងលើ ថ្ងៃកាលពោធិសត្វ
ទ្រង់កណ្ឌកភាជី ចេញសាងមហាភិនិក្ខមណ៍ ប្រាសាទនាគព័ន្ធ...... ១៥៣

៣២ – មុខវលាហកស្សៈ នៅលើកំពូលប្រាសាទព្រះខាន់ ទ្វារចូលខាងលិច .... ១៥៧

៣៣ – ភាពប្រាសាទវត្តអធ្វា ដែលនៅសល់នូវជីវភាព ............ ១៦៥

៣៤ – ភាពប្រាសាទភ្នំក្រោម មើលចំពាក់កណ្ដាល ............. ១៦៩

៣៥ – រូបទ្វារបាល គេទើបជីកបាន នៅប្រាសាទភ្នំក្រោម .......... ១៧៣

៣៦ – សសរក្រឡឹងមូល គោបុរៈខាងកើតនៃប្រាសាទព្រះគោ ........ ១៨១

# បញ្ជីរូបថត


ទំព័រ

១ — ព្រះសិរព្រះពុទ្ធរូប មានព្រះភក្ត្រស្រស់ញញឹម ប្រាសាទនគរវត្ត ...... ១

២ — ភាគប្រាសាទនគរវត្តទាំងមូល .................. ៥

៣ — ភាគប្រាសាទនគរវត្ត មើលពីទិសនិរតី .............. ៩

៤ — កាលព្រហាមសម្ងំយាមរាត្រី ដែលភ្លៀងខ្ទោចរំពើម ក្នុងរដូវភ្លៀងនៅជ្រុងទិសនិរតី ប្រាសាទនគរវត្ត .................. ១៣

៥ — រូបស្រីទេពអប្សរពាក់មកុដចេញសក់សំយាក រាងទន់ទាន់សម័យ ប្រាសាទនគរវត្ត .................. ២៣

៦ — ស្រីទេពអប្សរមានផ្គងសក់ជាមកុដ ខាងចុងទិសនិរតី ប្រាសាទនគរវត្ត... ២៧

៧ — ទ្វារជ័យ (ទ្វារធំកំផែងខាងកើត) ក្រុងអង្គរធំ ............ ៣៥

៨ — ភាគជាន់ក្រៅនៃប្រាសាទបាយ័ន មើលពីទិសនិរតី .......... ៣៩

៩ — ព្រះលោកេស្វរៈ នៅលើកំពូលប្រាសាទបាយ័ន .......... ៤៣

១០ — រូបស្រីទេពអប្សរកំពែងទន់ភ្លន់លើផ្កាឈូកនៅសសរខ្លួនជ្រុង ទ្វារចូលខាងកើត ប្រាសាទបាយ័ន .................. ៤៧

១១ — រូបស្រីទេពអប្សររាំរបាំល្អសល់លើផ្កាឈូក នៅសសរ៤ជ្រុង ទ្វារចូលខាងកើតប្រាសាទបាយ័ន .................. ៥១

១២ — ស្រីទេពអប្សរ នៅជញ្ជាំងប្រាសាទកណ្តាល ប្រាសាទបាយ័ន..... ៥៥

១៣ — ព្រះនារាយណ៍ដៃ៤ មានទេវតានិងមនុស្សប្រណម្យ ប្រាសាទបាយ័ន. ៥៩

១៤ — រូបសីហៈ នៅគោបុរៈខាងជើងនៃប្រាសាទបាយ័ន .......... ៦៣

១៥ — គោបុរៈនៃរោងទងខាងជើង ប្រាសាទបាយ័ន ............ ៦៧

១៦ — រឿងវាលីក្រំព្រះរាមនិងរាពណ៍ គោបុរខាងជើង កំពែងទី២ ឈៀងខាងកើត មុខខាងជើង.................. ៧១

១៧ — គោបុរៈខាងកើត នៃប្រាសាទបាលិលេយ្យ .............. ៧៥

ទំព័រ

៣៧ — រូបទ្វារបាលនៅប្រអប់ទ្វារបញ្ឆោត ប្រាសាទព្រះគោ .......... ១៨៣

៣៨ — រូបព្រះឥសូរនាងឧមានិងនាងគង្គាមើលពីខាងក្រោយ ទិសឦសាន ប្រាសាទបាគង ........................ ១៨៧

៣៩ — រូបព្រះឥសូរ នាងឧមានិងនាងគង្គាមើលពីមុខ ទិសឦសាន ប្រាសាទបាគង ........................ ១៨៩

៤០ — រូបយក្ស នៅគ្រឹះថ្នាក់ទី ៥ នៃប្រាសាទបាគង ............ ១៩៣

៤១ — គោបុរៈកំពែងទី៣ ប្រាសាទបន្ទាយស្រី ............... ១៩៧

៤២ — គោបុរៈកំពែងទី ៣ ខាងលិច មុខខាងកើត ប្រាសាទបន្ទាយស្រី .... ២០១

៤៣ — ទេពតា ឆ្លាក់ជាប់នៅជញ្ជាំង ប្រាសាទខាងជើងទិសនិរតី ប្រាសាទបន្ទាយស្រី ........................ ២០៥

៤៤ — ឥន្ទ្រ ប្រាសាទបន្ទាយសំរែ ................ ២០៧

៤៥ — សីហៈធំ នៅទីលានខាងកើត ប្រាសាទបន្ទាយសំរែ .......... ២១៣

៤៦ — ផ្តែរឈើខ្វាងទ្វារខាងក្នុងនៃប្រាសាទកណ្ដាល ប្រាសាទបន្ទាយសំរែ ... ២១៥

# បញ្ជីសៀវភៅដែលព្រះរាជបណ្ណាល័យបោះពុម្ពផ្សាយ

| | | | |
|---|---|---|---|
| ព្រះត្រៃបិដក (បាលីនិងប្រែ) ១ ឈុំ ........ | ចំនួន ១១០ | សៀវភៅថ្លៃ | ២៥០រ. ០០ |
| ព្រះចង្កូមកែវ ........................ | ១ | សៀវភៅថ្លៃ | ០រ. ១០ |
| អក្ខរោសកថា ........................ | | — | ០, ០៥ |
| អនត្តលក្ខណសូត្រ ........................ | | — | ០, ៤០ |
| អភិធម្មត្ថសង្គហ បាលី ........................ | | — | ០, ៥០ |
| អភិធម្មត្ថសង្គហ សម្រាយ ........................ | | — | ០, ៩០ |
| អរិយសច្ចកថា ........................ | | — | ០, ៨០ |
| អំពីព្រះពុទ្ធសាសនា ........................ | | — | ១, ៥០ |
| អំពីប្រាសាទខ្ទះនៅឥតរ ........................ | | — | ០, ២៥ |
| កាលាមសូត្រនិងបរាភវសូត្រ ........................ | | — | ០, ១៤ |
| គិរិមានន្ទសូត្រ ........................ | | — | ០, ១៥ |
| ច្បាប់ថ្មី ........................ | | — | ០, ១៧ |
| ញាណកថា ........................ | | — | ០, ១០ |
| ដំណាលពុទ្ធចេតិយ ........................ | | — | ០, ៨១ |
| ធម្មប្រទីប ........................ | | - | ០, ៦០ |
| ភាណវារ ........................ | | — | ១, ៥០ |
| តាពោបមាទិកថា ........................ | | — | ០, ០៧ |
| បករណវិសេសោ ........................ | | — | ១, ០០ |
| បាយាសិរាជញ្ញសូត្រ ........................ | | — | ០, ០៧ |
| ពាក្យកាព្យក្រមង៉ុយ ........................ | | — | ០, ០៣ |
| មនោបុព្វកថា ........................ | | — | ០, ១៧ |
| មរណានុស្សតិ ........................ | | — | ០, ២០ |
| មាតាបិតុឧបដ្ឋានកថា ........................ | | — | ០, ៣៥ |

| | | |
|---|---|---|
| ៤០០ គាថា | ១ សៀវភៅថ្លៃ | ០រ. ១០ |
| វិជ្ជាធរណកថា | — | ០, ៣១ |
| វុឌ្ឍោទយ | — | ០, ២៥ |
| សប្បុរិសធម៌ | — | ០, ០៩ |
| សត្តបរិត្តនិងទ្វាទសបរិត្ត | — | ០, ៨០ |
| សីហវិនិច្ឆ័យ | — | ០, ១០ |
| សុរិយាត្រូវឡើងស៊ក | — | ០, ៣០ |
| សុភាសិតប្បកាសិនី | — | ០, ៦០ |
| សេចក្តីផាស់ភឿន | — | ០, ០៦ |
| បញ្ចនិបាតវិធី និងប័ក្ខសម្រេច | — | ០, ៣០ |
| សម្ពុទ្ធមាណ | — | ១, ២៥ |
| សីលនិទ្ទេស | — | ០, ៧០ |
| សារទេសនា | — | ០, ០៨ |
| អក្សរខ្មែរជាប់និងប្រសព្វ | — | ០, ២០ |
| ប្រស្នាវិនយបិដកសង្ខេប | — | ១, ០០ |
| រតនប្បញ្ញា | — | ០, ៦១ |
| វិធីបង្ការរោគ | — | ០, ០៣ |
| ទសជាតិមោក្ខ | — | ០, ៤០ |
| គោលសមាធិកម្មដ្ឋាន | — | ០, ១៥ |
| ពុទ្ធមាមកវិធី (ស្បែកធម្មយុត្តិ) | — | ០, ៦០ |
| សាមណេរវិន័យ | — | ០, ៦០ |
| បញ្ចកភិក្ខុប្បច្ចវេក្ខណៈ | — | ០, ១០ |
| សិក្ខាលោហិទស្សត្រ | — | ០, ៣០ |
| អនុមោទនាវិធី | — | ០, ៥០ |
| ព្រះត្រៃលក្ខណ៍និងសង្វេគវត្ថុ | — | ០, ១៥ |

| | | | |
|---|---|---|---|
| ពាក្យកាព្យថ្លែងរឿងពុទ្ធប្រវត្តិ .................. | ១ សៀវភៅថ្លៃ | | ០រ. ១៥ |
| សែលសូត្រ .................... | | — | ០, ១៥ |
| តាតាជាតក .................... | | — | ១, ៦០ |
| សតិបដ្ឋានសូត្រ .................... | | — | ០, ៥០ |
| អវសានកិច្ច .................... | | — | ០, ៤៥ |
| វិជ្ជាប្រាំពីរប្រការ .................... | | — | ០, ៦៥ |
| រឿងកាកី .................... | | — | ០, ២៥ |
| ទសបារមីកថា .................... | | — | ១, ៧៥ |
| បាដិមោក្ខសង្ខេប .................... | | — | ០, ៤០ |
| សៀវភៅយានជំនិះខ្មែរ .................... | | — | ០, ៤៥ |
| វជិរសារ .................... | | — | ០, ៦០ |
| ធាតុកថា .................... | | — | ០, ៦០ |
| វេយ្យាករណ៍សំស្ក្រឹត .................... | | — | ០, ៦៥ |
| សិលាចារឹកនគរវត្ត .................... | | — | ១, ០០ |
| ជយវរ្ម័ន ទី ៧ (អក្សរខ្មែរ) .................... | | — | ០, ១០ |
| " " (អក្សរបារាំង) .................... | | — | ០, ៣០ |
| បទានុក្រមកាយកេរ្តិ៍ .................... | | — | ០, ០៥ |
| កាយកេរ្តិ៍ លក់រាយ .................... | | — | ០, ១០ |
| " លក់រួម .................... | ១៧ | — | ១, ៥០ |
| ទស្សនាវដ្តី (១ ឆ្នាំ) .................... | ២៤ | — | ៦, ៥០ |
| សាសនកិច្ចានុក្រម (១ ឆ្នាំ) .................... | ១២ | — | ១, ៥០ |
| វចនានុក្រមខ្មែរ ក្របរឹង .................... | ១ | — | ៤, ៥០ |
| " ក្របទន់ .................... | | — | ៣, ០០ |
| គំហើបនិបត្តិសង្ខេប .................... | | — | ០, ១៥ |
| គំហើបនិបត្តិពិស្តារ .................... | | — | ០, ៥០ |

| | | | |
|---|---|---|---|
| បព្វជ្ជាខន្ធកសង្ខេប | ១ សៀវភៅថ្លៃ | | ០រ. ៥៥ |
| សុភាទោសកថា | | — | ០, ១០ |
| មគ្គុទ្ទេសក៍នគរ | ភាគទី ១ | — | ០, ៤៥ |
| " | ភាគទី ២ | — | ១, ២០ |
| ក្រុងសុភាមិត្រ | ភាគទី ១ | — | ០, ៧០ |
| " | ភាគទី ២ | — | ០, ០០ |
| " | ភាគទី ៣ | — | ០, ០២ |
| មិលិន្ទប្បញ្ហា | ភាគទី ១ | — | ០, ៥០ |
| " | ភាគទី ២ | — | ០, ៧០ |
| មង្គលត្ថទីបនី | ភាគទី ១ | — | ២, ០០ |
| " | ភាគទី ២ | — | ២, ៥០ |
| " | ភាគទី ៣ | — | ៣, ០០ |
| " | ភាគទី ៤ | — | ០, ០០ |
| កច្ចាយនប្បករណ៍ | ភាគទី ១ | — | ១, ២០ |
| " " | ភាគទី ២ | — | ១, ៤០ |
| ធម្មបទដ្ឋកថា | ភាគទី ១ | — | ០, ៩០ |
| " | តាំងពីភាគទី ២ ដល់ភាគទី ៨ | — | ០, ៦៥ |
| គតិលោក | ភាគទី ១ | — | ០, ៦៥ |
| " | ភាគទី ២ - ៣ | — | ០, ១២ |
| " | ភាគទី ៤-៥-៦-៧-៨-៩-១០ | — | ០, ២៥ |
| រឿង ១ ពាន់ ១ យប់ | ភាគទី ១ | — | ០, ០២ |
| " | ភាគទី ២ - ៣ - ៤ - ៥ - ៦ - ៧ - ៨ - ៩ | — | ០, ២៥ |

យើងខ្ញុំជាកូន ខ្មៅ យុនសំរ៉ង ខ្មៅ យ៉ាតណៃ ខ្មៅសុខផល ខ្មៅ វិសាល ខ្មៅ ភ័មុន
ខ្មៅ ភាភង់ា ខ្មៅ ចំរើន ខ្មៅ ភារី

បានឧបត្ថម្ភការផ្សាយសៀវភៅនេះជា eBook
ដើម្បីឧទ្ទិសកុសលផលវិញ្ញាណក្ខន្ធ ឧបាសក ខ្មៅ ពាញ និង ឧបាសិកា ឈរ យឿន

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ **សួស សូរី**

សីហា ឆ្នាំ ២០១៥

បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ
ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធិ" របស់អ្នកនិពន្ធ។
យើងខ្ញុំ ពុំមានការប្រាស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ

ខ្មៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

មានលក់ដុំ និង លក់រាយ

សៀវភៅធម៌គ្រប់មុខគ្រប់ប្រភេទ នៅ "បណ្ណាគារត្រៃរតន៍"

# 136E0 វិថីខេមរភូមិន្ទ

ទូរស័ព្ទលេខៈ 012 706 581

097 905 00 55

សូមនិមន្ត និង អញ្ជើញដោយមេត្រីភាព ។